សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

សារណាបញ្ចប់ការសិក្សា

# អាជ្ញាអស់ជំនុំ
# នៃ
# សេចក្តីសម្រេចផ្នែករដ្ឋប្បវេណី

សរសេរសារណាពីថ្ងៃទី ០៣ ខែ មេសា ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៧

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ស៊ិន ច័ន្ទផល្លុន**

សាស្ត្រាចារ្យណែនាំ
លោកស្រី **ម៉ឹយ ធីតា**

ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ
ជំនាន់ទី២២ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៣
ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីធានាអះអាង

ខ្ញុំបាទឈ្មោះ **ស៊ិន ច័ន្ទផល្គុន** ជាភាសាឡាតាំង SIN CHANPHALKUN កើតថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ១៩៩៦ មានអាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៥២១ ផ្លូវលេខ ២០៨ ភូមិតាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល បច្ចុប្បន្នជានិស្សិតថ្នាក់អាហារូបករណ៍ ជំនាន់ទី២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងជាបេក្ខភាពការពារសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំសិក្សា ២០១៦-២០១៧ ។

ខ្ញុំបាទសូមធ្វើការធានាអះអាងថា រាល់ខ្លឹមសារនៃសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ប្រធានបទ «**អាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី**» ចំពោះមុខនេះ ពិតប្រាកដជាបានកើតចេញពីលទ្ធផលការសិក្សាស្រាវជ្រាវ ដែលមានការចង្អុលបង្ហាញ ពីសាស្ត្រាចារ្យណែនាំ។ គ្មានផ្នែកណាមួយ នៃសារណានេះត្រូវបានដកស្រង់យកមកសរសេរ ដោយមិនបានផ្តល់ប្រភព និងឯកសារយោង នៃស្នាដៃរបស់ អ្នកនិពន្ធ ឬ អ្នករៀបរៀង រូបណាឡើយ។

ខ្ញុំបាទសូមធ្វើការទទួលខុសត្រូវចំពោះមុខច្បាប់ស្តីពីសិទ្ធិ អ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ព្រមទាំងសុខចិត្តដោយឥតលក្ខខ័ណ្ឌក្នុងការទទួលយកទណ្ឌកម្មវិន័យចំពោះមុខសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ប្រសិនបើស្នាដៃនេះបានប៉ះពាល់ ដល់កម្មសិទ្ធិបញ្ញារបស់អ្នកដទៃ។

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ស៊ិន ច័ន្ទផល្លន** ជានិស្សិតអាហារូបករណ៍ ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២២ ក្នុងឆ្នាំសិក្សា **២០១៦-២០១៧** សូមសម្តែងនូវកតញ្ញូ ដឹងគុណដ៏ជ្រាលជ្រៅ មិនអាចកាត់ថ្លៃបាន ដល់លោកអ្នកមានគុណទាំងពីរ គឺ លោកឪពុក **ស៊ិន ទ្រី** និង អ្នកម្តាយ **ស៊ិន ពិសី** ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ និងផ្គត់ផ្គង់ចំពោះការរៀនសូត្ររបស់កូន តាំងពីថ្នាក់មតេយ្យសិក្សា រហូតមកដល់ពេលនេះ ព្រមទាំងសូមគោរពដឹងគុណដល់ ជីតា **ស៊ិន ស៊ីម** ជីដូន **អាន សៀកប៊ួយ** ព្រមទាំងជីដូន **ពួយ គង់** ដែលលោកទាំងអស់តែងតែ បីបាច់ ថែរក្សា អប់រំ ប្រៀបប្រដៅ ថៅប្រកបដោយព្រហ្មវិហារធម៌ទាំង៤។ សេចក្តីដឹងគុណទាំងអស់ពុំអាចថ្លែងត្រឹមសំណេរមួយទំព័រនេះបានឡើយ។

ខ្ញុំបាទ ក៏សូមថ្លែងអំណរគុណដល់ **ក្រសួងអប់រំ យុវជន និងកីឡា** ព្រមទាំង **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានផ្តល់នូវអាហារូបករណ៍ ដល់រូបខ្ញុំបាទ ឱ្យទទួលបានការក្រេបជញ្ជក់ចំណេះដឹងផ្នែកនីតិសាស្ត្រនេះ រហូតដល់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ប្រកបដោយភាពជោគជ័យ។

ជាបន្ត ខ្ញុំបាទ សូមថ្លែងអំណរគុណចំពោះ **ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ថ្នាក់ដឹកនាំ** និង **លោក/លោកស្រី សាស្ត្រាចារ្យ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទាំងអស់ ដែលលោកគ្រប់រូប បានផ្តល់ការអបរំ ទាំងចំណេះដឹង និងសីលធម៌ដល់រូបខ្ញុំបាទក្នុងអំឡុងពេល ៤ឆ្នាំនេះ។

ជាបន្ទាប់មកទៀត ខ្ញុំបាទសូមថ្លែងអំណរគុណដល់គណៈគ្រប់គ្រង ព្រមទាំងបុគ្គលិក នៃ **បណ្ណាល័យនីតិសាស្ត្រ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានរៀបចំ និងគ្រប់គ្រងសៀវភៅ ព្រមទាំងបង្ករជាភាពងាយស្រួលដល់ការស្រាវជ្រាវរបស់និស្សិតនៃសាកលវិទ្យាល័យទាំងមូល។

ពិសេសជាងនេះទៅទៀត ខ្ញុំបាទ សូមថ្លែងអំណរគុណ ដល់លោកស្រីសាស្ត្រាចារ្យ **ប៊ួយ ធីតា** ដែលជាព្រឹទ្ធបុរសរងមហាវិទ្យាល័យនីតិសាស្ត្រ ព្រមទាំងជាសាស្ត្រាចារ្យណែនាំការសរសេរសារណានេះ ដោយលោកស្រីបានចំណាយពេលវេលាដ៏មានតម្លៃ ផ្តល់ជាយោបល់កែសម្រួល និងត្រួសត្រាយផ្លូវដល់ខ្ញុំបាទ រហូតដល់បានប្រសូតជាស្នាដៃចំពោះមុខនេះ។

ជាចុងក្រោយខ្ញុំសូមថ្លែងអំណរគុណដល់ លោកមេធាវី **ស៊ិន សុពុទ្ធិ** ដែលបាន តម្រង់ទិសបណ្តុះបណ្តាល និងឧបត្ថម្ភ ចំពោះការសិក្សារបស់ខ្ញុំបាទ។ លោកមេធាវី ក៏បានចំណាយពេលដ៏មានតម្លៃ ចូលរួមចំណែក ផ្តល់ជាយោបល់ចំពោះខ្លឹមសារនៃប្រធានបទនេះផងដែរ។

# អារម្ភកថា

ដោយធ្លាប់បានសិក្សានៅថ្នាក់បរិញ្ញាបត្រឆ្នាំទី៤ ឆមាសទី១ នូវមុខវិជ្ជានីតិវិធីរដ្ឋប្បវេណី តាមកម្មវិធីសិក្សានៃសាកលវិទ្យាល័យ និងការស្រាវជ្រាវបន្ថែមពាក់ព័ន្ធនឹង របបអាជ្ញាអស់ជំនុំ ខ្ញុំបាទ បានចាប់អារម្មណ៍ជាខ្លាំងចំពោះចំណុចស្តីពីអាជ្ញាអស់ជំនុំនៃសាលក្រមចុងក្រោយ។ ក្រៅពីនេះទៀត ខ្ញុំបានសិក្សាស្រាវជ្រាវអំពីនីតិវិធីផ្សះផ្សា តាស់តឿន ជំនុំជម្រះសាជាថ្មី និងផ្សេងៗទៀតជាច្រើន ហើយអ្វីដែលខ្ញុំបានធ្វើការកត់សំគាល់គឺ រាល់ពេលដែលអ្នកនិពន្ធលើកយកសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីទាំងនោះមកអធិប្បាយ ពួកគេតែងតែបង្ហាញអំពីលក្ខណៈអាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចទាំងនោះ។ បន្ថែមពីនេះទៀត នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ជាបទប្បញ្ញត្តិដែលមានលក្ខណៈស្មុគស្មាញ ដែលយើងមិនអាចយល់ ដោយគ្រាន់តែអានបទប្បញ្ញត្តិនីមួយៗនោះទេ ពោលគឺត្រូវសិក្សាពីឫសគល់ដែលជាទ្រឹស្តីដើមនៃបទប្បញ្ញត្តិទាំងនោះ ហើយក្រមនេះក៏សម្បូរទៅដោយបទប្បញ្ញត្តិដែលកំណត់ឱ្យយកមកអនុវត្តដូចគ្នា ដែលជាហេតុធ្វើឱ្យមានការបកស្រាយផ្សេងៗពីគ្នានៃបទប្បញ្ញត្តិទាំងនោះ។ ផ្អែកលើមូលហេតុដូចបានរៀបរាប់នេះហើយ ទើបខ្ញុំបាទសម្រេចកំណត់យក ប្រធានបទស្តីពី «**អាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី**» ធ្វើជាកម្មវត្ថុនៃការសិក្សា និងការពារដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្ររបស់ខ្ញុំបាទ។

ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាមានលក្ខណៈស្មុគស្មាញ ព្រោះវាបង្កប់ទៅដោយគោលគំនិត និង ទ្រឹស្តីជាច្រើន ដែលជាឧបសគ្គដល់ការយកបទប្បញ្ញត្តិទាំងនេះទៅអនុវត្តឱ្យបានត្រឹមត្រូវ និងទូលំទូលាយ។ ក្រមនីតិវិធីរដ្ឋប្បវេណីដែលខ្ញុំបាទកំពុងបង្ហាញនេះ ត្រូវបានតាក់តែងដោយផ្អែកជាចម្បងលើច្បាប់នៃប្រទេសជប៉ុន ដែលរួមមាន ក្រមនីតិវិធីរដ្ឋប្បវេណី វិធាននីតិវិធីរដ្ឋប្បវេណី ច្បាប់ស្តីពីការអនុវត្តដោយបង្ខំ និងច្បាប់ស្តីពីការចាត់ចែងរក្សាការពារ និងច្បាប់មួយចំនួនទៀត ដែលសុទ្ធសឹងជាលិខិតបទដ្ឋានដែលមានលក្ខណៈស្មុគស្មាញ។ ទៀតសោត វាទើបតែត្រូវបានយកមកអនុវត្តទូទាំងប្រទេស នៅថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០០៧ (១០ឆ្នាំគិតមកទល់បច្ចុប្បន្ន) ហើយការផ្សព្វផ្សាយច្បាប់នេះដល់មន្ត្រីអនុវត្តច្បាប់ ក៏ពុំទាន់មានភាពទូលំទូលាយនៅឡើយ ។ កង្វះខាតសេចក្តីសម្រេចរបស់តុលាការដែលពាក់ព័ន្ធនឹងការយកមកអនុវត្តនូវអាជ្ញាអស់ជំនុំនេះ ព្រមទាំងអត្ថបទបកស្រាយជាភាសាជាតិទាក់ទងនឹងប្រធានបទនេះ ជាឧបសគ្គមួយដល់ការសិក្សាស្រាវជ្រាវរបស់ខ្ញុំបាទ។

ជាអវសាន ខ្ញុំសង្ឃឹមយ៉ាងជឿជាក់ថា ស្នាដៃចំពោះមុខនេះ នឹងចូលរួមចំណែក ដល់ការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយ ដែលអាចបម្រើដល់ការសិក្សារបស់ពួកគេ។ ខ្ញុំបាទក៏សង្ឃឹមថា ខ្លឹមសារនៃសារណានេះ អាចត្រូវបានយកទៅសិក្សាបន្ថែម និងកែសម្រួលចំណុចខុសឆ្គង និងខ្វះខាតក្នុងពេលអនាគតជាក់ជាពុំខាន។ ខ្ញុំបាទក៏សូមអភ័យទោសចំពោះកំហុស ខុសឆ្គង នៅក្នុងអត្ថបទនេះ ទាក់ទងនឹងខ្លឹមសារ ការប្រើប្រាស់អក្ខរាវិរុទ្ធ វេយ្យាករណ៍ ពុំបានត្រឹមត្រូវ ហើយខ្ញុំបាទរីករាយ នឹងទទួលយកការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់លោកសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវទាំងអស់។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........................................................................................ ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃអាជ្ញាអស់ជំនុំ**

**១.១ ទ្រឹស្តីទូទៅនៃអាជ្ញាអស់ជំនុំ** ........................................................... ៥

**១.១.១ លក្ខណៈអាជ្ញាអស់ជំនុំនៃប្រព័ន្ធច្បាប់ខមម៉ុនឡ** ........................................... ៧

១.១.១.១ ការហាមឃាត់ការទាមទារ ........................................................... ៨

១.១.១.២ ការហាមឃាត់ការធ្វើវិវាទអំពីអង្គហេតុ ............................................. ៩

១.១.១.៣. ល័ក្ខខ័ណ្ឌនៃអាជ្ញាអស់ជំនុំ ........................................................ ៩

**១.១.២ ទ្រឹស្តីអាជ្ញាអស់ជំនុំនៃប្រព័ន្ធច្បាប់ស៊ីវិលឡ** ............................................. ១២

១.១.២.១ ភាពចង្អៀតនៃវិសាលភាពអាជ្ញាអស់ជំនុំ ............................................ ១៣

**១.២ សញ្ញាណនៃអាជ្ញាអស់ជំនុំនៅក្នុងប្រព័ន្ធគតិយុត្តកម្ពុជា** ..................................... ១៤

**១.២.១ អត្ថន័យនៃអាជ្ញាអស់ជំនុំនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី** ................................. ១៤

**១.២.២ ប្រភេទនៃសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីដែលមានអានុភាពអាជ្ញាអស់ជំនុំ** .... ១៥

១.២.២.១ លក្ខណៈវិនិច្ឆ័យ .................................................................... ១៥

១.២.២.២ សាលក្រម ............................................................................ ១៩

១.២.២.៣ ដីកាសម្រេច .......................................................................... ២១

១.២.២.៤ កំណត់ហេតុសះជា ជាអាទិ៍ ........................................................ ២៦

១.២.២.៥ សេចក្តីសម្រេចរបស់មជ្ឈត្តករ ..................................................... ២៧

១.២.២.៦ សាលក្រមតុលាការបរទេស ........................................................ ៣០

# ជំពូកទី២
# អានុភាពអាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី

**២.១ អានុភាពអាជ្ញាអស់ជំនុំនៃសាលក្រមចុងក្រោយ** ........ ៣៣

**២.១.១ អាជ្ញាអស់ជំនុំជាលក្ខណ:សារធាតុ** ........ ៣៤

២.១.១.១ វិសាលភាពផ្នែកកម្មវត្ថុនៃអាជ្ញាអស់ជំនុំ ........ ៣៤

២.១.១.២ ពេលវេលាជាមូលដ្ឋាននៃអាជ្ញាអស់ជំនុំ ........ ៤១

២.១.១.៣ វិសាលភាពចំពោះប្រធាននៃអាជ្ញាអស់ជំនុំសារធាតុ ........ ៤៣

**២.១.២ អាជ្ញាអស់ជំនុំជាលក្ខណ:ទម្រង់** ........ ៤៨

២.១.២.១ ពេលដែលបង្កើតអានុភាពអាជ្ញាអស់ជំនុំលក្ខណ:ទម្រង់ ........ ៤៩

២.១.២.២ អញ្ញត្រកម្មចំពោះគោលការណ៍ភាពស្ថាពរនៃសាលក្រម/សាលដីកា ........ ៥៤

**២.២ អានុភាពអាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីផ្សេងទៀត** ........ ៥៧

**២.២.១. ដីកាសម្រេចដាស់តឿន** ........ ៥៨

២.២.១.១ វិសាលភាពផ្នែកកម្មវត្ថុ ........ ៥៩

២.២.១.២ ពេលវេលាជាមូលដ្ឋាននៃអាជ្ញាអស់ជំនុំ ........ ៦០

២.២.១.៣ វិសាលភាពនៃប្រធាន ........ ៦១

**២.២.២ សាលក្រមនៃតុលាការបរទេស** ........ ៦១

**២.២.៣ សាលក្រមនៃបណ្តឹងដែលមានចំនួនទឹកប្រាក់តិច** ........ ៦២

**២.២.៤ មជ្ឈត្តវិនិច្ឆ័យ** ........ ៦៤

២.២.៤.១. មជ្ឈត្តវិនិច្ឆ័យនៃវេទិកាមជ្ឈត្តកម្ម ........ ៦៤

២.២.៤.២ សេចក្តីសម្រេចនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ........ ៦៦

## ជំពូកទី៣
## ការអនុវត្តអាជ្ញាអស់ជំនុំនៅក្នុងនីតិវិធីរដ្ឋប្បវេណី


**៣.១ ការអះអាងអំពីអាជ្ញាអស់ជំនុំនៅក្នុងនីតិវិធីបណ្ដឹង** ............................................. ៦៩

**៣.១.១ ភាពចាំបាច់នៃការអះអាងអំពីអាជ្ញាអស់ជំនុំ និងបន្ទុកក្នុងការបញ្ជាក់** ............... ៧០

**៣.១.២ គស្តុតាងនៃអាជ្ញាអស់ជំនុំ** ...................................................................................... ៧៣

**៣.១.៣ នីតិវិធីនៃការអះអាងអំពីអាជ្ញាអស់ជំនុំ** ............................................................... ៧៤

**៣.២ ការវិនិច្ឆ័យអំពីចំណុចវិវាទនៃអាជ្ញាអស់ជំនុំ** .................................................... ៧៧

**៣.២.១ ភាពដូចគ្នានៃប្រធាន** .................................................................................................. ៧៧

**៣.២.២ ភាពដូចគ្នានៃការទាមទារ** ........................................................................................ ៧៩

៣.២.២.១ ភាពដូចគ្នាទាំងស្រុងនៃការទាមទារ ....................................................... ៧៩

៣.២.២.២ ភាពដូចគ្នាទាំងស្រុងនៃអង្គច្បាប់ ............................................................. ៨០

៣.២.២.៣ ភាពដូចគ្នានៃខ្លឹមសារនៃសិទ្ធិ និង ទំនាក់ទំនងគតិយុត្ត ............................. ៨១

**៣.២.៣. ភាពដូចគ្នានៃអង្គហេតុ** ............................................................................................ ៨២

**សេចក្ដីសន្និដ្ឋាន** ....................................................................................................................... ៨៥

**អនុសាសន៍** ............................................................................................................................ ៨៦

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ក្រោយទទួលបានសន្តិភាពពេញបរិបូរណ៍ កម្ពុជាបានចាប់ផ្តើមដំណើរការស្តារឡើងវិញនូវប្រព័ន្ធច្បាប់ ដែលវាតម្រូវឱ្យលិខិតបទដ្ឋានគតិយុត្តត្រូវដាក់ចេញឱ្យអនុវត្តជាបន្ទាន់។ នៅក្នុងនោះ វិស័យឯកជន រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងយុត្តិធម៌ បានសហការជាមួយ រដ្ឋាភិបាលជប៉ុន តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន ហៅកាត់ថា JICA បានបង្កើតជាគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងយុត្តិធម៌ (The Legal and Judicial Development Project) ក្រោមការដឹកនាំរបស់ក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា ដែលបច្ចុប្បន្នគម្រោងនេះបានឈានដល់ដំណាក់កាលទី៤ ព្រមជាមួយនឹងសមិទ្ធផលជាច្រើន ជាពិសេសជាងគេគឺការប្រកាសឱ្យប្រើផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្ត ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី។ សញ្ញាណនៃក្រមនីតិវិធីរដ្ឋប្បវេណីមានភាពថ្មីសន្លាងនៅក្នុងប្រព័ន្ធនីតិវិធីរដ្ឋប្បវេណីរបស់កម្ពុជា ដែលតម្រូវឱ្យធ្វើការផ្សព្វផ្សាយដល់មន្ត្រីអនុវត្តច្បាប់ជាមុន ក្រោយឈានដល់ការដាក់ឱ្យអនុវត្តទូទាំងប្រទេសនូវក្រមនេះ។ ប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី មានកម្មវត្ថុជាការដោះស្រាយវិវាទឯកជនតាមផ្លូវច្បាប់។ វិវាទដែលត្រូវបានដោះស្រាយរួចនឹងគ្មានប្រយោជន៍ ប្រសិនបើច្បាប់ ពុំបានធានានូវការបញ្ចប់វិវាទជាស្ថាពរ។ ហេតុនេះដើម្បីជាទំនុកចិត្តដល់ប្រជាពលរដ្ឋ គ្រប់យន្តការក្នុងការដោះស្រាយវិវាទ គប្បីបញ្ជាក់អំពីភាពចុងក្រោយនោះ គឺ អានុភាពអាជ្ញាអស់ជំនុំ។

អាជ្ញាអស់ជំនុំ គឺជាអានុភាពនៃសេចក្តីសម្រេចស្ថាពរ និងជាឧបករណ៍គតិយុត្តក្នុងការបញ្ចប់វិវាទរវាងភាគីជាស្ថាពរ។ វាមានអត្ថន័យធំធេងណាស់ នៅក្នុងប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី ដែលវាធានាដល់តម្លៃនៃយន្តការដោះស្រាយវិវាទ។ លក្ខណៈពិសេសនៃអាជ្ញាអស់ជំនុំ គឺការហាមឃាត់ការលើកយកវិវាទដែលត្រូវបានបញ្ចប់ជាស្ថាពរ មកតុលាការ ឬអង្គវិនិច្ឆ័យផ្សេងទៀតក្រៅពីតុលាការ។ យ៉ាងណាមិញ វាពុំត្រឹមតែបានយកមកប្រើប្រាស់នៅក្នុងតុលាការរដ្ឋប្បវេណីទេ សូម្បីតែអង្គវិនិច្ឆ័យដែលច្បាប់ទទួលស្គាល់ផ្សេងទៀត ជាអាទិ៍ មជ្ឈត្តការផ្នែកពាណិជ្ជកម្ម និង ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក៏បានយករបបគតិយុត្តនេះ ទៅអនុវត្ត ដើម្បីធានាតម្លៃនៃសេចក្តីសម្រេចរបស់ខ្លួនផងដែរ។

ស្របពេលនឹងវត្តមានអាជ្ញាអស់ជំនុំ ក្នុងគ្រប់ទម្រង់នៃការដោះស្រាយវិវាទ វាក៏ជួបប្រទះនឹងការលំបាកដែលពាក់ព័ន្ធនឹងការយកបទប្បញ្ញត្តិស្តីពីអាជ្ញាអស់ជំនុំ ទៅអនុវត្តអោយមានប្រសិទ្ធភាពព្រមទាំងសម្រេចបាននូវគោលបំណងដ៏សំខាន់គឺការបញ្ចប់វិវាទ។ លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការយកមកអនុវត្តនូវអាជ្ញាអស់ជំនុំ ហាក់បីដូចជាមានភាពតិចតួចនៅឡើយដែលជាឧបសគ្គដល់ការយករបបអាជ្ញាអស់ជំនុំទៅអនុវត្តអោយបានត្រឹមត្រូវ។ ហេតុនេះវាទាមទារឱ្យមានភាពច្បាស់លាស់មួយចំពោះរបបគតិយុត្តនេះ ដើម្បីយកមកអនុវត្តឱ្យចំវត្ថុបំណងរបស់វា គឺការបញ្ចប់

វិវាទប្រកបដោយប្រសិទ្ធភាព។ បន្ថែមពីនេះទៀត ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាតាក់តែងឡើងតាមប្រព័ន្ធផេនដេកទែន (Pandekten) ជាប្រព័ន្ធមាននិន្នាការពុំចែងឱ្យនិយមន័យ ដូច្នេះ វាជាចំណោទបញ្ហាមួយក្នុងការប្រមែប្រមូលមូលដ្ឋានដើម្បីកំណត់អំពីអត្ថន័យនៃអាជ្ញាអស់ជំនុំតាមក្រមនីតិវិធីរដ្ឋប្បវេណី។ ម្យ៉ាងវិញទៀត ភាពមិនច្បាស់លាស់នៃរបបអាជ្ញាអស់ជំនុំនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីបណ្តាលមកពីភាពមិនសម្បូរបែបនៃបទប្បញ្ញត្តិច្បាប់ ពោលគឺ វាត្រូវបានចែងតែនៅក្នុងមាត្រា១៩៤តែប៉ុណ្ណោះ ហើយត្រូវបានច្បាប់បញ្ញត្តអោយយករបបគតិយុត្តនៃអាជ្ញាអស់ជំនុំចំពោះសាលក្រមឬសាលដីកា ទៅអនុវត្តដូចគ្នាចំពោះសេចក្តីសម្រេចផ្សេងទៀត ដែលបង្កភាពងាយស្រួលដល់ការតាក់តែង ប៉ុន្តែបង្កភាពលំបាកដល់ការបកស្រាយ។ ជាបច្ច័យ វាបានធ្វើឱ្យមានភាពបកស្រាយផ្សេងៗគ្នាក្នុងចំណោមអ្នកច្បាប់ ចំពោះចំណុចស្តីពីសេចក្តីសម្រេចរដ្ឋប្បវេណីក្រៅពីសាលក្រមនិងសាលដីកា។

ការស្រាវជ្រាវនេះ មានគោលបំណងបង្ហាញឱ្យឃើញអំពីទស្សនទានជាសកលចំពោះការបកស្រាយអានុភាពអាជ្ញាអស់ជំនុំ ដែលបានយកទៅអនុវត្តនៅក្នុងប្រទេសដែលមានប្រព័ន្ធច្បាប់ជឿនលឿន រួមជាមួយនឹងការបង្ហាញអំពីអត្ថន័យនៃអាជ្ញាអស់ជំនុំក្នុងប្រព័ន្ធនីតិវិធីរដ្ឋប្បវេណីរបស់កម្ពុជា ដែលមានភាពស្រពិចស្រពិល។ ការស្រាវជ្រាវនេះ ក៏មានបំណងបង្ហាញឱ្យឃើញនូវទិដ្ឋភាពជាក់ស្តែង នៃការយកបទប្បញ្ញត្តិអាជ្ញាអស់ជំនុំ ទៅអនុវត្តក្នុងលំហូរនីតិវិធីជំនុំជម្រះលើកទី១ ព្រមទាំងនីតិវិធីឧបាស្រ័យនៃសេចក្តីសម្រេចផងដែរ។

លទ្ធផលដែលកើតចេញពីការស្រាវជ្រាវនេះ នឹងបានចូលរួមចំណែកជាទស្សទានក្នុងការបកស្រាយ ធ្វើឱ្យមានភាពកាន់តែច្បាស់លាស់នូវរបបគតិយុត្តនៃអាជ្ញាអស់ជំនុំ ដោយវាបានដកស្រង់អំពីទ្រឹស្តីនៃបណ្តាប្រទេសអភិវឌ្ឍផ្នែកប្រព័ន្ធច្បាប់។ កាលបើរបបគតិយុត្តនេះត្រូវបានបកស្រាយចំគោលដៅ វានឹងបង្កើតទំនុកចិត្តដល់ប្រព័ន្ធដោះស្រាយវិវាទឯកជន ហេតុនេះ ទំហំនៃប្រតិបត្តិការពាណិជ្ជកម្ម នឹងមានសន្ទុះកើនឡើងដោយសារតែយើងមានប្រព័ន្ធច្បាប់ដែលធានាដល់ការដោះស្រាយវិវាទ និងបញ្ចប់វិវាទជាស្ថាពរ ក៏ព្រោះតែវិវាទគឺជាការបង្អាក់ដល់ផលិតភាពនៃបុគ្គល។

វិសាលភាពនៃការស្រាវជ្រាវក្នុងសារណានេះ កម្រិតត្រឹមអាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី ដែលកើតចេញពីវិវាទរវាងបុគ្គលឯកជន ដោយវាពុំពន្លាតវិសាលភាពដល់សេចក្តីសម្រេចផ្សេងទៀតក្រៅពីរង្វង់វិវាទឯកជនឡើយ។ សេចក្តីសម្រេចផ្នែករដ្ឋប្បវេណី ដែលកំពុងរៀបរាប់នេះ សំដៅដល់សេចក្តីសម្រេចដែលចេញដោយតុលាការរដ្ឋប្បវេណី ផ្អែកលើបទប្បញ្ញត្តិទម្រង់ គឺក្រមនីតិវិធីរដ្ឋប្បវេណី ព្រមទាំងសេចក្តីសម្រេចទាំងឡាយណាដែលក្រមនីតិវិធីរដ្ឋប្បវេណី

ទទួលស្គាល់។ ក្រៅពីនេះ វាក៏ក្តោបផងដែរចំពោះ សេចក្តីសម្រេចមួយចំនួនដែលចេញដោយអង្គវិនិច្ឆ័យក្រៅពីតុលាការ តែវាជាសេចក្តីសម្រេចចំពោះទំនាក់ទំនងគតិយុត្តរវាងបុគ្គលឯកជនដែលមានវិវាទ ហើយវាព្រមទាំងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធដល់នីតិវិធីតុលាការទៀតផង ជាពិសេសនីតិវិធីឧបាស្រ័យចំពោះសេចក្តីសម្រេចទាំងនោះ ជាអាទិ៍សេចក្តីសម្រេចផ្នែកវិវាទពាណិជ្ជកម្ម និងវិវាទការងារ។ ការកំណត់បែបនេះក៏ព្រោះតែ នីតិវិធីដែលទាក់ទងនឹងការដោះស្រាយវិវាទពាណិជ្ជកម្ម និងការងារ ពុំទាន់បានដាក់ចេញនៅឡើយ ហើយច្បាប់ស្តីពីការរៀបចំអង្គការតុលាការបានបញ្ញត្តអោយយកក្រមនីតិវិធីរដ្ឋប្បវេណី មកធ្វើជាច្បាប់ទម្រង់ក្នុងការដោះស្រាយវិវាទទាំងនោះ។

ដើម្បីសម្រេចបាននូវស្នាដៃចំពោះមុខនេះ វាជៀសមិនផុតពីការសិក្សាស្រាវជ្រាវ លើឯកសារ និងប្រភពពត៌មានផ្សេងទៀត ដែលមានបង្កប់នូវខ្លឹមសារពាក់ព័ន្ធ ដើម្បីជាបង្អែកសម្រាប់ការ បកស្រាយអំពីចំណោទបញ្ហាខាងលើ។ អាស្រ័យហេតុនេះ ខ្ញុំបាទបានប្រើវិធីសាស្ត្រស្រាវជ្រាវដូចរៀបរាប់ខាងក្រោមនេះ ៖

- ទី១ [ពត៌មានផ្ទាល់ (Primary Data)]៖ ការសាកសួរមន្ត្រីអនុវត្តច្បាប់ រួមមាន ក្រឡាបញ្ជី និងមេធាវី ចំពោះបញ្ហាដែលពាក់ព័ន្ធនឹងការយកមកអនុវត្តនូវអាជ្ញាអស់ជំនុំក្នុងនីតិវិធីរដ្ឋប្បវេណីជាក់ស្តែង។
- ទី២ [ពត៌មានមិនផ្ទាល់ (Secondary Data)]៖ ការស្រាវជ្រាវតាមរយៈការអានសៀវភៅដែលបោះពុម្ពផ្សាយ ជាភាសាខ្មែរ និងអង់គ្លេស និងសេចក្តីសម្រេចរបស់តុលាការ។ សៀវភៅជាភាសាខ្មែរភាគច្រើនបោះពុម្ពដោយក្រសួងយុត្តិធម៌ (សេចក្តីកំណត់មាត្រានីមួយៗ និងសេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ព្រមទាំងឯកសារសិក្ខាសាលានានាក្នុងក្របខ័ណ្ឌកម្មវិធីអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងយុត្តិធម៌) ចំណែកឯសៀវភៅជាភាសាបរទេស ទាក់ទងនឹងទ្រឹស្តីអាជ្ញាអស់ជំនុំនៃប្រទេសប្រកាន់ប្រព័ន្ធ Common Law។
- ទី៣ [ពត៌មានមិនផ្ទាល់ (Secondary Data)]៖ ឯកសារដែលបានផ្សាយលើ អ៊ីនធើនែតជាសៀវភៅ ព្រមទាំង ជើណាល (Journal) ដែលភាគច្រើនអ្នកនិពន្ធសរសេរទាក់ទងនឹង អាជ្ញាអស់ជំនុំនៃសេចក្តីសម្រេច របស់តុលាការនៃប្រទេស Common Law និងមួយចំនួនទៀតសរសេរដោយអ្នកច្បាប់នៃប្រទេសជប៉ុន និងអាឡឺម៉ង់។

ដើម្បីបកស្រាយអំពីប្រធានបទ អាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីនេះឱ្យបាន ស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ ឆ្លើយតបទៅនឹងបញ្ហាគតិយុត្ត ដូចបានរៀបរាប់ខាងលើ រចនាបទនៃ ការស្រាវជ្រាវត្រូវបានគាក់តែងដូចខាងក្រោម៖

**ជំពូកទី១ ៖ សញ្ញាណទូទៅនៃអាជ្ញាអស់ជំនុំ**

**ជំពូកទី២ ៖ អានុភាពអាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី**

**ជំពូកទី៣ ៖ ការអនុវត្តអាជ្ញាអស់ជំនុំនៅក្នុងនីតិវិធីរដ្ឋប្បវេណី។**

# ជំពូកទី១ ៖ សញ្ញាណទូទៅនៃអាជ្ញាអស់ជំនុំ

ការដោះស្រាយវិវាទឯកជន មានគោលបំណងផ្តល់ដំណោះស្រាយដល់វិវាទរវាងបុគ្គល ក្នុងទំនាក់ទំនងឯកតិយុត្តរបស់ពួកគេ។ មិនតែប៉ុណ្ណោះវាត្រូវតែធានាឱ្យបានថាវិវាទដែលបានដោះស្រាយចប់សព្វគ្រប់ ត្រូវតែដល់ទីបញ្ចប់ ដែលហាមឃាត់ភាគីនៃវិវាទ មិនឱ្យធ្វើការទាមទារចំពោះចំណុចដែលត្រូវបានវិនិច្ឆ័យរួច សាជាថ្មីម្តងទៀត។ ហេតុនេះគ្រប់យន្តការក្នុងការដោះស្រាយវិវាទ មិនថាជាដំណោះស្រាយក្រៅប្រព័ន្ធតុលាការ ឬ តាមប្រព័ន្ធតុលាការ ត្រូវតែបញ្ជាក់ឱ្យច្បាស់ពីភាពស្ថាពរនៃសេចក្តីសម្រេច ដើម្បីកុំឱ្យបាត់បង់តម្លៃនៃសេចក្តីសម្រេចនោះ។ ដើម្បីធានាតម្លៃនៃសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី គ្រប់ប្រព័ន្ធច្បាប់តម្រូវឱ្យមានការបង្កើតនូវអានុភាពនៃការហាមឃាត់មិនឱ្យវិវាទដែលត្រូវបានបញ្ចប់ អាចត្រូវបានភាគីលើកយកមកម្តងទៀត។ អានុភាពនៃការហាមឃាត់នេះហៅថា «**អាជ្ញាអស់ជំនុំ**»។

របបអាជ្ញាអស់ជំនុំដែលបានបញ្ញត្តនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា យើងពុំអាចស្វែងយល់បាន ដោយមិនសិក្សាឱ្យបានស៊ីជម្រៅ ទៅលើទ្រឹស្តីដែលជាប្រភពដើមនៃបញ្ញត្តិនេះឡើយ។ វាចាំបាច់ ឱ្យយើងយល់ដឹងអំពីទ្រឹស្តីទូទៅ ដែលជាមូលដ្ឋានក្នុងការបកស្រាយច្បាប់អាជ្ញាអស់ជំនុំនេះ ដើម្បីចៀសវាងភាពស្រពិចស្រពិលទាំងឡាយ បណ្តាលមកភាពមិនសម្បូរបែបនៃបទប្បញ្ញត្តិនៃរបបគតិយុត្តនេះ នៅក្នុងនីតិវិជ្ជមានកម្ពុជា។ សេចក្តីរៀបរាប់ទាំងនេះនឹងត្រូវលើកយកមកសិក្សាក្នុងចំណុច **១.១ ស្តីពី ទ្រឹស្តីទូទៅនៃអាជ្ញាអស់ជំនុំ**។ ម្យ៉ាងវិញទៀត ដើម្បីជាជំនួយដល់ការសិក្សាលំអិតជាបន្តអំពីចរិតលក្ខណៈនៃអាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី យើងគប្បីស្វែងយល់ពី ទិដ្ឋភាពទូទៅ ជុំវិញរបបគតិយុត្តមួយនេះ ទៅលើអត្ថន័យ និងការផ្តល់គុណវុឌ្ឍិនៃសេចក្តីសម្រេចដែលមានអាជ្ញាអស់ជំនុំ នៅក្នុងចំណុច **១.២ សញ្ញាណនៃអាជ្ញាអស់ជំនុំនៅក្នុងប្រព័ន្ធគតិយុត្តកម្ពុជា**។

## ១.១ ទ្រឹស្តីទូទៅនៃអាជ្ញាអស់ជំនុំ

តាមលក្ខណៈអក្សរសាស្ត្រ ពាក្យ **«អាជ្ញាអស់ជំនុំ»** ប្រែថា “ការបង្គាប់បញ្ហាដែលពុំអាចវិនិច្ឆ័យម្តងទៀតបាន”។ ក្នុងន័យគតិយុត្ត វាចង់សំដៅលើ “ចំណុចដែលត្រូវបានសម្រេចដោយតុលាការ ឬ អង្គវិនិច្ឆ័យ ដែលមានសមត្ថកិច្ច តាមនីតិវិធីច្បាប់រួចហើយ ពុំអាចក្លាយជាកម្មវត្ថុនៃការវិនិច្ឆ័យម្តងទៀតបានទេ”។

ប្រព័ន្ធយុត្តាធិការគ្រប់បណ្តាប្រទេស មិនថាប្រកាន់យកនិន្នាការនៃប្រព័ន្ធច្បាប់ Common Law ឬ Civil Law សុទ្ធសឹងតែអនុវត្តទ្រឹស្តីអាជ្ញាអស់ជំនុំនេះ[1]។ វាជាទ្រឹស្តីដែលមិនអាចខ្វះបាននៅក្នុងប្រព័ន្ធច្បាប់ទូទាំងសកលលោក ព្រោះវាដើរតួជាឧបករណ៍គតិយុត្តក្នុងការបញ្ចប់វិវាទមិនអោយកើតឡើងសាជាថ្មី។ អវត្តមាននៃអាជ្ញាអស់ជំនុំនៅក្នុងប្រព័ន្ធច្បាប់ នឹងធ្វើអោយមានអស្ថិរភាពគតិយុត្ត ព្រមទាំងមិនអាចសម្រេចបាន នូវការការពារសិទ្ធិរបស់បុគ្គលឯកជន ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ។[2]

ទស្សនៈជាសកលយល់ឃើញថា ការបង្កើតអានុភាពអាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី ជាអន្តរាគមន៍ពីរដ្ឋ ដើម្បីបញ្ឈប់វិវាទមិនអោយបន្ត ក្នុងគោលបំណងការពារផលប្រយោជន៍សាធារណៈ ដោយអ្នកទ្រឹស្តីយល់ឃើញថា ការបណ្តោតបណ្តោយអោយវិវាទអូសបន្លាយនឹងធ្វើអោយប៉ះពាល់ដល់សេដ្ឋកិច្ច ស្ថិរភាពគតិយុត្ត ព្រមទាំងកិត្យានុភាពនៃស្ថាប័នតុលាការ។[3] ទន្ទឹមនឹងនេះ វាក៏មានគោលបំណងការពារសិទ្ធិរបស់បុគ្គលឯកជន ពីបណ្តឹងដែលធ្វើឡើងម្តងហើយម្តងទៀត។ ទ្រឹស្តីអាជ្ញាអស់ជំនុំត្រូវបានគេចាត់ទុកថាជាទ្រឹស្តីសំខាន់បំផុតមួយនៅក្នុងនីតិវិធីរដ្ឋប្បវេណី ដែលវាដើរតួជាទីបញ្ចប់នៃវិវាទ។ អាជ្ញាអស់ជំនុំគឺត្រូវបានយកទៅអនុវត្ត ជាសកលដើម្បីហាមឃាត់វិវាទមិនអោយលើកឡើងសាជាថ្មីម្តងទៀតតាមរយៈទ្រឹស្តីនៃអាជ្ញាអស់ជំនុំ ក្នុងគោលបំណងបញ្ចប់វិវាទរបស់ភាគីជាស្ថាពរ។[4]

ទ្រឹស្តីអាជ្ញាអស់ជំនុំនៃប្រទេសមួយចំនួនទទួលឥទ្ធិពលពីប្រទេសដែលមានភាពជឿនលឿនផ្នែកប្រព័ន្ធច្បាប់ ជាពិសេសប្រទេសដែលមានប្រព័ន្ធច្បាប់ដូចគ្នា។ ជាឧទាហរណ៍ យុត្តាធិការកាណាដា បានទទួលឥទ្ធិពលនៃទ្រឹស្តីអាជ្ញាអស់ជំនុំផ្នែកចំណុចវិវាទ (Issue Estoppel) ពីយុត្តិសាស្ត្ររបស់តុលាការអាមេរិក[5] និងអង់គ្លេស[6]។ ដូចគ្នាផងដែរ ទ្រឹស្តីអាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចផ្នែក

[1] Yuval Sinai, Reconsidering Res Judicata- A Comparative Perspective [ការទទួលស្គាល់អាជ្ញាអស់ជំនុំ - ក្នុងគោលបំណងប្រៀបធៀប], (២០១១), ៣៥៤

[2] មាត្រា ១២៨ថ្មី (មាត្រា១០៩ចាស់) កថាខណ្ឌទី២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

[3] Yuval Sinai, Reconsidering Res Judicata- A Comparative Perspective [ការទទួលស្គាល់អាជ្ញាអស់ជំនុំ - ក្នុងគោលបំណងប្រៀបធៀប], (២០១១), ៣៦០

[4] A.C. FREEMAN, *A TREATISE OF THE LAW OF JUDGMENTS ភាគ១*, បោះពុម្ពលើកទី៥ (សេនហ្វ្រេនស៊ីស្កូ៖ Bancroft-Whitney Company, ១៩២៥), ១៣២១

[5] Donald J. Lange, *The Doctrine of Res Judicata in Canada,* [ទ្រឹស្តីនៃអាជ្ញាអស់ជំនុំក្នុងប្រទេសកាណាដា], បោះពុម្ពលើកទី៣ (កាណាដា ៖ LexisNexis, ២០១០), ២៩

[6] Donald J. Lange, *The Doctrine of Res Judicata in Canada,* [ទ្រឹស្តីនៃអាជ្ញាអស់ជំនុំក្នុងប្រទេសកាណាដា], *បោះពុម្ពលើកទី៣* (កាណាដា ៖ LexisNexis, ២០១០), ២

រដ្ឋប្បវេណីដែលកម្ពុជាកំពុងអនុវត្តសព្វថ្ងៃនេះ បានទទួលឥទ្ធិពលពីក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន និងអាឡឺម៉ង់[7]។ ក្នុងហេតុផលនេះ ការស្វែងយល់អំពីគោលគំនិតនៃទ្រឹស្តីដើមរបស់ប្រទេសដែលជាប្រភពនៃនីតិកម្មកម្ពុជា ព្រមទាំងច្បាប់នៃប្រទេសជឿនលឿន មានភាពសំខាន់នៅក្នុងការបកស្រាយបទប្បញ្ញត្តិ ដែលទាក់ទងនឹងអាជ្ញាអស់ជំនុំនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា។

ផ្នែកនេះ មានកម្មវត្ថុបកស្រាយនូវទ្រឹស្តីអាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីក្នុងប្រព័ន្ធច្បាប់ធំៗទាំងពីរ គឺ ផ្នែក ១.១.១ លក្ខណៈអាជ្ញាអស់ជំនុំនៃប្រព័ន្ធច្បាប់ Common Law និង ផ្នែក ១.១.២ លក្ខណៈអាជ្ញាអស់ជំនុំនៃប្រព័ន្ធច្បាប់ Civil Law។

### ១.១.១ លក្ខណៈអាជ្ញាអស់ជំនុំនៃប្រព័ន្ធច្បាប់ខមម៉ុនឡ

ច្បាប់នៃប្រទេសដែលប្រកាន់យកប្រព័ន្ធ Common Law ពុំមានលក្ខណៈរូបិយ ពោលគឺពុំផ្អែកលើវិធានសរសេរ ប៉ុន្តែវាផ្អែកយ៉ាងសំខាន់ទៅលើយុត្តិសាស្ត្ររបស់តុលាការ។ ដោយសារតែយុត្តិសាស្ត្រជាប្រភពនៃច្បាប់ របបគតិយុត្តនៃអាជ្ញាអស់ជំនុំនៅក្នុងប្រព័ន្ធច្បាប់នេះមានប្រភពចេញពីយុត្តិសាស្ត្ររបស់តុលាការ[8]។ តុលាការដើរតួជាអ្នកបង្កើតច្បាប់ក្រោមរូបភាពជាយុត្តិសាស្ត្រ ដើម្បីដោះស្រាយវិវាទក្នុងការបកស្រាយទ្រឹស្តីអាជ្ញាអស់ជំនុំ។ ប្រទេសនីមួយៗ ទោះបីជាមានប្រព័ន្ធច្បាប់ដូចគ្នា ក៏ទ្រឹស្តីអាជ្ញាអស់ជំនុំមានភាពខុសប្លែកគ្នាផងដែរ។ នៅក្នុងផ្នែកនេះ យើងពុំធ្វើការសិក្សាលើភាពដោយឡែកនៃទ្រឹស្តីនេះទេ ប៉ុន្តែយើងនឹងសិក្សាពីទស្សនទានជារួមនៃប្រទេសដែលប្រកាន់ប្រព័ន្ធច្បាប់នេះ ចំពោះទ្រឹស្តីនៃអាជ្ញាអស់ជំនុំ។

យុត្តិសាស្ត្រដ៏ល្បីមួយរបស់អង់គ្លេស គឺ Handerson v. Handerson ដែលជារឿងក្តីទាក់ទងនឹងចំណែកមរតករបស់គ្រួសារ Handerson។ ក្នុងរឿងក្តីនេះ វាបានបង្កើតជាគោលការណ៍មួយដែលត្រូវបានបណ្តាប្រទេសនានាយកទៅអនុវត្ត ដូចជា សិង្ហបុរី ហុងកុង ម៉ាឡេស៊ី អូស្ត្រាលី និងហ្វូឡង់[9]។ វិធានក្នុងរឿងក្តីនេះសំដែងថា “ទាំងទម្រង់នៃការហាមឃាត់ការទាមទារ និង ការហាមឃាត់ចំណុចវិវាទ ការហាមឃាត់មិនអនុវត្តចំពោះតែចំណុចដែលត្រូវបានសម្រេចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង

---

[7] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី, *សេចក្តីកំណត់មាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី*, (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០០៧), មាត្រា ១៩៤ (ផ្នែកយោង)

[8] Donald J. Lange, *The Doctrine of Res Judicata in Canada*, [ទ្រឹស្តីនៃអាជ្ញាអស់ជំនុំក្នុងប្រទេសកាណាដា], *បោះពុម្ពលើកទី៣* (កាណាដា ៖ LexisNexis, ២០១០), ២ ដល់ ៣

[9] David A R WILLIAMS QC និង Mark TUSHINGHAM, *The Application of The Henderson v Henderson Rule in International Arbitration*, [ការយកមកអនុវត្តនៃវិធានក្នុងរឿងក្តី ហេនដឺសិន នៅក្នុងមជ្ឈត្តការអន្តរជាតិ], (សិង្ហបុរី៖ Singapore Academy of Law Journal, ២០១៤), ២

ចំពោះចំណុចដែលអាចពាក់ព័ន្ធនឹងបណ្តឹង ហើយដែលភាគីដែលបានចូលរួម មានឱកាសលើកឡើងនៅពេលនោះផងដែរ។”[10] [បកប្រែ]

ប្រព័ន្ធច្បាប់ Common Law បានអោយនិយមន័យពាក្យអាជ្ញាអស់ជំនុំផ្អែកលើ ភាសាឡាតាំង “Res Judicata” ប្រែថា “ចំណុចដែលបានវិនិច្ឆ័យរួច” ហើយតាមទស្សនទាននៃប្រព័ន្ធច្បាប់នេះ អាជ្ញាអស់ជំនុំសំដៅលើទម្រង់នៃការហាមឃាត់ចំនួនពីរប្រភេទគឺ ***ការហាមឃាត់ការទាមទារ*** និង ***ការហាមឃាត់ចំណុចវិវាទ***។

**១.១.១.១ ការហាមឃាត់ការទាមទារ** (*Cause of action Estoppel)*

ចំពោះការទាមទារដែលត្រូវបានតុលាការដែលមានសមត្ថកិច្ច បានវិនិច្ឆ័យ និងចេញសេចក្តីសម្រេចលើអង្គសេចក្តីចំពោះការទាមទារនោះរួចហើយ ភាគីនៃបណ្តឹងមុនត្រូវបានហាមឃាត់ចំពោះកម្មវត្ថុនៃការទាមទារដដែល ទោះបីជាផ្អែកលើអង្គហេតុផ្សេងក៏ដោយ។ ទស្សនទាននៃការហាមឃាត់នេះផ្អែកលើពាក្យស្លោកជាភាសាឡាតាំងដែលបានសម្តែងថា «Nemo debet lis vexari pro una at eadem causa» ប្រែថា «គ្មាននរណាម្នាក់ត្រូវបានគេប្តឹងម្តងហើយម្តងទៀតចំពោះការទាមទារដដែល»។[11] [បកប្រែ]

នៅក្នុងមុខងារហាមឃាត់ការទាមទារនេះ ភាគីមិនត្រូវបានអនុញ្ញាតឱ្យធ្វើការបំបែកការទាមទារឡើយ (Split Claim)។ បើភាគីបានទាមទារសិទ្ធិលើបំណុលមួយភាគ ក្នុងចំណោមសិទ្ធិលើបំណុលសរុបដែលខ្លួនមាន ភាគផ្សេងទៀតដែលមិនបានទាមទារ ត្រូវចងភាគីមិនឱ្យធ្វើការទាមទារនៅពេលក្រោយ[12]។ ការហាមឃាត់នេះ គឺដើម្បីកុំឱ្យមានការទាមទារច្រើនដង ដែលវាបង្កើតបន្ទុកមិនសមហេតុផលដល់ចុងចម្លើយប្រសិនបើមានបណ្តឹងច្រើន ដែលមានកម្មវត្ថុដដែលបានធ្វើឡើងចំពោះខ្លួន។

ដើម្បីកំណត់ឱ្យបានថា ការទាមទារថ្មីស្ថិតក្រោមវិសាលភាពនៃការហាមឃាត់ឬទេ តុលាការត្រូវពិចារណាលើស្ថានភាពដូចខាងក្រោម ៖

---

[10] Yuval Sinai, Reconsidering Res Judicata- A Comparative Perspective [ការទទួលស្គាល់អាជ្ញាអស់ជំនុំ - ក្នុងគោលបំណងប្រៀបធៀប], (២០១១), ៣៥៨

[11] ការបកប្រែជាភាសាអង់គ្លេស ដោយគេហទំព័រ ៖ http://www.duhaime.org/LegalDictionary/N/NemoDebetBisVexariProUnaEtEademCausa.aspx

[12] Larry L. Teply និង Ralph U. Whitten, *Civil Procedure* [នីតិវិធីរដ្ឋប្បវេណី], បោះពុម្ពលើកទី៣ (រដ្ឋធានីនូយ៉កៈ Foundation Press, ២០០៤), ៩៤៧

"ទី១ ៖ សេចក្តីសម្រេចដែលបានវិនិច្ឆ័យរួចហើយ ត្រូវតែជាសេចក្តីសម្រេចស្ថាពរ ដែលបានចេញដោយតុលាការមានសមត្ថកិច្ច។
ទី២ ៖ ភាគីនៅក្នុងវិវាទក្រោយ ត្រូវតែធ្លាប់បានធ្វើជាភាគី ឬអ្នកចូលរួមអន្តរាគមន៍ ជាមួយភាគីនៅក្នុងបណ្តឹងមុន (ភាពដូចគ្នានៃភាគី)។
ទី៣ ៖ អង្គហេតុជាមូលហេតុនៃការទាមទារ នៃបណ្តឹងមុន ត្រូវដូចគ្នានឹងអង្គហេតុនៃបណ្តឹងក្រោយ។
ទី៤ ៖ អង្គហេតុជាមូលហេតុនៃការទាមទារ ត្រូវតែជាចំណុចវិវាទ ឬគួរតែជាចំណុចវិវាទនៃបណ្តឹងមុន។"[13] [បកប្រែ]

### **១.១.១.២ ការហាមឃាត់ការធ្វើវិវាទអំពីអង្គហេតុ** *(Issue Estoppel)*

ស្រដៀងនឹងការហាមឃាត់ចំពោះការទាមទារខាងលើដែរ ចំពោះចំណុចវិវាទដែលត្រូវបានតុលាការដែលមានសមត្ថកិច្ចសម្រេចដោយផ្អែកលើសាលក្រមស្ថាពររួចហើយ ភាគីត្រូវចងដោយសេចក្តីសម្រេចនោះ ពោលគឺពុំអាចអះអាងអំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុផ្ទុយទៅនឹងសាលក្រមស្ថាពរបានឡើយ ទោះបីបណ្តឹងថ្មីនោះផ្អែកលើការទាមទារផ្សេងក៏ដោយ[14]។ ការហាមឃាត់ការធ្វើវិវាទអំពីអង្គហេតុ ពង្រីកវិសាលភាពចំពោះអង្គហេតុដែលពុំបានធ្វើការអះអាងដោយភាគី តែអង្គហេតុនោះគួរតែអាចអះអាងបាន ក្នុងនីតិវិធីនៃបណ្តឹងមុន។

***<u>ឧទាហរណ៍</u>*** *(១)* ៖ នៅក្នុងបណ្តឹងទាមទារប្រាក់កម្ចី ដើមចោទគប្បីអះអាងអំពីអង្គហេតុនៃការប្រគល់ប្រាក់ ប៉ុន្តែដើមចោទពុំបានអះអាង ដែលជាហេតុនាំអោយ សាលក្រមស្ថាពរច្រានចោលការទាមទារប្រាក់កម្ចីនោះ មានអានុភាពអាជ្ញាអស់ជំនុំលើអង្គហេតុប្រគល់ប្រាក់ ហើយវាហាមឃាត់ដើមចោទមិនអោយអះអាងអំពីអង្គហេតុប្រគល់ប្រាក់ ទោះបីការទាមទារលើកក្រោយផ្អែកលើសេចក្តីចម្រើនឥតហេតុក៏ដោយ។

### **១.១.១.៣. ល័ក្ខខ័ណ្ឌនៃអាជ្ញាអស់ជំនុំ**

ដើម្បីឱ្យសេចក្តីសម្រេចរដ្ឋប្បវេណីមានអាជ្ញាអស់ជំនុំ វាទាមទារឱ្យមានគុណវុឌ្ឍិដែលបានរៀបរាប់ខាងក្រោមនេះ៖

---

[13] សាលដីកាតុលាកាកំពូលកាណាដា, Grandview (Town) v. Doering [1976], ដកស្រង់ពីសៀវភៅ Doctrine of res judicata ទំព័រ ១៩១

[14] Larry L. Teply និង Ralph U. Whitten, *Civil Procedure* [នីតិវិធីរដ្ឋប្បវេណី], បោះពុម្ពលើកទី៣ (រដ្ឋធានីនូយ៉កៈ Foundation Press, ២០០៤), ៩៦៣

### ក. សាលក្រមស្ថាពរលើអង្គសេចក្តី

ជាគោលការណ៍ អាជ្ញាអស់ជំនុំ នឹងត្រូវយកមកអនុវត្តក្នុងករណីដែលតុលាការដែលចេញសាលក្រម នោះបានវិនិច្ឆ័យលើអង្គសេចក្តី ពោលគឺវិនិច្ឆ័យអំពីសិទ្ធិ និងទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃវិវាទ។ ក្នុងករណីដែលតុលាការលើកចោលបណ្តឹងដោយពុំផ្អែកលើការវិនិច្ឆ័យលើអង្គសេចក្តី តែដោយផ្អែកលើភាពមិនគ្រប់គ្រាន់នៃលក្ខខ័ណ្ឌបណ្តឹង ជាអាទិ៍សមត្ថភាពជាភាគី ឬសមត្ថកិច្ចតុលាការ សាលក្រមបែបមិនមែនជាសាលក្រមលើអង្គសេចក្តី ហើយវាពុំមានអានុភាពអាជ្ញាអស់ជំនុំទេ។[15] បន្ថែមពីនេះទៀត សេចក្តីសម្រេចដែលមានចរិតលក្ខណៈជាការដឹកនាំនីតិវិធី ក៏ពុំមែនជាកម្មវត្ថុនៃការជំនុំជម្រះលើអង្គសេចក្តីដែរ ហេតុនេះវាក៏គ្មានអាជ្ញាអស់ជំនុំនោះទេ។

***ឧទាហរណ៍៖*** តុលាការបានលើកចោលបណ្តឹងរបស់ដើមចោទដោយផ្អែកលើភាពមិនអាចកែតម្រូវបាននៃសមត្ថភាពជាភាគី (ការខ្វះសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្តឹង)។ ការលើកចោលនេះមិនបានផ្អែកលើការវិនិច្ឆ័យលើអង្គសេចក្តី ដែលជាហេតុនាំអោយភាគីមិនអាចត្រូវបានហាមឃាត់ក្នុងការទាមទារ ដែលមានកម្មវត្ថុដូចនឹងការទាមទារដែលត្រូវបានលើកចោលដោយសេចក្តីសម្រេចមុនឡើយ។ ភាគីអាចដាក់បណ្តឹងដែលមានការទាមទារដដែល នៅពេលដែលមានសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្តឹងឡើងវិញ។

សេចក្តីសម្រេចដែលមានអាជ្ញាអស់ជំនុំត្រូវតែជាសេចក្តីសម្រេចស្ថាពរ។[16] សេចក្តីសម្រេចដែលចូលជាស្ថាពរ ជាសេចក្តីសម្រេចដែលលែងជាកម្មវត្ថុនៃបណ្តឹងឧបាស្រ័យណាមួយទៀត។ សាលក្រមដែលជំនុំជម្រះលើអង្គសេចក្តីដែលបានចេញដោយតុលាការនៃនីតិវិធីជំនុំជម្រះលើកទី១ ពុំចាត់ទុកថាស្ថាពរឡើយ ប្រសិនបើអំឡុងពេលសម្រាប់បណ្តឹងឧបាស្រ័យពុំទាន់ផុត។ ពេលស្ថាពរនៃសាលក្រមជាចំណុចចាប់ផ្តើមនៃអានុភាពអាជ្ញាអស់ជំនុំ។

### ខ. សាលក្រមដែលចេញដោយតុលាការមានសមត្ថកិច្ច

សមត្ថកិច្ចតុលាការជាចំណុចសំខាន់ក្នុងការធានាភាពត្រឹមត្រូវនៃការវិនិច្ឆ័យ។ ប្រសិនបើសេចក្តីសម្រេច ជាអាទិ៍សាលក្រម ពុំបានចេញដោយតុលាការដែលមានសមត្ថកិច្ចតាមលំនៅឋាន ឬតាមកម្មវត្ថុវិវាទទេនោះ ត្រូវចាត់ទុកថាមានអសុពលភាព។ ភាពមិនត្រឹមត្រូវនៃសមត្ថកិច្ចតុលាការ

---

[15] Larry L. Teply និង Ralph U. Whitten, *Civil Procedure* [នីតិវិធីរដ្ឋប្បវេណី], បោះពុម្ពលើកទី៣ (រដ្ឋធានីនូយ៉ក៖ Foundation Press, ២០០៤),៩៤៧

[16] Donald J. Lange, *The Doctrine of Res Judicata in Canada,* [ទ្រឹស្តីនៃអាជ្ញាអស់ជំនុំក្នុងប្រទេសកាណាដា], បោះពុម្ពលើកទី៣ (កាណាដា ៖ LexisNexis, ២០១០), ៩៤

មានផលប៉ះពាល់ដល់លទ្ធផលនៃនីតិវិធីបណ្តឹង ហេតុនេះសាលក្រម ឬសាលដីកាដែលចេញដោយតុលាការគ្មានសមត្ថកិច្ច ត្រូវចាត់ទុកថាមោឃៈ។

តុលាការប្រទេសកាណាដា នៅក្នុងសំណុំរឿង Hanna v. Costeron ឆ្នាំ១៩១៨ បានសម្តែងនូវគោលការណ៍មួយថា "នឹងមិនមានអានុភាពអាជ្ញាអស់ជំនុំឡើយប្រសិនបើតុលាការដែលបានចេញសាលក្រមនោះពុំមានសមត្ថកិច្ច។"[17] តាមរយៈឃ្លានេះ តុលាការចង់សង្កត់ធ្ងន់ទៅលើកំហុសផ្នែកនីតិវិធីដែលធ្វើឱ្យសេចក្តីសម្រេចដែលចេញមកចាត់ទុកជាគ្មានបានការ ហើយមិនអាចទទួលស្គាល់អានុភាពអាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចនោះឡើយ។

ដើម្បីអះអាងអំពីការមិនយកមកអនុវត្តនូវអានុភាពអាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចមុន ភាគីនៃបណ្តឹងក្រោយ អាចអះអាងអំពីអសមត្ថកិច្ចយុត្តាធិការនៃតុលាការដែលបានចេញសាលក្រម ឬសាលដីកាមុនដើម្បីជាមធ្យោបាយការពារ។

### គ. ចរិតលក្ខណៈនៃការទាញហេតុផល

ការទាញហេតុផលផ្ទាល់មាត់លើអង្គសេចក្តី ជាគុណវុឌ្ឍិមួយនៃអាជ្ញាអស់ជំនុំ។ សេចក្តីសម្រេចផ្អែកលើនីតិវិធីដែលពុំមានចរិតលក្ខណៈជាការទាញហេតុផល ពុំមែនជាកម្មវត្ថុនៃអាជ្ញាអស់ជំនុំឡើយ។ វាចាំបាច់ត្រូវតែមានភាគីពីរ ដែលមានផលប្រយោជន៍ផ្ទុយគ្នា ទាញហេតុផល ហើយសាលក្រម ឬសាលដីកានៃបណ្តឹងមុនត្រូវបានចេញក្នុងប្រយោជន៍ភាគីណាម្ខាង។ សាលក្រមក្នុងនីតិវិធីដែលមានចរិតលក្ខណៈជាការជំនុំជម្រះដោយឆន្ទានុសិទ្ធិ មិនមានអានុភាពអាជ្ញាអស់ជំនុំទេ។[18]

មូលហេតុចំបងនៃការកំណត់គុណវុឌ្ឍិនេះ គឺដោយសារតែអ្នកទ្រឹស្តីពុំពង្រីកវិសាលភាពនៃអាជ្ញាអស់ជំនុំ ចំពោះសេចក្តីសម្រេច ដែលពុំមានការចូលរួមក្នុងសកម្មភាពបណ្តឹងរបស់ភាគី។ ប្រសិនបើភាគីពុំមានឱកាសគ្រប់គ្រាន់ក្នុងការទាញហេតុផលនោះទេ ពុំគប្បីអោយសេចក្តីសម្រេចប្រភេទនោះមានអានុភាពអាជ្ញាអស់ជំនុំឡើយ។

[17] Donald J. Lange, *The Doctrine of Res Judicata in Canada,* [ទ្រឹស្តីនៃអាជ្ញាអស់ជំនុំក្នុងប្រទេសកាណាដា], បោះពុម្ពលើកទី៣ (កាណាដា ៖ LexisNexis, ២០១០), ៩៤

[18] Donald J. Lange, *The Doctrine of Res Judicata in Canada,* [ទ្រឹស្តីនៃអាជ្ញាអស់ជំនុំក្នុងប្រទេសកាណាដា], បោះពុម្ពលើកទី៣ (កាណាដា ៖ LexisNexis, ២០១០), ៩២

### ឃ. អង្គវិនិច្ឆ័យ

សេចក្តីសម្រេចដែលមានលក្ខណៈអាជ្ញាអស់ជំនុំ ត្រូវតែជាសេចក្តីសម្រេចដែលបានធ្វើដោយផ្អែកលើភាពដែលអាចទុកចិត្តបាននៃសមភាព និងយុត្តិធម៌ នៃអង្គវិនិច្ឆ័យ ក៏ព្រោះថាអាជ្ញាអស់ជំនុំបង្កើតនូវអានុភាពហាមឃាត់ការធ្វើបណ្តឹងថ្មី វាមានផលប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីនៃបណ្តឹង។ មតិមួយរបស់តុលាការកាណាដាយល់ឃើញថា ដើម្បីអោយសេចក្តីសម្រេចដែលធ្វើដោយអង្គវិនិច្ឆ័យមួយមានអានុភាពអាជ្ញាអស់ជំនុំ វាពឹងផ្អែកលើការទទួលស្គាល់ដោយច្បាប់ជាតិ។ ប្រសិនបើនីតិបញ្ញត្តិមានភាពជឿទុកចិត្តលើអង្គវិនិច្ឆ័យមួយថាអាចជំនុំជម្រះ និងដោះស្រាយវិវាទដោយត្រឹមត្រូវ និងយុត្តិធម៌ នីតិបញ្ញត្តិនឹងសម្តែងនៅក្នុងលិខិតបទដ្ឋានគតិយុត្តទទួលស្គាល់សេចក្តីសម្រេចរបស់អង្គវិនិច្ឆ័យនោះមានអាជ្ញាអស់ជំនុំ។[19]

## ១.១.២ ទ្រឹស្តីអាជ្ញាអស់ជំនុំនៃប្រព័ន្ធច្បាប់ស៊ីវិលឡ

ខុសពីនីតិកម្មនៃប្រទេសប្រកាន់ប្រព័ន្ធច្បាប់ Common Law ប្រទេសដែលប្រកាន់ប្រព័ន្ធច្បាប់ Civil Law មានទំនោរទៅរកការតាក់តែងជាអត្ថបទច្បាប់។ បទប្បញ្ញត្តិស្តីពីអាជ្ញាអស់ជំនុំ យើងអាចឃើញនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃបណ្តាប្រទេសដែលប្រកាន់និន្នាការ Civil Law។ ទ្រឹស្តីអាជ្ញាអស់ជំនុំនៃប្រទេសប្រកាន់និន្នាការ Civil Law នេះ មានលក្ខណៈចង្អៀតជាងទ្រឹស្តីនៃប្រទេស Common Law ដោយវាទទួលស្គាល់តែអានុភាពអាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចចំពោះការទាមទារប៉ុណ្ណោះ ដោយពុំពង្រីកវិសាលភាពដល់ចំណុចវិវាទដែលបានសម្រេចក្នុងសំអាងហេតុនៃសាលក្រមឡើយ។ ទោះជាយ៉ាងនេះក្តី ការកំណត់ពីវិសាលភាពនៃអាជ្ញាអស់ជំនុំមានមានភាពខុសប្លែកគ្នារវាងប្រទេសនីមួយៗ។ តួយ៉ាងនៅប្រទេសអាឡឺម៉ង់ និង ស្វីស អាជ្ញាអស់ជំនុំត្រូវបានកម្រិតត្រឹមផ្នែកនៃសេចក្តីសម្រេចនៃសាលក្រម ដោយពុំគ្របដណ្តប់ផ្នែកសំអាងហេតុឡើយ។ ចំណែកឯប្រទេសបារាំង បែលហ្ស៊ិក និងអ៊ីតាលី វិញមានការទទួលស្គាល់មួយចំនួនចំពោះអានុភាពអាជ្ញាអស់ជំនុំនៃផ្នែកសំអាងហេតុ។[20]

[19] Donald J. Lange, *The Doctrine of Res Judicata in Canada,* [ទ្រឹស្តីនៃអាជ្ញាអស់ជំនុំក្នុងប្រទេសកាណាដា], បោះពុម្ពលើកទី៣, (កាណាដា ៖ LexisNexis, ២០១០), ១២០

[20] Gretta Walters, “Fitting a Square Peg into a Round Hole: Do Res Judicata Challenges in International Arbitration Constitute Jurisdictional or Admissibility Problems?”, *Kluwer Law International* 29 (២០១២): ២

### ១.១.២.១ ភាពចង្អៀតនៃវិសាលភាពអាជ្ញាអស់ជំនុំ

ទ្រឹស្តីអាជ្ញាអស់ជំនុំនៅក្នុងប្រព័ន្ធច្បាប់ Civil Law កម្រិតត្រឹមតែចំណុចដែលត្រូវបានវិនិច្ឆ័យនៅក្នុង ***ផ្នែកសេចក្តីសម្រេចបញ្ចប់*** នៃសាលក្រមតែប៉ុណ្ណោះ។ ហេតុនេះហើយទើបវាមានលក្ខណៈចង្អៀតជាងរបបគតិយុត្តនៃអាជ្ញាអស់ជំនុំតាមប្រព័ន្ធច្បាប់ Common Law។

នៅក្នុងសាលក្រមរដ្ឋប្បវេណី វាត្រូវបានបែងចែកជាពីរផ្នែកសំខាន់ៗ គឺ សំអាងហេតុ និងសេចក្តីសម្រេចបញ្ចប់។ សំអាងហេតុ ជាផ្នែកដែលតុលាការសម្តែងការយល់ឃើញរបស់ខ្លួនចំពោះអង្គហេតុដែលជាចំណុចវិវាទ។ តុលាការត្រូវសម្រេចទទួលស្គាល់ ឬមិនទទួលស្គាល់នូវអង្គហេតុដែលជាចំណុចវិវាទ ព្រមទាំងផ្តល់ហេតុផលអោយបានសមស្រប។ ចំណែកឯផ្នែកសេចក្តីសម្រេចបញ្ចប់គឺជាផ្នែកដែលតុលាការធ្វើការសម្រេចចំពោះការទាមទាររបស់ដើមចោទ និងបណ្តឹងតបរបស់ចុងចម្លើយ។ ប្រសិនបើតុលាការយល់ឃើញថាអង្គហេតុដែលដើមចោទបានអះអាងអាចនាំអោយកកើតសិទ្ធិទាមទារ នោះតុលាការនឹងសម្រេចតាមការទាមទារនៅក្នុងផ្នែកសេចក្តីសម្រេចនេះ។ ជាគោលការណ៍ វិសាលភាពនៃអានុភាពអាជ្ញាអស់ជំនុំ មានតែចំពោះផ្នែកសេចក្តីសម្រេចនៃសាលក្រមតែប៉ុណ្ណោះ។[21]

លក្ខណៈខុសគ្នាមួយទៀតនៃអាជ្ញាអស់ជំនុំនៅក្នុងប្រព័ន្ធច្បាប់ទាំងពីរ ប្រព័ន្ធច្បាប់ Common Law ប្រកាន់យកគោលការណ៍នៃការបកស្រាយតឹងរ៉ឹងទាក់ទងចំពោះអានុភាពនៃអាជ្ញាអស់ជំនុំដែលហាមឃាត់ការទាមទារ។ ក្នុងគោលការណ៍ទូលាយនៃប្រព័ន្ធច្បាប់ Common Law ការទាមទារដែលគួរតែអាចលើកឡើងតែបែរជាមិនបានលើកឡើង ដូចសម្តែងក្នុងឧទាហរណ៍ (១)[22] ខាងលើត្រូវបានរារាំងការទាមទារដោយអាជ្ញាអស់ជំនុំ។ ផ្ទុយទៅវិញទ្រឹស្តីនៅក្នុងប្រព័ន្ធច្បាប់ Civil Law ពុំទទួលស្គាល់ការពង្រីកវិសាលភាពបែបនេះទេ។ អាជ្ញាអស់ជំនុំចំពោះការទាមទារ មានតែចំពោះការទាមទារដែលត្រូវបានតុលាការសម្រេចហើយតែប៉ុណ្ណោះ។ ចំពោះការទាមទារដែលគួរតែធ្វើឡើងតែមិនបានធ្វើ ពុំស្ថិតក្នុងវិសាលភាពនៃអាជ្ញាអស់ជំនុំ តាមប្រព័ន្ធច្បាប់ Civil Law ឡើយ។

***<u>ឧទាហរណ៍</u> ៖*** ក្នុងបណ្តឹងទាមទាររបស់ដើមចោទ ដើមចោទបានទាមទារអោយតុលាការចេញសាលក្រមដែលមានខ្លឹមសារថា បង្គាប់អោយចុងចម្លើយបង់ប្រាក់ដើមចំនួន $១,០០០ ប៉ុន្តែពុំបានសម្តែងឆន្ទៈទាមទារការប្រាក់ទេ ទោះបីជាដើមចោទមានសិទ្ធិទាមទារក៏ដោយ។ ក្នុងន័យចង្អៀតដែលប្រព័ន្ធច្បាប់ Civil Law ប្រកាន់យក គឺអាជ្ញាអស់ជំនុំពុំមានចំពោះសិទ្ធិលើបំណុលជាការប្រាក់ទេ ហេតុនេះដើមចោទអាចធ្វើការទាមទារការប្រាក់នៅក្នុងបណ្តឹងក្រោយ។

---

[21] មាត្រា ១១៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន

[22] សូមមើលទំព័រ៨

## ១.២ សញ្ញាណនៃអាជ្ញាអស់ជំនុំនៅក្នុងប្រព័ន្ធគតិយុត្តកម្ពុជា

ពុំមានភាពខុសគ្នាពីបណ្តាយុត្តាធិកាផ្សេងៗទៀតឡើយ កម្ពុជាក៏បានបង្កើតឱ្យមាននូវរបប អាជ្ញាអស់ជំនុំនៅក្នុងនីតិវិជ្ជមានរបស់ខ្លួនដែរ។ មុននឹងឈានដល់ការសិក្សាដោយលំអិតអំពី លក្ខណៈនៃរបបនេះនៅក្នុងជំពូកបន្ទាប់ យើងគប្បីស្វែងយល់អំពីនិយមន័យរបស់របបគតិយុត្តនេះ ព្រមទាំងធ្វើការកំណត់ឱ្យបានជាក់លាក់ អំពីលក្ខណសម្បត្តិនៃសេចក្តីសម្រេចរដ្ឋប្បវេណីដែលមាន អាជ្ញាអស់ជំនុំ។

### ១.២.១ អត្ថន័យនៃអាជ្ញាអស់ជំនុំនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី

សញ្ញាណនេះបានចាក់ឫសក្នុងប្រព័ន្ធគតិយុត្តកម្ពុជា តាំងពីមុនវត្តមាននៃក្រមនីតិវិធី រដ្ឋប្បវេណីឆ្នាំ២០០៦ មកម្ល៉េះ។ ទោះបីជាពុំបានសម្តែងក្នុងន័យច្បាស់លាស់ក្តី មាត្រា ១៥ នៃច្បាប់ ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា ដែលធ្លាប់ត្រូវបានអនុវត្ត ចាប់ពីឆ្នាំ ១៩៩៣ មកទល់នឹងកាលបរិច្ឆេទនៃការអនុវត្តក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៦[23] បានបង្កប់នូវ ខ្លឹមសារដូច្នេះថា «បណ្តឹងសើរើធ្វើបានចំពោះសាលក្រម ឬសាលដីកាស្ថាពរ ហើយដែលមាន **អំណាចដាច់ខាត**»។ មាត្រានេះមានគោលគំនិតថា “អំណាចដាច់ខាត” (សំដៅលើអាជ្ញាអស់ជំនុំ) ពុំ ត្រូវបានបំពានជាដាច់ខាតលើកលែងតែមានបណ្តឹងសើរើ (បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី)។

ពុំមានបទប្បញ្ញត្តិជាក់លាក់ណាមួយនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា បានសម្តែងពី និយមន័យនៃអាជ្ញាអស់ជំនុំទេ។ បទប្បញ្ញត្តិតែមួយគត់ ស្តីពីអាជ្ញាអស់ជំនុំ ដែលយើងអាចឃើញ គឺ មាត្រា ១៩៤។ កថាខណ្ឌទី១ នៃមាត្រា ១៩៤ បានសម្តែងថា « នៅពេលដែលសាលក្រមចូលជា ស្ថាពរហើយ អានុភាពនៃអាជ្ញាអស់ជំនុំនឹងកើតឡើង។» មាត្រានេះពុំមែនជាបទប្បញ្ញត្តិដែលកំណត់ អំពីនិយមន័យនៃអាជ្ញាអស់ជំនុំទេ ប៉ុន្តែវាគឺជាមូលដ្ឋានក្នុងការកំណត់អំពីនិយមន័យនៃអាជ្ញាអស់ ជំនុំ។

តាមអត្ថន័យនៃ បញ្ញត្តិនេះ យើងអាចបកស្រាយបានថា គ្រប់សាលក្រមដែលចូលជាស្ថាពរ សុទ្ធសឹងតែមានអានុភាពអាជ្ញាអស់ជំនុំ។ តើអាជ្ញាអស់ជំនុំ នាំអោយសាលក្រមដែលចូលជាស្ថាពរ មានអានុភាពដូចម្តេច? មាត្រា ៣០៧ កថាខណ្ឌទី១ ចំណុច ញ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានចាត់ ទុកសាលក្រម ឬសាលដីកាដែលសម្រេចផ្ទុយនឹង សាលក្រមឬសាលដីកាស្ថាពរ ជាសាលក្រមខុស ច្បាប់ និងជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី។ ហេតុនេះរាល់សេចក្តីសម្រេច ដែលធ្វើ

[23] មាត្រា ៥៨៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា (ការនិរាករណ៍ដោយផ្នែកនៃបទប្បញ្ញត្តិដែលផ្ទុយ)

ឡើងផ្ទុយនឹងសាលក្រមស្ថាពរ ដែលមានអានុភាពអាជ្ញាអស់ជំនុំតាមមាត្រា១៩៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ជាសេចក្តីសម្រេចដែលផ្ទុយនឹងអានុភាពនៃអាជ្ញាអស់ជំនុំ។

យើងអាចសង្រួមជានិយមន័យបានថា « **អាជ្ញាអស់ជំនុំគឺជាអានុភាពហាមឃាត់នៃសេចក្តីសម្រេចជាស្ថាពរដែលធ្វើឡើងដោយតុលាការមានសមត្ថកិច្ច មិនអោយមានការទាមទារ ឬការសម្រេចសេចក្តីថ្មី ដែលផ្ទុយនឹងសេចក្តីសម្រេចជាស្ថាពរនោះ** »។

យ៉ាងណាមិញ ការកំណត់អំពីនិយមន័យនេះ ពុំមែនជាវិធីសាស្ត្រដែលគប្បីយកមកប្រើប្រាស់គ្រប់ស្ថានភាពនោះទេ។ មូលហេតុដែលនីតិនិពន្ធពុំមានទំនោរទៅរកការចែងឱ្យនិយមន័យ ក៏ព្រោះពួកគេយល់ឃើញថា ការចែងអំពីនិយមន័យនៃរបបគតិយុត្តជាក់លាក់មួយ វាអាចបង្កឱ្យបទប្បញ្ញត្តិទាំងនោះពុំអាចយកទៅបកស្រាយដោយបត់បែនបាន ដោយសារតែភាពជាក់លាក់ពេករបស់វា។ ការព្យាយាមកំណត់និយមន័យក្នុងផ្នែកនេះ គ្រាន់តែដើម្បីស្វែងយល់អំពីលក្ខណៈទូទៅនៃរបបគតិយុត្តនេះតែប៉ុណ្ណោះ។

### ១.២.២ ប្រភេទនៃសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីដែលមានអានុភាពអាជ្ញាអស់ជំនុំ

ដើម្បីអាចដោះស្រាយវិវាទ តុលាការរដ្ឋប្បវេណីអាចប្រើប្រាស់សេចក្តីសម្រេចក្រោមទម្រង់ជា សាលក្រម សាលដីកា ឬដីកាសម្រេច ទៅតាមលក្ខណៈនៃនីតិវិធី[24]។ បន្ថែមពីនេះទៀត ក្រមនីតិវិធីរដ្ឋប្បវេណីក៏ទទួលស្គាល់នូវសេចក្តីសម្រេចដែលធ្វើដោយអង្គវិនិច្ឆ័យផ្សេងទៀតដូចជា សេចក្តីបង្គាប់របស់មជ្ឈត្តករ[25] និងសាលក្រមនៃតុលាការបរទេស[26]។ នៅក្នុងផ្នែកនេះមានគោលបំណងបកស្រាយអំពី មូលដ្ឋាននៃការវិនិច្ឆ័យអំពីលក្ខណសម្បត្តិ ព្រមទាំងធ្វើការកំណត់ផ្អែកលើមូលដ្ឋានវិនិច្ឆ័យទាំងនោះ ដើម្បីធ្វើការបែងចែកឱ្យបានប្រត្យក្ស រវាងប្រភេទនៃសេចក្តីសម្រេច ដែលមានអានុភាពអាជ្ញាអស់ជំនុំ និងដែលគ្មានអានុភាពអាជ្ញាអស់ជំនុំ។

#### ១.២.២.១ លក្ខណៈវិនិច្ឆ័យ

ការបកស្រាយអំពីរបបគតិយុត្តនៃអាជ្ញាអស់ជំនុំ ពឹងផ្អែកទាំងស្រុងលើសេចក្តីសម្រេចដែលជាសាលក្រមចុងក្រោយ[27]។ ប៉ុន្តែមានករណីខ្លះដែលសេចក្តីសម្រេចដែលមិនមែនជាសាលក្រមត្រូវបានច្បាប់ កំណត់ឱ្យយកមកអនុវត្តដូចគ្នា នឹងបញ្ញត្តិស្តីពីសាលក្រម ដែលជាមូលហេតុនាំឱ្យ

---

[24] មាត្រា ១៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[25] មាត្រា ៣៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[26] មាត្រា ៣៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[27] មាត្រា ១៩៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

មានការបកស្រាយថា តើវាពិតជាមានអាជ្ញាអស់ជំនុំដូចសាលក្រមចុងក្រោយដែរឬទេ? ដូច្នេះ នៅក្នុងផ្នែកនេះ យើងនឹងធ្វើការសិក្សាលើ លក្ខណៈវិនិច្ឆ័យនៃសេចក្តីសម្រេច ដែលអាចយករបបគតិយុត្តនៃអាជ្ញាអស់ជំនុំមកអនុវត្តបាន។ សេចក្តីសម្រេចទាំងនោះ ត្រូវឈរលើគុណវុឌ្ឍិមួយចំនួនដូចខាងក្រោម ៖

### ក. សេចក្តីសម្រេចផ្អែកលើការទាញហេតុផល

សេចក្តីសម្រេចដែលបានកំណត់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី អាចចេញដោយផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់លើអង្គសេចក្តី ហើយករណីមួយចំនួនទៀត វាត្រូវបានចេញដោយពុំផ្អែកលើការទាញហេតុផល។[28] ភាគច្រើននៃសេចក្តីសម្រេចដែលមានទម្រង់ជាសាលក្រម សុទ្ធសឹងតែត្រូវផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់ (លើកលែងតែការចេញសាលក្រមកំបាំងមុខ)[29]។

មូលហេតុដែលកំណត់យកនីតិវិធី ដែលមានចរិតលក្ខណៈជាការទាញហេតុផលលើអង្គសេចក្តី ជាគុណវុឌ្ឍិនៃអាជ្ញាអស់ជំនុំ ដោយសារតែនីតិវិធីប្រភេទនេះបានផ្តល់សិទ្ធិស្មើគ្នាដល់ភាគីក្នុងការទាញហេតុផល ហើយលទ្ធផលនៃការទាញហេតុផលជាមូលដ្ឋានដើម្បីឱ្យតុលាការចេញសាលក្រមលើអង្គសេចក្តី[30]។ នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ភាគីនៃវិវាទមានសិទ្ធិ និងឱកាសពេញលេញក្នុងការប្រើប្រាស់សិទ្ធិជាមូលដ្ឋាននៃនីតិវិធី (គោលការណ៍ចំពោះមុខ) របស់ខ្លួន ដូចជាការអះអាង ការទទួលស្គាល់ការទាមទារ ឬបដិសេធការទាមទារ ការដាក់ភស្តុតាងជាអាទិ៍ ហេតុនេះលទ្ធផលដែលកើតចេញពីការវិនិច្ឆ័យលើអង្គសេចក្តី ត្រូវចងគូភាគីដែលបានចូលរួមទាញហេតុផលនោះ។[31]

ផ្ទុយមកវិញ នីតិវិធីដែលពុំមានចរិតលក្ខណៈជាការទាញហេតុផល ដែលភាគច្រើនយើងឃើញនៅក្នុងនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង[32] ពុំឈរលើគោលការណ៍នៃការទាញហេតុផលនោះទេ។ ក្នុងនីតិវិធីប្រភេទនេះ តុលាការពុំត្រូវចងដោយលទ្ធផលនៃការទាញហេតុផលរបស់ភាគីទេ ដែលវាបានបង្ហាញថា គោលការណ៍ចំពោះមុខពុំត្រូវបានគោរពពេញលេញ។ ហេតុ

---

[28] មាត្រា ១១៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[29] មាត្រា ២០០ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[30] មាត្រា ១៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[31] Larry L. Teply និង Ralph U. Whitten, *Civil Procedure* [នីតិវិធីរដ្ឋប្បវេណី], បោះពុម្ពលើកទី៣ (រដ្ឋធានីន្យូយ៉កៈ Foundation Press, ២០០៤), ៩៨១

[32] មាត្រា ២៨ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

នេះលទ្ធផលដែលពុំកើតចេញពីការទាញហេតុផលរវាងភាគីនៃវិវាទ ពុំមានអានុភាពអាជ្ញាអស់ជំនុំឡើយ។

**ខ. នីតិវិធីដែលបានផ្តល់ឱកាសគ្រប់គ្រាន់ដល់ភាគី**

ទោះបីជានីតិវិធីនោះមានចរិតលក្ខណៈជាការទាញហេតុផលដូចបានរៀបរាប់ខាងលើនេះក៏ដោយ ប្រសិនបើភាគីពុំត្រូវបានផ្តល់ឱកាសគ្រប់គ្រាន់ឱ្យចូលរួមក្នុងការទាញហេតុផលទេ សេចក្តីសម្រេចប្រភេទនោះគ្មានអាជ្ញាអស់ជំនុំទេ។ ការផ្តល់ឱកាសនេះ អាចស្តែងក្រោមរូបភាពជាការបញ្ជូនដីកាកោះហៅតាមកាលបរិច្ឆេទ ការបញ្ជូនពាក្យបណ្តឹងទៅភាគី ជាអាទិ៍។ ការផ្តល់ឱកាសគ្រប់គ្រាន់ និងស្មើភាពគ្នាដល់ភាគីទាំងអស់នៃវិវាទ ជាការធានាឱ្យបាននូវការអនុវត្តសិទ្ធិទាញហេតុផលបានពេញលេញ។

យើងសង្កេតឃើញថានីតិវិធីដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ជាអាទិ៍ នីតិវិធីជំនុំជម្រះលើកទី១ នីតិវិធីជាស់តឿន នីតិវិធីនៃការចេញសាលក្រមកំបាំងមុខ សុទ្ធសឹងតែបានបញ្ញត្តដោយយកចិត្តទុកដាក់ចំពោះឱកាសក្នុងការចូលរួមដំណើរការនីតិវិធីរបស់ភាគី[33]។ ហេតុនេះទោះបីជានៅក្នុងឱកាសនៃការទាញហេតុផល ភាគីអវត្តមានក៏ដោយ ក៏ពុំត្រូវចាត់ទុកថាសេចក្តីសម្រេចដែលពុំផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់ពុំមានអានុភាពអាជ្ញាអស់ជំនុំដែរ ព្រោះភាគីបានទទួលការជូនដំណឹងត្រឹមត្រូវតាមនីតិវិធី ដែលធានាបាននូវឱកាសក្នុងការទាញហេតុផលរួចជាស្រេចហើយ។

**គ. ភាពចុងក្រោយនៃសេចក្តីសម្រេច**

ជាគោលការណ៍ អាជ្ញាអស់ជំនុំត្រូវកើតឡើងនៅពេលដែលសេចក្តីសម្រេចចូលជាស្ថាពរ[34]។ ភាពស្ថាពរ ត្រូវកំណត់ដោយការផុតអំឡុងពេលនៃបណ្តឹងឧបាស្រ័យស្របច្បាប់។ ដរាបណាសេចក្តីសម្រេចពុំទាន់ចូលជាស្ថាពរ ភាគីពុំត្រូវបានចងដោយសេចក្តីសម្រេចនោះឡើយ ពោលគឺភាគីដែលមិនសុខចិត្តនឹងសេចក្តីសម្រេចនោះ នៅតែអាចអនុវត្តសិទ្ធិឧបាស្រ័យស្របច្បាប់របស់ខ្លួន។ ស្ថានភាពដែលនាំអោយសេចក្តីសម្រេចចូលជាស្ថាពរនឹងត្រូវបកស្រាយលំអិតនៅក្នុងជំពូកបន្ទាប់។

[33] មាត្រា ៧៩ កថាខណ្ឌទី១, មាត្រា ១១៥ កថាខណ្ឌទី១, មាត្រា ២០២ មាត្រា ៣១៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[34] មាត្រា ១៩៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

ជាអញ្ញត្រកម្មទៅនឹងគោលការណ៍នេះ ទោះបីជាសាលក្រម ឬសេចក្តីសម្រេចផ្សេងទៀត ចូលជាស្ថាពរក៏ដោយ ប្រសិនបើមានសាលក្រម ឬសាលដីកាត្រូវបានចេញដោយតុលាការនៃបណ្តឹងទាមទារអោយជំនុំជម្រះសាជាថ្មី សេចក្តីសម្រេចដែលបានចូលជាស្ថាពរនោះនឹងបាត់បង់អានុភាពអាជ្ញាអស់ជំនុំ។ មាត្រា ៥៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីប្រទេសអាឡឺម៉ង់បានបញ្ញត្តអំពីការបាត់បង់អានុភាពអាជ្ញាអស់ជំនុំនេះយ៉ាងច្បាស់លាស់ដូច្នេះថា “នីតិវិធីដែលត្រូវបានបញ្ចប់ដោយសាលក្រមចុងក្រោយដែលមានអានុភាពអាជ្ញាអស់ជំនុំ អាចនឹងត្រូវបានបើកម្តងទៀតដោយបណ្តឹងមោឃភាព និង ដោយបណ្តឹងទាមទារអោយជំនុំជម្រះសាជាថ្មី”។[35] [បកប្រែ]

### ឃ. អង្គវិនិច្ឆ័យដែលត្រូវបានច្បាប់ទទួលស្គាល់

តុលាការគឺជាអង្គវិនិច្ឆ័យ ដែលរដ្ឋធម្មនុញ្ញទទួលស្គាល់ ថាមានតួនាទីក្នុងការការពារសិទ្ធិឯកជន[36]។ ដោយឡែក ការទទួលស្គាល់អង្គវិនិច្ឆ័យផ្សេងទៀតក្រៅពីតុលាការ ក្នុងការដោះស្រាយវិវាទឯកជន ត្រូវបានពិចារណាយ៉ាងដិតដល់ពីភាពដែលអាចទុកចិត្តបាននៃនីតិវិធី និងសេចក្តីសម្រេចរបស់អង្គវិនិច្ឆ័យនោះ។ ប្រសិនបើមានបញ្ញត្តិនៅក្នុងលិខិតបទដ្ឋានគតិយុត្តដែលទទួលស្គាល់អំពីអានុភាពចងនៃសេចក្តីសម្រេចដែលបានចេញដោយអង្គវិនិច្ឆ័យមួយ សេចក្តីសម្រេចនោះត្រូវបានចងតុលាការដោយអានុភាពអាជ្ញាអស់ជំនុំរបស់វា។

ប្រសិនបើគ្មានលិខិតបទដ្ឋានគតិយុត្តណាមួយ ចេញមកដើម្បីទទួលស្គាល់អំពីភាពចុងក្រោយនៃសេចក្តីសម្រេចរបស់អង្គវិនិច្ឆ័យផ្សេងក្រៅពីតុលាការទេ ត្រូវបកស្រាយថា អាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី មានវិសាលភាពត្រឹមសេចក្តីសម្រេចដែលធ្វើឡើងដោយតុលាការរដ្ឋប្បវេណី។ ការទទួលស្គាល់នូវសេចក្តីសម្រេចរបស់អង្គវិនិច្ឆ័យក្រៅពីតុលាការអាចសម្តែងនៅក្នុងច្បាប់ជាតិ ជាអាទ៏ ច្បាប់ស្តីពីការយល់ព្រម និងការអនុវត្ត អនុសញ្ញាអង្គការសហប្រជាជាតិ ចែងអំពីការទទួលស្គាល់ និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស[37] (ហៅកាត់ថាអនុសញ្ញាទីក្រុងនូយ៉ក) ឬ ដោយកិច្ចព្រមព្រៀងអន្តរជាតិ ជាអាទ៏ អនុសញ្ញាទីក្រុងឡាអេស្តីពីការទទួលស្គាល់សាលក្រមតុលាការបរទេសផ្នែករដ្ឋប្បវេណី និងពាណិជ្ជកម្ម[38]។

---

[35] គន្ថី៤ មាត្រា ៥៧៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីអាឡឺម៉ង់

[36] មាត្រា ១២៨ថ្មី (មាត្រា ១០៩ចាស់) នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

[37] ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០១/១០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១

[38] ការលើកឡើងនូវអនុសញ្ញានេះគ្រាន់តែជាឧទាហរណ៍មួយតែប៉ុណ្ណោះ។ ដោយឡែកកម្ពុជាពុំមែនជាភាគីហត្ថលេខីនៃអនុសញ្ញានេះទេ។ តាមបច្ចុប្បន្នភាពចុងក្រោយ (https://www.hcch.net/en/instruments/conventions/status-table/?cid=78) មានតែ៥ប្រទេសប៉ុណ្ណោះដែលជាភាគីហត្ថលេខីនៃអនុសញ្ញានេះ។

### ១.២.២.២ សាលក្រម

សាលក្រមគឺជាសេចក្តីសម្រេចដែលតុលាការធ្វើជាលិខិត ដែលមានលក្ខណៈគ្រប់គ្រាន់ ទៅតាមទម្រង់ដែលច្បាប់បានកំណត់ ដោយផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់ លើកលែងតែក្នុងករណីដែលមានកំណត់ពិសេសនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ឬ ក្នុងច្បាប់ផ្សេង ហើយកើតអានុភាព ដោយការប្រកាស ដោយផ្អែកលើលិខិតសាលក្រមនោះ។[39] និយមន័យដែលផ្តល់អោយនេះ មានវិសាលភាពទូលាយ ដែលវាក្តោបរួមនូវ ៖ សាលក្រមលើអង្គសេចក្តី សាលក្រមនីតិវិធី សាលក្រមកំបាំងមុខ និងសាលក្រមរបៀប។ ក្នុងផ្នែកនេះមានគោលបំណងកំណត់នូវប្រភេទសាលក្រមដែលមានលក្ខណៈអាជ្ញាអស់ជំនុំ និងដែលពុំមានលក្ខណៈអាជ្ញាអស់ជំនុំ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យក្នុងផ្នែក១.២.២.១ ខាងលើនេះ។

#### ក. សាលក្រមលើអង្គសេចក្តី

សាលក្រមលើអង្គសេចក្តីគឺជាសាលក្រមដែលចេញដោយតុលាការដែលបានវិនិច្ឆ័យពីសិទ្ធិ និង ទំនាក់ទំនងគតិយុត្តនៃភាគីវិវាទ ដោយផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់ជាគោលការណ៍។ សាលក្រមប្រភេទនេះមានអាជ្ញាអស់ជំនុំ ដោយសារតែវាត្រូវបានចេញដោយផ្អែកលើគោលការណ៍នៃការទាញហេតុផល ពោលគឺចងភាគីទាំងអស់នៃទំនាក់ទំនងគតិយុត្តដែលមានវិវាទដែលបានចូលរួម ព្រមទាំងមានឱកាសក្នុងការចូលរួមស្មើគ្នា អោយទទួលស្គាល់អានុភាពដែលជាលទ្ធផលកើតចេញពីការទាញហេតុផលនោះ។

សាលក្រមលើអង្គសេចក្តីមានពីរសណ្ឋាន គឺ សាលក្រមទទួលស្គាល់ការទាមទារ និងសាលក្រមច្រានចោលការទាមទារ។ សាលក្រមទាំងពីរប្រភេទនេះមានតម្លៃអាជ្ញាអស់ជំនុំស្មើគ្នា ដោយសារតែវាសុទ្ធតែត្រូវបានចេញដោយតុលាការ បន្ទាប់ពីបានវិនិច្ឆ័យអំពីសិទ្ធិ និងទំនាក់ទំនងគតិយុត្តជាលក្ខណៈសារធាតុផ្អែកលើគោលការណ៍ទាញហេតុផលរួចហើយ។

សាលក្រមលើអង្គសេចក្តីក៏ត្រូវបានអ្នកទ្រឹស្តីបែងចែកជា៣ប្រភេទទៀត គឺ សាលក្រមបង្គាប់អោយផ្តល់តាវកាលិក, សាលក្រមបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាព នៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត, និងសាលក្រមបង្កើត កែប្រែ ឬរំលត់ទំនាក់ទំនងគតិយុត្ត។ មិនថាវាជាសាលក្រមប្រភេទណាមួយឡើយ អាជ្ញាអស់ជំនុំត្រូវអនុវត្តចំពោះសាលក្រមលើអង្គសេចក្តី។ ចំពោះសាលក្រមបង្គាប់អោយផ្តល់តាវកាលិក អានុភាពអាជ្ញាអស់ជំនុំមានទៅលើសេចក្តីសម្រេចដែល បង្គាប់អោយភាគីណាមួយ ផ្តល់តាវកាលិកទៅភាគីម្ខាងទៀត រីឯសាលក្រមបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬ

[39] មាត្រា ១៧៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

ទំនាក់ទំនងគតិយុត្ត មានអានុភាពចំពោះសេចក្តីសម្រេចដែលថា សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្តឹង មាន ឬគ្មានអត្ថិភាព។ ចំណែកឯសាលក្រមបង្កើត កែប្រែ ឬរំលត់ទំនាក់ទំនងគតិយុត្ត មានអានុភាពអាជ្ញាអស់ជំនុំចំពោះចំណុចដែលតុលាការសម្រេច បង្កើត កែប្រែ ឬរំលត់ទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃវិវាទ។

### ខ. សាលក្រមនីតិវិធី ឬសាលក្រមលើកចោលបណ្តឹង

ខុសពីសាលក្រមលើអង្គសេចក្តី សាលក្រមនីតិវិធីគឺជាសាលក្រមដែលចេញដោយផ្អែកលើការវិនិច្ឆ័យលើសិទ្ធិជាលក្ខណៈនីតិវិធី។ សាលក្រមនីតិវិធីត្រូវចេញក្រោមរូបភាពជាសាលក្រមលើកចោលបណ្តឹង[40] ដោយយកមូលហេតុនៃភាពផ្ទុយនឹងល័ក្ខខ័ណ្ឌនៃបណ្តឹងជាអាទិ៍ ៖

(១) ការដាក់ពាក្យបណ្តឹង និងការបញ្ជូនពាក្យបណ្តឹងដែលមានសុពលភាព

(២) ភាពត្រឹមត្រូវជាភាគី និងសមត្ថភាពជាភាគី

(៣) ចុងចម្លើយស្ថិតនៅក្រោមសិទ្ធិជម្រះក្តីរបស់ព្រះរាជាណាចក្រកម្ពុជា

(៤) សិទ្ធិជម្រះក្តីរបស់តុលាការ

(៥) ផលប្រយោជន៍នៃបណ្តឹង។[41]

***<u>ឧទាហរណ៍</u> ៖*** តុលាការត្រូវចេញសាលក្រមលើកចោលបណ្តឹង បន្ទាប់ពីភាគីដើមចោទមិនអាចកែប្រែសមត្ថភាពក្នុងការធ្វើបណ្តឹង ក្រោយពេលតុលាការចេញដីកាសម្រេចឱ្យកែតម្រូវតាមមាត្រា៣៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីរួចហើយ។

ដោយសារតែសាលក្រមនីតិវិធីមានចរិតលក្ខណៈជាសេចក្តីសម្រេចផ្អែកសិទ្ធិនីតិវិធី វាពុំត្រូវបានផ្អែកលើ សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ជាលក្ខណៈសារធាតុ ដែលជាកម្មវត្ថុនៃវិវាទឡើយ ហេតុនេះអានុភាពអាជ្ញាអស់ជំនុំពុំមានចំពោះសាលក្រមប្រភេទនេះឡើយ។

### គ. សាលក្រមព្រហ្មទណ្ឌដែលកំណត់អោយផ្តល់តាវការលិក

ថ្វីដ្បិតតែសាលក្រមព្រហ្មទណ្ឌត្រូវបានចេញដោយផ្អែកលើការវិនិច្ឆ័យពីពិរុទ្ធភាព តាមនីតិវិធីនៃក្រមនីតិវិធីព្រហ្មទណ្ឌក៏ដោយ ក៏តុលាការព្រហ្មទណ្ឌអាចសម្រេចអំពីសំណងការខូចខាតក្នុង

---

[40] មាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[41] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១: នីតិវិធីបណ្តឹង*, (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០០៨), ១២១ ដល់ ១២២

សាលក្រមព្រហ្មទណ្ឌបានដែរ[42] ប្រសិនបើមានការទាមទារពីដើមបណ្តឹងរដ្ឋប្បវេណី។ តុលាការព្រហ្មទណ្ឌ ត្រូវផ្អែកលើបទប្បញ្ញត្តិសារធាតុស្តីពីអំពើអនីត្យានុកូល ដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ដើម្បីសម្រេចអំពីសំណងការខូចខាត ដោយសារតែវាជាទំនាក់ទំនងរវាងបុគ្គល និងបុគ្គល ដែលពាក់ព័ន្ធនឹងសិទ្ធិលើបំណុល[43]។ សាលក្រមព្រហ្មទណ្ឌដែលកំណត់អោយផ្តល់តាវកាលិក មានតម្លៃស្មើនឹងសាលក្រមរដ្ឋប្បវេណី ហេតុនេះប្រសិនបើតុលាការព្រហ្មទណ្ឌបានចេញសាលក្រម ឬសាលដីកាស្ថាពរ បង្គាប់អោយចារីសងការខូចខាតរួចហើយ ទោះបីជាមានបណ្តឹងពីជនរងគ្រោះទៅតុលាការរដ្ឋប្បវេណី ក៏តុលាការរដ្ឋប្បវេណី ត្រូវលើកចោលពាក្យបណ្តឹងដោយចេញសាលក្រម ដោយយកមកមូលហេតុនៃភាពផ្ទុយច្បាប់[44] (ផ្ទុយនឹងអានុភាពអាជ្ញាអស់ជំនុំនៃសាលក្រមព្រហ្មទណ្ឌដែលសម្រេចពីសិទ្ធិផ្នែករដ្ឋប្បវេណី)។

### ១.២.២.៣ ដីកាសម្រេច

ដីកាសម្រេចគឺជាសេចក្តីសម្រេចដែលតុលាការ ឬ ចៅក្រមអាចធ្វើដោយមិនឆ្លងកាត់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់បាន ហើយមិនមែនជាសាលក្រម។[45] ដោយសារតែមាត្រា ២១៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានបញ្ញត្តថា «បញ្ញត្តិស្តីពីសាលក្រមត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេច លើកលែងតែបញ្ញត្តិស្តីពីសាលក្រមនោះ មានភាពផ្ទុយគ្នាពីលក្ខណៈនៃដីកាសម្រេច» ហេតុនេះនាំអោយមានការបកស្រាយថា ដីកាសម្រេចមានអាជ្ញាអស់ជំនុំ។

ប៉ុន្តែនៅក្នុងសៀវភៅពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ដែលតាក់តែងឡើងដោយក្រុមការងារជប៉ុន ដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា បានសម្តែងពីស្ថានភាពដែលបទប្បញ្ញត្តិស្តីពីសាលក្រម ពុំត្រូវយកមកអនុវត្តចំពោះដីកាសម្រេច។ នៅក្នុងនេះ អ្នកនិពន្ធបានលើកយកមកពន្យល់នូវចំណុច ចំនួនបី គឺ[46] ៖

---

[42] មាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា

[43] មាត្រា ១ នៃក្រមរដ្ឋប្បវេណីកម្ពុជា

[44] មាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[45] មាត្រា ១៧៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[46] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១: នីតិវិធីបណ្តឹង*, (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០០៨), ១៥៥ ដល់ ១៥៦

"(១) នីតិវិធីក្នុងការចេញសាលក្រមធ្វើឡើងដោយការទាញហេតុផលលើអង្គសេចក្តី[47] ចំណែកឯដីកាសម្រេចអាចត្រូវបានចេញដោយពុំផ្អែកលើការទាញហេតុផល[48]។
(២) ចំណុចដែលសាលក្រមចេញគឺការវិនិច្ឆ័យអំពីសិទ្ធិ និងទំនាក់ទំនងគតិយុត្តតាមផ្លូវច្បាប់សារធាតុ ប៉ុន្តែដីកាសម្រេចចេញចំពោះចំណុចបន្ទាប់បន្សំតាមផ្លូវនីតិវិធី ដែលពុំពាក់ព័ន្ធនឹងសិទ្ធិ ឬកាតព្វកិច្ចរបស់ភាគីតាមផ្លូវច្បាប់សារធាតុឡើយ។
(៣) សាលក្រមត្រូវប្រកាសក្នុងសវនាការជាសាធារណៈ និងត្រូវបញ្ជូនទៅភាគី ចំណែកឯដីកាសម្រេចអាចធ្វើការជូនដំណឹងតាមវិធីដែលតុលាការយល់ឃើញថាសមរម្យ ព្រមទាំង វាពុំតម្រូវអោយធ្វើជាលាយល័ក្ខណ៍អក្សរដាច់ខាតនោះទេ។"[49] [ដកស្រង់ដោយសង្ខេបខ្លឹមសារដើម]

មាត្រា ១៩៤ ដែលបញ្ញត្តអំពីអាជ្ញាអស់ជំនុំនៃសាលក្រម កំណត់យកជាស្ថាពរនូវសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត នាពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ហេតុនេះវាផ្ទុយនឹងបទប្បញ្ញត្តិស្តីពីដីកាសម្រេចដែលពុំធ្វើការសម្រេចសេចក្តីអំពីសិទ្ធិ ឬកាតព្វកិច្ចរបស់ភាគី ព្រមទាំងពុំផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់ទៀតផង។

តាមការបកស្រាយខាងលើ ទោះបីជាបទប្បញ្ញត្តិនៃមាត្រា ២១៦នៃក្រមនីតិវិធីរដ្ឋប្បវេណីកំណត់ឱ្យយកបញ្ញត្តិស្តីពីសាលក្រមមកអនុវត្តដូចគ្នាចំពោះដីកាសម្រេចក៏ដោយ ក៏បញ្ញត្តិស្តីពីអាជ្ញាអស់ជំនុំដែលមានចែងក្នុងមាត្រា១៩៤ ពុំត្រូវយកមកអនុវត្តចំពោះដីកាសម្រេចឡើយ ដោយសារតែវាមានភាពផ្ទុយគ្នានឹងចរិតលក្ខណៈនៃបញ្ញត្តិស្តីពីដីកាសម្រេច។

ការពុំឱ្យគុណវុឌ្ឍិនៃអាជ្ញាអស់ជំនុំ គឺដោយផ្អែកលើចរិតលក្ខណៈនៃនីតិវិធីចេញដីកាសម្រេច ដែលវាពុំផ្អែកលើការទាញហេតុផល និងវិនិច្ឆ័យលើសិទ្ធិ និងទំនាក់ទំនងគតិយុត្តជាលក្ខណៈអង្គសេចក្តី ប៉ុន្តែ នៅក្នុងនីតិវិធីរដ្ឋប្បវេណីខ្លះ ក៏មានដីកាសម្រេចមួយចំនួនត្រូវបានចេញចំពោះសិទ្ធិ និងទំនាក់ទំនងគតិយុត្តរបស់ភាគីដែរ ដូចជា ដីកាសម្រេចក្នុងនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង[50] ដីកាសម្រេចដាស់តឿន[51] ដីកាសម្រេចអោយប្រគល់[52]។

---

[47] មាត្រា ១១៤ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា
[48] មាត្រា ១១៤ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា
[49] មាត្រា ២១៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា
[50] មាត្រា ៣ កថាខណ្ឌទី២ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង
[51] មាត្រា ៣៣៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា
[52] មាត្រា ៤៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

### ក. ដីកាសម្រេចក្នុងនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

នីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ជានីតិវិធីដែលកម្មវត្ថុនៃការទាមទារស្ថិតក្រោមចំណុចដែលជាសិទ្ធិអំណាចរបស់តុលាការ។[53] នៅក្នុងនីតិវិធីនេះ តុលាការត្រូវសម្រេចសេចក្តីដោយចេញដីកាសម្រេច។ ដោយសារតែមាត្រា ៣ នៃច្បាប់នេះបានយកបទប្បញ្ញត្តិស្តីពីដីកាសម្រេចដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីមកអនុវត្តដូចគ្នាចំពោះដីកាសម្រេចក្នុងនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ហេតុនេះដីកាសម្រេចក្នុងរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ពុំមានអានុភាពអាជ្ញាអស់ជំនុំទេ។

ម្យ៉ាងទៀត គោលគំនិតដើមនៃបទប្បញ្ញត្តិច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ត្រូវបានដកស្រង់ចេញពី ច្បាប់ស្តីពីនីតិវិធីរឿងក្តីគ្រួសាររបស់ប្រទេសជប៉ុន[54]។ នៅក្នុងគោលគំនិតដើមនៃនីតិវិធីនេះ តុលាការត្រូវមានតួនាទីជាអ្នកការពារផលប្រយោជន៍សាធារណៈ[55] ហេតុនេះ សេចក្តីសម្រេចដែលត្រូវបានចេញតាមរយៈនីតិវិធីនេះ មានលក្ខណៈជាការការពារផលប្រយោជន៍សាធារណៈ។ ក្នុងករណីដែលដីកាសម្រេចស្ថាពរ បានប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ ដីកាសម្រេចនោះគប្បីអាចត្រូវបាន កែប្រែ ឬលុបចោល ដោយសារតែសង្គមមិនអាចនៅតែបន្តទទួលស្គាល់សេចក្តីសម្រេច ដែលមានលក្ខណៈប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈឡើយ។

***<u>ឧទាហរណ៍</u> ៖*** ប្រសិនបើដីកាសម្រេចចាប់ផ្តើមសុំកូនធម្មតា ត្រូវបានចេញ ហើយចូលជាស្ថាពរ ប៉ុន្តែការបង្កើតសុំធម្មតានោះផ្ទុយនឹងមាត្រា ១០២០ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី (កូនសុំជាបុព្វញាតិរបស់ឪពុកម្តាយចិញ្ចឹម) យើងមិនអាចនៅតែបន្តទទួលស្គាល់អានុភាពនៃដីកាសម្រេចដែលផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងប្រពៃណីរបស់កម្ពុជានេះឡើយ។

ក្នុងករណីខាងលើនេះ ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង និងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ពុំបានបញ្ញត្តនូវយន្តការក្នុងការលុបចោលដីកាសម្រេចឡើយ ទោះបីជា

---

[53] មាត្រា ៣ កថាខណ្ឌទី១ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

[54] ច្បាប់លេខ ៥២ ស្តីពីនីតិវិធីរឿងក្តីគ្រួសារនៃប្រទេសជប៉ុន (Domestic Relations Case Procedure Act) ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១១ [បកប្រែជាភាសាអង់គ្លេសដោយគេហទំព័របកប្រែច្បាប់នៃក្រសួងយុត្តិធម៌ប្រទេសជប៉ុន] www.japanlawtranslation.go.jp

[55] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី, *សេចក្តីកំណត់មាត្រានីមួយៗនៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង,* (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០១១), មាត្រា៣

មានមូលហេតុផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈក៏ពិតមែន ប៉ុន្តែយើងអាចឃើញនៅក្នុងអត្ថបទច្បាប់នីតិវិធីគ្រួសាររបស់ប្រទេសជប៉ុន[56] មាត្រា ៧៨ ដែលមានខ្លឹមសារទាំងស្រុងដូចខាងក្រោម ៖

"(១) នៅពេលដែលតុលាការគ្រួសារបានចេញដីកាសម្រេច ក្រោយមកយល់ឃើញថាដីកាសម្រេចនោះពុំមានមូលហេតុត្រឹមត្រូវទេ ***<u>អាចលុបចោល ឬ កែប្រែ ដីកាសម្រេចនោះ</u>*** ដោយឆន្ទានុសិទ្ធិបាន លើកលែងតែ ដីកាសម្រេចដូចខាងក្រោម ៖

(ក) ដីកាសម្រេចដែលច្រានចោលពាក្យសុំ ក្នុងករណីដែលដីកាសម្រេចនោះអាចចេញតែក្នុងករណីមានពាក្យសុំ។

(ខ) ដីកាសម្រេចចំពោះពាក្យបណ្តឹងជំទាស់។

(២) បន្ទាប់ពីរយៈពេល ២ឆ្នាំ បានកន្លងផុត រាប់ចាប់ពីពេលដែលដីកាសម្រេចចូលជាស្ថាពរ តុលាការគ្រួសារពុំអាចធ្វើការលុបចោល ឬ កែប្រែ ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះឡើយ។ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ប្រសិនបើតុលាការរកឃើញថា មូលហេតុមិនសមហេតុផលនោះ កើតចេញពីការផ្លាស់ប្តូរកាលៈទេសៈ។" [បកប្រែ]

តាមការបកស្រាយមាត្រានេះ ដីកាសម្រេចដែលចូលជាស្ថាពរហើយ ក៏អាចត្រូវបានកែប្រែ ឬលុបចោល ដោយតុលាការបានដែរ ប្រសិនបើវាផ្អែកលើមូលហេតុមិនសមហេតុផល និងផ្ទុយនឹងផលប្រយោជន៍សាធារណៈ។ ទោះបីជាដីកាសម្រេចនោះបានចូលជាស្ថាពរ ប៉ុន្តែតុលាការអាចធ្វើការសម្រេចឡើងវិញចំពោះបញ្ហាដែល សបញ្ជាក់អោយឃើញថា អានុភាពអាជ្ញាអស់ជំនុំពុំត្រូវយកមកអនុវត្តឡើយចំពោះដីកាសម្រេចក្នុងរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។

ថ្វីដ្បិតតែការបកស្រាយខាងលើពុំផ្អែកលើបទប្បញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែវាជាការព្យាយាមបកស្រាយស្វែងរកនូវគោលគំនិតដើមនៃបទប្បញ្ញត្តិច្បាប់នីតិវិធីមួយនេះ ដើម្បីកំណត់អំពីអានុភាពអាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចក្នុងរឿងក្តីទាក់ទងនឹងគ្រួសារ។

## ខ. ដីកាសម្រេចដាស់តឿន

ដីកាសម្រេចដាស់តឿនគឺជាដីកាសម្រេចបង្គាប់អោយកូនបំណុល ផ្តល់តាវកាលិកដែលមានគោលបំណងអោយសងជាប្រាក់។ វាខុសពីដីកាសម្រេចនៅក្នុងនីតិវិធីបណ្តឹង ដែលវាជាដីកាសម្រេចអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ម្ចាស់បំណុល និងកូនបំណុល ពោលគឺតុលាការបានវិនិច្ឆ័យលើអង្គសេចក្តីចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់។ ទោះបីជាដីកាសម្រេច

[56] បទប្បញ្ញត្តិនៃច្បាប់នេះត្រូវបានយកមកធ្វើជាមូលដ្ឋានក្នុងការតាក់តែងច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងនៃព្រះរាជាណាចក្រកម្ពុជា

ដាស់តឿនត្រូវបានចេញដោយពុំផ្អែកលើការទាញហេតុផលក៏ដោយ[57] ក៏ក្រមនីតិវិធីរដ្ឋប្បវេណី បានធានានូវសិទ្ធិតវ៉ាចំពោះដីកាសម្រេចដាស់តឿនចំនួនពីរលើក ពោលគឺមុនពេលតុលាការប្រកាសអោយអនុវត្តជាបណ្តោះអាសន្ន និងបន្ទាប់ពីតុលាការប្រកាសអោយអនុវត្តជាបណ្តោះអាសន្ននូវដីកាសម្រេចដាស់តឿន។ ដោយសារតែដីកាសម្រេចដាស់តឿនត្រូវបញ្ជូនទៅកូនបំណុល ហេតុនេះវាបានធានានូវសិទ្ធិស្មើគ្នាចំពោះនីតិវិធីរួចស្រេចហើយ។ កូនបំណុលមានឱកាសក្នុងការតវ៉ាចំពោះដីកាសម្រេចដាស់តឿន ហើយការតវ៉ានោះនឹង ប្រែក្លាយនីតិវិធីដាស់តឿន ទៅជានីតិវិធីបណ្តឹងអង្គសេចក្តីវិញ[58]។

ដោយផ្អែកលើការបញ្ជូនដែលជាល័ក្ខខ័ណ្ឌបង្កើតអានុភាពនៃដីកាសម្រេច និងការផ្តល់សិទ្ធិតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលជាការផ្តល់លទ្ធភាពគ្រប់គ្រាន់សម្រាប់កូនបំណុលធ្វើសកម្មភាពបណ្តឹង ប្រសិនបើកូនបំណុលនៅតែខកខាន មិនអនុវត្តសិទ្ធិតវ៉ាទាំងនោះដែលបានកំណត់ខាងលើ កូនបំណុលគប្បីចងដោយអានុភាពស្ថាពរនៃដីកាសម្រេច ហើយពុំអាចធ្វើវិវាទអំពីនត្ថិភាពនៃសិទ្ធិលើបំណុល ដែលបានសម្រេចក្នុងដីកាសម្រេចដាស់តឿនក្នុងនីតិវិធីក្រោយបានឡើយ។

ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាបានកំណត់ឱ្យដីកាសម្រេចដាស់តឿនដែលចូលជាស្ថាពរត្រូវមានអានុភាពដូចសាលក្រមស្ថាពរ។ ហេតុនេះរបបអាជ្ញាអស់ជំនុំដែលអនុវត្តចំពោះសាលក្រមស្ថាពរក៏ត្រូវយកមកអនុវត្តចំពោះដីកាសម្រេចដាស់តឿនផងដែរ។ នៅក្នុងអត្ថបទមួយដែលចេញដោយតុលាការកំពូលនៃប្រទេសជប៉ុន បានបង្ហាញនូវអត្ថន័យនៃការយកមកអនុវត្តដូចគ្នានៃសាលក្រមស្ថាពរថា “ប្រសិនបើអំឡុងពេលដែលបានកំណត់សម្រាប់បណ្តឹងជំទាស់ចំពោះដីកាសម្រេចដាស់តឿនបានកន្លងផុត ដីកាសម្រេចដាស់តឿននោះត្រូវមានអានុភាពដូចសាលក្រមស្ថាពរ ហើយកូនបំណុលនឹងបាត់បង់ឱកាស ក្នុងការធ្វើវិវាទអំពីខ្លឹមសារនៃដីកាសម្រេចដាស់តឿននោះទៀត ...។”[59] [បកប្រែ]

ពេលវេលាដែលដីកាសម្រេចដាស់តឿនចូលជាស្ថាពរ និងមានអានុភាពអាជ្ញាអស់ជំនុំ គឺក្នុងករណីដូចខាងក្រោម ៖

---

[57] មាត្រា ៣២៣ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[58] មាត្រា ៣២៧ កថាខណ្ឌទី២ និងមាត្រា ៣៣១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[59] តុលាការកំពូលនៃប្រទេសជប៉ុន, *Outline of Civil Procedure in JAPAN* [ការពណ៌នាអំពីនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន], (ប្រទេសជប៉ុន៖ តុលាការកំពូលនៃប្រទេសជប៉ុន, ២០១៤), ២៤

- គ្មានពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនណាមួយដែលបានធ្វើឡើង ក្នុងអំឡុងពេល ២សប្តាហ៍បន្ទាប់ពីកាលបរិច្ឆេទនៃការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន។
- ដីកាសម្រេចលើកចោលពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយការអនុវត្តជាបណ្តោះអាសន្ន បានចូលជាស្ថាពរ។[60]

### ១.២.២.៤ កំណត់ហេតុសះជា ជាអាទិ៍

កំណត់ហេតុសះជា ត្រូវបានចេញដោយផ្អែកលើការធ្វើសម្បទានពីគ្នាទៅវិញទៅមករវាងភាគីនៃវិវាទ។ ភាគីអាចសះជានឹងគ្នានៅក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ទាញហេតុផល ឬនីតិវិធីទាញហេតុផល ឬកាលបរិច្ឆេទនៃការផ្សះផ្សា។ ការសះជាមានខ្លឹមសារថា ភាគីដើមចោទយល់ព្រមលះបង់ភាគខ្លះនៃសិទ្ធិទាមទារ ឬ/និង ផ្តល់អត្ថប្រយោជន៍ដល់ចុងចម្លើយ ប្រសិនបើចុងចម្លើយយល់ព្រមផ្សះផ្សា ឯចុងចម្លើយ សុខចិត្តទទួលស្គាល់សិទ្ធិទាមទាររបស់ដើមចោទ។ ប្រសិនបើការផ្សះផ្សាទទួលបានលទ្ធផលជាវិជ្ជមាន ក្រឡាបញ្ជីត្រូវកត់ហេតុអំពីការផ្សះផ្សាចូលទៅក្នុងកំណត់ហេតុនៅក្នុងកាលបរិច្ឆេទ។ កំណត់ហេតុនេះអានុភាពដូចសាលក្រមស្ថាពរ ហើយមានតម្លៃជាលិខិតអនុវត្ត[61]។ នៅក្នុងកំណត់ហេតុសះជា ក្រឡាបញ្ជីត្រូវសរសេរអោយដូចទៅនឹងខ្លឹមសារនៃសេចក្តីសម្រេចនៃសាលក្រម ដើម្បីអាចយកទៅអនុវត្តដោយបង្ខំបាន។ ហេតុនេះវាបង្កើតឱ្យមានចម្ងល់ថា តើពាក្យថា អានុភាពដូចសាលក្រមស្ថាពរ នាំឱ្យកំណត់ហេតុសះជាមានអានុភាពអាជ្ញាអស់ជំនុំដែរទេ?

ការសះជាគឺការចាត់ចែងសិទ្ធិរបស់ភាគី។ ប្រសិនបើការបង្ហាញឆន្ទៈនោះមានវិការៈ ភាគីដែលបានបង្ហាញឆន្ទៈនោះអាចលុបចោលសកម្មភាព(ការសះជា) នោះបាន។ តុលាការពុំបានចូលរួមក្នុងការវិនិច្ឆ័យអំពីអត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត របស់ភាគីទេ ខុសពីនីតិវិធីបណ្តឹងដែលតុលាការត្រូវកំណត់ចំណុចវិវាទ និងទទួលស្គាល់អង្គហេតុតាមរយៈភស្តុតាង។

ទស្សនៈមួយលើកឡើងថា អវត្តមានរបស់តុលាការក្នុងការវិនិច្ឆ័យលើអង្គសេចក្តី ទោះបីជាសេចក្តីសម្រេចដែលចេញមកមានអានុភាពដូចជាសាលក្រមស្ថាពរយ៉ាងណាក្តី ក៏វាពុំមានអានុភាពអាជ្ញាអស់ជំនុំដែរ ដោយសារតែអាជ្ញាអស់ជំនុំគឺជាការធានានូវភាពមិនអាចជំនុំជម្រះជាថ្មីចំពោះសេចក្តីដែលត្រូវបានតុលាការ ឬអង្គវិនិច្ឆ័យដែលត្រូវបានច្បាប់ទទួលស្គាល់ បានវិនិច្ឆ័យរួច។

---

[60] មាត្រា ៣៣៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[61] មាត្រា ៣៥០ កថាខណ្ឌទី២ ចំណុច ឈ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

### ១.២.២.៥ សេចក្ដីសម្រេចរបស់មជ្ឈត្តករ

ក្រៅពីសេចក្ដីសម្រេចផ្នែករដ្ឋប្បវេណីដែលចេញដោយតុលាការរដ្ឋប្បវេណី វាក៏អាចត្រូវបានចេញដោយអង្គវិនិច្ឆ័យផ្សេងទៀតផងដែរ។ ដូចបានសម្ដែងនៅក្នុងផ្នែកទី ១.២.២.១ (លក្ខណៈវិនិច្ឆ័យ) ខាងលើនេះ សេចក្ដីសម្រេចរបស់មជ្ឈត្តករ មានអាជ្ញាអស់ជំនុំ ក្នុងករណីដែលច្បាប់បានសម្ដែងនូវការទទួលស្គាល់ភាពស្ថាពរនៃសេចក្ដីសម្រេចនោះ។ នៅកម្ពុជា ច្បាប់ទទួលស្គាល់នីតិវិធីក្នុងការដោះស្រាយវិវាទក្រៅផ្លូវតុលាការដែលមានដូចជា ៖ មជ្ឈត្តការផ្នែកពាណិជ្ជកម្ម[62], អាជ្ញាកណ្ដាលការងារ[63], និង គណៈកម្មការសុរិយោដីថ្នាក់ជាតិ[64]។

### ក. មជ្ឈត្តវិនិច្ឆ័យ

ការដោះស្រាយវិវាទតាមរយៈយន្តការមជ្ឈត្តការ គឺជាជម្រើសរបស់ពាណិជ្ជករចំពោះវិវាទដែលទាក់ទងនឹងពាណិជ្ជកម្ម។ មិនថាវិវាទនោះត្រូវបានដោះស្រាយតាមផ្លូវតុលាការ ឬក្រៅផ្លូវតុលាការ ភាគីទាំងសងខាង សុទ្ធសឹងតែចង់អោយវិវាទរបស់ខ្លួនត្រូវបានបញ្ចប់ជាស្ថាពរ ជាពិសេសភាគីដែលជាពាណិជ្ជករ។ ក្នុងរឿងពាណិជ្ជកម្ម ភាគីអាចជ្រើសរើសការដោះស្រាយវិវាទតាមរយៈការធ្វើមជ្ឈត្តការ។ យុត្តាធិការរបស់មជ្ឈត្តការពាណិជ្ជកម្ម ជាយុត្តាធិការផ្ដាច់មុខ ដែលសូម្បីតែតុលាការក៏ពុំមានសមត្ថកិច្ចជំនុំជម្រះលើអង្គសេចក្ដី ទាក់ទងនឹងវិវាទពាណិជ្ជកម្មដែរ ប្រសិនបើមានការព្រមព្រៀងកំណត់យកមជ្ឈត្តការជាយន្តការដោះស្រាយវិវាទ លើកលែងតែសមត្ថកិច្ចលើបណ្ដឹងលុបចោលមជ្ឈត្តវិនិច្ឆ័យ[65]។ ប្រសិនបើគ្មានមូលហេតុនៃបណ្ដឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យនោះទេ មជ្ឈត្តវិនិច្ឆ័យត្រូវក្លាយជាស្ថាពរ[66]។

ភាពស្ថាពរនៃមជ្ឈត្តវិនិច្ឆ័យ គឺជាគុណសម្បត្តិនៃមជ្ឈត្តកម្ម ដែលវាអាចបញ្ចប់វិវាទជាស្ថាពររវាងភាគី ក្រៅពីវិវាទដែលដោះស្រាយតាមផ្លូវតុលាការ[67]។ ប្រសិនបើតាមរយៈផ្លូវមជ្ឈត្តការពុំអាចដោះស្រាយវិវាទជាស្ថាពរ វានឹងធ្វើអោយបាត់បង់តម្លៃនៃមជ្ឈត្តកម្ម ដោយសារតែមជ្ឈត្តវិនិច្ឆ័យនៅ

[62] ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៥០៦/០១០ ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦

[63] ប្រកាសលេខ ០៩៩ ស.ក.ប.យ. ស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤

[64] អនុក្រឹត្យលេខ ៤៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២

[65] មាត្រា ៤៤ កថាខណ្ឌទី២ (ក-ខ) នៃច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (២០០៦)

[66] មាត្រា ៤០ នៃច្បាប់ស្ដីពីមជ្ឈត្តការពាណិជ្ជកម្ម (២០០៦)

[67] មេធាវី ស៊ីវិន អ៊ែម អូស្ទើរមីឡឺរ៍, *ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ : សៀវភៅសិក្សាស្ដីពីទស្សនាទានសំខាន់ៗ*, បោះពុម្ពលើកទី២, (ភ្នំពេញ៖ ២០១០), ១៥០

តែអាចត្រូវបានកែប្រែដោយតុលាការនៃបណ្ដឹងជំទាស់ដូចនីតិវិធីបណ្ដឹងធម្មតាដែរ។ បណ្ដឹងជំទាស់អាចត្រូវបានធ្វើតែនៅក្នុងល័ក្ខខ័ណ្ឌដ៏ចង្អៀតប៉ុណ្ណោះ ជាអាទិ៍ មជ្ឈត្តវិនិច្ឆ័យត្រូវបានចេញដោយវេទិកាមជ្ឈត្តកម្មអសមត្ថកិច្ច។

យោងតាមការបកស្រាយខាងលើ ច្បាប់កម្ពុជាបានទទួលស្គាល់នូវការដោះស្រាយវិវាទពាណិជ្ជកម្មតាមផ្លូវមជ្ឈត្តការ ព្រមទាំងទទួលស្គាល់ភាពស្ថាពរនៃមជ្ឈត្តវិនិច្ឆ័យផងដែរ។ ហេតុនេះមជ្ឈត្តវិនិច្ឆ័យត្រូវចងតុលាការ ចំពោះការវិនិច្ឆ័យចំណុចដែលត្រូវបានសម្រេចក្នុងមជ្ឈត្តវិនិច្ឆ័យ។

តុលាការកំពូលប្រទេសប៉ូឡូញ បានបកស្រាយអានុភាពអាជ្ញាអស់ជំនុំនៃមជ្ឈត្តវិនិច្ឆ័យនៅក្នុងសាលដីកាចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់ខ្លួនយ៉ាងដូច្នេះថា “មជ្ឈត្តការពុំមែនជាតុលាការហេតុនេះវាមិនត្រូវចងដោយមជ្ឈត្តវិនិច្ឆ័យផ្សេងទៀតឡើយ។ វាក៏ព្រោះតែ មាត្រា ៣៦៥(១) នៃក្រមនីតិវិធីរដ្ឋប្បវេណីប៉ូឡូញ អនុវត្តចំពោះតែអាជ្ញាអស់ជំនុំនៃសេចក្ដីសម្រេចរបស់តុលាការតែប៉ុណ្ណោះ។” ក្រោយមកទស្សនៈនេះ ត្រូវបានកែប្រែដោយសាលដីកាតុលាការកំពូលចុះថ្ងៃទី ១៣ ខែមេសា ឆ្នាំ២០១២ ដោយតុលាការកំពូលបានសម្ដែងថា “មជ្ឈត្តវិនិច្ឆ័យដែលផ្ទុយពីមជ្ឈត្តវិនិច្ឆ័យមុន ដែលមានភាគីដដែល អាចធ្វើអោយប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ ហេតុនេះមជ្ឈត្តវិនិច្ឆ័យមុនដែលត្រូវបានទទួលស្គាល់ និងមានអានុភាពអាជ្ញាអស់ជំនុំដូចសាលក្រមស្ថាពររបស់តុលាការប៉ូឡូញដូច្នេះដែរ។”[68] [បកប្រែ]

## ខ. សេចក្ដីបង្គាប់អាជ្ញាកណ្ដាល

ថ្វីដ្បិតតែវាមានភាពខុសគ្នាក្នុងការប្រើប្រាស់ពាក្យពេជន៍ ក៏យន្តការនៃការដោះស្រាយវិវាទតាមរយៈក្រុមអាជ្ញាកណ្ដាល ជាប្រភេទមួយនៃមជ្ឈត្តការដែរ។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលគឺជាអង្គវិនិច្ឆ័យដែលត្រូវបានច្បាប់ស្ដីពីការងារទទួលស្គាល់ពីសមត្ថកិច្ចផ្ដាច់មុខរបស់វា ក្នុងការដោះស្រាយវិវាទការងាររួម[69]។ ដើម្បីដោះស្រាយវិវាទការងាររួម ក្រុមអាជ្ញាកណ្ដាលត្រូវចេញសេចក្ដីបង្គាប់អាជ្ញាកណ្ដាល។ សេចក្ដីបង្គាប់អាជ្ញាកណ្ដាលមានពីរប្រភេទ គឺ សេចក្ដីបង្គាប់ជាប់កាតព្វកិច្ច និងសេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច។ សេចក្ដីបង្គាប់ជាប់កាតព្វកិច្ចដែលចេញដោយក្រុមអាជ្ញាកណ្ដាល មានលក្ខណៈស្ថាពរ ដែលបិទសិទ្ធិភាគីមិនអោយធ្វើបណ្ដឹងឧបាស្រ័យទៅតុលាការ[70]។ សេចក្ដីបង្គាប់មិន

[68] Kubas Kos Galkowski, *Supreme Court decides on res judicata of arbitral award*, [ការវិនិច្ឆ័យរបស់តុលាការកំពូលចំពោះអាជ្ញាអស់ជំនុំនៃមជ្ឈត្តវិនិច្ឆ័យ], (ប្រទេសប៉ូឡូញ ៖ Lexology ២០១៦) ដកស្រង់ពី http://www.lexology.com/library/detail.aspx?g=0d4523ef-8109-45f5-aebb-ef079aa1ae3c

[69] មាត្រា ៣០៩ នៃច្បាប់ស្ដីពីការងារ

[70] ប្រការ ៤២ នៃប្រកាសលេខ ០៩៩ ស.ក.ប.យ. ស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាល

ជាប់កាតព្វកិច្ចបើកសិទ្ធិឱ្យភាគីធ្វើឧបាស្រ័យចំពោះចំណុចវិវាទដែលទាក់ទងនឹងសិទ្ធិតាមផ្លូវច្បាប់សារធាតុ (ច្បាប់ស្តីពីការងារជាអាទិ៍)[71]។

យើងអាចផ្តល់ជាសេចក្តីសន្និដ្ឋានយ៉ាងដូច្នេះថា សេចក្តីបង្គាប់អាជ្ញាកណ្តាលអំពីផលប្រយោជន៍ក្រៅពីផ្លូវច្បាប់ ទោះបីជាប់កាតព្វកិច្ចក្តី ឬមិនជាប់កាតព្វកិច្ចក្តី និង សេចក្តីបង្គាប់អាជ្ញាកណ្តាល អំពីសិទ្ធិ ដែលជាប់កាតព្វកិច្ច មានអានុភាពអាជ្ញាអស់ជំនុំ។ វាហាមឃាត់ក្រុមអាជ្ញាកណ្តាលនៃសំណុំរឿងក្រោយ រួមទាំងតុលាការផង មិនអោយធ្វើការជំនុំជម្រះលើអង្គសេចក្តីដែលត្រូវបានសម្រេចដោយសេចក្តីបង្គាប់ដែលបានចេញដោយក្រុមអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនរួចហើយ។

នៅក្នុងសំណុំរឿងលេខ ៤២/០៧ សៅធន៍បេ ក្រុមអាជ្ញាកណ្តាលបានលើកឡើងពីអានុភាពអាជ្ញាអស់ជំនុំនៃសេចក្តីបង្គាប់របស់ខ្លួនដែលវាមានលក្ខណៈជាយុត្តិសាស្ត្រ។ នៅក្នុងហេតុផលនៃចំណុចវិវាទទី១ ក្រុមអាជ្ញាកណ្តាលបានលើកឡើងថា ៖

> “ចំណុចវិវាទមួយនឹងត្រូវបានបដិសេធពិចារណា ប្រសិនបើចំណុចវិវាទនេះបំពេញល័ក្ខខ័ណ្ឌចំនួន ០៣ ដូចខាងក្រោម ៖
>
> (១) ភាគីវិវាទធ្លាប់ចូលរួមលើចំណុចវិវាទនេះពីមុនមក
>
> (២) ចំណុចវិវាទដែលធ្លាប់នាំមកក្រុមប្រឹក្សា អាជ្ញាកណ្តាល និង
>
> (៣) ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចលើអង្គសេចក្តីចប់សព្វគ្រប់។”

សេចក្តីបកស្រាយនេះ ត្រូវបានក្រុមប្រឹក្សាអាជ្ញាកណ្តាលយកមកសំអាងជាបន្តបន្ទាប់[72] ដែលនាំអោយវាក្លាយទៅជាយុត្តិសាស្ត្រ[73]។

### គ. សេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ

នៅក្នុងក្របខណ្ឌនៃការដោះស្រាយវិវាទដីធ្លីដែលមិនទាន់បានចុះបញ្ជី វាជាសមត្ថកិច្ចផ្តាច់មុខរបស់គណៈកម្មការសុរិយោដី[74]។ វិវាទរដ្ឋប្បវេណីទាក់ទងនឹងដីធ្លីដែលមិនទាន់បានចុះបញ្ជីនេះ តុលាការមានសមត្ថកិច្ច តែក្នុងករណីដែលមានបណ្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់គណៈ

---

[71] ប្រការ ៤០ វាក្យខណ្ឌទី៤ នៃប្រកាសលេខ ០៩៩ ស.ក.ប.យ. ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល

[72] សេចក្តីបង្គាប់លេខ ០០៩/១៧-អ៊ឹម វ៉េ កាត់ដេរអន្តរជាតិ (សាខាទី៣) ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០១៧ ទំព័រ ៦ដល់៧

[73] ក្រុមប្រឹក្សាអាជ្ញាកណ្តាល, *សេចក្តីសង្ខេបយុត្តិសាស្ត្ររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ៨*, (ភ្នំពេញ៖ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ២០០៧), ៥

[74] ប្រការ១ នៃប្រកាសអន្តរក្រសួង លេខ ០២ប្រកន/០៣ ស្តីពីការកំណត់ភារកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងរឿងវិវាទដីធ្លី ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០០៣

កម្មការសុរិយោដីថ្នាក់ជាតិដែលបានដាក់ជូនប៉ុណ្ណោះ។ ក្នុងករណីនេះតុលាការរដ្ឋប្បវេណីដើរតួជាតុលាការនៃបណ្តឹងឧបាស្រ័យ។

នីតិវិធីនៅក្នុងការដោះស្រាយវិវាទដីធ្លីត្រូវបានកំណត់ជាក់លាក់នៅក្នុង អនុក្រឹត្យលេខ៤៧ អនក្រ/បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី និងប្រកាសលេខ១១២ ដនស/ប្រក ស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី ព្រមទាំងសេចក្តីណែនាំលេខ ១៩៥៥ ដនស/គសដ ស្តីពីនីតិវិធីសវនាការនៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ជាអាទិ៍។ លិខិតបទដ្ឋានគតិយុត្តទាំងនោះបានបង្កើតជា ស្ថាប័ន និងយន្តការក្នុងការដោះស្រាយវិវាទដីធ្លីដែលមិនទាន់បានចុះបញ្ជី ហេតុនេះវាអាចផ្តល់នូវភាពទុកចិត្តបានអំពីប្រសិទ្ធភាពនៃការដោះស្រាយវិវាទឯកជនដែលទាក់ទងនឹងដីដែលមិនទាន់បានចុះបញ្ជី។

បន្ថែមពីនេះទៀត ដើម្បីឱ្យកាន់តែមានភាពច្បាស់លាស់នៃអានុភាពនៃសេចក្តីសម្រេចដែលចេញដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិ មាត្រា ២៣ នៃអនុក្រឹត្យលេខ ៤៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ព្រមទាំង ប្រការ ៤៨ នៃប្រកាសលេខ ១១២ បានកំណត់ដែលមានខ្លឹមសារប្រហាក់ប្រហែលគ្នាថា “សេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ **ក្លាយជាសេចក្តីសម្រេចស្ថាពរ** នៅក្រោយរយៈពេល ៣០ថ្ងៃ បន្ទាប់ពីសេចក្តីសម្រេចនោះត្រូវបានបញ្ជូនទៅដល់ភាគីនៃវិវាទទាំងអស់...។”

ដើម្បីរក្សានូវតម្លៃនៃសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ គប្បីផ្តល់ភាពស្ថាពរដល់សេចក្តីសម្រេចនេះ ក្នុងគោលបំណងហាមឃាត់ការធ្វើវិវាទជាបន្តបន្ទាប់ ដែលរាំងស្ទះដល់ការអនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី។

### ១.២.២.៦ សាលក្រមតុលាការបរទេស

ផ្អែកលើឯករាជ្យភាពនៃរដ្ឋ សាលក្រមរបស់តុលាការបរទេស អាចពុំត្រូវបានបង្ខំឱ្យរដ្ឋអធិបតេយ្យ ទទួលស្គាល់ភាពស្របច្បាប់របស់វា ហើយក៏ពុំអាចចងតុលាការដោយសារភាពស្ថាពរនៃសាលក្រមបរទេសនោះដែរ។ អធិបតេយ្យភាពនេះក៏មិនរារាំងឱ្យកម្ពុជា ពុំឱ្យទទួលស្គាល់នូវអានុភាពស្ថាពរនៃសាលក្រមបរទេសដែរ ប៉ុន្តែសាលក្រមបរទេសត្រូវបានចេញដោយតុលាការបរទេស ផ្អែកលើច្បាប់បរទេស និងនីតិវិធីនៃប្រទេសដែលតុលាការនោះតាំងនៅ ហេតុនេះការទទួលស្គាល់ភាពស្របច្បាប់នៃសាលក្រមស្ថាពរប្រទេស ក្នុងយុត្តាធិការកម្ពុជា ក៏ត្រូវពិចារណាយ៉ាងដិតដល់ផងដែរ។

លុះត្រាតែសាលក្រមរបស់តុលាការបរទេស ត្រូវបានច្បាប់ជាតិទទួលស្គាល់ភាពស្ថាពររបស់វា ទើបវាមានអានុភាពចងតុលាការកម្ពុជា។ ការទទួលស្គាល់ភាពស្ថាពរនៃសាលក្រមបរទេស ត្រូវបានបញ្ញត្តក្នុងមាត្រា ១៩៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា "សាលក្រមស្ថាពររបស់តុលាការបរទេស ត្រូវមានអានុភាព លុះត្រាតែបានបំពេញល័ក្ខខ័ណ្ឌទាំងអស់ខាងក្រោមនេះ ៖

- បើសិទ្ធិជម្រះក្តីរបស់តុលាការបរទេសត្រូវបានទទួលស្គាល់ ដោយច្បាប់ ឬ សន្ធិសញ្ញា ឬ អនុសញ្ញា ដែលព្រះរាជាណាចក្រកម្ពុជាជាភាគី។
- បើចុងចម្លើយដែលចាញ់ក្តី បានទទួលការបញ្ជូនដីកាកោះហៅ ដោយច្បាប់ ឬ ដែលចាំបាច់ដើម្បីចាប់ផ្តើមនីតិវិធី ឬ មិនបានទទួលទេ តែបានឆ្លើយដោះសារតបចំពោះបណ្តឹងនោះ។
- បើខ្លឹមសារនៃសាលក្រម និង នីតិវិធីនៃបណ្តឹងនោះ មិនប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬ ទំនៀមទម្លាប់ល្អនៃព្រះរាជាណាចក្រកម្ពុជា។
- មានការធានាទៅវិញទៅមករវាងព្រះរាជាណាចក្រកម្ពុជា និងបរទេស។"

ការទទួលស្គាល់អានុភាពស្ថាពរនៃសាលក្រមបរទេស ពុំតម្រូវឱ្យមាននីតិវិធីណាមួយឡើយ។ ប្រសិនបើសាលក្រមរបស់តុលាការបរទេស បានបំពេញគ្រប់ល័ក្ខខ័ណ្ឌ ដែលមានចែងក្នុងមាត្រា ១៩៩ នៃក្រមនេះ សាលក្រមស្ថាពរនោះ នឹងមានអានុភាពដូចសាលក្រមស្ថាពររបស់តុលាការកម្ពុជា។ អានុភាពស្ថាពរនេះ ពុំតម្រូវទាល់តែធ្វើនីតិវិធីបណ្តឹងទាមទារឱ្យតុលាការចេញសាលក្រមអនុវត្តតាមមាត្រា ៣៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឡើយ។ លុះត្រាតែភាគីឈ្នះក្តី មានបំណងចង់អនុវត្តដោយបង្ខំផ្អែកលើសាលក្រមស្ថាពរបរទេស ទើបនីតិវិធីនៃមាត្រា ៣៥២ ចាំបាច់ត្រូវបំពេញ។

ប្រសិនបើមានភាគីណាមួយនៃនីតិវិធី ដែលត្រូវបានតុលាការបរទេសបញ្ចប់ដោយចេញសាលក្រម ហើយសាលក្រមនោះចូលជាស្ថាពរហើយ បានដាក់ពាក្យបណ្តឹងមកតុលាការកម្ពុជា ទោះបីជាតុលាការកម្ពុជាមានសមត្ថកិច្ចក្នុងការជំនុំជម្រះក៏ដោយ (ឧទាហរណ៍ ៖ ភាគីណាមួយមានលំនៅឋាននៅកម្ពុជា) ក៏ភាគីដែលនឹងខូចប្រយោជន៍ អាចអះអាងអំពីអានុភាពអាជ្ញាអស់ជំនុំនៃសាលក្រមស្ថាពររបស់តុលាការបរទេស ដើម្បីជាមធ្យោបាយការពារខ្លួនបាន។ ក្នុងករណីនេះ តុលាការត្រូវធ្វើការវិនិច្ឆ័យថា តើសាលក្រមស្ថាពរនោះ បានបំពេញគ្រប់ល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ១៩៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីឬទេ? បើរកឃើញថា ល័ក្ខខ័ណ្ឌពុំត្រូវបានបំពេញ តុលាការពុំទទួលស្គាល់អានុភាពអាជ្ញាអស់ជំនុំនៃសាលក្រមស្ថាពរបរទេស ហើយអាចចេញសាលក្រមដោយពុំផ្អែកលើសាលក្រមស្ថាពររបស់តុលាការបរទេសនោះបាន។

អាជ្ញាអស់ជំនុំនៃសាលក្រមស្ថាពរនៃតុលាការបរទេស មាននៅពេលដែលវាបានបំពេញតាមល័ក្ខខ័ណ្ឌនៃមាត្រា ១៩៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ហើយវាចងតុលាការកម្ពុជាមិនអោយធ្វើការសម្រេចសេចក្តីផ្ទុយពីចំណុចដែលត្រូវបាននិច្ឆ័យក្នុងសាលក្រមស្ថាពរបរទេសនោះ។ មិនតែប៉ុណ្ណោះ ទោះបីជានៅក្នុងនីតិវិធីបណ្តឹងទាមទារឱ្យចេញសាលក្រមអនុវត្ត តាមមាត្រា ៣៥២ ក៏ដោយ ក៏ច្បាប់បានហាមឃាត់តុលាការនៃបណ្តឹងទាមទារសាលក្រមអនុវត្ត មិនអោយធ្វើការស្រាវជ្រាវអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃសាលក្រម ឬសាលដីការបស់តុលាការបរទេសឡើយ[75] នាំអោយយើងអាចសន្និដ្ឋានបានថា ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ទទួលស្គាល់ភាពស្របច្បាប់យ៉ាងពេញលេញ នូវអានុភាពអាជ្ញាអស់ជំនុំនៃសាលក្រមស្ថាពររបស់តុលាការបរទេស ដែលបានបំពេញគ្រប់ល័ក្ខខ័ណ្ឌតម្រូវនៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា។

ផ្អែកតាមការបកស្រាយនៅក្នុងជំពូកនេះ វាបង្កើតឱ្យបានជាមូលដ្ឋានក្នុងការសិក្សាបន្តបន្ទាប់ទៀតស្តីពីចរិតលក្ខណៈនៃអានុភាព និងការយកទ្រឹស្តីនេះទៅអនុវត្តនៅក្នុងនីតិវិធីជាក់ស្តែងដែលនឹងបកស្រាយនៅជំពូកបន្តបន្ទាប់ ក៏ព្រោះតែ បើយើងពឹងផ្អែកលើតែការបកស្រាយតែមួយគត់នៃមាត្រា ១៩៩ យើងប្រាកដជាមិនដឹងអំពីឫសគល់នៃការបង្កើតឱ្យមាននូវរបបគតិយុត្តមួយនេះ ក៏ដូចជាអត្ថន័យជាក់លាក់នៃអាជ្ញាអស់ជំនុំឡើយ។

[75] មាត្រា ៣៥២ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

# ជំពូកទី២ ៖ អានុភាពអាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី

នីតិវិធីបណ្តឹងដែលទាក់ទងនឹងវិវាទរដ្ឋប្បវេណីនឹងក្លាយទៅជាអសារបង់ ប្រសិនបើសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីដែលចូលជាស្ថាពរហើយ ពុំមានអានុភាពចងភាគី មិនអោយធ្វើវិវាទដដែល និងតុលាការ មិនឱ្យជំនុំជម្រះលើវិវាទដដែល។ ការបកស្រាយអំពីអានុភាពអាជ្ញាអស់ជំនុំតាមច្បាប់កម្ពុជា ផ្អែកយ៉ាងសំខាន់ទៅលើសេចក្តីសម្រេចរបស់តុលាការដែលជា សាលក្រមចុងក្រោយ[76]។ ចំណែកឯអាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីផ្សេងទៀត ត្រូវបានក្រមនីតិវិធីបញ្ញត្តឱ្យ **យកមកអនុវត្តដូចគ្នា** នូវបទប្បញ្ញត្តិអាជ្ញាអស់ជំនុំនៃសាលក្រម ចំពោះសេចក្តីសម្រេចទាំងនោះដែលវាជាបច្ចេកទេសនីតិកម្មក្នុងការតាក់តែងក្រមនីតិវិធីរដ្ឋប្បវេណីរបស់កម្ពុជា។ ហេតុនេះការបកស្រាយអំពីអានុភាពអាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី វាផ្តើមចេញពីការសិក្សាអំពីអាជ្ញាអស់ជំនុំនៃសាលក្រមរដ្ឋប្បវេណីក្នុងចំណុច **២.១ អានុភាពអាជ្ញាអស់ជំនុំនៃសាលក្រមចុងក្រោយ**។ ដោយផ្អែកលើការយកមកអនុវត្តដូចគ្នានៃបទប្បញ្ញត្តិស្តីពីសាលក្រម នាំអោយសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីផ្សេងទៀត មានអានុភាពអាជ្ញាអស់ជំនុំដូចនឹងសាលក្រមដែរ។ លក្ខណៈអាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចរដ្ឋប្បវេណីក្រៅពីសាលក្រមឬសាលដីកា នឹងលើកយកមកសិក្សាក្នុងចំណុច **២.២ អាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីផ្សេងទៀត**។

## ២.១ អានុភាពអាជ្ញាអស់ជំនុំនៃសាលក្រមចុងក្រោយ

សាលក្រមចុងក្រោយគឺជាសេចក្តីសម្រេចរបស់តុលាការចំពោះសិទ្ធិ និង ទំនាក់ទំនងគតិយុត្តដែលមានវិវាទ បន្ទាប់ពីបានទាញហេតុផល និងពិនិត្យភស្តុតាង ចប់សព្វគ្រប់។ ដូចបានបកស្រាយនៅក្នុង**ចំណុច ១.១ ស្តីពីទស្សនទានទូទៅនៃអាជ្ញាអស់ជំនុំ** ទ្រឹស្តីអាជ្ញាអស់ជំនុំដែលត្រូវបានបញ្ចូលក្នុងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា បានដកស្រង់គោលគំនិតពី ក្រមនីតិវិធីរដ្ឋប្បវេណីប្រទេសជប៉ុន និងអាឡឺម៉ង់ ហើយវាមានលក្ខណៈចង្អៀត។

អាជ្ញាអស់ជំនុំតាមក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា បានបង្កើតមុខងារហាមឃាត់ជាលក្ខណៈសារធាតុ និងជាលក្ខណៈទម្រង់។ លក្ខណៈសារធាតុនៃការហាមឃាត់នេះផ្តោតលើខ្លឹមសារនៃការហាមឃាត់ ពោលគឺ វិសាលភាពនៃអានុភាពអាជ្ញាអស់ជំនុំ (ចំណុច **២.១.១ អាជ្ញាអស់ជំនុំលក្ខណៈសារធាតុ**)។ ចំណែកឯ លក្ខណៈទម្រង់នៃអាជ្ញាអស់ជំនុំ (ចំណុច **២.១.២ អាជ្ញាអស់ជំនុំលក្ខណៈ**

[76] មាត្រា ១៩៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

**ទម្រង់**) ជាឧបករណ៍ក្នុងការហាមឃាត់ តុលាការ និងអង្គវិន្ន័យផ្សេងទៀត មិនឱ្យធ្វើការវិនិច្ឆ័យ លើចំណុចសារធាតុដែលមានអាជ្ញាអស់ជំនុំ ព្រមទាំងតុលាការនៃបណ្ដឹងឧបាស្រ័យ មិនអោយវិនិច្ឆ័យចំពោះសាលក្រម ឬសាលដីកា របស់តុលាការថ្នាក់ទាប ដែលបានចូលជាស្ថាពរ។

### ២.១.១ អាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ

ផ្អែកលើនិយមន័យដែលថា អាជ្ញាអស់ជំនុំគឺជាការហាមឃាត់មិនឱ្យសម្រេចសេចក្ដីចំពោះចំណុចដែលត្រូវបានសម្រេចហើយ យើងពុំអាចកំណត់អំពីវិសាលភាពនៃអានុភាពអាជ្ញាអស់ជំនុំដែលមានចែងក្នុងមាត្រា ១៩៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាបានឡើយ។ វិសាលភាពនៃអានុភាពអាជ្ញាអស់ជំនុំនៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា មានលក្ខណៈចង្អៀតដូចបានបកស្រាយក្នុងជំពូកទី១ ហើយវាត្រូវបានកំណត់តាមទស្សនវិស័យ ៣ គឺ[77] ៖

(១) វិសាលភាពផ្អែកកម្មវត្ថុ ៖ ចំណុចនៃសាលក្រមដែលមានអាជ្ញាអស់ជំនុំ

(២) វិសាលភាពចំពោះភាគី ៖ បុគ្គលដែលទទួលអានុភាពនៃសាលក្រមស្ថាពរ

(៣) វិសាលភាពចំពោះពេលវេលា ៖ ពេលវេលាជាមូលដ្ឋាននៃអាជ្ញាអស់ជំនុំ។

ដើម្បីកំណត់ថា រឿងក្ដីនៃបណ្ដឹងក្រោយ ស្ថិតក្រោមវិសាលភាពនៃអានុភាពអាជ្ញាអស់ជំនុំ តុលាការត្រូវរកអោយឃើញនូវចំណុចជាសារធាតុទាំង៣ ខាងលើ ថាតើកម្មវត្ថុនៃការទាមទារនៃបណ្ដឹងក្រោយ មានភាពដូចគ្នានឹងការសម្រេចក្នុងបណ្ដឹងមុនដែរទេ? ថាតើភាគីនៃបណ្ដឹងក្រោយស្ថិតក្រោមវិសាលភាពនៃអាជ្ញាអស់ជំនុំដែរទេ? និងថាតើការទាមទារនៃបណ្ដឹងក្រោយ ផ្អែកលើសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលកើតឡើងមុនពេលវេលាជាមូលដ្ឋាននៃអាជ្ញាអស់ជំនុំដែរឬទេ?

#### ២.១.១.១ វិសាលភាពផ្អែកកម្មវត្ថុនៃអាជ្ញាអស់ជំនុំ

អាជ្ញាអស់ជំនុំ គឺជាអានុភាពហាមឃាត់ មិនអោយតុលាការធ្វើការវិនិច្ឆ័យលើចំណុចដែលត្រូវបានសម្រេចជាស្ថាពររួចហើយ។ ប្រសិនបើយើងយោងទៅលើនិយមន័យនេះ វាមានភាពទូលាយពេក ដែលវាខុសទៅនឹងវិសាលភាពនៃអានុភាពអាជ្ញាអស់ជំនុំតាមន័យនៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា។ ដើម្បីដឹងថាការទាមទារនៃបណ្ដឹងថ្មីស្ថិតនៅក្រោមអានុភាពអាជ្ញាអស់ជំនុំឬទេ យើងត្រូវមើលលើលិខិតសាលក្រម។ ប៉ុន្តែនៅក្នុងលិខិតសាលក្រម វាមានច្រើនផ្នែកជាអាទិ៍ អង្គហេតុ និងចំណុចវិវាទ, សំអាងហេតុ និងសេចក្ដីសម្រេចបញ្ចប់ជាអាទិ៍។ បើតាមន័យទូលាយ

[77] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្ដីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១: នីតិវិធីបណ្ដឹង*, (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០០៨), ១៣៨

អាជ្ញាអស់ជំនុំត្រូវមានអានុភាពចំពោះចំណុចទាំងអស់ដែលត្រូវបានសម្រេច ប៉ុន្តែយោងតាមក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា អាជ្ញាអស់ជំនុំនៃសាលក្រមមានតែចំពោះ **ផ្នែកសេចក្តីសម្រេចបញ្ចប់នៃសាលក្រម** តែប៉ុណ្ណោះ[78]។

សេចក្តីសម្រេចបញ្ចប់ គឺជាចំណុចដែលតុលាការត្រូវសម្រេចចំពោះការទាមទារទាំងអស់របស់ភាគី[79]។ វាពុំត្រឹមតែជាការសម្រេចចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញទេ វាថែមទាំងជាសេចក្តីសម្រេចចំពោះបណ្តឹងតបរបស់ចុងចម្លើយ ប្រសិនបើមាន។ តុលាការត្រូវសរសេរចូលនូវចំណុចស្តីពីការទទួលស្គាល់អង្គហេតុ និង ភស្តុតាង នៅក្នុង**ផ្នែកសំអាងហេតុ** ហើយសម្រេចទទួលស្គាល់ ឬច្រានចោលការទាមទារនៅក្នុង **ផ្នែកសេចក្តីសម្រេចបញ្ចប់**។ ចំណុចដែលតុលាការសម្រេចដែលក្រៅពីការទាមទារក្នុងពាក្យបណ្តឹងរបស់ដើមចោទ ឬ បណ្តឹងតបរបស់ចុងចម្លើយ ជាគោលការណ៍ពុំមានអានុភាពអាជ្ញាអស់ជំនុំឡើយ ពោលគឺមានតែផ្នែកនៃសេចក្តីសម្រេចបញ្ចប់ប៉ុណ្ណោះដែលមានអាជ្ញាអស់ជំនុំ។[80]

មូលហេតុដែលនីតិនិពន្ធបានកម្រិតនូវវិសាលភាពផ្នែកកម្មវត្ថុត្រឹមចំណុចដែលតុលាការបានសម្រេចក្នុងសេចក្តីសម្រេចបញ្ចប់ ដោយសារតែ ៖ ទី១ ចង់ឱ្យភាគីនៃបណ្តឹងផ្តោតសំខាន់លើលទ្ធផលនៃសេចក្តីសម្រេចបញ្ចប់ បើពុំដូច្នេះទេ ភាគីនឹងធ្វើសកម្មភាពគ្រប់បែបយ៉ាងដើម្បីទទួលបានផលប្រយោជន៍នៃការសម្រេចសេចក្តីក្នុងសំអាងហេតុ ដែលវាមិនពាក់ព័ន្ធទាល់តែសោះក្នុងការសម្រេចសិទ្ធិទាមទាររបស់ខ្លួន។ ទី២ ដើម្បីអោយមានភាពបត់បែនក្នុងការធ្វើការសម្រេចសេចក្តីរបស់តុលាការ[81]។

នៅក្នុងផ្នែកសេចក្តីសម្រេចបញ្ចប់ តុលាការវិនិច្ឆ័យអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ដែលត្រូវបានបញ្ចប់ការទាញហេតុផលលើអង្គសេចក្តីចំពោះ សិទ្ធិ ឬទំនាក់ទំនងគតិយុត្ត នោះ[82] ហេតុនេះ បើមានការទាមទារថ្មី ដោយភាគីអះអាងអំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តផ្សេងពីអ្វីដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ក្នុងនីតិវិធីមុន វាពុំចងតុលាការ មិនអោយធ្វើការសម្រេចសេចក្តីចំពោះការទាមទារថ្មីនោះទេ ដោយហេតុថា ការទាមទារថ្មី ពុំស្ថិតក្រោមអានុភាពនៃវិសាលភាពអាជ្ញាអស់ជំនុំផ្នែកកម្មវត្ថុ។

---

[78] មាត្រា ១៩៤ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[79] មាត្រា ១៨២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[80] ទម្រង់នៃសាលក្រមចុងក្រោយ សូមមើលឧបសម្ព័ន្ធ១ និងឧបសម្ព័ន្ធ៥

[81] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១: នីតិវិធីបណ្តឹង*, (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០០៨), ១៣៨

[82] មាត្រា ១៩៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

***ឧទាហរណ៍ ៖*** ទោះបីនៅក្នុងសាលក្រមស្ថាពរ តុលាការបានច្រានចោលការទាមទារឱ្យផ្តល់តារកាលិកផ្អែកលើកិច្ចសន្យាខ្ចីបរិភោគក៏ដោយ ក៏វាមិនមានអានុភាពហាមឃាត់ភាគីមិនអោយធ្វើវិវាទអំពីសិទ្ធិលើបំណុលដែលផ្អែកលើសេចក្តីចម្រើនឥតហេតុនោះទេ ដោយសារតែខ្លឹមសារនៃសិទ្ធិ និងទំនាក់ទំនងគតិយុត្តនៃបណ្តឹងមុន និងបណ្តឹងក្រោយមានភាពខុសគ្នា។ ប្រសិនបើនៅក្នុងបណ្តឹងក្រោយ តុលាការទទួលស្គាល់ថាដើមចោទពិតជាមានសិទ្ធិលើបំណុលផ្អែកលើសេចក្តីចម្រើនដោយឥតហេតុ តុលាការនឹងចេញសាលក្រមតាមការទាមទារ ហើយសាលក្រមនេះមិនផ្ទុយនឹងសាលក្រមនៃបណ្តឹងមុននោះទេ ពោលគឺវាពុំស្ថិតក្រោមវិសាលភាពផ្ទៃកកម្មវត្ថុនៃអាជ្ញាអស់ជំនុំឡើយ[83]។ យោងតាមហេតុផលទាំងនេះ តុលាការនឹងអាចធ្វើការសម្រេចសេចក្តីដោយមានភាពបត់បែនដូចគោលបំណងដែលបានបង្ហាញក្នុងកថាខណ្ឌខាងលើ។

ដូច្នេះដើម្បីសម្រេចអំពី ថាតើការទាមទារនៃបណ្តឹងថ្មី ស្ថិតក្រោមវិសាលភាពនៃអាជ្ញាអស់ជំនុំនៃបណ្តឹងមុនដែរឬទេ តុលាការត្រូវប្រៀបធៀប ថាតើមានភាពដូចគ្នានៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែរឬទេ ដោយមើលទៅលើសំអាងហេតុ ដែលសម្រេចអំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលមានវិវាទ ជាមួយនឹងសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលភាគីនៃបណ្តឹងថ្មីផ្អែកលើ ដើម្បីទាមទារឱ្យតុលាការចេញសាលក្រម។

### គ. បណ្តឹងតប

បណ្តឹងតប គឺជាបណ្តឹងដែលធ្វើឡើងដោយចុងចម្លើយនៃបណ្តឹងដើម ពាក់ព័ន្ធនឹង ការទាមទារដែលជាកម្មវត្ថុនៃបណ្តឹងដើម ឬមធ្យោបាយការពារនៃបណ្តឹងដើម។ ដើមចោទនៃបណ្តឹងដើមត្រូវក្លាយទៅជាចុងចម្លើយនៃបណ្តឹងតប។ ខ្លឹមសារនៃបណ្តឹងតបត្រូវតែមានកម្មវត្ថុដូចគ្នានឹងបណ្តឹងដើម ឬមួយក៏អង្គហេតុជាមូលហេតុនៃបណ្តឹងតប ត្រូវគ្នានឹងអង្គហេតុជាមូលហេតុនៃការទាមទារនៃបណ្តឹងដើម។[84]

---

[83] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១: នីតិវិធីបណ្តឹង*, (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០០៨), ១៣៨-១៣៩

[84] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១: នីតិវិធីបណ្តឹង*, (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០០៨), ១៧៦-១៧៧

នៅក្នុងសាលក្រមរដ្ឋប្បវេណីលេខ ៥៣០ “ង”ភ.ព.រ.វ ចុះថ្ងៃទី ២៩ ខែមេសាឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ[85] បន្ទាប់ពីឆ្លងកាត់នីតិវិធីត្រៀមទាញហេតុផល តុលាការបានកំណត់ចំណុចវិវាទ ២ក្នុងចំណោមចំណុចវិវាទទាំង៨ ដែលពាក់ព័ន្ធនឹងបណ្ដឹងតបដែលមានខ្លឹមសារថា “តើចុងចម្លើយមានសិទ្ធិទាមទារភាគហ៊ុនពីសហដើមចោទចំនួន ៨៣៩,០៦៨.១៦ (ប៉ែតសិបបីម៉ឺនប្រាំបួនពាន់ហុកសិបប្រាំបីដុល្លារអាមេរិក និងដប់ប្រាំមួយសេន) និងការប្រាក់២,៥% (ពីរក្បៀសប្រាំភាគរយ) ក្នុងមួយខែ លើចំនួនប្រាក់នេះគិតចាប់ពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១០ រហូតដល់ថ្ងៃសងគ្រប់ចំនួនដែរឬទេ? និងតើចុងចម្លើយមានសិទ្ធិក្នុងការទាមទារផលប្រយោជន៍បានមកពីផ្សារទាំង ០៥កន្លែង ដែលកើតចេញពីទ្រព្យសម្បត្តិ និងពលកម្មរបស់ខ្លួនចំនួន ១,០០០,០០០ដុល្លារ (មួយលានដុល្លារអាមេរិក) ពីសហដើមចោទដែរឬទេ?។” នៅក្នុងសំអាងហេតុចំណុចវិវាទទី៦ និងទី៧ នៃសាលក្រម តុលាការបានសំដែងការយល់ឃើញថា “កម្មវត្ថុនៃការទាមទាររបស់ដើមចោទ ដែលចុងចម្លើយទាមទារនៅក្នុងបណ្ដឹងតប ពុំមានមូលដ្ឋានដែលអាចឱ្យតុលាការសម្រេចតាមការទាមទារឡើយ ដូច្នេះចុងចម្លើយគប្បីធ្វើបណ្ដឹងទាមទារនៅក្នុងនីតិវិធីបណ្ដឹងផ្សេង ហេតុដូច្នេះចំណុចនេះគប្បីតុលាការច្រានចោលការទាមទាររបស់សហចុងចម្លើយ។”

ដើម្បីឱ្យមានសមភាពរវាងភាគីនៃវិវាទ ការទាមទារនៅក្នុងបណ្ដឹងដើម និងការទាមទារតបរបស់ចុងចម្លើយ គប្បីមានតុល្យភាព ហើយតុលាការត្រូវសម្រេចសេចក្ដីចំពោះការទាមទារទាំងនោះនៅក្នុងសេចក្ដីសម្រេចបញ្ចប់។ កាលណាមានបណ្ដឹងតប តុលាការត្រូវទាញហេតុផលលើបណ្ដឹងតប និងសម្រេចចំពោះបណ្ដឹងតប នៅក្នុងសាលក្រមតែមួយនៃបណ្ដឹងដើម[86]។

***<u>ឧទាហរណ៍</u> ៖*** ដើមចោទនៃបណ្ដឹងដើម ទាមទារឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារថា ៖ បង្គាប់ឱ្យចុងចម្លើយប្រគល់ការកាន់កាប់អចលនវត្ថុដែលមានប័ណ្ណកម្មសិទ្ធិលេខ xxxxx មកអោយដើមចោទដោយផ្អែកលើសិទ្ធិកាន់កាប់។ ក្នុងករណីនេះប្រសិនបើចុងចម្លើយជាកម្មសិទ្ធិករនៃដី គាត់អាចដាក់ពាក្យបណ្ដឹងតបដែលមានខ្លឹមសារថា បញ្ជាក់អំពីអត្ថិភាពនៃកម្មសិទ្ធិនៃដី xxxxx ដែលជាកម្មវត្ថុនៃការទាមទារនៅក្នុងបណ្ដឹងដើម (ហៅថាបណ្ដឹងតបដើម្បីទាមទារឱ្យបញ្ជាក់ពាក់កណ្ដាលទី[87])។ តុលាការត្រូវធ្វើការទាញហេតុផលចំពោះបណ្ដឹងដើម និងបណ្ដឹងតប ហើយនៅក្នុង

---

[85] សាលាដំបូងរាជធានីភ្នំពេញ, សំណុំរឿងលេខ៖ ១០៦៦ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២, សាលក្រមលេខ៖ ៥៣០ “ង” ភ.ព.រ.វ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៥ (សូមមើលឧបសម្ព័ន្ធ៥)

[86] មាត្រា ១៩៤ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[87] មាត្រា ៨៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

ក្នុងផ្នែកសេចក្ដីសម្រេចបញ្ចប់នៃសាលក្រម តុលាការត្រូវសម្រេចទទួលស្គាល់ ឬច្រានចោលការទាមទាររបស់ដើមចោទ និងចុងចម្លើយ។ អានុភាពអាជ្ញាអស់ជំនុំ មានចំពោះសេចក្ដីសម្រេច ចំពោះបណ្ដឹងដើមរបស់ដើមចោទ និង បណ្ដឹងតបរបស់ចុងចម្លើយ។

នៅក្នុងសេចក្ដីសម្រេចបញ្ចប់នៃសាលក្រមរដ្ឋប្បវេណីលេខ ៥៣០ "ង"ភ.ព.វ.វ ចុះថ្ងៃទី ២៩ ខែមេសាឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ[88] ត្រង់សេចក្ដីសម្រេចទី៤ និងទី៥ តុលាការបានធ្វើការច្រានចោលបណ្ដឹងតបរបស់សហចុងចម្លើយ ដោយយកមូលហេតុដែលបានរៀបរាប់ក្នុងសំអាងហេតុចំណុចវិវាទទី ៦ និងទី៧។ ដោយសារតែការសម្រេចចំពោះបណ្ដឹងតបត្រូវបញ្ចូលទៅក្នុងផ្នែកសេចក្ដីសម្រេចបញ្ចប់នៃសាលក្រម ហេតុនេះអានុភាពនៃអាជ្ញាអស់ជំនុំសារធាតុផ្នែកកម្មវត្ថុក៏មានវិសាលភាពចំពោះបណ្ដឹងតបរបស់ចុងចម្លើយផងដែរ។

### ខ. ការទូទាត់

ការទូទាត់គឺជាសកម្មភាពរំលត់កាតព្វកិច្ច[89]។ ប្រសិនបើកូនបំណុលបានបង្ហាញឆន្ទៈទូទាត់សិទ្ធិលើបំណុលដែលខ្លួនមានចំពោះម្ចាស់បំណុល កាតព្វកិច្ចដែលម្ចាស់បំណុលធ្លាប់មានចំពោះកូនបំណុលត្រូវរលត់។ ការទូទាត់គឺជាសកម្មភាពនៃការបង្ហាញឆន្ទៈ ហេតុនេះទោះបីជាវាធ្វើនៅក្នុងនីតិវិធី ឬក្រៅនីតិវិធីក៏ដោយ ក៏កាតព្វកិច្ចត្រូវរលត់។ ប្រសិនបើកម្មវត្ថុនៃការទាមទាររបស់ដើមចោទត្រូវរលត់ដោយសារការទូទាត់ នោះតុលាការនឹងចេញសាលក្រមច្រានចោលការទាមទារ ដោយសំអាងថាសិទ្ធិលើបំណុលរបស់ដើមចោទ បានរលត់តាមរយៈការទូទាត់។ ជាធម្មតាការទូទាត់គឺជាមធ្យោបាយតទល់ដែលវាជាអង្គហេតុតវ៉ាចំពោះអង្គហេតុជាមូលហេតុនៃការទាមទារ។[90]

***ឧទាហរណ៍ ៖*** ដើមចោទបានដាក់បណ្ដឹងទៅតុលាការ ទាមទារឱ្យចុងចម្លើយសងប្រាក់ដើមចំនួន ១០លានរៀល ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ។ នៅក្នុងនីតិវិធីត្រៀមសម្រាប់ទាញហេតុផល ចុងចម្លើយបានអះអាងថាខ្លួនមានសិទ្ធិលើបំណុលចំពោះដើមចោទចំនួន ១០ លានរៀលផ្អែកលើកិច្ចសន្យាលក់ទិញរថយន្ត ហើយចុងចម្លើយបានបង្ហាញឆន្ទៈទូទាត់នៅក្នុងកាលបរិច្ឆេទនោះតែម្ដង។ ដោយសារតែការទូទាត់ធ្វើអោយកាតព្វកិច្ចសងប្រាក់ចំនួន ១០លានរៀលរបស់ចុងចម្លើយ

---

[88] សាលាដំបូងរាជធានីភ្នំពេញ, សំណុំរឿងលេខ៖ ១០៦៦ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២, សាលក្រមលេខ៖ ៥៣០ "ង" ភ.ព.វ.វ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៥ (សូមមើលឧបសម្ព័ន្ធ៥)

[89] មាត្រា ៤៦៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីកម្ពុជា

[90] ក្រុមការងារកិច្ចការរដ្ឋប្បវេណី នៃគណៈមេធាវី និងកម្មវិធីសហប្រតិបត្តិការផ្នែកតុលាការជាមួយគណៈមេធាវី, *សៀវភៅមេរៀនស្ដីពីមូលដ្ឋាននៃអង្គហេតុចម្បង*, (ភ្នំពេញ ៖ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, ២០១០), ២ដល់៣

ត្រូវរលត់ ហេតុនេះ តុលាការត្រូវចេញសាលក្រមដែលមានខ្លឹមសារថា៖ ច្រានចោលការទាមទារ របស់ដើមចោទ។ ប៉ុន្តែប្រសិនបើតុលាការពុំទទួលស្គាល់អត្ថិភាពនៃសិទ្ធិលើបំណុលតបនោះទេ តុលាការត្រូវសម្រេចអំពីការមិនទទួលស្គាល់នេះនៅក្នុង **ផ្នែកសំអាងហេតុ** ហើយសម្រេចអំពីការ បង្គាប់ឱ្យផ្តល់តាវកាលិកនៅក្នុង **ផ្នែកសេចក្តីសម្រេចបញ្ចប់**។

ដូច្នេះ សេចក្តីសម្រេចដែលបង្គាប់អោយផ្តល់តាវកាលិកមានអាជ្ញាអស់ជំនុំ ប៉ុន្តែសេចក្តី សម្រេចអំពីនត្ថិភាពនៃសិទ្ធិលើបំណុលតបពុំមានអាជ្ញាអស់ជំនុំឡើយ ព្រោះវាត្រូវបានសរសេរនៅ ក្នុងផ្នែកសំអាងហេតុ។ នាំអោយចុងចម្លើយដែលចាញ់ក្តីក្នុងបណ្តឹងមុន អាចធ្វើវិវាទអំពីអត្ថិភាពនៃ សិទ្ធិលើបំណុលតបដដែល។ ហេតុនេះវានឹងនាំអោយមានវិសមភាពរវាងដើមចោទ និងចុងចម្លើយ កើតឡើង។

ឧទាហរណ៍ខាងលើ គឺជាមូលហេតុដែលនាំអោយនីតិនិពន្ធបង្កើតជាអញ្ញត្រកម្មមួយចំពោះ វិសាលភាពនៃអានុភាពអាជ្ញាអស់ជំនុំសារធាតុ[91]។ មាត្រា ១៩៤ កថាខណ្ឌទី៤ បានបញ្ញត្តជាករណី លើកលែងនៃកថាខណ្ឌទី៣ នៃមាត្រានេះ ចំពោះវិសាលភាពនៃកម្មវត្ថុនៃអាជ្ញាអស់ជំនុំ ដូច្នេះថា ៖ “ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី៣ ខាងលើនេះក៏ដោយ បើចុងចម្លើយទាមទារការទូទាត់ដោយ សិទ្ធិលើបំណុលតប សេចក្តីវិនិច្ឆ័យក្នុងសាលក្រមស្ថាពរដែលសម្រេចថា **គ្មានសិទ្ធិលើបំណុលតប ទេនោះ** ត្រូវបង្កើតអានុភាពនៃអាជ្ញាអស់ជំនុំ លើចំនួនប្រាក់ដែលបានតវ៉ា ដោយការទូទាត់នោះ។” ក្នុងន័យនេះ អាជ្ញាអស់ជំនុំមានចំពោះទំហំនៃសិទ្ធិលើបំណុល ដែលបានទូទាត់នោះតែប៉ុណ្ណោះ។ ប្រសិនបើដើមចោទមានសិទ្ធិលើបំណុល ១០លានរៀល ចំណែកឯចុងចម្លើយមានសិទ្ធិលើបំណុល ចំនួន ១២លានរៀល អាជ្ញាអស់ជំនុំនឹងមានចំពោះសិទ្ធិលើបំណុលចំនួន ១០លានរៀលដែលចុង ចម្លើយមានចំពោះដើមចោទ ដោយឡែក សិទ្ធិលើបំណុលដែលនៅសល់ចំនួន ២លានរៀលទៀត មិនត្រូវហាមឃាត់ចុងចម្លើយមិនឱ្យទាមទារនោះទេ។ ក្នុងករណីនេះ តុលាការពុំត្រូវចេញសេចក្តី សម្រេចបង្គាប់ឱ្យដើមចោទបង់ប្រាក់ ២លានរៀល ទៅចុងចម្លើយនៅក្នុងសេចក្តីសម្រេចបញ្ចប់ទេ ព្រោះការអះអាងអំពីការទូទាត់គឺជាអង្គហេតុតវ៉ា ពុំមែនជាបណ្តឹងតបទេ[92]។

---

[91] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១: នីតិវិធីបណ្តឹង*, (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០០៨), ១៣៩-១៤១

គំនិតនេះក៏បានបញ្ចូលទៅក្នុងមាត្រា១១៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីប្រទេសជប៉ុន និង មាត្រា៣០២ នៃក្រម នីតិវិធីរដ្ឋប្បវេណីប្រទេសអាឡឺម៉ង់

[92] មាត្រា ១៨២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

**គ. ការទាមទារមួយភាគ**

ការទាមទារឱ្យតុលាការចេញសាលក្រមចំពោះសិទ្ធិលើបំណុលមួយភាគ ក្នុងចំណោមសិទ្ធិលើបំណុលទាំងមូល គឺជាការទាមទារមួយភាគ។ ជាគោលការណ៍សេរីភាពក្នុងការចាត់ចែងសិទ្ធិ ច្បាប់ពុំបានហាមឃាត់ចំពោះការទាមទារមួយភាគឡើយ។ ប៉ុន្តែប្រសិនបើតុលាការចេញសាលក្រមចំពោះសិទ្ធិលើបំណុលមួយភាគ សិទ្ធិលើបំណុលដែលនៅសល់នឹងត្រូវហាមឃាត់មិនឱ្យដើមចោទទាមទារទៀតឬមួយយ៉ាងណា?

មានមតិពីរផ្ទុយគ្នាចំពោះការបកស្រាយអំពីអាជ្ញាអស់ជំនុំចំពោះការទាមទារមួយភាគ[93]។ មតិទីមួយលើកឡើងថា ម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលផ្តល់តាវកាលិកមួយភាគបានក្រៅផ្លូវតុលាការ ហេតុនេះតាមផ្លូវតុលាការក៏ម្ចាស់បំណុលអាចអនុវត្តសិទ្ធិទាមទារមួយភាគនេះបានដែរ[94]។ ក្នុងករណីនេះតុលាការត្រូវធ្វើការសម្រេចចំពោះការទាមទារមួយភាគនោះ ទោះបីជាទទួលស្គាល់នៅក្នុងសំអាងហេតុ ថាដើមចោទមានសិទ្ធិលើបំណុលលើសពីមួយភាគនោះក៏ដោយ[95]។ សេចក្តីសម្រេច បង្គាប់ឱ្យចុងចម្លើយសងសិទ្ធិលើបំណុលមួយភាគ គឺផ្អែកលើសំអាងហេតុដែលថា ដើមចោទមានសិទ្ធិលើបំណុលចំពោះកូនបំណុល ហើយដើមចោទ ពុំបានបង្ហាញឆន្ទៈលើកលែងសិទ្ធិលើបំណុលដែលជាមូលហេតុនាំឱ្យសិទ្ធិលើបំណុលដែលនៅសល់រលត់ឡើយ[96]។ ហេតុនេះគប្បីបកស្រាយថា សិទ្ធិលើបំណុលមួយភាគដែលនៅសល់មិនត្រូវរលត់ ហើយក៏មិនត្រូវហាមឃាត់ដើមចោទមិនឱ្យទាមទារនៅបណ្តឹងក្រោយទៀតដែរ។ ប៉ុន្តែមតិមួយទៀត បានចេញមកបដិសេធថា ការមិនផ្តល់ឱ្យនូវអានុភាពអាជ្ញាអស់ជំនុំចំពោះសិទ្ធិលើបំណុលដែលនៅសល់វានឹងធ្វើឱ្យខាតបង់ផលប្រយោជន៍យ៉ាងធ្ងន់ធ្ងរដល់ចុងចម្លើយ ដោយសារខ្លួនត្រូវទទួលបន្ទុកសោហ៊ុយ និងខាតបង់ពេលវេលាក្នុងការទាញហេតុផលនៅតុលាការច្រើនដង។ ការអនុវត្តសិទ្ធិរបស់ដើមចោទទោះបីជាពុំមានបទប្បញ្ញត្តិជាក់លាក់ហាមឃាត់មិនឱ្យទាមទារមួយភាគក៏ដោយ ក៏ទង្វើនេះវាផ្ទុយនឹងគោលការណ៍សុចរិតភាព និងភាពស្មោះត្រង់[97]។

ហេតុនេះអាជ្ញាអស់ជំនុំសារធាតុចំពោះសិទ្ធិលើបំណុលមួយភាគដែលបានទាមទារ គប្បីមានអានុភាពហាមឃាត់ដើមចោទមិនឱ្យធ្វើការទាមទារចំពោះសិទ្ធិលើបំណុលដែលនៅសល់ផ្សេង

---

[93] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគ១: នីតិវិធីបណ្តឹង*, ទំព័រ ៥៦-៥៨

[94] មាត្រា ៣៨៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[95] មាត្រា ១៨២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[96] មាត្រា ៩៧៣ នៃក្រមរដ្ឋប្បវេណីកម្ពុជា

[97] មាត្រា ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

ទៀត។ ទោះជាយ៉ាងនេះក្តី វាស្ថិតនៅក្នុងចំណុចដែលមានភាពពុំច្បាស់លាស់ក្នុងការកំណត់យក ដែលជាភារកិច្ចរបស់តុលាការនៅក្នុងការបង្កើតយុត្តិសាស្ត្របកស្រាយភាពប្រទាំងប្រទើសនេះ។

### ២.១.១.២ ពេលវេលាជាមូលដ្ឋាននៃអាជ្ញាអស់ជំនុំ

កាលបរិច្ឆេទនៃការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ គឺជាពេលរាប់គិតអាជ្ញាអស់ជំនុំ។ វាពុំបានន័យថា អាជ្ញាអស់ជំនុំកើតឡើងនៅពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ទេ។ កាលបរិច្ឆេទនៃការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់គឺ ជាពេលចុងក្រោយដែលតុលាការវិនិច្ឆ័យជាស្ថាពរនូវ អត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដោយផ្អែកលើអង្គហេតុដែលភាគីបានអះអាង ព្រមទាំងធ្វើការទទួលស្គាល់ឬមិនទទួលស្គាល់ភស្តុតាងដែលភាគីបានដាក់។ សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលកើតក្រោយពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ពុំស្ថិតក្នុងចំណុចដែលតុលាការអាចដឹងបាន ព្រមទាំងអាចវិនិច្ឆ័យបានទេ។ ហេតុនេះអាជ្ញាអស់ជំនុំសារធាតុមានតែចំពោះសិទ្ធិ និង ទំនាក់ទំនងគតិយុត្ត ដែលកើតឡើងមុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ប៉ុណ្ណោះ[98]។ ការទាមទារនៃបណ្តឹងក្រោយដោយភាគីអះអាងអំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលកើតមានក្រោយពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ពុំស្ថិតក្នុងវិសាលភាពនៃអាជ្ញាអស់ជំនុំសារធាតុឡើយ។ កាលបរិច្ឆេទនៃការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នេះ អ្នកទ្រឹស្តីបានហៅវាថាជា ***«ពេលវេលាជាមូលដ្ឋាននៃអាជ្ញាអស់ជំនុំ»***[99]។

***<u>ឧទាហរណ៍</u> ៖*** នៅក្នុងបណ្តឹងមុនតុលាការបានចេញសាលក្រមបង្គាប់អោយចុងចម្លើយសងប្រាក់ ៥លានរៀល ទៅឱ្យចុងចម្លើយ ដោយនៅក្នុងសំអាងហេតុ តុលាការទទួលស្គាល់នូវសិទ្ធិទាមទាររបស់ដើមចោទផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ។ នីតិវិធីទាញហេតុផលនេះត្រូវបានតុលាការបញ្ចប់នៅថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ២០១៧។ ក្រោយមកនៅថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០១៧ ដើមចោទបានលើកលែងកាតព្វកិច្ច ៥លានរៀលនោះ ជាហេតុនាំអោយកាតព្វកិច្ចត្រូវរលត់។ ស្ថានភាពបែបនេះមិនអាចហាមឃាត់ចុងចម្លើយ មិនឱ្យដាក់បណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃកាតព្វកិច្ចទៅកាន់តុលាការទេ ព្រោះសិទ្ធិ និងទំនាក់ទំនងគតិយុត្តបានផ្លាស់ប្តូរ (រលត់) ក្រោយពេលបញ្ចប់កាលបរិច្ឆេទចុងក្រោយនៃការទាញហេតុផលដោយផ្ទាល់មាត់។

---

[98] មាត្រា ១៩៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[99] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១: នីតិវិធីបណ្តឹង*, (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០០៨), ១៣៧

ទស្សនទាននៃពេលវេលាជាមូលដ្ឋាននៃអាជ្ញាអស់ជំនុំនេះ ត្រូវបានយកទៅអនុវត្តនៅប្រទេសជប៉ុន ប្រទេស ស្វីស ព្រមទាំងប្រទេសផ្សេងៗទៀត ដែលទទួលឥទ្ធិពលពីប្រព័ន្ធច្បាប់ស៊ីវិល។ អត្ថបទមួយចេញដោយតុលាការកំពូលប្រទេសស្វីស មានចំណងជើងថា New Developments on res judicata (Swiss Supreme Court)បានសម្តែងការយល់ឃើញដូចខាងក្រោមនេះ ៖

> "អានុភាពអាជ្ញាអស់ជំនុំកំណត់ចំពោះអង្គហេតុទាំងអស់ដែលកើតឡើងក្នុងសាលក្រមដំបូង មិនថាភាគីបានដឹង ឬបានអះអាងដោយភាគី ឬ ត្រូវបានយកមកពិចារណានៅក្នុងសាលក្រមដំបូង។ ម្យ៉ាងវិញទៀត សាលក្រមដំបូងមិនត្រូវយកមកពិចារណាឡើយ ប្រសិនបើការទាមទារថ្មី ផ្អែកទៅលើការផ្លាស់ប្តូរផ្នែកកាលៈទេសៈដែលកើតឡើងក្រោយពេលសាលក្រមដំបូង។"[100] [បកប្រែ]

ទោះបីជានៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដើមចោទ ឬចុងចម្លើយ ខកខានមិនបានអះអាងអំពីអង្គហេតុដែលបញ្ជាក់ពី សិទ្ធិ ឬទំនាក់ទំនងគតិយុត្តក៏ដោយ ឱ្យតែអង្គហេតុនោះកើតឡើងមុនពេលបញ្ចប់នីតិវិធីទាញហេតុផល អង្គហេតុទាំងនោះនឹងត្រូវហាមឃាត់មិនឱ្យអះអាងនៅក្នុងបណ្តឹងក្រោយ ហើយភាគីនោះមិនអាចបដិសេធអានុភាពអាជ្ញាអស់ជំនុំនៃសាលក្រមមុនចំពោះខ្លួនបានទេ។

***<u>ឧទាហរណ៍</u>*** ***៖*** ផ្អែកលើការទាញហេតុផលដែលបានបញ្ចប់កាលពីថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ២០១៧ តុលាការបានចេញសាលក្រមច្រានចោលការទាមទារប្រាក់ ៥លានរៀលរបស់ដើមចោទដោយនៅក្នុងសំអាងហេតុ តុលាការរកពុំឃើញអង្គហេតុដែលបញ្ជាក់ថាដើមចោទបានប្រគល់ប្រាក់ទៅចុងចម្លើយ។ នៅក្នុងបណ្តឹងក្រោយ ដើមចោទបានដាក់បណ្តឹងដែលមានការទាមទារដដែលដោយអះអាងអំពីអង្គហេតុប្រគល់ប្រាក់ នៅថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០១២ ព្រមទាំងភស្តុតាងជាលិខិតប្រគល់ទទួលប្រាក់។ ក្នុងស្ថានភាពនេះ សាលក្រមច្រានចោលការទាមទារនៃបណ្តឹងមុនមានអានុភាពអាជ្ញាអស់ជំនុំចំពោះការទាមទារនៃបណ្តឹងក្រោយ ដោយសារតែ អង្គហេតុប្រគល់ប្រាក់បានកើតមុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ហើយភាគីដើមចោទបានខកខាន មិនបានអះអាង ទោះបីជាការខកខាននោះពុំមែនជាកំហុសរបស់ដើមចោទក៏ដោយ។

ប្រសិនបើការទាញហេតុផលដោយផ្ទាល់មាត់ដែលត្រូវបានបញ្ចប់ ត្រូវបានបើកឡើងវិញតាមមាត្រា ១៨០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី កាលបរិច្ឆេទចុងក្រោយត្រូវរាប់គិតពីពេល

---

[100] Prof Dr Nathalie Voser និង Julie Raneda, *New developments on res judicata (Swiss Supreme Court)*, [ការវិវឌ្ឍថ្មីៗនៃអាជ្ញាអស់ជំនុំ (តុលាការកំពូលប្រទេសស្វីស)], (អង់គ្លេស៖ Thomson Reuters, ២០១៤), ២

ដែលតុលាការបានធ្វើការបញ្ចប់ការទាញហេតុផលចុងក្រោយនោះ។ កាលបរិច្ឆេទនៃការបញ្ចប់ការទាញហេតុផលនេះ ជាចំណុចសំខាន់នៅក្នុងលិខិតសាលក្រម ដែលក្រមនីតិវិធីរដ្ឋប្បវេណីបានបញ្ញត្តជាចំណុចដែលត្រូវសរសេរបញ្ចូលជាចាំបាច់[101]។ ការខកខានមិនបានសរសេរចូល នាំអោយសាលក្រម ឬសាលដីកានោះ ក្លាយទៅជាកម្មវត្ថុនៃការជំនុំជម្រះសាជាថ្មី[102]។

## **២.១.១.៣ វិសាលភាពចំពោះប្រធាននៃអាជ្ញាអស់ជំនុំសារធាតុ**

ជាគោលការណ៍ សាលក្រមចុងក្រោយ កំណត់ជាស្ថាពរនូវសិទ្ធិ និងទំនាក់ទំនងគតិយុត្តរវាងភាគីនៃបណ្តឹង ដោយសារតែពួកគេមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចូលរួមក្នុងសកម្មភាពបណ្តឹងតាំងពីដើមរហូតដល់ពេលបញ្ចប់។ នៅក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រមចុងក្រោយ តុលាការត្រូវសរសេរឈ្មោះ ឬនាមករណ៍របស់ដើមចោទនិងចុងចម្លើយ។ ឧទាហរណ៍៖ បង្គាប់ឱ្យចុងចម្លើយ ឈ្មោះ សុខ សម្បត្តិ សងប្រាក់ចំនួន ១០លានរៀល ទៅដើមចោទ ឈ្មោះ សែន សំបូរ។ ហេតុនេះអាជ្ញាអស់ជំនុំសារធាតុនឹងកើតមានចំពោះដើមចោទ និងចុងចម្លើយខាងលើនេះ។ ប៉ុន្តែដើម្បីសម្រេចគោលបំណងនៃការបញ្ចប់វិវាទ វិសាលភាពចំពោះប្រធាន គប្បីពង្រីករហូតដល់បុគ្គលដែលមិនមែនជាភាគីនៃបណ្តឹង ដោយសារតែពួកគេទាំងនោះត្រូវបានសន្មតថាមានទំនាក់ទំនងផ្នែកផលប្រយោជន៍ចំពោះលទ្ធផលនៃសកម្មភាពបណ្តឹងរបស់ភាគី។ អាជ្ញាអស់ជំនុំសារធាតុមានចំណងចំពោះបុគ្គល ដែលបានកំណត់ដូចខាងក្រោមនេះ ៖

### **ក. ភាគី**

ភាគីគឺជាបុគ្គលដែលត្រូវបានកំណត់នៅក្នុងច្បាប់សារធាតុថាមានសិទ្ធិ និងកាតព្វកិច្ច ហើយក្នុងសាលក្រម តុលាការបានសម្រេចជាស្ថាពរនូវ សិទ្ធិ និងទំនាក់ទំនងគតិយុត្តជាកម្មវត្ថុនៃវិវាទនោះ។ ភាគីអាចជាដើមចោទ ឬ ចុងចម្លើយ។ នៅក្នុងសាលក្រម តុលាការត្រូវសរសេរអំពីសញ្ញាណនៃភាគីជាចាំបាច់[103]។ យើងអាចដឹងអំពីសញ្ញាណនៃភាគីដែលទទួលអានុភាពនៃសាលក្រម ឬសាលដីកាស្ថាពរដោយគ្រាន់តែពិនិត្យមើលក្នុងលិខិតសាលក្រម។

---

[101] មាត្រា ១៨៩ កថាខណ្ឌទី១ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[102] មាត្រា ៣០៧ កថាខណ្ឌទី១ ចំណុច ឈ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[103] មាត្រា ១៨៩ កថាខណ្ឌទី១ ចំណុច គ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

### ខ. តតិយជន

តតិយជនក្នុងន័យនេះសំដៅដល់បុគ្គលដែលមិនមែនជាភាគី ប៉ុន្តែ សិទ្ធិ និងទំនាក់ទំនងគតិយុត្តរបស់ពួកគេត្រូវបានសម្រេចដោយសាលក្រម ឬសាលដីកាស្ថាពរ។ ក្នុងករណីសហបណ្តឹង ច្បាប់បានអនុញ្ញាតឱ្យសហបណ្តឹង អាចជ្រើសរើសបុគ្គលម្នាក់ ឬច្រើននាក់ធ្វើជាភាគីនៃបណ្តឹង[104]។ ក្នុងករណីដែលបានជ្រើសរើសភាគី បុគ្គលផ្សេងទៀតដែលមិនត្រូវបានជ្រើសរើស ត្រូវដកខ្លួនចេញពីបណ្តឹងជាស្វ័យប្រវត្តិ[105] ហើយទទួលឋានៈជា **តតិយជន**។ តតិយជនសំដៅលើបុគ្គលប្រភេទនេះ។ សាលក្រមស្ថាពរ នឹងមានចំណងចំពោះតតិយជន ក្នុងករណីដែលភាគី ធ្វើជាដើមចោទ ឬចុងចម្លើយដើម្បីតតិយជននោះ[106]។

***<u>ឧទាហរណ៍</u>*** ៖ ក ខ និង គ គឺជាជនរងគ្រោះនៅក្នុងព្រឹត្តិការណ៍គ្រោះថ្នាក់ចរាចរណ៍ដែលបង្កដោយ អ។ ក ខ គ បានដាក់បណ្តឹងរួមគ្នាក្នុងនាមជាសហដើមចោទ ទាមទារសំណងការខូចខាតចំពោះ អំពើរបស់ អ។ ក និង ខ បានសម្រេចជ្រើសរើស គ ធ្វើជាភាគីតាមមាត្រា ៤២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ក្នុងករណីនេះ ក និង ខ ត្រូវក្លាយទៅជាតតិយជននៅក្នុងបណ្តឹងនេះ។ សាលក្រមចំពោះការទាមទារសំណងការខូចខាត នឹងមានចំណងចំពោះ ក ខ គ និង អ ទោះបីជា ក និង ខ ពុំមែនជាភាគីនៃបណ្តឹងក៏ដោយ។

### គ. បុគ្គលដែលទទួលបន្តនូវសិទ្ធិ ឬភាតព្វកិច្ចដែលជាកម្មវត្ថុនៃវិវាទ

បុគ្គលប្រភេទនេះ សំដៅលើបុគ្គលដែលបានទទួលបន្តនូវកម្មវត្ថុនៃវិវាទ ក្រោយពេលបណ្តឹងត្រូវបានចាត់ការ។ ជាគោលការណ៍ច្បាប់មិនបានហាមឃាត់ភាគីមិនឱ្យធ្វើការចាត់ចែងកម្មវត្ថុនៃវិវាទឡើយ ទោះបីជាបណ្តឹងកំពុងដំណើរការក៏ដោយ។ ចុងចម្លើយអាចធ្វើអនុប្បទាននូវវត្ថុ សិទ្ធិ ឬទំនាក់ទំនងគតិយុត្តនៅក្នុងដំណើរការនៃនីតិវិធីបាន[107]។ អនុប្បទាននេះ ពុំមានឥទ្ធិពលដល់ឋានៈជាភាគីនៃបណ្តឹងទេ។ ឧទាហរណ៍ ទោះបីជា កម្មសិទ្ធិលើអចលនវត្ថុមួយកន្លែងជាកម្មវត្ថុនៃវិវាទក៏ដោយ ក៏អនុប្បទាននៃកម្មសិទ្ធិលើអចលនវត្ថុនោះ ពុំបណ្តាលឱ្យចុងចម្លើយបាត់បង់លក្ខណសម្បត្តិជាភាគីដែរ[108]។

---

[104] មាត្រា ៤២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[105] មាត្រា ៤២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[106] មាត្រា ១៩៦ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[107] មាត្រា ៨៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[108] មាត្រា ៨៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

សាលក្រមស្ថាពរមានចំណងចំពោះអ្នកដែលទទួលបន្តនូវសិទ្ធិ ឬ កាតព្វកិច្ចពីបុគ្គលដែលជាភាគី មានន័យថា បុគ្គលនោះនឹងត្រូវចងដោយអានុភាពអាជ្ញាអស់ជំនុំ ហើយនៅពេលដែលម្ចាស់បំណុលបានដាក់ពាក្យសុំអនុវត្តដោយបង្ខំចំពោះបុគ្គលទាំងនោះ បុគ្គលទាំងនោះមិនអាចយកអនុប្បទានកម្មសិទ្ធិនោះមកតតាំងជាមួយនឹងម្ចាស់បំណុលបានឡើយ[109]។

បុគ្គលដែលបានកំណត់ខាងលើនេះ ពុំសំដៅដល់បុគ្គលដែលទទួលបន្តនូវឋានៈជាភាគីតាមមាត្រា ១៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីទេ (សន្តតិជន, នីតិបុគ្គលក្រោយការរួមបញ្ចូល ជាអាទិ៍) ព្រោះបុគ្គលទាំងនេះ នឹងទទួលបានឋានៈជាភាគីក្រោយពេលតុលាការចេញដីកាសម្រេចចំពោះពាក្យសុំបន្តនីតិវិធី[110]។ បុគ្គលប្រភេទនេះ ហៅថាភាគីដែលទទួលបន្តនីតិវិធី ពុំមែនជាបុគ្គលដែលទទួលបន្តនូវកម្មវត្ថុនៃបណ្តឹងឡើយ។

### ឃ. បុគ្គលដែលបានកាន់កាប់កម្មវត្ថុនៃវិវាទ

បុគ្គលដែលបានកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃវិវាទ ពុំមានទំនាក់ទំនងផលប្រយោជន៍នៃលទ្ធផលនៃបណ្តឹងឡើយ ដោយសារបុគ្គលនេះគ្រាន់តែជាអ្នកកាន់កាប់ដើម្បីប្រយោជន៍ភាគីណាម្នាក់តែប៉ុណ្ណោះ។ ការកំណត់ឱ្យបុគ្គលប្រភេទនេះទទួលវិសាលភាពនៃអាជ្ញាអស់ជំនុំសារធាតុ គឺនីតិនិពន្ធមានបំណងចង់ការពារម្ចាស់បំណុលពីការធ្វើបណ្តឹងទាមទារឱ្យប្រគល់ច្រើនដង។ ប្រសិនបើវាពុំមានអានុភាពចំពោះអ្នកកាន់កាប់កម្មវត្ថុទេ ទោះបីជាឈ្នះក្តីនៃបណ្តឹងទាមទារឱ្យប្រគល់ក៏ដោយ ក៏កម្មសិទ្ធិករ ឬអ្នកដែលមានសិទ្ធិនាំអោយមានមូលហេតុគតិយុត្ត ពុំអាចយកសាលក្រមទៅអនុវត្តដោយផ្ទាល់ ចំពោះបុគ្គលដែលបានកាន់កាប់កម្មវត្ថុនោះបានដែរ ពោលគឺតម្រូវអោយដាក់បណ្តឹងទាមទារឱ្យប្រគល់ចំពោះអ្នកកាន់កាប់កម្មវត្ថុនោះម្តងទៀត។ ជាលទ្ធផលដើមចោទ ត្រូវដាក់បណ្តឹងទាមទារមិនចេះចប់ ដូច្នេះវិវាទរវាងបុគ្គលឯកជន នៅតែបន្តមិនអាចដោះស្រាយបាន។

ដើម្បីឱ្យសាលក្រម ឬសាលដីកាស្ថាពរមានអានុភាពអាជ្ញាអស់ជំនុំចំពោះអ្នកកាន់កាប់កម្មវត្ថុនៃវិវាទ លុះត្រាតែការកាន់កាប់នោះ ធ្វើឡើងដើម្បីប្រយោជន៍ម្ចាស់សិទ្ធិ ពុំមែនជាការកាន់កាប់ដើម្បីប្រយោជន៍ខ្លួនឯងឡើយ។ ហេតុនេះវាពុំរាប់បញ្ចូលបុគ្គលដែលកាន់កាប់ដោយផ្អែកលើមូលហេតុគតិយុត្តនៃការកាន់កាប់ជាអាទិ៍ ភតិសន្យា ឬផលុបភោគ ឡើយ ព្រោះការកាន់កាប់របស់បុគ្គលទាំងនោះ គឺដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន។

---

[109] មាត្រា ៣៥១ កថាខណ្ឌទី១ ចំណុច គ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[110] មាត្រា ១៧៥ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី

### ខ. តតិយជនក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល

ក្រៅពីបុគ្គលដែលបានកំណត់ក្នុងមាត្រា ១៩៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី តតិយជននៃសាលក្រមឋានៈបុគ្គលក៏ទទួលអានុភាពអាជ្ញាអស់ជំនុំនៃសាលក្រម ឬសាលដីកាស្ថាពរដែរ[111]។ ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលគឺជាបទប្បញ្ញត្តិពិសេសនៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលវាជានីតិវិធីពិសេសចំពោះរឿងក្តីដែលបានកំណត់ជាក់លាក់នៅក្នុងមាត្រា ៣ នៃច្បាប់នេះ[112]។ សាលក្រមនៃបណ្តឹងដែលបានកំណត់ក្នុងមាត្រា ៣ គឺជាសាលក្រមឋានៈបុគ្គល ហើយលទ្ធផលនៃបណ្តឹងនេះ ពុំមែនគ្រាន់តែប៉ះពាល់ដល់ផលប្រយោជន៍ភាគីនៃវិវាទប៉ុណ្ណោះទេ ប៉ុន្តែវាប៉ះពាល់ដល់ ឋានៈនៃបុគ្គលផ្សេងទៀតនៃទំនាក់ទំនងឋានៈបុគ្គល និងផលប្រយោជន៍សាធារណៈផងដែរ។

***ឧទាហរណ៍*** ៖ តុលាការបានចេញសាលក្រមបង្គាប់ឱ្យ «ក» ជាឪពុក បង្ហាញឆន្ទៈទទួលស្គាល់កូន «ខ»។ សាលក្រមនេះ ធ្វើឱ្យ «ខ» មានឪពុកតាមផ្លូវច្បាប់ ហេតុនេះវាចង គ ដែលជាតតិយជននៃទំនាក់ទំនងឋានៈបុគ្គលរវាង ក និង ខ មិនឱ្យ «គ» ទទួលស្គាល់ «ខ» បានឡើយ[113] ដោយសារតែអានុភាពអាជ្ញាអស់ជំនុំនៃសាលក្រមស្ថាពរនៃបណ្តឹងទាមទារឱ្យទទួលស្គាល់ មានវិសាលភាពចំពោះតតិយជន។

ទន្ទឹមនឹងការពង្រីកវិសាលភាពនៃបុគ្គលដែលទទួលអានុភាពនៃសាលក្រមស្ថាពរ ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ក៏បានគិតគូរដល់ការការពារផលប្រយោជន៍ស្របច្បាប់របស់តតិយជននោះដែរ។ ការការពារផលប្រយោជន៍នេះស្តែងឡើងតាមរយៈ ការអនុញ្ញាតឱ្យតតិយជនចូលរួមជួយអន្តរាគមន៍ក្នុងបណ្តឹង ការកម្រិតនូវបុគ្គលដែលមានលក្ខណសម្បត្តិជាភាគីត្រឹមត្រូវតាមភាពជាក់ស្តែង និងសិទ្ធិនីតិវិធីរបស់ជននោះ ជាដើម[114]។

### ច. អ្នកចូលរួមជួយអន្តរាគមន៍

វិសាលភាពនៃអាជ្ញាអស់ជំនុំនៃសាលក្រមចំពោះអ្នកចូលរួមជួយអន្តរាគមន៍ពុំបានបញ្ញត្តក្នុងមាត្រា១៩៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីនោះទេ ប៉ុន្តែវាត្រូវបានបញ្ញត្តក្នុងមាត្រា ៩៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ សាលក្រមស្ថាពរមានចំណងរវាង អ្នកចូលរួមជួយអន្តរាគមន៍ និងអ្នកដែលត្រូវបានគេ

[111] មាត្រា ១៧ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល

[112] មាត្រា ១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល

[113] មាត្រា ៩៩៣ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី

[114] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី, *សេចក្តីកំណត់មាត្រានីមួយៗនៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល,* (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០១១), មាត្រា១៧

ជួយអន្តរាគមន៍ ទាល់តែសាលក្រមនោះជាសាលក្រមស្ថាពរដែលធ្វើឱ្យខូចប្រយោជន៍ដល់អ្នកដែលត្រូវបានគេចូលរួមអន្តរាគមន៍។ ទោះបីយ៉ាងនេះក្តី ប្រសិនបើមានស្ថានភាពដូចខាងក្រោមនេះ សាលក្រមស្ថាពរ ពុំមានអានុភាពអាជ្ញាអស់ជំនុំចំពោះអ្នកចូលរួមជួយអន្តរាគមន៍ឡើយ[115] ៖

- “បើអ្នកចូលរួមជួយអន្តរាគមន៍ មិនអាចធ្វើសកម្មភាពបណ្តឹង ដោយបញ្ញត្តិនៃវាក្យខណ្ឌទី២ កថាខណ្ឌទី១ មាត្រា ៩៦ (សកម្មភាពបណ្តឹងរបស់អ្នកចូលរួមជួយអន្តរាគមន៍)។
- បើសកម្មភាពបណ្តឹងរបស់អ្នកចូលរួមជួយអន្តរាគមន៍ គ្មានអានុភាព តាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា ៩៦ (សកម្មភាពបណ្តឹងនៃអ្នកចូលរួមអន្តរាគមន៍)។
- បើអ្នកត្រូវគេចូលរួមជួយអន្តរាគមន៍ បានរារាំងសកម្មភាពបណ្តឹងរបស់អ្នកចូលរួមជួយអន្តរាគមន៍។
- បើអ្នកត្រូវគេចូលរួមជួយអន្តរាគមន៍ មិនបានធ្វើសកម្មភាពបណ្តឹង ដែលអ្នកចូលរួមជួយអន្តរាគមន៍មិនអាចធ្វើបាន ដោយចេតនា ឬ ដោយកំហុសរបស់ខ្លួន។”

ស្ថានភាពខាងលើគឺជាការរារាំងសិទ្ធិនីតិវិធីរបស់អ្នកចូលរួមអន្តរាគមន៍ ហេតុនេះប្រសិនបើពុំមានវត្តមាននៃកាលៈទេសៈខាងលើនេះទេ អ្នកចូលរួមអន្តរាគមន៍ត្រូវទទួលអានុភាពអាជ្ញាអស់ជំនុំសារធាតុនៃសាលក្រមស្ថាពរដែលកំណត់ឱ្យអ្នកដែលត្រូវគេជួយអន្តរាគមន៍ខាតប្រយោជន៍ចំពោះទំនាក់ទំនងរវាងអ្នកដែលត្រូវបានគេជួយអន្តរាគមន៍។ វាស្របទៅនឹងទស្សនៈដែលបានរៀបរាប់នៅក្នុងចំណុច ១.៣.១.២ នៃជំពូកទី១ ខាងលើនេះដែលថា ឱកាសក្នុងការចូលរួមរបស់ភាគីគឺជាភាពចាំបាច់ដើម្បីឱ្យសេចក្តីសម្រេចដែលបានចេញ មានចំណាងចំពោះភាគីនោះ។

***<u>ឧទាហរណ៍</u> ៖*** នៅក្នុងបណ្តឹងមួយមានដើមចោទ «ក» ជាម្ចាស់បំណុល និងចុងចម្លើយ «ខ» ជាអ្នកធានាដោយបុគ្គល។ «គ» គឺជាកូនបំណុលបានចូលរួមជួយអន្តរាគមន៍ក្នុងបណ្តឹងនេះ។ ប្រសិនបើតុលាការចេញសាលក្រមបង្គាប់ឱ្យ «ខ» ជាអ្នកធានាដោយបុគ្គល សងសិទ្ធិលើបំណុលទៅ «ក» ហើយសាលក្រមបានចូលជាស្ថាពរ «គ» មានករណីយកិច្ចសងសិទ្ធិលើបំណុលដែល «ខ» បានសងទៅកាន់ «ក» (មាត្រា ៩១១ នៃក្រមរដ្ឋប្បវេណី) ហើយ «គ» ពុំអាចធ្វើវិវាទអំពីនត្ថិភាពនៃកាតព្វកិច្ចសងសិទ្ធិលើបំណុលចំពោះ «ខ» បានឡើយ ដោយសារតែ «ខ» បានបាត់បង់ផលប្រយោជន៍តាមរយៈសាលក្រមនៃបណ្តឹងដែល «គ» បានចូលរួមជួយអន្តរាគមន៍។

អានុភាពអាជ្ញាអស់ជំនុំនៃសាលក្រមដែលមានការចូលរួមអន្តរាគមន៍នេះ កើតមានតែចំពោះសាលក្រមដែលធ្វើឱ្យខូចប្រយោជន៍ដល់ភាគី ដែលត្រូវបានគេចូលរួមជួយអន្តរាគមន៍ប៉ុណ្ណោះ ពោលគឺសាលក្រមដែលកំណត់ថាអ្នកត្រូវបានគេជួយអន្តរាគមន៍ចាញ់ក្តី។ ចំពោះសាលក្រមដែល

[115] មាត្រា ៩៧ ចំណុច ក ដល់ ឃ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

មិនធ្វើឱ្យអ្នកត្រូវបានគេចូលរួមជួយអន្តរាគមន៍កើនប្រយោជន៍ វាពុំមានអាជ្ញាអស់ជំនុំសារធាតុ រវាងអ្នកចូលរួមអន្តរាគមន៍ និងអ្នកដែលត្រូវបានគេចូលរួមជួយអន្តរាគមន៍ឡើយ។

### ២.១.២ អាជ្ញាអស់ជំនុំជាលក្ខណៈទម្រង់

ជាគោលការណ៍សាលក្រមចុងក្រោយនៃតុលាការជាន់ទាប អាចនឹងត្រូវបានកែប្រែ ឬលុបចោលដោយសាលដីកានៃតុលាការជាន់ខ្ពស់តាមរយៈបណ្តឹងឧបាស្រ័យ។ បណ្តឹងឧបាស្រ័យមានគោលបំណង ឱ្យតុលាការជាន់ខ្ពស់វិនិច្ឆ័យឡើងវិញ អំពីចំណុចដែលបានសម្រេចនៅក្នុងសាលក្រម ឬសាលដីកាដែលជាកម្មវត្ថុនៃឧបាស្រ័យនោះ។ ឧបាស្រ័យគឺជាសិទ្ធិនីតិវិធីជាមូលដ្ឋាននៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ប៉ុន្តែសិទ្ធិនេះនឹងត្រូវរលត់ដោយសារតែភាពស្ថាពរនៃសេចក្តីសម្រេចដែលជាកម្មវត្ថុនៃឧបាស្រ័យនោះ[116]។ ប្រសិនបើសាលក្រម ឬសាលដីកា បានចូលជាស្ថាពរតាមបញ្ញត្តិច្បាប់ សាលក្រម ឬសាលដីកានោះ លែងជាកម្មវត្ថុនៃបណ្តឹងឧបាស្រ័យ ហើយវាចងតុលាការ និងអង្គវិនិច្ឆ័យផ្សេងទៀត មិនឱ្យជំនុំជម្រះចំពោះចំណុចដែលបានវិនិច្ឆ័យរួចនោះ។ អានុភាពនេះហៅថា «***អាជ្ញាអស់ជំនុំជាលក្ខណៈទម្រង់នៃសាលក្រមចុងក្រោយ***»។

អាជ្ញាអស់ជំនុំជាលក្ខណៈទម្រង់គឺជាល័ក្ខខ័ណ្ឌមូលដ្ឋាននៃការកើតមាន អាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ[117] អានុភាពអនុវត្ត[118] និងការបង្កើត ការផ្លាស់ប្តូរ ឬ រំលត់សិទ្ធិ ឬទំនាក់ទំនងគតិយុត្ត។

***<u>ឧទាហរណ៍</u>*** ***(១) ៖*** (អាជ្ញាអស់ជំនុំទម្រង់ជាល័ក្ខខ័ណ្ឌបង្កើតអានុភាពនៃអាជ្ញាអស់ជំនុំលក្ខណៈសារធាតុ) ប្រសិនបើសាលក្រម ឬសាលដីកា ដែលបានទាញហេតុផលលើអង្គសេចក្តីពុំទាន់ចូលជាស្ថាពរទេ ភាគីនៃបណ្តឹង ពុំទាន់ត្រូវបានហាមឃាត់មិនឱ្យធ្វើបណ្តឹងឧបាស្រ័យដើម្បីឱ្យតុលាការជាន់ខ្ពស់ លុបចោល ឬកែប្រែ សាលក្រម ឬសាលដីកា លើអង្គសេចក្តីដែលមិនទាន់ចូលជាស្ថាពរនោះឡើយ។

***<u>ឧទាហរណ៍</u>*** ***(២) ៖*** (អាជ្ញាអស់ជំនុំទម្រង់ជាល័ក្ខខ័ណ្ឌដើម្បីបង្កើតអានុភាពអនុវត្ត)[119] លើកលែងតែសាលក្រម ឬសាលដីកាចុងក្រោយបានភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះ

---

[116] មាត្រា ២៥៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[117] មាត្រា ១៩៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[118] មាត្រា ១៩៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[119] ក្រោយពេលសាលក្រម/សាលដីកាបង្កើតអានុភាពអាជ្ញាអស់ជំនុំ ភាគីឈ្នះក្តី អាចដាក់ពាក្យសុំរូបមន្តអនុវត្ត និងអាចយក សេចក្តីសម្រេចនោះ ទៅអនុវត្តដោយបង្ខំបាន (សូមមើលឧបសម្ព័ន្ធ៣)

អាសន្ន សាលក្រម ឬសាលដីកា ដែលមិនទាន់ចូលជាស្ថាពរ ពុំមានអានុភាពអនុវត្តឡើយ ព្រោះវាពុំមែនជាលិខិតអនុវត្តដែលបានកំណត់ក្នុងមាត្រា ៣៥០ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

***ឧទាហរណ៍ (៣) ៖*** (អាជ្ញាអស់ជំនុំជាលក្ខណៈទម្រង់ ជាល័ក្ខខ័ណ្ឌដើម្បីបង្កើត ផ្លាស់ប្តូរ ឬរំលត់សិទ្ធិ ឬទំនាក់ទំនងគតិយុត្ត) សាលក្រមស្តីពីការផ្តាច់សមគ្គសង្វាសតាមផ្លូវច្បាប់ មានកម្មវត្ថុចំបងជាការកាត់ផ្តាច់ទំនាក់ទំនងអាពាហ៍ពិពាហ៍ ដូច្នេះសេចក្តីសម្រេចអំពីការផ្តាច់សមគ្គសង្វាស គឺជាការរំលត់ទំនាក់ទំនងគតិយុត្ត។ ហេតុនេះទំនាក់ទំនងគតិយុត្តត្រូវរលត់នៅពេលដែលសាលក្រម ឬ សាលដីកាចុងក្រោយសម្រេចផ្តាច់សមគ្គសង្វាស បានចូលជាស្ថាពរ។

### ២.១.២.១ ពេលដែលបង្កើតអានុភាពអាជ្ញាអស់ជំនុំលក្ខណៈទម្រង់

ភាពស្ថាពរនៃសាលក្រមគឺជាពេលវេលាបង្កើតអានុភាពនៃអាជ្ញាអស់ជំនុំ[120]។ ទោះបីជាច្បាប់គោរពនូវសិទ្ធិឧបាស្រ័យច្រើនថ្នាក់ចំពោះសាលក្រមចុងក្រោយ ក៏វិវាទដែលជាកម្មវត្ថុនៃឧបាស្រ័យនោះត្រូវតែទៅដល់ទីបញ្ចប់មួយ ដែលហាមឃាត់ភាគីមិនឱ្យធ្វើវិវាទបន្តទៀតចំពោះចំណុចដែលមានអាជ្ញាអស់ជំនុំសារធាតុ។ យើងអាចកំណត់ភាពស្ថាពរនៃសាលក្រមតាមស្ថានភាពដូចខាងក្រោម ៖

#### ក. ការផុតអំឡុងពេលឧបាស្រ័យចំពោះសាលក្រម/សាលដីកាចុងក្រោយ

ប្រសិនបើពុំមានបណ្តឹងឧបាស្រ័យណាមួយ បានធ្វើចំពោះសាលក្រមដែលអាចប្តឹងឧបាស្រ័យបានក្នុងអំឡុងពេលដែលច្បាប់បានកំណត់ សាលក្រម/សាលដីកាចុងក្រោយនោះនឹងចូលជាស្ថាពរ ហើយអាជ្ញាអស់ជំនុំជាលក្ខណៈទម្រង់ នឹងកើតឡើង។ ជាគោលការណ៍អំឡុងពេលសម្រាប់ភាគីដើម្បីឧបាស្រ័យចំពោះសាលក្រម/សាលដីកាចុងក្រោយទៅតុលាការគឺ ១ខែ[121] រាប់គិតពីពេល ដែលបានទទួលការបញ្ជូនលិខិតសាលក្រម/សាលដីកា ឬ ពេលដែលបានជូនដំណឹងអំពីដីកាសម្រេចច្រានចោល ឬលើកចោលបណ្តឹងទាស់ចំពោះសាលក្រម/សាលដីកា កំបាំងមុខ។ ក្នុងករណីដែលតុលាការបានចេញដីកាសម្រេចច្រានចោល ឬលើកចោលពាក្យបណ្តឹងទាស់តាមមាត្រា ២០៧ កថាខណ្ឌទី២ ភាគីពុំអាចប្តឹងជំទាស់ចំពោះដីកាសម្រេចទាំងនោះបានទេ[122] ប៉ុន្តែភាគីនៅមានសិទ្ធិប្តឹងឧទ្ធរណ៍ចំពោះសាលក្រមកំបាំងមុខនោះបាន ហេតុនេះទើបមាត្រា ២៦៤ កំណត់យកអំឡុងពេលប្តឹងឧទ្ធរណ៍ ដោយរាប់គិតពីថ្ងៃដែលបានទទួលការជូនដំណឹងអំពីដីកាសម្រេចពីរខាងលើ។

[120] មាត្រា ១៩៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[121] មាត្រា ២៦៤ កថាខណ្ឌទី១ និង មាត្រា ២៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[122] មាត្រា ២៥៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

ក្នុងករណីដែលតុលាការបានចេញសាលក្រមកំបាំងមុខ ប្រសិនបើមានបណ្ដឹងទាស់ចំពោះសាលក្រមកំបាំងមុខ ហើយតុលាការយល់ឃើញថាបណ្ដឹងទាស់មានមូលហេតុត្រឹមត្រូវ តុលាការនឹងធ្វើការជំនុំជម្រះជាថ្មី ហើយចេញសាលក្រមថ្មី។ សាលក្រមថ្មីនេះមានលក្ខណៈដូចសាលក្រមលើអង្គសេចក្ដីខាងលើដែរ ដោយវាត្រូវបានចេញដោយផ្អែកលើការទាញហេតុផលលើអង្គសេចក្ដីជាថ្មី ដោយគោលការណ៍ចំពោះមុខ។ ហេតុនេះ អំឡុងពេលសម្រាប់ប្ដឹងឧបាស្រ័យដូចបានរៀបរាប់ខាងលើ ត្រូវយកមកអនុវត្តដូចគ្នាចំពោះសាលក្រមដែលបានចេញដោយផ្អែកលើការជំនុំជម្រះជាថ្មី តាមមាត្រា ២០៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ការគណនាអំឡុងពេលនៃឧបាស្រ័យ អនុវត្តដូចគ្នានឹងរបៀបនៃគណនាអំឡុងពេលតាមក្រមរដ្ឋប្បវេណី[123] ពោលគឺអំឡុងពេលត្រូវចាប់រាប់គិតនៅម៉ោងសូន្យនៃថ្ងៃបន្ទាប់ពីថ្ងៃបញ្ជូនសាលក្រម/សាលដីកា[124] ហើយអំឡុងពេលត្រូវផុតនៅពេលផុតថ្ងៃចុងក្រោយ ពោលគឺម៉ោងសូន្យបន្ទាប់ពីថ្ងៃចុងក្រោយ។

***ឧទាហរណ៍*** ៖ ប្រសិនបើតុលាការបានប្រកាសសាលក្រមចុងក្រោយនៅសវនាការជាសាធារណៈថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០១៧ ហើយបានបញ្ជូនសាលក្រមទៅដើមចោទនៅថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០១៧ អំឡុងពេលនៃសិទ្ធិប្ដឹងឧទ្ធរណ៍ចំពោះសាលក្រមចុងក្រោយនឹងចាប់រាប់ពីម៉ោងសូន្យថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០១៧ និងបញ្ចប់នៅម៉ោងសូន្យ ថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០១៧។

### ខ. ការដកពាក្យបណ្ដឹងឧបាស្រ័យ

ជាគោលការណ៍ការចូលជាស្ថាពរនៃសាលក្រមត្រូវរាប់គិតតាមអំឡុងពេលនៃឧបាស្រ័យ ប៉ុន្តែប្រសិនបើមានស្ថានភាពដែលភាគីអស់ផ្លូវក្នុងការឧបាស្រ័យ អំឡុងពេលដែលច្បាប់បានកំណត់សម្រាប់ឧបាស្រ័យនោះនឹងក្លាយទៅជាឥតន័យទៅវិញ។ ប្រសិនបើមានបណ្ដឹងឧទ្ធរណ៍ចំពោះសាលក្រមចុងក្រោយរបស់តុលាការនៃនីតិវិធីជំនុំជម្រះលើកទី១ ហើយក្រោយមកបណ្ដឹងនោះត្រូវបានដកវិញមុនពេលដែលតុលាការនៃបណ្ដឹងឧទ្ធរណ៍ចេញសាលដីកាចុងក្រោយ អានុភាពនៃការដកនោះត្រូវចាត់ទុកថាបណ្ដឹងឧទ្ធរណ៍ពុំត្រូវបានចាត់ការតាំងពីដំបូង ហើយភាគីដែលបានដកពាក្យបណ្ដឹងឧទ្ធរណ៍ត្រូវបានហាមឃាត់មិនឱ្យធ្វើបណ្ដឹងឧទ្ធរណ៍ដូចគ្នាម្ដងទៀតទេ[125] រួមទាំងបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំផងដែរ។ ដោយហេតុថាភាគីដែលបានដកពាក្យបណ្ដឹងត្រូវបានហាម

---

[123] មាត្រា ២៤៣ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[124] មាត្រា ៣៣៤ នៃក្រមរដ្ឋប្បវេណី

[125] មាត្រា ២១៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

ឃាត់មិនឱ្យធ្វើបណ្ដឹងឧទ្ធរណ៍ ផ្លូវឧបាស្រ័យស្នើសុំឱ្យ លុបចោល ឬកែប្រែសាលក្រមចុងក្រោយលែងមានទៀត ហេតុនេះការគោរពអំឡុងពេលចូលស្ថាពរក្លាយជាឥតបានការ។ ដូច្នេះប្រសិនបើពាក្យបណ្ដឹងឧទ្ធរណ៍ត្រូវបានដកវិញ សាលក្រមចុងក្រោយដែលជាកម្មវត្ថុនៃបណ្ដឹងឧទ្ធរណ៍នឹងចូលជាស្ថាពរនៅពេលជាមួយគ្នានៃការដកពាក្យបណ្ដឹងឧទ្ធរណ៍[126]។ អានុភាពនៃការដកពាក្យបណ្ដឹងឧទ្ធរណ៍ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះការដកពាក្យបណ្ដឹងសាទុក្ខ[127]។

### គ. ភាពស្ថាពរនៃសាលដីកាចំពោះបណ្ដឹងឧទ្ធរណ៍

បណ្ដឹងឧទ្ធរណ៍មានអានុភាពបង្អាក់ការចូលជាស្ថាពរនៃសាលក្រមដើម។ ជាគោលការណ៍ ប្រសិនបើមានបណ្ដឹងឧទ្ធរណ៍ ភាពស្ថាពរនៃសាលក្រមដើមអាស្រ័យលើភាពស្ថាពរនៃសាលដីការបស់តុលាការនៃបណ្ដឹងឧទ្ធរណ៍នោះ។ ប្រសិនបើមានបណ្ដឹងឧទ្ធរណ៍ត្រូវបានដាក់ប្រឆាំងនឹងសាលក្រមចុងក្រោយក្នុងគោលបំណងឱ្យសាលាឧទ្ធរណ៍ដែលជាសាលាជម្រះក្ដីលើកទី២ លុបចោល ឬកែប្រែសាលក្រមចុងក្រោយ ការសម្រេចចំពោះបណ្ដឹងឧទ្ធរណ៍នេះអាចមានរូបភាព៣ដូចខាងក្រោមនេះ។ ដោយហេតុថា សេចក្ដីសម្រេចរបស់តុលាការនៃបណ្ដឹងឧទ្ធរណ៍មានច្រើនប្រភេទ ហើយមានសេចក្ដីសម្រេចមួយចំនួន ទោះបីជាចូលជាស្ថាពរ ក៏មិនបណ្ដាលឱ្យសាលក្រមនៃនីតិវិធីជំនុំជម្រះលើកទី១ចូលជាស្ថាពរដែរ ហេតុនេះយើងនឹងសិក្សាពីប្រភេទនីមួយៗនៃសាលដីការបស់តុលាការនៃបណ្ដឹងឧបាស្រ័យ។

**ដីកាសម្រេចលើកចោល (មាត្រា ២៦៦) ៖** ដីកាសម្រេចលើកចោលត្រូវចេញ ក្នុងករណីដែលដើមបណ្ដឹងឧទ្ធរណ៍ខកខាន មិនបានកែតម្រូវពាក្យបណ្ដឹងឧទ្ធរណ៍ ដែលខុសលក្ខខ័ណ្ឌទម្រង់ (មាត្រា ២៦៥ កថាខណ្ឌទី២) ឬ មិនបានបង់ពន្ធតាមមាត្រា ៦១ កថាខណ្ឌទី៣ ក្នុងអំឡុងពេលដែលតុលាការចេញដីកាបង្គាប់ឱ្យកែតម្រូវ។ ដីកាសម្រេចនេះអាចប្ដឹងជំទាស់បាន ហេតុនេះប្រសិនបើដីកាសម្រេចប្រភេទនេះ ចូលជាស្ថាពរដោយដើមបណ្ដឹងឧទ្ធរណ៍មិនបានធ្វើបណ្ដឹងជំទាស់ មុនពេលផុតអំឡុងពេលឧបាស្រ័យចំពោះសាលក្រមដើម ភាពស្ថាពររបស់វាមិនបណ្ដាលឱ្យសាលក្រមដើមចូលជាស្ថាពរទេ ដោយសារដើមបណ្ដឹងឧទ្ធរណ៍នៅមានសិទ្ធិក្នុងការដាក់ពាក្យបណ្ដឹងឧទ្ធរណ៍សាជាថ្មីម្ដងទៀត។ ប៉ុន្តែប្រសិនបើវាត្រូវបានចូលជាស្ថាពរក្រោយអំឡុងពេលឧបាស្រ័យដែលកំណត់ដោយច្បាប់ សាលក្រមចុងក្រោយនឹងចូលជាស្ថាពរនៅពេលដែលដីកាសម្រេចលើកចោល

---

126 ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្ដីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១: នីតិវិធីបណ្ដឹង*, (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០០៨), ទំព័រ ១៥៨

127 មាត្រា ២៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ការយកមកអនុវត្តដូចគ្នានៃមាត្រា ២៦៩

នោះចូលជាស្ថាពរ ព្រោះដើមបណ្តឹងឧទ្ធរណ៍ផុតអំឡុងពេលនៅក្នុងការដាក់ពាក្យបណ្តឹងឧទ្ធរណ៍សាជាថ្មីទៀតហើយ។

**សាលដីកាលើកចោលពាក្យបណ្តឹងឧទ្ធរណ៍ (មាត្រា២៦៨) ៖** ប្រសិនបើកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍មានលក្ខណៈផ្ទុយច្បាប់ ហើយចំណុចខ្វះខាតនោះមិនអាចកែតម្រូវបានទេ តុលាការអាចចេញសាលដីកាលើកចោលបណ្តឹងឧទ្ធរណ៍ ដោយមិនចាំបាច់ទាញហេតុផលដោយផ្ទាល់មាត់។ មូលហេតុផ្ទុយច្បាប់នេះ សំដៅលើផលប្រយោជន៍នៃបណ្តឹង។ ក្នុងករណីដែលភាគីឈ្នះក្តីទាំងស្រុងនៅក្នុងនីតិវិធីជំនុំជម្រះលើកទី១ វាគ្មានផលប្រយោជន៍អ្វីដែលភាគីត្រូវប្តឹងឧទ្ធរណ៍ចំពោះសាលក្រមឈ្នះក្តីរបស់ខ្លួនឡើយ ហេតុនេះបណ្តឹងឧទ្ធរណ៍ប្រភេទនេះចាត់ទុកថាផ្ទុយផលប្រយោជន៍នៃបណ្តឹង តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវលើកចោលដោយសាលដីកា[128]។ ដោយសារតែសាលដីកាលើកចោលជាប្រភេទមួយនៃសាលដីកាចុងក្រោយ ហេតុនេះបណ្តឹងសាទុក្ខអាចធ្វើចំពោះសាលដីកាប្រភេទនេះបាន។ ប្រសិនបើផុតអំឡុងពេលសម្រាប់ធ្វើបណ្តឹងសាទុក្ខ នាំឱ្យសាលដីកាលើកចោលបណ្តឹងឧទ្ធរណ៍ចូលជាស្ថាពរ ហេតុនេះសាលក្រមចុងក្រោយ ត្រូវចូលជាស្ថាពរ នៅពេលដែលផុតអំឡុងពេលឧបាស្រ័យនៃសាលដីកាលើកចោល។

**សាលដីកាលុបចោលសាលក្រមដើមហើយវិនិច្ឆ័យឡើងវិញ (មាត្រា២៧៩)** ៖ ប្រសិនបើឆ្លងកាត់ការទាញហេតុផលដែលត្រូវបានបើកឡើងវិញដោយបណ្តឹងឧទ្ធរណ៍ស្របច្បាប់[129] ហើយតុលាការនៃបណ្តឹងឧទ្ធរណ៍យល់ឃើញថា សាលក្រមដើមមានភាពផ្ទុយច្បាប់ ឬ ខុសនីតិវិធីធ្ងន់ធ្ងរ តុលាការត្រូវចេញសាលដីកាដែលមានខ្លឹមសារថា (១) លុបចោលសាលក្រមដើម, (២) សម្រេច..... ឬ កែប្រែសាលក្រមដើម.....។ សាលដីកាប្រភេទនេះគឺជាសាលដីកាសម្រេចលើអង្គសេចក្តីដែលកែប្រែសាលក្រមដើម ហេតុនេះ សាលក្រមដើមត្រូវបាត់បង់អានុភាពនៅពេលដែលសាលដីកាលុបចោលហើយវិនិច្ឆ័យឡើងវិញ បានចូលជាស្ថាពរ។ ដូច្នេះ សាលក្រមដើមពុំចូលជាស្ថាពរ នៅពេលដែលសាលដីកានេះចូលជាស្ថាពរទេ ផ្ទុយទៅវិញ វាបានបាត់បង់អានុភាពនៅពេលដែលសាលដីកានោះចូលជាស្ថាពរ។ អានុភាពអាជ្ញាអស់ជំនុំចំពោះសាលក្រមដើមត្រូវរលត់ ហើយអានុភាពអាជ្ញាអស់ជំនុំនៃសាលដីកាចុងក្រោយរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវបង្កើតអានុភាព។

---

[128] មាត្រា ២៦៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[129] គោលការណ៍នៃការជំនុំជម្រះបន្ត (Resumed Trial)

**សាលដីកាលុបចោលសាលក្រមដើមហើយបញ្ជូនរឿងក្តីត្រឡប់ទៅវិញ (មាត្រា២៨០) ៖** ក្នុងករណីដែលមានបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមលើកចោលបណ្តឹងដោយមូលហេតុផ្ទុយច្បាប់ ប្រសិនបើតុលាការនៃបណ្តឹងឧទ្ធរណ៍យល់ឃើញថាសាលក្រមលើកចោលនោះ ពុំត្រឹមត្រូវទេ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវចេញសាលដីកាលុបចោលសាលក្រមលើកចោលបណ្តឹងនោះ ហើយបញ្ជូនរឿងក្តីឱ្យសាលាដំបូងធ្វើការជំនុំជម្រះឡើងវិញ[130]។ ក្នុងករណីដែលតុលាការនៃបណ្តឹងឧទ្ធរណ៍យល់ឃើញថាចាំបាច់ត្រូវទាញហេតុផលផ្ទាល់មាត់បន្ថែមទៀត ក៏អាចចេញសាលដីកាខាងលើនេះបានដែរ[131]។ នៅពេលដែលសាលដីការបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ដែលបានលុបចោលសាលក្រមដើម ហើយបញ្ជូនឱ្យជំនុំជម្រះឡើងវិញ បានចូលជាស្ថាពរ សាលក្រមដើមត្រូវបាត់បង់អានុភាពដោយការលុបចោលនោះ ហើយ**អាជ្ញាអស់ជំនុំក៏រលត់តាមនេះដែរ**។

តាមរយៈការបកស្រាយខាងលើ មានតែ **សាលដីកាស្ថាពររបស់សាលាឧទ្ធរណ៍ដែលច្រានចោលបណ្តឹងឧទ្ធរណ៍** ទេទើបបង្កើតអានុភាពអាជ្ញាអស់ជំនុំនៃសាលក្រមចុងក្រោយរបស់តុលាការនៃនីតិវិធីជំនុំជម្រះលើកទី១។

នៅក្នុងសាលដីកាលេខ ៨២ “ក្រVIញ” របស់សាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៦ ខែ សីហា ឆ្នាំ២០១២ តុលាការបានច្រានចោលពាក្យបណ្តឹងរបស់ដើមបណ្តឹងឧទ្ធរណ៍ (ចុងចម្លើយ) ហើយសាលដីកានេះបានចូលជាស្ថាពរ។ ភាពស្ថាពរនៃសាលដីកានេះ បានធ្វើឱ្យសេចក្តីសម្រេចបញ្ចប់ក្នុងសាលក្រមលេខ១៩៤ របស់សាលាដំបូងរាជធានីភ្នំពេញចុះថ្ងៃទី ២០.២០.២០១១ ចូលជាស្ថាពរ ហេតុនេះវាបង្កើតឱ្យមាននូវអាជ្ញាអស់ជំនុំលក្ខណៈទម្រង់។ ចុងបណ្តឹងឧទ្ធរណ៍នៅក្នុងសំណុំរឿងនេះក៏បានដាក់ពាក្យសុំរូបមន្តអនុវត្ត ដើម្បីអនុវត្តដោយបង្ខំផ្អែកលើសាលដីកាស្ថាពររបស់សាលាឧទ្ធរណ៍ដែលមានអាជ្ញាអស់ជំនុំទម្រង់នោះផងដែរ[132]។

### ឃ. សាលដីកាតុលាការកំពូល

សាលដីកាតុលាការកំពូលគឺជាសេចក្តីសម្រេចលើបណ្តឹងសាទុក្ខ ដែលបានធ្វើចំពោះសាលក្រមនៃតុលាការនៃនីតិវិធីជំនុំជម្រះលើកទី១ ឬ សាលដីការបស់តុលាការនៃបណ្តឹងឧទ្ធរណ៍។ ដោយសារតែតុលាការកំពូលគឺជាសាលាជម្រះក្តីថ្នាក់ចុងក្រោយ ហេតុនេះសេចក្តីសម្រេចរបស់

---

[130] មាត្រា ២៨០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[131] មាត្រា ២៨០ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[132] រូបមន្តអនុវត្តសាលាឧទ្ធរណ៍លេខ ២២ រមអវ/វវ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ ដោយក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ (សូមមើលឧបសម្ព័ន្ធ៣)

តុលាការកំពូលមានភាពស្ថាពរ ដោយមិនរង់ចាំការផុតអំឡុងពេលនៃឧបាស្រ័យស្របច្បាប់ណាមួយឡើយ[133]។ ប្រហាក់ប្រហែលនឹងនីតិវិធីនៃការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ដែរ ដើម្បីបញ្ចប់បណ្តឹងតុលាការកំពូលអាចចេញសេចក្តីសម្រេចក្រោមរូបភាពជា ដីកាសម្រេចលើកចោលបណ្តឹងសាទុក្ខ, សាលដីកាលើកចោលបណ្តឹងសាទុក្ខ, សាលដីកាច្រានចោលបណ្តឹងសាទុក្ខ ហើយបញ្ជូនត្រលប់, និង សាលដីកាច្រានចោលបណ្តឹងសាទុក្ខ ហើយវិនិច្ឆ័យដោយខ្លួនឯង។ សេចក្តីសម្រេចរបស់តុលាការកំពូលខាងលើនេះ ត្រូវចូលជាស្ថាពរភ្លាមៗនៅពេលដែលវាត្រូវបានប្រកាស។

ប៉ុន្តែភាពស្ថាពរនៃសេចក្តីសម្រេចមួយចំនួនរបស់តុលាការកំពូលពុំបណ្តាលឱ្យសាលក្រម ឬ សាលដីកាដែលជាកម្មវត្ថុនៃបណ្តឹងសាទុក្ខ ចូលជាស្ថាពរទេ ពោលគឺមានតែសាលដីកាស្ថាពរដែលសម្រេចច្រានចោលបណ្តឹងសាទុក្ខតែប៉ុណ្ណោះ ដែលធ្វើឱ្យសាលក្រម ឬ សាលដីកាដែលជាកម្មវត្ថុនៃបណ្តឹងសាទុក្ខ ចូលជាស្ថាពរ។

### ២.១.២.២ អញ្ញត្រកម្មចំពោះគោលការណ៍ភាពស្ថាពរនៃសាលក្រម/សាលដីកា

ដើម្បីធានានូវគោលបំណងនៃការបញ្ចប់វិវាទជាស្ថាពរ នីតិវិធីជំនុំជម្រះត្រូវការទីបញ្ចប់មួយ ពោលគឺត្រូវការសេចក្តីសម្រេចជាស្ថាពរដែលបិទផ្លូវតវ៉ា ប៉ុន្តែប្រសិនបើសេចក្តីសម្រេចនោះត្រូវបានចេញដោយផ្អែកលើកំហុសធ្ងន់ធ្ងរ សេចក្តីសម្រេចនោះត្រូវតែអាចសើរើឡើងវិញបាន។ ដូច្នេះ ទោះបីជាសាលក្រម ឬសាលដីកាដែលបានចូលស្ថាពរ មានអានុភាពអាជ្ញាអស់ជំនុំទម្រង់ក៏ដោយ ក៏អានុភាពនេះត្រូវបានបាត់បង់ដោយការលុបចោលសាលក្រម ឬសាលដីកា ដែលបានចូលជាស្ថាពរនោះដែរ តាមរយៈ **នីតិវិធីជំនុំជម្រះសាជាថ្មី**។

ជាគោលការណ៍ កាលបើសាលក្រម ឬ សាលដីកា បានចូលជាស្ថាពរតាមច្បាប់ហើយ សាលក្រម ឬសាលដីកានោះលែងជាកម្មវត្ថុនៃឧបាស្រ័យណាមួយហើយ។ ប៉ុន្តែជាអញ្ញត្រកម្ម ប្រសិនបើល័ក្ខខ័ណ្ឌត្រូវបានបំពេញ ភាគីនៃសាលក្រមស្ថាពរ អាចដាក់ពាក្យបណ្តឹងទាមទារជំនុំជម្រះសាជាថ្មីបាន។ អ្នកច្បាប់មួយចំនួនហៅបណ្តឹងនេះថាជា **«ឧបាស្រ័យពិសេស»** ដោយសារតែវាធ្វើឡើងចំពោះសាលក្រម ឬសាលដីកាដែលបានចូលជាស្ថាពររួចហើយ[134]។

ទន្ទឹមនឹងនេះ ប្រសិនបើអនុញ្ញាតឱ្យឧបាស្រ័យបែបនេះ អាចធ្វើបានដោយគ្មានល័ក្ខខ័ណ្ឌរឹតត្បិតតឹងរ៉ឹង វាអាចបណ្តាលឱ្យ ប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ភាគី បាត់បង់នូវតម្លៃនៃអាជ្ញាអស់ជំនុំ ក៏ដូចជាកិត្យានុភាពនៃស្ថាប័នយុត្តាធិការ ហេតុនេះបណ្តឹងទាមទារឱ្យជំនុំជម្រះសាជា

---

[133] ការបកស្រាយច្រាសនៃមាត្រា ១៩៣ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[134] មេធាវី អ៊ីវ ប៉ូលី, *កម្រងមេរៀនឆ្នាំ២០១៥ : នីតិវិធីនៃការជំនុំជម្រះសាជាថ្មី*, (ភ្នំពេញ ៖ វិភាគទានច្បាប់, ២០១៦), ៦៧

ថ្មីត្រូវផ្អែកលើមូលហេតុដែលតឹងរ៉ឹង ហើយភាគច្រើននៃមូលហេតុទាំងនោះ គឺការផ្ទុយច្បាប់យ៉ាងធ្ងន់ធ្ងរ[135]។

### គ. ការបើកឡើងវិញនូវការវិនិច្ឆ័យនៃសាលក្រម ឬសាលដីកាស្ថាពរ

ប្រសិនបើពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីត្រូវបានដាក់ប្រឆាំងនឹងសាលក្រម ឬសាលដីកាស្ថាពរ តុលាការត្រូវពិនិត្យមើលលើទម្រង់នៃពាក្យបណ្ដឹង[136] អំឡុងពេលនៃការធ្វើបណ្ដឹង[137] និងមូលហេតុនៃបណ្ដឹង[138] ។ ប្រសិនបើយល់ឃើញថាមានភាពត្រឹមត្រូវចំពោះចំណុចទាំងអស់នោះ តុលាការនឹងចេញដីកាសម្រេចចាប់ផ្ដើមជំនុំជម្រះសាជាថ្មី។ ផ្ទុយមកវិញ ប្រសិនបើពុំបានបំពេញគ្រប់ល័ក្ខខ័ណ្ឌនៃបណ្ដឹង តុលាការត្រូវចេញដីកាសម្រេចច្រានចោលពាក្យសុំ[139]។

នៅពេលដែលដីកាសម្រេចចាប់ផ្ដើមជំនុំជម្រះសាជាថ្មីបានចូលជាស្ថាពរ តុលាការត្រូវបើកការវិនិច្ឆ័យ និងសម្រេចលើអង្គសេចក្ដីតាមទំហំដែលបានឧបាស្រ័យ។ ដោយសារការយកមកអនុវត្តដូចគ្នានៃនីតិវិធីជំនុំជម្រះសាជាថ្មី[140] ហេតុនេះរាល់សកម្មភាពបណ្ដឹងដែលភាគីបានធ្វើនៅក្នុងនីតិវិធីមុនៗ មានអានុភាពនៅក្នុងនីតិវិធីនៃការជំនុំជម្រះសាជាថ្មី[141]។

ក្រោយពេលបញ្ចប់ការទាញហេតុផលចំពោះបណ្ដឹង ទោះបីជាមានមូលហេតុនៃការជំនុំជម្រះសាជាថ្មីក៏ដោយ ប្រសិនបើតុលាការបានវិនិច្ឆ័យលើអង្គសេចក្ដី ហើយយល់ឃើញថាសាលក្រម ឬសាលដីកា ដែលជាកម្មវត្ថុនៃការជំនុំជម្រះសាជាថ្មី ត្រឹមត្រូវ តុលាការត្រូវច្រានចោលការទាមទារដោយចេញសាលក្រម ឬសាលដីកា[142] ។ ផ្ទុយទៅវិញប្រសិនបើតុលាការនៃនីតិវិធីជំនុំជម្រះសាជាថ្មី យល់ឃើញថា សាលក្រម ឬ សាលដីកា ដើម ពុំមានភាពត្រឹមត្រូវទេ តុលាការត្រូវចេញសាលក្រម ឬ សាលដីកា លុបចោល សាលក្រម ឬ សាលដីកា ដើម និងសម្រេចឡើងវិញក្នុងកម្រិតនៃទំហំដែលបានឧបាស្រ័យ[143]។

---

[135] មាត្រា ៣០៧ កថាខណ្ឌទី១ និងមាត្រា ៣០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[136] មាត្រា ៣១០ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[137] មាត្រា ៣១១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[138] មាត្រា ៣១៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[139] សាលាឧទ្ធរណ៍, សំណុំរឿងជំនុំជម្រះសាជាថ្មី លេខ៖ ១៩ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥, ដីកាសម្រេចលេខ៖ ១៦ "ក្រVIIង" ដកស ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ (សូមមើលឧបសម្ព័ន្ធ៨)

[140] មាត្រា ៣១០ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[141] មាត្រា ២៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[142] មាត្រា ៣១៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[143] មាត្រា ៣១៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

### ខ. អានុភាពនៃសាលក្រម ឬសាលដីកា ផ្អែកលើនីតិវិធីជំនុំជម្រះសាជាថ្មី

សាលក្រម ឬ សាលដីកា ដែលបានចេញដោយផ្អែកលើនីតិវិធីជំនុំជម្រះសាជាថ្មី អាចប្តឹងឧបាស្រ័យបាន[144],[145]។ ហេតុនេះប្រសិនបើផុតអំឡុងពេលនៃឧបាស្រ័យដែលបានកំណត់ខាងដើមនេះ សាលក្រម ឬ សាលដីកា ផ្អែកលើនីតិវិធីជំនុំជម្រះសាជាថ្មីនោះ ត្រូវចូលជាស្ថាពរ។ ដូចបានបកស្រាយក្នុងចំណុច ក ខាងលើ តុលាការនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី អាចចេញសាលក្រម ឬសាលដីកាលើអង្គសេចក្តី ដោយ (១) *ច្រានចោលការទាមទារ ឬ (២) លុបចោលសាលក្រម ឬ សាលដីកា ដើម ហើយសម្រេចឡើងវិញចំពោះទំហំដែលបានឧបាស្រ័យ* ហេតុនេះ អានុភាពនៃសាលក្រម ឬ សាលដីកា ស្ថាពរទាំងអស់នោះមានភាពខុសគ្នា។

**សាលក្រម ឬសាលដីកា ច្រានចោលការទាមទារ ផ្អែកលើការជំនុំជម្រះសាជាថ្មី** ពុំមានឥទ្ធិពលទៅលើភាពស្ថាពរ និង អាជ្ញាអស់ជំនុំនៃសាលក្រម ឬសាលដីកាស្ថាពរដែលជាកម្មវត្ថុនៃការជំនុំជម្រះសាជាថ្មីនោះឡើយ។ ប្រសិនបើតុលាការច្រានចោលការទាមទារ បានសេចក្តីថាតុលាការយល់ឃើញថាសាលក្រម ឬសាលដីកាដើម ទោះបីជាមានមូលហេតុនៃការជំនុំជម្រះសាជាថ្មីក៏ដោយ ក៏ការវិនិច្ឆ័យនៅក្នុងសាលក្រម ឬ សាលដីកាដើមនោះមានភាពត្រឹមត្រូវដែរ[146] ហើយខ្លឹមសារនៃសាលក្រម ឬ សាលដីកាដើម ពុំត្រូវបានកែប្រែដោយសាលក្រម ឬ សាលដីកា ច្រានចោលការទាមទារនេះឡើយ។

**សាលក្រម ឬ សាលដីកា លុបចោលសាលក្រម ឬ សាលដីកាដើម** មានឥទ្ធិពលចំពោះ សាលក្រម ឬ សាលដីកាស្ថាពរដើម ដូចខាងក្រោម ៖

- លុបចោល សាលក្រម ឬសាលដីកាស្ថាពរដើម ៖ អានុភាពនេះធ្វើឱ្យសេចក្តីសម្រេចអំពីសិទ្ធិ ឬទំនាក់ទំនងដែលត្រូវបានសម្រេចដោយសាលក្រម ឬ សាលដីកាស្ថាពរដើម បាត់បង់អានុភាព។
- រំលត់អានុភាពអាជ្ញាអស់ជំនុំ ៖ ដោយសារតែសាលក្រម ឬសាលដីកាស្ថាពរដើម ត្រូវបានមោឃៈដោយអានុភាពស្ថាពរនៃសាលក្រម ឬ សាលដីកាជំនុំជម្រះសាជាថ្មី អានុភាពអាជ្ញាអស់ជំនុំដែលបង្កើតឡើងដោយសាលក្រម ឬ សាលដីកាស្ថាពរដើម

---

[144] មាត្រា ៣១០ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា «ការយកមកអនុវត្តដូចគ្នាចំពោះនីតិវិធីបណ្តឹងនៃការជំនុំជម្រះសាជាថ្មី»

[145] Prof Higashio Kazuyuki, Prof Yukawa Ryo, Prof Uchiyama Jun, *បញ្ហានានាដែលមាននៅក្នុងរឿងក្តីរដ្ឋប្បវេណី*, (ភ្នំពេញ ៖ក្រសួងយុត្តិធម៌ និង វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ, ២០១៧), ៧១

[146] មាត្រា ៣១៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

នោះ ត្រូវរលត់។ ហេតុនេះវាពុំមានអានុភាពហាមឃាត់តុលាការនៃនីតិវិធីក្រោយ រួមទាំងតុលាការនៃនីតិវិធីជំនុំជម្រះសាជាថ្មីផង មិនឱ្យសម្រេចផ្ទុយពីសាលក្រម ឬសាលដីកានោះឡើយ។

- សម្រេចឡើងវិញត្រឹមទំហំដែលបានឧបាស្រ័យ ៖ បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីមានកម្មវត្ថុភ្លោះ គឺការទាមទារឱ្យលុបចោលសាលក្រម ឬសាលដីកាស្ថាពរដោយយកមូលហេតុថាវាត្រូវបានចេញដោយខុសច្បាប់ ព្រមទាំងឱ្យតុលាការនៃបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី សម្រេចឡើងវិញនូវការទាមទាររបស់ដើមចោទ ឬបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបន្ទាប់បន្សំរបស់ចុងចម្លើយ[147]។
- លុបចោលការអនុវត្តដោយបង្ខំ ៖ សាលក្រម ឬ សាលដីកា លុបចោល សាលក្រម ឬ សាលដីកាដើម មានមុខងារជា *សេចក្តីសម្រេចលុបចោលលិខិតអនុវត្ត*[148]។ ហេតុនេះប្រសិនបើភាគីដែលខូចប្រយោជន៍ដោយសារការអនុវត្តដោយបង្ខំ បានដាក់ឯកសារចម្លងយថាភូតនៃសាលក្រម ឬ សាលដីកា លុបចោលលិខិតអនុវត្ត ការអនុវត្តដោយបង្ខំ ត្រូវបានលុបចោល ហើយការចាត់ចែងដែលបានធ្វើក៏ត្រូវលុបចោលផងដែរ។

ទោះបីជាតុលាការអនុវត្តទទួលស្គាល់នូវពាក្យសុំផ្អាកការអនុវត្តដោយបង្ខំ ផ្អែកលើការដាក់ពាក្យបណ្តឹងឱ្យធ្វើការជំនុំជម្រះសាជាថ្មី តាមមាត្រា ៣៦៦ កថាខណ្ឌទី១ ចំណុច ក ក៏ដោយ ក៏ដីកាសម្រេចផ្អាកនេះ **ពុំមានឥទ្ធិពលលើអានុភាពអាជ្ញាអស់ជំនុំឡើយ**។ វាគ្រាន់តែជាអានុភាពផ្អាកការអនុវត្តលិខិតអនុវត្តដែលអាចត្រូវបានលុបចោលផ្អែកលើសាលក្រម ឬ សាលដីកានៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនៅពេលខាងមុខ ប៉ុណ្ណោះ។

## ២.២ អានុភាពអាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីផ្សេងទៀត

ដូចបានបកស្រាយនៅក្នុងផ្នែក **១.២.២ (ប្រភេទនៃសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីដែលមានអានុភាពអាជ្ញាអស់ជំនុំ)** ខាងលើនេះ ក្រៅពីសាលក្រម និងសាលដីកាចុងក្រោយ របបគតិយុត្តនៃអាជ្ញាអស់ជំនុំក៏ត្រូវយកមកអនុវត្ត ចំពោះសេចក្តីសម្រេចរបស់តុលាការរដ្ឋប្បវេណីផ្សេងទៀតផងដែរ។ ការបកស្រាយអំពីអានុភាពអាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីផ្សេងពីសាលក្រម

---

[147] មេធាវី អ៊ីវ ប៉ូលី, *កម្រងមេរៀនឆ្នាំ២០១៥ : នីតិវិធីនៃការជំនុំជម្រះសាជាថ្មី*, (ភ្នំពេញ ៖ វិភាគទានច្បាប់, ២០១៦), ៧៦

[148] មាត្រា ៣៧០ កថាខណ្ឌទី១ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

ឬ សាលដីកា ទាមទារឱ្យយើងធ្វើការស្វែងយល់អំពី វិសាលភាព អត្ថន័យ និងអានុភាព នៃបទប្បញ្ញត្តិដែលយកមកអនុវត្តដូចគ្នា។ បន្ថែមពីបទប្បញ្ញត្តិដែលយកមកអនុវត្តដូចគ្នា យើងក៏ឃើញមានបទប្បញ្ញត្តិដែលចែងអំពី អានុភាពដូចសាលក្រមស្ថាពរ[149]។ តើការចែងបែបនេះធ្វើឱ្យយើងអាចបកស្រាយថា សេចក្តីសម្រេចនោះមានអានុភាពអាជ្ញាអស់ជំនុំដូចសាលក្រមស្ថាពរដែរឬក៏យ៉ាងណា? ហើយសេចក្តីសម្រេចនោះមានលក្ខណៈអាជ្ញាអស់ជំនុំយ៉ាងដូចម្តេច? ហើយផ្នែកណាមួយនៃសេចក្តីសម្រេចនោះមានអាជ្ញាអស់ជំនុំ?

សេចក្តីសម្រេចផ្នែករដ្ឋប្បវេណីនៅក្នុងផ្នែកនេះ ក៏សំដៅទៅលើសេចក្តីសម្រេចដែលចេញដោយអង្គវិនិច្ឆ័យផ្សេងក្រៅពីតុលាការ ជាអាទិ៍ មជ្ឈត្តវិនិច្ឆ័យ ដែលចេញដោយមជ្ឈត្តការពាណិជ្ជកម្ម និងសេចក្តីបង្គាប់អាជ្ញាកណ្តាលដែលចេញដោយក្រុមប្រឹក្សាអាជ្ញាកណ្តាលដែរ។ មូលហេតុដែល កំណត់ថាពួកវាគឺជាសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី ក៏ព្រោះតែវាគឺជាសេចក្តីសម្រេចក្នុងវង្វង់វិវាទបុគ្គលឯកជន ហើយមានទំនោរទៅរកការការពារសិទ្ធិរបស់បុគ្គលឯកជន ព្រមទាំងស្ថិតនៅក្នុងចង្កោមនៃនីតិឯកជនផងដែរ។ ម្យ៉ាងវិញទៀត វាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធដល់ការយកមកអនុវត្តនូវបញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី។ តាមរយៈច្បាប់ស្តីពីការរៀបចំអង្គការតុលាការ នៅពេលមិនទាន់មានបទប្បញ្ញត្តិស្តីពីនីតិវិធីពាណិជ្ជកម្ម និងការងារ ការជំនុំជម្រះរឿងក្តីទាំងនោះ ត្រូវអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី និងបទប្បញ្ញត្តិច្បាប់ផ្សេងៗ ទៀតជាធរមាន។[150]

បញ្ហាខាងលើនេះ គឺជាកម្មវត្ថុនៃការបកស្រាយអំពីរបបគតិយុត្តនៃអាជ្ញាអស់ជំនុំចំពោះសេចក្តីសម្រេចផ្សេងក្រៅពីសាលក្រម ឬសាលដីកាចុងក្រោយ។

### ២.២.១. ដីកាសម្រេចដាស់តឿន

ដីកាសម្រេចដាស់តឿនគឺជាដីកាសម្រេចដែលខុសពីដីកាសម្រេចនៅក្នុងនីតិវិធីបណ្តឹងដែលវាមានលក្ខណៈជាសេចក្តីសម្រេចលើអង្គសេចក្តីនៃពាក្យសុំរបស់ម្ចាស់បំណុល ទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ចដែលមានគោលបំណងឱ្យសងជាប្រាក់។ ប្រសិនបើដីកាសម្រេចដាស់តឿនបានចូលជាស្ថាពរតាមមាត្រា ៣៣៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីហើយ ដីកាសម្រេចនោះនឹងមានអានុភាពដូចសាលក្រមស្ថាពរ។ ដូច្នេះបញ្ញត្តិនៃមាត្រា ១៩៤ ស្តីពីអាជ្ញាអស់ជំនុំ ក៏ត្រូវយក

---

[149] មាត្រា ៣៣៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[150] មាត្រា ៨៩ កថាខណ្ឌទី១ និងទី២ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៤

មកអនុវត្តចំពោះដីកាសម្រេចដាស់តឿនដែរ ហើយទស្សនវិស័យទាំង៣ ដែលបានបកស្រាយក្នុងផ្នែកមុន ក៏ត្រូវយកមកអនុវត្តដូចគ្នាដែរ។

### ២.២.១.១ វិសាលភាពផ្នែកកម្មវត្ថុ

ទម្រង់នៃដីកាសម្រេចដាស់តឿនមានលក្ខណៈប្រហាក់ប្រហែលនឹងសាលក្រមចុងក្រោយដែរ[151]។ តុលាការត្រូវតាក់តែងដីកាសម្រេចដាស់តឿនដែលរួមបញ្ចូលនូវ សំអាងហេតុ ព្រមទាំងសេចក្តីសម្រេចបញ្ចប់។ នៅក្នុងសំអាងហេតុ តុលាការត្រូវសំដែងនូវការយល់ឃើញរបស់ខ្លួនចំពោះមូលហេតុនៃការទាមទារ ថាតើម្ចាស់បំណុលមានសិទ្ធិលើបំណុលចំពោះកូនបំណុលដែរឬទេ (ការវិនិច្ឆ័យលើអង្គសេចក្តីចំពោះការទាមទារ)[152]។ ចំណែកឯនៅក្នុងសេចក្តីសម្រេចបញ្ចប់ តុលាការត្រូវបង្គាប់ឱ្យកូនបំណុលសងប្រាក់ទៅឱ្យម្ចាស់បំណុល ព្រមទាំងបញ្ជាក់អំពីការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន។

ដោយអនុលោមតាមការយកមកអនុវត្តដូចគ្នា នៃអាជ្ញាអស់ជំនុំនៃដីកាសម្រេចដាស់តឿនដើម្បីកំណត់ពីវិសាលភាពផ្នែកកម្មវត្ថុនៃអាជ្ញាអស់ជំនុំចំពោះដីកាសម្រេចដាស់តឿន តុលាការត្រូវពិនិត្យមើលទៅលើផ្នែកសេចក្តីសម្រេចបញ្ចប់នៃដីកាសម្រេចដាស់តឿន ក៏ព្រោះតែអាជ្ញាអស់ជំនុំសារធាតុនៃដីកាសម្រេចដាស់តឿន មានតែចំពោះផ្នែកនៃសេចក្តីសម្រេចបញ្ចប់ប៉ុណ្ណោះ[153]។

ដោយឡែកចំពោះកថាខណ្ឌទី៣ នៃមាត្រា ១៩៤ ដែលស្តីពីបណ្តឹងតបវិញ ពុំត្រូវយកមកអនុវត្តចំពោះអាជ្ញាអស់ជំនុំសារធាតុនៃដីកាសម្រេចដាស់តឿនឡើយ ដោយសារតែដីកាសម្រេចដាស់តឿនត្រូវបានចេញដោយមិនចាំបាច់សួរកូនបំណុល[154] ហេតុនេះកូនបំណុលពុំបានចូលរួមនៅក្នុងនីតិវិធីទាញហេតុផលដើម្បីចេញដីកាសម្រេចដាស់តឿនឡើយ នាំឱ្យបណ្តឹងតបមិនអាចកើតឡើងទេក្នុងទិដ្ឋភាពនេះ។ ដូចគ្នាផងដែរ ចំពោះការទាមទារទូទាត់សិទ្ធិលើបំណុលតប ដែលមានចែងក្នុងកថាខណ្ឌទី៤នៃមាត្រាដដែល ដោយសារតែពុំមានឱកាសក្នុងការទាញហេតុផលនៅក្នុងនីតិវិធីនៃការចេញដីកាសម្រេច កូនបំណុលពុំអាចអះអាងអំពីសិទ្ធិលើបំណុលតបឡើយ។ ផ្ទុយមកវិញប្រសិនបើកូនបំណុលចង់ធ្វើបណ្តឹងតប ឬ ទាមទារការទូទាត់ ត្រូវដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនតាមមាត្រា ៣២៧ ឬ ៣២៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

---

151 មាត្រា ៣១៦ និង មាត្រា១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា (ការអនុវត្តដូចគ្នាចំពោះទម្រង់នៃដីកាសម្រេចដាស់តឿន)

152 មាត្រា ៣២២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

153 មាត្រា ៣១៦, មាត្រា ៣៣៣ និងមាត្រា ១៩៤ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

154 មាត្រា ៣២៣ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

### ២.២.១.២ ពេលវេលាជាមូលដ្ឋាននៃអាជ្ញាអស់ជំនុំ

ពេលវេលាជាមូលដ្ឋាននៃអាជ្ញាអស់ជំនុំចំពោះសាលក្រមចុងក្រោយត្រូវបានកំណត់នៅពេលតុលាការបិទបញ្ចប់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់។ ដោយសារតែនីតិវិធីនៃការចេញដីកាសម្រេចដាស់តឿន មានគោលបំណងធានាភាពឆាប់រហ័សនៃការទទួលបានលិខិតអនុវត្ត[155] ហេតុនេះតុលាការពុំទាញហេតុផល ព្រមទាំងមិនសួរកូនបំណុលឡើយ ដើម្បីចេញដីកាសម្រេចឡើយ។ ហេតុនេះការកំណត់ពេលវេលាជាមូលដ្ឋាននៃអាជ្ញាអស់ជំនុំចំពោះដីកាសម្រេចដាស់តឿន ត្រូវពឹងផ្អែកលើគោលគំនិតនៃការតាក់តែង។

ជាគោលគំនិតដើមនៃការកំណត់យកកាលបរិច្ឆេទចុងក្រោយនៃការទាញហេតុផលផ្ទាល់មាត់ គឺដោយសារតែកាលបរិច្ឆេទនោះ ជាពេលចុងក្រោយដែលភាគីបានទាញហេតុផល ព្រមទាំងជាឱកាសចុងក្រោយដែលតុលាការធ្វើការពិនិត្យភស្តុតាង ដើម្បីទទួលបានធនធានជាមូលដ្ឋានក្នុងការសម្រេចសេចក្តី ហេតុនេះយើងអាចបកស្រាយថា នៅពេលដែលតុលាការបញ្ចប់ការវិនិច្ឆ័យអំពីសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ ពេលនោះគឺជាពេលចុងក្រោយនៃការវិនិច្ឆ័យ។

***<u>ឧទាហរណ៍</u> ៖*** នៅពេលដែលពិនិត្យពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន ដែលប្រព្រឹត្តទៅនៅកាលបរិច្ឆេទនៃការសាកសួរម្ចាស់បំណុល ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៧ តុលាការបានពិនិត្យលើអង្គហេតុជាមូលហេតុនៃការទាមទារ ហើយយល់ឃើញថាម្ចាស់បំណុលពិតជាមានសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ចំពោះកូនបំណុលពិតមែន។ កូនបំណុលពុំបានដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនទាំងមុន និងក្រោយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន នាំឱ្យដីកាសម្រេចដាស់តឿនត្រូវចូលជាស្ថាពរ។ កូនបំណុលបានសងសិទ្ធិលើបំណុលទៅម្ចាស់បំណុលនៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧ ដែលជាហេតុនាំឱ្យសិទ្ធិលើបំណុលដែលបានសម្រេចក្នុងដីកាសម្រេចដាស់តឿនស្ថាពររលត់។ ហេតុនេះប្រើសិនបើមានបណ្តឹងចំពោះកូនបំណុល ទាក់ទងនឹងសិទ្ធិលើបំណុលដែលជាកម្មវត្ថុនៃដីកាសម្រេចដាស់តឿនស្ថាពរ វាពុំហាមឃាត់កូនបំណុល ក្នុងការអះអាងអំពី ការមិនយកមកអនុវត្តនូវអានុភាពអាជ្ញាអស់ជំនុំឡើយ ដោយសារ មានហេតុដែលកើតក្រោយពេលវេលាជាមូលដ្ឋាន (អង្គហេតុនៃការសង)។

---

155 ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១: នីតិវិធីបណ្តឹង*, (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០០៨), ២៤១

### ២.២.១.៣ វិសាលភាពនៃប្រធាន

ស្តីពីភាគីដែលទទួលអានុភាពនៃអាជ្ញាអស់ជំនុំនៃដីកាសម្រេចដាស់តឿន ពុំត្រូវយកមកអនុវត្តដូចគ្នាទាំងស្រុងនោះទេ។ ក្រៅពីភាគីនៃនីតិវិធីដាស់តឿន បុគ្គលមួយចំនួនដែលបានកំណត់ក្នុងមាត្រា ១៩៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ពុំអាចលេចវត្តមានឡើយដោយសារតែនីតិវិធីបណ្តឹងខុសពីនីតិវិធីដាស់តឿន។

បុគ្គលដែលបានកំណត់ក្នុងចំណុច ខ នៃមាត្រា ១៩៨ (តតិយជនក្នុងករណីដែលភាគីធ្វើជាដើមចោទ ឬ ចុងចម្លើយជំនួសតតិយជននោះ) ពុំទទួលអានុភាពនៃអាជ្ញាអស់ជំនុំ ក៏ព្រោះតែនៅក្នុងនីតិវិធីដាស់តឿន ពុំមានការទាញហេតុផលដោយផ្ទាល់មាត់ ក៏ពុំមានសហបណ្តឹងដែរ ហេតុនេះការជ្រើសរើសភាគីតាមមាត្រា ៤២ ក៏ពុំអាចធ្វើទៅរួច។

ចំណែកឯបុគ្គលដែលបានកំណត់ក្នុងចំណុច គ និង ឃ នៃមាត្រាដដែល ត្រូវទទួលអានុភាពនៃអាជ្ញាអស់ជំនុំនៃដីកាសម្រេចដាស់តឿន ដោយសារតែវាអាចមានស្ថានភាពដែលមានការទទួលបន្តនូវកាតព្វកិច្ចតាមរយៈសន្តតិកម្មពីកូនបំណុលក្រោយពេលដែលចាត់ការនីតិវិធីដាស់តឿន ឬមានការកាន់កាប់កម្មវត្ថុនៃដីកាសម្រេចដាស់តឿន (ប្រាក់) ក្រោមរូបភាពជាបញ្ញើនៅធនាគារជាដើម។

### ២.២.២ សាលក្រមនៃតុលាការបរទេស

សាលក្រមដែលបានចេញដោយតុលាការបរទេស ហើយបានចូលជាស្ថាពរមានអានុភាពដូចសាលក្រមស្ថាពររបស់តុលាការកម្ពុជា ប្រសិនបើបានបំពេញគ្រប់ល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ១៩៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ វានឹងកើតឡើងនូវបញ្ហាដែលត្រូវបកស្រាយ ថាតើអាជ្ញាអស់ជំនុំនៃសាលក្រមស្ថាពរបរទេសស្ថិតក្រោមការអភិបាលនៃច្បាប់កម្ពុជា ឬ ច្បាប់នៃប្រទេសដែលតុលាការបានប្រកាសសាលក្រមតាំងនៅ? ប្រសិនបើមានភាពមិនដូចគ្នានៃបទប្បញ្ញត្តិទាំងនោះ តើអាជ្ញាអស់ជំនុំអាចកើតឡើងបានដែរឬទេ?[156] ឧទាហរណ៍ថា សាលក្រមនៃតុលាការប្រទេសអង់គ្លេស ប្រកាន់យកអានុភាពហាមឃាត់ចំណុចវិវាទ (Issue Estoppel)[157] ប៉ុន្តែអាជ្ញាអស់ជំនុំនៃច្បាប់កម្ពុជាពុំទទួលស្គាល់អានុភាពហាមឃាត់ចំណុចវិវាទនោះឡើយ។ ហេតុនេះថាតើភាគីនៃ

---

[156] ដោយសារតែមាត្រា ១៩៩ ពុំបានបញ្ញត្តនូវស្ថានភាពដែលមានភាពផ្ទុយគ្នាខាងបទប្បញ្ញត្តិទេ វាគ្រាន់តែធានាថានីតិវិធីរបស់តុលាការបរទេស បានធានានូវគោលការណ៍ចំពោះមុខ ហើយសេចក្តីសម្រេចនោះមិនផ្ទុយនឹងសណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈរបស់កម្ពុជា។

[157] ចរិតលក្ខណៈនៃការហាមឃាត់ចំណុចវិវាទបានបកស្រាយក្នុងផ្នែក ១.១.១.២ ខាងលើ

វិវាទក្នុងសាលក្រមបរទេស អាចអះអាងអំពីការយកមកអនុវត្តនូវច្បាប់អាជ្ញាអស់ជំនុំនៃប្រទេសដែលបានចេញសាលក្រមដែរឬទេ?

តុលាការអាមេរិក ដើម្បីសម្រេចសេចក្តីពាក់ព័ន្ធនឹងការយកមកអនុវត្តច្បាប់អាជ្ញាអស់ជំនុំនៃតុលាការបរទេស បានពឹងផ្អែកលើសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញ (Declarations of experts) (អាចជាមេធាវីបរទេស) របស់ភាគីទាំងសងខាង។ អ្នកជំនាញទាំងនោះ មាននិន្នាការការពារផលប្រយោជន៍របស់កូនក្តីរៀងៗខ្លួន ហេតុនេះតុលាការត្រូវពិនិត្យលើសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញទាំងនោះដើម្បីចេញសេចក្តីសម្រេចទាក់ទងនឹងអាជ្ញាអស់ជំនុំ។ ការធ្វើបែបនេះបង្ហាញថា តុលាការទទួលស្គាល់ការយកមកអនុវត្តនូវច្បាប់អាជ្ញាអស់ជំនុំនៃប្រទេសដែលតុលាការចេញសាលក្រមតាំងនៅ។[158] ប៉ុន្តែការអនុវត្តបែបនេះត្រូវការចំណាយច្រើន ហើយត្រូវបានរិះគន់ថា មិនបានធានាភាពច្បាស់លាស់ ដូច្នេះគប្បីឱ្យតុលាការប្រើច្បាប់នៃប្រទេសរបស់ខ្លួន ដែលមានភាពច្បាស់លាស់ជាង ដើម្បីបកស្រាយអំពីអាជ្ញាអស់ជំនុំនោះ។

សម្រាប់កម្ពុជាវិញ ពុំទាន់មានការអនុវត្តណាមួយពាក់ព័ន្ធនឹងបញ្ហាការយកមកអនុវត្តច្បាប់អាជ្ញាអស់ជំនុំនៃតុលាការបរទេសឡើយ។ ប៉ុន្តែយើងអាចបកស្រាយបានថា ដោយសារតែសាលក្រមស្ថាពរនោះត្រូវបានទទួលស្គាល់ដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា (មាត្រា១៩៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ហេតុនេះច្បាប់ដែលត្រូវអភិបាលចំពោះអាជ្ញាអស់ជំនុំ គប្បីតែជាច្បាប់របស់កម្ពុជាដូចគ្នាដែរ។

ដូច្នេះគ្រប់សាលក្រមរបស់តុលាការបរទេសដែលបានបំពេញគ្រប់ល័ក្ខខ័ណ្ឌនៃមាត្រា ១៩៩ មានអានុភាពដូចសាលក្រមស្ថាពរកម្ពុជា ហើយបញ្ញត្តិស្តីពីអាជ្ញាអស់ជំនុំចំពោះសាលក្រមចុងក្រោយ ដែលបានកំណត់ក្នុងមាត្រា ១៩៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ក៏ត្រូវយកមកអនុវត្តចំពោះសាលក្រមរបស់តុលាការបរទេសដែរ។

### ២.២.៣ សាលក្រមនៃបណ្តឹងដែលមានចំនួនទឹកប្រាក់តិច

ថ្វីដ្បិតតែសាលក្រមនៃបណ្តឹងដែលមានចំនួនទឹកប្រាក់តិចជាសាលក្រមចុងក្រោយ ប៉ុន្តែចំពោះទម្រង់នៃសាលក្រមនេះមានភាពខុសប្លែកគ្នាពីសាលក្រមចុងក្រោយ ដែលវាផ្អែកលើនីតិវិធីបណ្តឹងធម្មតា ដោយហេតុថានីតិវិធីនេះធានាការប្រព្រឹត្តទៅយ៉ាងឆាប់រហ័សដោយប្រើនីតិវិធី

[158] L. Rachel Lerman & Peter Morris, "*Foreign Country Judgments and the Res Judicata Puzzle: Whose* Preclusion Law Should U.S. Courts Apply?" [សាលក្រមតុលាការបរទេស និង បញ្ហានៃអាជ្ញាអស់ជំនុំ: តើច្បាប់នៃប្រទេសណាដែលតុលាការអាមេរិកយកមកអនុវត្ត?], *Civil Procedure Review,* ០១ (២០១៥): ៦៨

សង្ខេប[159] ជាអាទិ៍ ការដាក់ពាក្យបណ្តឹងដោយផ្ទាល់មាត់ ការជំនុំជម្រះក្នុងតាមកាលបរិច្ឆេទតែមួយថ្ងៃ។

សាលក្រមនៃបណ្តឹងដែលមានចំនួនទឹកប្រាក់តិចអាចត្រូវបានប្រកាសដោយផ្អែកលើច្បាប់ដើមនៃមូលសាលក្រម ឬដោយមិនផ្អែកបាន។ ប្រសិនបើតុលាការប្រកាសសាលក្រមដោយពុំផ្អែកលើច្បាប់ដើមនៃមូលសាលក្រម ក្រឡាបញ្ជីត្រូវកត់ត្រាចូលក្នុងកំណត់ហេតុនៃកាលបរិច្ឆេទនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នូវចំណុចដូចខាងក្រោម ហើយកំណត់ហេតុនេះមានតម្លៃស្មើការធ្វើលិខិតសាលក្រម៖

ក. ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានភាគី ហើយនិង ឈ្មោះ និងអាសយដ្ឋានអ្នកតំណាងដែលច្បាប់បានកំណត់។

ខ. សាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ

គ. សេចក្តីសម្រេចបញ្ចប់។

ប្រសិនបើតុលាការប្រកាសសាលក្រមដោយពុំផ្អែកលើច្បាប់ដើមនៃមូលសាលក្រម (ប្រកាសតាមកថាខណ្ឌទី២នៃមាត្រា២៣៦) ទម្រង់នៃសាលក្រមត្រូវតាក់តែងចំណុចដែលបានរៀបរាប់ខាងលើ។ ដោយសារតែវាជាសាលក្រមដែលសម្រេចលើអង្គសេចក្តីនៃសិទ្ធិទាមទាររបស់ដើមចោទ ហេតុនេះវាជាសាលក្រមចុងក្រោយដែលមានអាជ្ញាអស់ជំនុំ។ ប៉ុន្តែការយកវិធាននៃអាជ្ញាអស់ជំនុំ(មាត្រា១៩៤) មកអនុវត្តចំពោះកំណត់ហេតុនេះនឹងមានបញ្ហាដែលត្រូវការការបកស្រាយ ក៏ព្រោះតែកំណត់ហេតុខាងលើពុំបានកំណត់ឱ្យក្រឡាបញ្ជីត្រូវសរសេរចូលនូវ **សំអាងហេតុ** នៃសាលក្រមឡើយ។

ភាពចាំបាច់នៃការបញ្ចូលសំអាងហេតុនៅក្នុងកំណត់ហេតុសាលក្រមដែលមានចំនួនទឹកប្រាក់តិច ត្រូវពឹងផ្អែកលើគោលគំនិតដើមនៃនីតិវិធីនេះ។ ពាក្យថា «ករណីយល់ឃើញថាមិនសមរម្យ» ដែលបានកំណត់ក្នុងមាត្រា ២៣៦ កថាខណ្ឌទី១ សំដៅលើករណីដែលតុលាការផ្សះផ្សាហើយភាគីពុំមានការសះជា[160]។ យើងអាចបកស្រាយតាមបដិលោមវិធីមកវិញ[161] ប្រសិនបើភាគីព្រមសះជា បានន័យថា វាជាករណីសមរម្យដែលតុលាការអាចចេញសាលក្រមតាមរយៈកថាខណ្ឌទី២ នៃ

---

[159] មាត្រា២២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[160] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី, *សេចក្តីកំណត់មាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី,* (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០០៧), ២១៧

[161] សាស្ត្រាចារ្យ ស៊ឹម សុខម្ហ, *បច្ចេកទេស និងវិធីសាស្ត្របកស្រាយបទដ្ឋានគតិយុត្តនានា,* (ភ្នំពេញ ៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០០៩), ៦ដល់៧

មាត្រា ២៣៦ បាន។ ហេតុនេះយើងអាចសង្រួមជាន័យតាមវិធានអនុមានវិធី[162]បានថា ក្នុងករណីដែលភាគីពុំមានវិវាទចំពោះសិទ្ធិទាមទារទេ ឬ មួយក៏ចុងចម្លើយបានទទួលស្គាល់នូវអង្គហេតុដែលដើមចោទបានលើកឡើង ឬ មួយក៏មិនបានធ្វើសេចក្តីតវ៉ាចំពោះអង្គហេតុ ឬ ការទាមទារនោះទេ បានន័យថា ពុំមានភាពចាំបាច់ដែលត្រូវកត់ចូលទៅក្នុងផ្នែកសំអាងហេតុនូវហេតុទាំងនោះឡើយ។

ដូច្នេះ វត្តមាននៃផ្នែកសំអាងហេតុ នៅក្នុងកំណត់ហេតុដែលមានតម្លៃស្មើសាលក្រមនៃបណ្តឹងដែលមានចំនួនទឹកប្រាក់តិច ពុំមានភាពចាំបាច់ដើម្បីបញ្ចូល ហើយវាក៏ពុំមានផលប៉ះពាល់អ្វីដល់ការបកស្រាយអំពីអាជ្ញាអស់ជំនុំនៃសាលក្រមចំនួនទឹកប្រាក់តិចនេះឡើយ។

### ២.២.៤ មជ្ឈត្តវិនិច្ឆ័យ

យោងតាមបទប្បញ្ញត្តិដែលយកមកអនុវត្តដូចគ្នា ដែលមានចែងនៅក្នុងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មជ្ឈត្តវិនិច្ឆ័យដែលចេញដោយវេទិកាមជ្ឈត្តកម្ម និង សេចក្តីបង្គាប់របស់អាជ្ញាកណ្តាល ដែលចេញដោយក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវយកមកអនុវត្តដូចគ្នាផងដែរនូវនីតិវិធីរដ្ឋប្បវេណី ចំពោះនីតិវិធីទាំងនោះ រហូតដល់មានលិខិតបទដ្ឋានគតិយុត្តចែងជាក់លាក់អំពីនីតិវិធីដោះស្រាយវិវាទទាំងនោះនៅតុលាការ[163]។ ហេតុនេះអត្ថន័យនៃអាជ្ញាអស់ជំនុំចំពោះសាលក្រមចុងក្រោយដែលមានចែងនៅក្នុងមាត្រា ១៩៤ ក៏ត្រូវយកមកអនុវត្តដូចគ្នា ចំពោះសេចក្តីសម្រេចទាំងនោះដែរ។

#### ២.២.៤.១. មជ្ឈត្តវិនិច្ឆ័យនៃវេទិកាមជ្ឈត្តកម្ម

ការបកស្រាយលើភាពស្ថាពរនៃមជ្ឈត្តវិនិច្ឆ័យនៃវេទិកាមជ្ឈត្តកម្មផ្អែកលើការបកស្រាយអំពីអាជ្ញាអស់ជំនុំលក្ខណៈទម្រង់តាមច្បាប់ស្តីពីមជ្ឈត្តការពាណិជ្ជកម្ម[164] និង អាជ្ញាអស់ជំនុំលក្ខណៈសារធាតុ ដែលជាការយកមកអនុវត្តដូចគ្នានូវមាត្រា ១៩៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

---

162 ដូចមុន, ទំព័រ៧

163 មាត្រា ៨៩ កថាខណ្ឌទី១ និង ២ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៤

164 ច្បាប់នេះមានគោលបំណងកំណត់អំពីនីតិវិធីក្នុងការដោះស្រាយវិវាទពាណិជ្ជកម្មដោយមជ្ឈត្តការ ហើយវាជាល័ក្ខខ័ណ្ឌតម្រូវរបស់អង្គការ WTO ចំពោះរដ្ឋដែលជាសមាជិកនៃអង្គការនេះ។ វាត្រូវបានដកស្រង់យកគោលគំនិតដើមចេញពីច្បាប់គំរូនៃមជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិ “Model Law on International Commercial Arbitration” របស់ UNCITRAL។

### ក. អាជ្ញាអស់ជំនុំលក្ខណៈទម្រង់នៃមជ្ឈត្តវិនិច្ឆ័យ

វេទិកាមជ្ឈត្តកម្ម អាចបញ្ចប់ជាស្ថាពរនូវវិវាទពាណិជ្ជកម្ម ដោយចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរ។ ដោយសារតែមជ្ឈត្តការ មានទំនោរទៅរកភាពឆាប់រហ័សក្នុងការដោះស្រាយវិវាទ ក្នុងគោលបំណងកាត់បន្ថយភាពយឺតយ៉ាវនៃការដោះស្រាយវិវាទដែលរាំងស្ទះដល់សកម្មភាពពាណិជ្ជកម្ម មជ្ឈត្តវិនិច្ឆ័យអាចត្រូវបានប្ដឹងជំទាស់តែក្នុងល័ក្ខខ័ណ្ឌដ៏រឹតត្បិតមួយប៉ុណ្ណោះ។ ភាគីអាចប្ដឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យតាមផ្លូវតុលាការ ដោយសំអាងលើហេតុដែលបានកំណត់ក្នុងមាត្រា ៤៤ កថាខណ្ឌទី២ និងទី៣នៃច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ ដោយសារតែច្បាប់ បានបើកផ្លូវឱ្យមានឧបាស្រ័យ (បណ្ដឹងជំទាស់) ទៅនឹងមជ្ឈត្តវិនិច្ឆ័យ ហេតុនេះមជ្ឈត្តវិនិច្ឆ័យនៃវេទិកាមជ្ឈត្តកម្ម ពុំមានអាជ្ញាអស់ជំនុំលក្ខណៈទម្រង់ឡើយ បើអំឡុងពេលនៃឧបាស្រ័យមិនទាន់ផុត។

ឧបាស្រ័យចំពោះមជ្ឈត្តវិនិច្ឆ័យអាចធ្វើឡើងក្រោមទម្រង់ជាការបដិសេធមជ្ឈត្តវិនិច្ឆ័យ[165]។ ភាគីដែលមិនសុខចិត្តចំពោះមជ្ឈត្តវិនិច្ឆ័យ ហើយដែលយល់ថា មជ្ឈត្តវិនិច្ឆ័យនោះមានមូលហេតុដូចបានកំណត់ក្នុងមាត្រា ៤៤ កថាខណ្ឌទី២ និងទី៣ ខាងលើ មានសិទ្ធិប្ដឹងជំទាស់ក្នុងអំឡុងពេល ៣០ថ្ងៃ រាប់ចាប់ពីថ្ងៃដែលភាគីសុំបដិសេធនោះបានទទួលការបញ្ជូនមជ្ឈត្តវិនិច្ឆ័យ ឬ រាប់ពីថ្ងៃដែលវេទិកាមជ្ឈត្តកម្មបានដោះស្រាយចំពោះសំណើសុំបកស្រាយតាមមាត្រា ៤១ នៃច្បាប់នេះ។

ឧបាស្រ័យចំពោះសេចក្ដីសម្រេចរបស់សាលាឧទ្ធរណ៍ក៏ត្រូវបានទទួលស្គាល់ផងដែរ។ ភាគីដែលមិនសុខចិត្តចំពោះសេចក្ដីសម្រេចរបស់សាលាឧទ្ធរណ៍ អាចប្ដឹងជំទាស់ទៅតុលាការកំពូលក្នុងអំឡុងពេល ១៥ថ្ងៃ ក្រោយទទួលបានការបញ្ជូនសេចក្ដីសម្រេចរបស់សាលាឧទ្ធរណ៍ចំពោះបណ្ដឹងជំទាស់[166]។

ដូច្នេះ ប្រសិនបើផុតអំឡុងពេលឧបាស្រ័យស្របច្បាប់ដូចបានកំណត់ខាងលើ អានុភាពអាជ្ញាអស់ជំនុំលក្ខណៈទម្រង់នឹងកើតឡើង ហើយវារាំងភាគីនៃវិវាទពុំឱ្យធ្វើការបដិសេធចំពោះខ្លឹមសារដែលមានចែងក្នុងមជ្ឈត្តវិនិច្ឆ័យ ទោះបីជាមានមូលហេតុក្នុងការប្ដឹងជំទាស់ក៏ដោយ។

---

[165] មាត្រា ៤៤ នៃច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

[166] មាត្រា ៤៣ នៃច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

**ខ. អាជ្ញាអស់ជំនុំលក្ខណៈសារធាតុនៃមជ្ឈត្តវិនិច្ឆ័យ**

នៅក្នុងច្បាប់ស្តីពីមជ្ឈត្តការពាណិជ្ជកម្ម ពុំបានបញ្ជាក់អំពីលក្ខណៈសារធាតុនៃអាជ្ញាអស់ជំនុំចំពោះមជ្ឈត្តវិនិច្ឆ័យទេ ដូច្នេះ ការបកស្រាយស្តីពីអាជ្ញាអស់ជំនុំលក្ខណៈសារធាតុនេះត្រូវពឹងផ្អែកលើច្បាប់នីតិវិធីគោល គឺក្រមនីតិវិធីរដ្ឋប្បវេណី។[167]

យោងតាមមាត្រា ៣៩ នៃច្បាប់ស្តីពីមជ្ឈត្តការផ្ទែកពាណិជ្ជកម្ម ទម្រង់នៃមជ្ឈត្តវិនិច្ឆ័យត្រូវមានទ្រង់ទ្រាយ និងខ្លឹមសារដូចខាងក្រោម ៖

១. មជ្ឈត្តវិនិច្ឆ័យ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ព្រមទាំងមានហត្ថលេខារបស់មជ្ឈត្តករ

២. ហេតុផលនៃសេចក្តីសម្រេចនៃមជ្ឈត្តវិនិច្ឆ័យ

៣. សោហ៊ុយដែលត្រូវបានចំណាយ

៤. កាលបរិច្ឆេទ និងទីកន្លែងដែលធ្វើការផ្សះផ្សា។ [ស្រង់ដោយសង្ខេបពីខ្លឹមសារដើម]

ដោយពិនិត្យមើលលើទម្រង់នៃមជ្ឈត្តវិនិច្ឆ័យនេះ វាមានលក្ខណៈដូចគ្នាស្ទើរតែទាំងស្រុងទៅនឹងទម្រង់នៃសាលក្រម ដែលមានដូចជា សំអាងហេតុ ប្រាក់ប្រដាប់ក្តី កាលបរិច្ឆេទបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ព្រមទាំង ទម្រង់ជាលាយល័ក្ខណ៍អក្សរ។ ហេតុនេះ ការយកមកអនុវត្តនូវមាត្រា ១៩៥ នៃក្រមនីតិវិធីចំពោះអាជ្ញាអស់ជំនុំសារធាតុនៃមជ្ឈត្តវិនិច្ឆ័យពុំមានចោទជាបញ្ហាឡើយ។

**២.២.៤.២ សេចក្តីសម្រេចនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល**

សេចក្តីបង្គាប់អាជ្ញាកណ្តាលមានអានុភាពចងអាជ្ញាកណ្តាលនៃសំណុំរឿងក្រោយ ដោយអនុវត្តតាមគោលការណ៍នៃអាជ្ញាអស់ជំនុំដូចបានរៀបរាប់នៅក្នុងចំណុចខ ផ្នែក ១.២.២.៥. (សេចក្តីបង្គាប់អាជ្ញាកណ្តាល ចងអាជ្ញាកណ្តាល)។ ហេតុនេះផ្នែកនេះសូមលើកយកតែករណីវិវាទនោះត្រូវបានឧបាស្រ័យទៅកាន់តុលាការតាមរយៈបណ្តឹងជំទាស់នឹងសេចក្តីបង្គាប់អាជ្ញាកណ្តាល។

**ក. អាជ្ញាអស់ជំនុំជាលក្ខណៈទម្រង់នៃសេចក្តីបង្គាប់អាជ្ញាកណ្តាល**

ដូចសេចក្តីធ្លាប់បានបកស្រាយនៅជំពូកទី១ ខាងលើនេះ សេចក្តីសម្រេចដែលជាប់កាតព្វកិច្ច ឬ សេចក្តីបង្គាប់ដែលសម្រេចអំពីផលប្រយោជន៍មិនមែនជាសិទ្ធិ បង្កើតអានុភាពអាជ្ញាអស់ជំនុំជាលក្ខណៈទម្រង់ តាំងពីពេលដែលផុតអំឡុងពេលសម្រាប់បណ្តឹងជំទាស់នឹង សេចក្តី

---

[167] មាត្រា ៨៩ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

បង្គាប់នោះ (៨ថ្ងៃប្រតិទិន)[168]។ ក្រៅពីនេះ សេចក្ដីបង្គាប់ដែលមិនជាប់កាតព្វកិច្ច ឬ សេចក្ដីសម្រេច ដែលបានសម្រេចចំពោះសិទ្ធិ ដែលមានវិវាទ វាជាកម្មវត្ថុនៃបណ្ដឹងឧបាស្រ័យទៅកាន់តុលាការ ហេតុនេះវាមិនអាចចូលជាស្ថាពរបានឡើយមុនពេលផុតអំឡុងពេល ប្ដឹងជំទាស់ទៅកាន់តុលាការ (៨ថ្ងៃប្រតិទិន) រាប់ចាប់ពីថ្ងៃដែលបានទទួលដំណឹង។

## ខ. អាជ្ញាអស់ជំនុំលក្ខណៈសារធាតុនៃសេចក្ដីបង្គាប់អាជ្ញាកណ្ដាល

ដោយសារតែក្រុមប្រឹក្សាអាជ្ញាកណ្ដាល អាចប្រើគោលការណ៍សមធម៌ក្នុងការសម្រេចសេចក្ដី ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល អាចយោងលើសំណុំរឿងយុត្តិសាស្ត្រនេះ ដើម្បីបកស្រាយអំពីអាជ្ញាអស់ជំនុំនៃសេចក្ដីបង្គាប់មុន អំពីវិសាលភាពអាជ្ញាអស់ជំនុំ[169]។ ប៉ុន្ដែប្រសិនបើមានវិវាទបានដាក់ទៅតុលាការអំពីអាជ្ញាអស់ជំនុំនេះ ឧទាហរណ៍ ក្នុងរឿងក្ដីសេនារីយ៉ូមួយ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការច្រានចោលការទាមទាររបស់កម្មករនិយោជិត ចំពោះប្រាក់បំណាច់បញ្ចប់កិច្ចសន្យា ដោយសំអាងថា វាត្រូវបានដោះស្រាយជាស្ថាពរក្នុងសំណុំរឿងមុន (ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានលើកអំពីគោលការណ៍អាជ្ញាអស់ជំនុំក្នុងសំណុំរឿង សៅធបេ) បន្ទាប់មកភាគីកម្មករនិយោជិត បានប្ដឹងជំទាស់ចំពោះសេចក្ដីបង្គាប់ច្រានចោលនេះទៅកាន់តុលាការ។ តុលាការពុំត្រូវចងដោយយុត្តិសាស្ត្ររបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅក្នុងការបកស្រាយអំពីវិសាលភាពនៃអាជ្ញាអស់ជំនុំសារធាតុនៃសេចក្ដីបង្គាប់អាជ្ញាកណ្ដាលនៃសំណុំរឿងមុនឡើយ។ តុលាការត្រូវយោងលើការយកមកអនុវត្តដូចគ្នានូវមាត្រា ១៩៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីដើម្បីបកស្រាយអំពីវិសាលភាពនៃអាជ្ញាអស់ជំនុំសារធាតុនៃសេចក្ដីបង្គាប់។

ម្យ៉ាងវិញទៀត ប្រសិនបើមាន សេចក្ដីបង្គាប់ពីរ ដែលផ្ទុយគ្នា ហើយភាគីណាមួយនៃវិវាទការងារ បានស្នើសុំឱ្យអនុវត្តសេចក្ដីបង្គាប់ដែលបានចេញផ្ទុយនឹងគោលការណ៍អាជ្ញាអស់ជំនុំនៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការអាចបដិសេធចំពោះសេចក្ដីបង្គាប់អាជ្ញាកណ្ដាលបាន ដោយសំអាងថា សេចក្ដីបង្គាប់នោះត្រូវបានចេញ ដោយផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ[170] (ផ្ទុយនឹងគោលការណ៍អាជ្ញាអស់ជំនុំ)។ ក្នុងករណីនេះតុលាការ ត្រូវរកឱ្យឃើញថាសេចក្ដីបង្គាប់អាជ្ញាកណ្ដាលដែលភាគីបានស្នើសុំអនុវត្ត ស្ថិតក្នុងវិសាលភាពនៃអាជ្ញាអស់ជំនុំនៃសេចក្ដីបង្គាប់មុន ផ្អែកតាមការបកស្រាយ មាត្រា ១៩៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

---

[168] មាត្រា ៤០ វាក្យខណ្ឌទី១ និងមាត្រា ៤១ នៃប្រកាសលេខ ០៩៩ ស.ក.ប.យ. ស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាល

[169] មាត្រា ៣១២ កថាខណ្ឌទី២ វាក្យខណ្ឌទី២ នៃច្បាប់ស្ដីពីការងារ ១៩៩៧

[170] មាត្រា ៣៥៣ កថាខណ្ឌទី៤ ចំណុចខ នៃក្រមនីតិវិធីរដ្ឋប្បវេណី

**កំណត់សម្គាល់ ៖** សេចក្ដីសម្រេចដូចបានរៀបរាប់នៅក្នុងជំពូកនេះ សុទ្ធសឹងតែមានអាជ្ញាអស់ជំនុំព្រមទាំងជាលិខិតអនុវត្ត។[171] យ៉ាងនេះក្ដី លិខិតយថាភូតដែលចេញដោយសារការីដែលមានសេចក្ដីថ្លែងការណ៍ថា កូនបំណុលនឹងទទួលការអនុវត្តដោយបង្ខំភ្លាមៗ ក៏ជាលិខិតអនុវត្តដែរ ប៉ុន្តែលិខិតនេះពុំមានអាជ្ញាអស់ជំនុំដូចសេចក្ដីសម្រេចផ្សេងទៀតឡើយ។ លិខិតយថាភូតដែលចេញដោយសារការី ពុំមែនជាសេចក្ដីសម្រេចដែលកើតចេញពីការទាញហេតុផល ឬ ចេញដោយអង្គវិនិច្ឆ័យស្របច្បាប់ណាមួយឡើយ ហេតុនេះ វាពុំបង្កើតឱ្យមានលក្ខណៈអាជ្ញាអស់ជំនុំចំពោះលិខិតនេះទេ។ ក៏ប៉ុន្តែ ប្រសិនបើភាគីបានដាក់ពាក្យបណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិកទៅកាន់តុលាការចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ដែលបានកំណត់ក្នុងលិខិតយថាភូតចេញដោយសារការី បណ្ដឹងបែបនេះនឹងត្រូវបានតុលាការច្រានចោល ដោយសារតែផ្ទុយនឹងផលប្រយោជន៍នៃបណ្ដឹង។[172] ការច្រានចោលនេះ ពុំផ្អែកលើគោលការណ៍អាជ្ញាអស់ជំនុំនោះទេ ប៉ុន្តែវាផ្អែកលើផលប្រយោជន៍នៃបណ្ដឹងដែលជាល័ក្ខខ័ណ្ឌនៃបណ្ដឹង។[173]

ជាសេចក្ដីសន្និដ្ឋានចំពោះខ្លឹមសារនៃជំពូកទី២នេះ អាជ្ញាអស់ជំនុំតាមន័យក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ជាឧបករណ៍គតិយុត្តក្នុងការហាមឃាត់មិនឱ្យវិវាទដដែល ដែលបានចូលជាស្ថាពរត្រូវបានលើកយកមកសម្រេចសេចក្ដីម្ដងទៀត ក្នុងគោលបំណងរក្សាតម្លៃនៃសេចក្ដីសម្រេចរបស់តុលាការ ក៏ដូចជាអង្គវិនិច្ឆ័យផ្សេងៗទៀត ព្រមទាំង ការពារផលប្រយោជន៍ដល់បុគ្គលឯកជនដែលជាភាគីនៃវិវាទ។ ក្រៅពីសេចក្ដីសម្រេចដែលចេញដោយតុលាការ ផ្នែកនេះក៏បានលើកយកមកសិក្សាចំពោះសេចក្ដីសម្រេចផ្សេងទៀតដែលចេញដោយអង្គវិនិច្ឆ័យ ដែលត្រូវបានច្បាប់ទទួលស្គាល់ ដោយសារតែសេចក្ដីសម្រេចទាំងនោះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធដល់នីតិវិធីឧបាស្រ័យ ក៏ដូចជាអានុភាពអនុវត្តដោយបង្ខំផ្អែកលើលិខិតអនុវត្តទាំងនោះ។ ដោយអនុលោមតាម បទប្បញ្ញត្តិដែលយកមកអនុវត្តដូចគ្នា អាជ្ញាអស់ជំនុំនៃសាលក្រមចុងក្រោយ ដែលមានចែងនៅក្នុងមាត្រា ១៩៤ ត្រូវយកទៅអនុវត្តចំពោះសេចក្ដីសម្រេចផ្សេងទៀត ត្រឹមទំហំដែលមិនផ្ទុយគ្នា។ ស្ដីពីការយកមកអនុវត្តនូវអាជ្ញាអស់ជំនុំនេះនៅក្នុងនីតិវិធីជាក់ស្ដែង នឹងត្រូវយកមកសិក្សានៅជំពូកបន្ទាប់។

---

[171] មាត្រា ៣៥០ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[172] ដោយសារតែម្ចាស់បំណុលមានលិខិតអនុវត្តរួចហើយ ហេតុនេះគ្មានភាពចាំបាច់ដើម្បីដាក់ពាក្យបណ្ដឹងអង្គសេចក្ដីម្ដងទៀតឡើយ។

[173] មាត្រា ៧៨ និង មាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

# ជំពូកទី៣ ៖ ការអនុវត្តអាជ្ញាអស់ជំនុំនៅក្នុងនីតិវិធីរដ្ឋប្បវេណី

វិវាទអំពីអាជ្ញាអស់ជំនុំនឹងកើតឡើងប្រសិនបើមានភាគីណាមួយបានលើកឡើងនូវចំណុចវិវាទដែលស្ថិតក្នុងវិសាលភាពអាជ្ញាអស់ជំនុំនៃសាលក្រមស្ថាពរ។ ប្រសិនបើគ្មានវិវាទស្តីពីអាជ្ញាអស់ជំនុំទេ ការបកស្រាយថាសាលក្រមមួយ ឬសេចក្តីសម្រេចមួយ មានអាជ្ញាអស់ជំនុំពុំមានប្រយោជន៍ ព្រោះវាពុំបានយកទៅប្រើប្រាស់ដើម្បីហាមឃាត់តុលាការមិនឱ្យសម្រេចផ្ទុយពីខ្លឹមសារនៃសេចក្តីសម្រេចស្ថាពរ។ ដូចបានបកស្រាយនៅក្នុងជំពូកទី១ អាជ្ញាអស់ជំនុំមានមុខងារពីរ គឺហាមឃាត់ដើមចោទមិនឱ្យធ្វើបណ្តឹងដែលមានខ្លឹមសារដូចគ្នាម្តងទៀត និងហាមឃាត់ចុងចម្លើយមិនឱ្យធ្វើវិវាទអំពីនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលបានសម្រេចនៅក្នុងសាលក្រម ឬសាលដីកាដែលមានអាជ្ញាអស់ជំនុំ ហេតុនេះភាគីទាំងសងខាងសុទ្ធតែមានប្រយោជន៍ អំពីការលើកឡើងនូវអានុភាពអាជ្ញាអស់ជំនុំនេះ ដើម្បីការពារផលប្រយោជន៍របស់ខ្លួនរៀងៗខ្លួនទៅតាមកាលៈទេសៈ។

ដើម្បីទទួលបានផលប្រយោជន៍ពីអាជ្ញាអស់ជំនុំ តើភាគីដែលឈ្នះក្តីនៃបណ្តឹងមុនត្រូវមានបន្ទុកក្នុងការលើកឡើង និង បញ្ជាក់ភស្តុតាងដែរឬទេ? ហើយថាតើការអះអាងនេះតម្រូវឱ្យភាគីធ្វើនីតិវិធីយ៉ាងដូចម្តេច? ប្រសិនបើខកខានមិនបានអះអាង តើតុលាការអាចទទួលស្គាល់អានុភាពអាជ្ញាអស់ជំនុំនេះដោយឆន្ទានុសិទ្ធិដែរឬទេ? ចំណោទបញ្ហាទាំងនេះ នឹងត្រូវបកស្រាយក្នុង **ចំណុច ៣.១ ស្តីពី ការអះអាងអំពីអាជ្ញាអស់ជំនុំនៅក្នុងនីតិវិធីបណ្តឹង**។ ម្យ៉ាងទៀត នៅពេលដែលអាជ្ញាអស់ជំនុំក្លាយទៅជាចំណុចវិវាទ តុលាការត្រូវវិនិច្ឆ័យអំពីចំណុចជាសារធាតុមួយចំនួនដែលនាំឱ្យអានុភាពអាជ្ញាអស់ជំនុំនៃបណ្តឹងមុន អាចមានចំពោះបណ្តឹងក្រោយ ហើយថាតើដើម្បីទទួលស្គាល់អង្គហេតុទាំងនោះតុលាការត្រូវផ្អែកលើភស្តុតាងអ្វីខ្លះ[174]? បញ្ហាគតិយុត្តនេះនឹងត្រូវបានបកស្រាយនៅក្នុង **ចំណុច ៣.២ ស្តីពី ចំណុចជាសារធាតុដែលកំណត់អំពីវិសាលភាពនៃអាជ្ញាអស់ជំនុំ**។

## ៣.១ ការអះអាងអំពីអាជ្ញាអស់ជំនុំនៅក្នុងនីតិវិធីបណ្តឹង

តាមលក្ខណៈអញ្ញមញ្ញ (Reciprocal of Res Judicata) នៃអាជ្ញាអស់ជំនុំ ភាគីទាំងសងខាងនៃសាលក្រមដែលមានអាជ្ញាអស់ជំនុំ អាចទទួលផលប្រយោជន៍ពីការអះអាងអាជ្ញាអស់ជំនុំ។

[174] ដើម្បីទទួលស្គាល់អង្គហេតុដែលជាចំណុចវិវាទមួយ តុលាការចាំបាច់ត្រូវផ្អែកលើភស្តុតាងជាគោលការណ៍ លើកលែងតែករណីដែលមានចែងក្នុងមាត្រា ១២៣ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ប្រសិនបើមានបណ្តឹងទៅកាន់តុលាការ ចុងចម្លើយដែលយល់ឃើញថាការទាមទាររបស់ដើមចោទនៅក្នុងបណ្តឹងថ្មីនេះស្ថិតក្រោមវិសាលភាពនៃសេចក្តីសម្រេចស្ថាពរ អាចលើកឡើងពីអាជ្ញាអស់ជំនុំជាមធ្យោបាយការពារខ្លួនបាន។

### ៣.១.១ ភាពចាំបាច់នៃការអះអាងអំពីអាជ្ញាអស់ជំនុំ និងបន្ទុកក្នុងការបញ្ជាក់

យោងតាមទ្រឹស្តីនៃអង្គហេតុចម្បង អាជ្ញាអស់ជំនុំគឺជាអង្គហេតុរាំងសិទ្ធិទាមទារ[175] ព្រោះវាមានតួនាទីរាំងមិនឱ្យដើមចោទនៃបណ្តឹងថ្មី លើកឡើងអំពីចំណុចដែលមានអាជ្ញាអស់ជំនុំ ជាអាទ៍ហាមឃាត់មិនឱ្យដាក់ពាក្យបណ្តឹងដែលមានខ្លឹមសារដដែល។ នៅក្នុងទ្រឹស្តីនេះ ក៏តម្រូវឱ្យបែងចែកបន្ទុកនៅក្នុងការអះអាងដែរ។ ក្នុងករណីដែលពុំមានការអះអាងនូវអង្គហេតុស្តីពីអាជ្ញាអស់ជំនុំ អ្នកទ្រឹស្តីបានប្រើប្រាស់នូវការសន្មតដែលថា នត្ថិភាពនៃការអះអាង គឺនត្ថិភាពនៃអង្គហេតុ (លើកលែងតែអង្គហេតុដែលកើតឡើងតាមការសន្មត ឬអង្គហេតុពិតជាក់ស្តែង)។[176] អ្នកច្បាប់នៃប្រទេស Common Law ក៏មានការយល់ឃើញដូចគ្នាផងដែរចំពោះភាពចាំបាច់នៃការលើកឡើងអំពីអាជ្ញាអស់ជំនុំនេះ ៖

តុលាការនៃរដ្ឋណ័ស ខារ៉ូឡាញណា (North Carolina) សហរដ្ឋអាមេរិក ក្នុងសំណុំរឿង Reid v. Holden ដែលបានដកស្រង់ចេញពី សំណុំរឿង Sanderson v. Aetna Life Ins. Co. នូវខ្លឹមសារដូចខាងក្រោម ៖

> “អាជ្ញាអស់ជំនុំគឺជាការលើកឡើងដើម្បីហាមឃាត់ ដែលវាត្រូវតែធ្វើឡើងតាមរយៈឯកសារចម្លើយ និងត្រូវបញ្ជាក់ដោយភស្តុតាងសមស្រប។ នៅពេលដែលវាត្រូវបានលើកឡើង ការវិនិច្ឆ័យលើចំណុចនេះ ត្រូវធ្វើតាមការអនុវត្តរបស់តុលាការ ប៉ុន្តែមធ្យោបាយការពារនេះមិនអាចធ្វើឡើងនៅក្នុងពាក្យសុំឱ្យច្រានចោលការទាមទារឡើយ។” [177] [បកប្រែ]

---

175 អង្គហេតុចម្បងមាន៤ប្រភេទ ៖ អង្គហេតុកកើតឡើងនៃសិទ្ធិ, អង្គហេតុរាំងសិទ្ធិ, អង្គហេតុរលត់សិទ្ធិ និងអង្គហេតុទប់ស្កាត់សិទ្ធិ។ អាជ្ញាអស់ជំនុំជាអង្គហេតុរាំងសិទ្ធិ ក៏ព្រោះតែវាមានតួនាទីរាំងមិនឱ្យដើមចោទមានសិទ្ធិទាមទារ ដោយហេតុថាសិទ្ធិទាមទារនេះត្រូវបានសម្រេចជាស្ថាពរម្តងហើយនៅក្នុងសេចក្តីសម្រេចរដ្ឋប្បវេណីដែលមានអាជ្ញាអស់ជំនុំ។

176 ក្រុមការងារកិច្ចការរដ្ឋប្បវេណី នៃគណៈមេធាវី និងកម្មវិធីសហប្រតិបត្តិការផ្នែកតុលាការជាមួយគណៈមេធាវី, *សៀវភៅមេរៀនស្តីពីមូលដ្ឋាននៃអង្គហេតុចម្បង*, (ភ្នំពេញ ៖ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, ២០១០), ៥

177 C. Theodore Leonard, JR., *“PLEADING AND PROVING THE DEFENSE OF RES JUDICATA IN NORTH CAROLINA”* [ការអះអាង និងការបញ្ជាក់អំពីមធ្យោបាយការពារនៃអាជ្ញាអស់ជំនុំ នៅរដ្ឋណ័ស ខារ៉ូឡាញណា], UNC School of Law*,* ៣៤, ៤, (១៩៥៦): ៤៥៨

នៅក្នុងសៀវភៅ Doctrine of Res Judicata in Canada [ទ្រឹស្តីនៃអាជ្ញាអស់ជំនុំនៅប្រទេសកាណាដា] អ្នកនិពន្ធបានដកស្រង់ការយល់ឃើញរបស់តុលាការកាណាដា ចំពោះភាពចាំបាច់នៃការលើកឡើងអំពីអាជ្ញាអស់ជំនុំនេះ នៅក្នុងសំណុំរឿងមួយចំនួន ៖

> "...ប្រសិនបើមិនអះអាង[អំពីអាជ្ញាអស់ជំនុំ]ទេ វាមិនអាចត្រូវបានលើកឡើងជាមូលដ្ឋាននៅក្នុងបណ្តឹងឧបាស្រ័យឡើយ។ អាជ្ញាអស់ជំនុំគឺជាវិធានភស្តុតាង ដែលត្រូវតែអះអាងប្រសិនបើវាកើតឡើងនៅក្នុងតុលាការ។ ប្រសិនបើមិនដូច្នេះទេនោះ ភាគីដែលខកខាន នៅពេលដែលមានឱកាសក្នុងការអះអាង ត្រូវចាត់ទុកថាបានបោះបង់ចោលផលប្រយោជន៍នៃអានុភាពហាមឃាត់នៃអាជ្ញាអស់ជំនុំ..." ។[178] [បកប្រែ]

ស្តីពីបន្ទុកក្នុងការបញ្ជាក់ "ភាគីដែលបានអះអាងអំពីអាជ្ញាអស់ជំនុំ មានបន្ទុកក្នុងការបញ្ជាក់ឱ្យឃើញថា ចំណុចជាក់លាក់មួយដែលខ្លួនសំអាងថាមានអាជ្ញាអស់ជំនុំនោះស្ថិតនៅក្នុងវិសាលភាពនៃចំណុចដែលត្រូវបានបិទបញ្ចប់នៅក្នុងបណ្តឹងមុន។"[179]

ក្នុងករណីដែលភាគីដែលនឹងខូចប្រយោជន៍ដោយសារតែបណ្តឹងក្រោយបំពានអានុភាពអាជ្ញាអស់ជំនុំ ពុំបានលើកឡើងអំពីអានុភាពអាជ្ញាអស់ជំនុំទេនោះ តុលាការក៏មិនសម្រេចអំពីចំណុចវិវាទទាក់ទងនឹងអាជ្ញាអស់ជំនុំដែរ ហើយភាគីនោះនឹងបាត់បង់ផលប្រយោជន៍នៃការលើកឡើងអំពីអាជ្ញាអស់ជំនុំនៅពេលក្រោយ។ ជាគោលការណ៍ តុលាការនៅក្នុងរឿងក្តីរដ្ឋប្បវេណីគឺជាតុលាការអកម្ម ពោលគឺពុំដើរតួសកម្មនៅក្នុងដំណើរការនៃការទាញហេតុផលរវាងភាគីទេ។ ប្រសិនបើតុលាការត្រូវធ្វើការវិនិច្ឆ័យដោយឆន្ទានុសិទ្ធិ អំពីអាជ្ញាអស់ជំនុំជាមុន វានឹងនាំឱ្យនីតិវិធីអូសបន្លាយយូរ ដែលផ្ទុយនឹងគោលការណ៍ យុត្តិធម៌ និងភាពឆាប់រហ័ស[180]។ ម្យ៉ាងទៀត វាក៏បង្ហាញឱ្យឃើញនូវការលូកដៃការពារផលប្រយោជន៍ភាគីហួសហេតុ ទាំងដែលភាគីពុំបានខ្វាយខ្វល់ផងនោះ ដែលវាសម្តែងឱ្យឃើញនូវរូបភាពនៃភាពមិនអព្យាក្រឹតរបស់តុលាការ។ រាល់ការអះអាង ការដាក់ភស្តុតាងគឺជាបន្ទុករបស់ភាគី ចំណែកឯការវិនិច្ឆ័យទទួលស្គាល់អង្គហេតុ ភស្តុតាង និងសម្រេច

---

[178] Donald J. Lange, *The Doctrine of Res Judicata in Canada,* [ទ្រឹស្តីនៃអាជ្ញាអស់ជំនុំក្នុងប្រទេសកាណាដា], បោះពុម្ពលើកទី៣ (កាណាដា ៖ LexisNexis, ២០១០), ១៥

[179] C. Theodore Leonard, JR., "PLEADING AND PROVING THE DEFENSE OF RES JUDICATA IN NORTH CAROLINA" [ការអះអាង និងការបញ្ជាក់អំពីមធ្យោបាយការពារនៃអាជ្ញាអស់ជំនុំ នៅរដ្ឋណ័ស ខារ៉ូឡាញណា], UNC School of Law, ៣៤, ៤, (១៩៥៦): ៤៦១

[180] គោលការណ៍យុត្តិធម៌ និងភាពឆាប់រហ័ស មានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា ៤ ដែលដកស្រង់គំនិតចេញពីពាក្យស្លោកមួយពោលថា «យុត្តិធម៌យឺតយ៉ាវ ស្មើនឹង ការបដិសេធយុត្តិធម៌» ប្រែមកពីពាក្យស្លោកជាភាសាអង់គ្លេសថា «Justice Delays is Justice Denies»

សេចក្តីចំពោះការទាមទាររបស់ភាគី គឺជាបន្ទុករបស់តុលាការ។ ជារួម តុលាការពុំអាចយកអង្គហេតុដែលភាគីមិនបានលើកឡើង ជាមូលដ្ឋានក្នុងចេញសាលក្រមរដ្ឋប្បវេណីឡើយ។

ប៉ុន្តែបញ្ហានឹងកើតឡើង នៅពេលដែលភាគីនៅក្នុងបណ្តឹងថ្មីមិនបានលើកឡើងអំពីអាជ្ញាអស់ជំនុំ ហើយតុលាការបានចេញសាលក្រមដោយពុំផ្អែកលើអាជ្ញាអស់ជំនុំ ពោលគឺសាលក្រមក្រោយមានខ្លឹមសារផ្ទុយនឹង សាលក្រមដើម។ ស្ថានភាពបែបនេះគឺជាមូលហេតុនៃការជំនុំជម្រះសាជាថ្មី[181]។ ហេតុនេះវានឹងបើកសិទ្ធិឱ្យភាគីអាចប្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ទោះបីជាសាលក្រមក្រោយចូលជាស្ថាពរក៏ដោយ។ ដូច្នេះហើយទើបនីតិនិពន្ធបានបង្កើតបទប្បញ្ញត្តិវាក្យខណ្ឌទី២នៃមាត្រា ៣០៧ ដែលសម្តែងថា “ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីបានធ្វើការអះអាងអំពីមូលហេតុនោះ នៅពេលធ្វើបណ្តឹងឧបាស្រ័យ ទៅតុលាការជាន់ខ្ពស់ ឬភាគីបានដឹងអំពីមូលហេតុនេះហើយ **តែមិនធ្វើការអះអាង**។” ខ្លឹមសារនៃអញ្ញត្រកម្មនេះមានន័យថា នៅពេលដែលមានបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដោយយកមូលហេតុនៃចំណុច ញ តុលាការនឹងពិនិត្យលើ ស្ថានភាព៣ ដូចខាងក្រោម ដើម្បីចេញដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី ៖

១. តើពិតជាសាលក្រមដែលជាកម្មវត្ថុនៃបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី ផ្ទុយនឹងសាលក្រមស្ថាពរមុនដែរឬទេ?

២. តើភាគីបានយកមូលហេតុនេះ អះអាងនៅក្នុងនីតិវិធីបណ្តឹងឧបាស្រ័យដែរឬទេ?

៣. ភាគីបានខកខានក្នុងការលើកឡើងអំពីមូលហេតុនេះនៅក្នុងបណ្តឹងមុនដែរឬទេ?

ចំពោះចំណុចទី២ បើសិនជាមូលហេតុនៃការជំនុំជម្រះសាជាថ្មីណាមួយត្រូវបានភាគីដែលស្នើសុំជំនុំជម្រះសាជាថ្មីបានលើកឡើងនៅក្នុងនីតិវិធីឧបាស្រ័យរួចហើយ វាត្រូវបានហាមឃាត់មិនឱ្យលើកឡើងនូវអង្គហេតុនោះម្តងទៀត ជាមូលហេតុដើម្បីទាមទារជំនុំជម្រះសាជាថ្មី។ នៅក្នុងដីកាសម្រេចលើបណ្តឹងទាមទារជំនុំជម្រះសាជាថ្មីលេខ៖ ១៦ “ក្រVIIង” ដកស ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ ២០១៥ ផ្នែកសំអាងហេតុ ចំណុចទី១ សាលាឧទ្ធរណ៍បានយល់ស្របចំពោះ សេចក្តីថ្លែងការណ៍របស់មេធាវីចុងចម្លើយ ដែលថា ដើមចោទ [**ពុំមានហេតុផល និងភស្តុតាងថ្មី**] ស្របតាមល័ក្ខខ័ណ្ឌនៃ

[181] មាត្រា ៣០៧ កថាខណ្ឌទី១ ចំណុច ញ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

ការជំនុំជម្រះសាជាថ្មីតាមមាត្រា ៣០៧ និង ៣០៨ ឡើយ ដូច្នេះតុលាការបានច្រានចោលពាក្យសុំទាមទារជំនុំជម្រះសាជាថ្មីនោះ។[182]

ជារួម អាជ្ញាអស់ជំនុំគឺជាអង្គហេតុតវ៉ាដែលត្រូវតែអះអាងនៅក្នុងនីតិវិធីក្រោយ បើមិនដូច្នេះ ភាគីដែលខកខាន នឹងលែងមានសិទ្ធិអះអាងអំពីវានៅបណ្តឹងក្រោយៗទៀត ហើយអាចរងការខូចខាតដោយសារតែការមិនបានអះអាងនោះ។ តុលាការ ទោះបីជាមានស្ថានភាពដែលលេចឡើងដែលនាំឱ្យ យល់បានថា ការទាមទារថ្មីស្ថិតក្នុងវិសាលភាពនៃអាជ្ញាអស់ជំនុំ ក៏មិនអាចទទួលស្គាល់អំពីអង្គហេតុនេះបានឡើយ ប្រសិនបើភាគីមិនបានលើកឡើង។

### ៣.១.២ ភស្តុតាងនៃអាជ្ញាអស់ជំនុំ

អាជ្ញាអស់ជំនុំគឺជាអង្គហេតុដែលបង្ហាញថាមានអត្ថិភាពនៃសាលក្រមស្ថាពរមុន ដែលមានវិសាលភាពចំពោះបណ្តឹងក្រោយ។ ជាគោលការណ៍ អង្គហេតុត្រូវបញ្ជាក់ដោយភស្តុតាង[183]។ ភស្តុតាងដែលអាចបញ្ជាក់ពីអាជ្ញាអស់ជំនុំគឺ **លិខិតនៃសេចក្តីសម្រេចរដ្ឋប្បវេណី**នោះ។ ប្រសិនបើសេចក្តីសម្រេចជាសាលក្រម ឬ សាលដីកា ភស្តុតាងដែលបញ្ជាក់អំពីអាជ្ញាអស់ជំនុំគឺ មូលសាលក្រម។ ចំណែកឯសេចក្តីសម្រេចដែលជាសេចក្តីសម្រេចរបស់មជ្ឈត្តករ គឺមជ្ឈត្តវិនិច្ឆ័យ។

លិខិតដូចបានរៀបរាប់ខាងលើ គឺជាសេចក្តីសម្រេចដែលចេញដោយស្ថាប័នសាធារណៈ ជាអាទិ៍ តុលាការ, ក្រុមប្រឹក្សាអាជ្ញាកណ្តាល, គណៈកម្មការសុរិយោដីថ្នាក់ជាតិ និងខ្លះទៀតចេញដោយមជ្ឈត្តករ ដែលជាមន្ត្រីឯកជនដែលទទួលបាននីតិសម្បទាក្នុងការដោះស្រាយវិវាទ[184]។ ប្រសិនបើវាជាឯកសារសាធារណៈ វាត្រូវសន្មតថាត្រូវបានបង្កើតឡើងយ៉ាងត្រឹមត្រូវ ហើយតុលាការក៏ពុំធ្វើការពិនិត្យលើភាពត្រឹមត្រូវនៃឯកសារទាំងនោះដែរ[185]។ តុលាការគ្រាន់តែពិនិត្យ លើខ្លឹមសារនៃលិខិតទាំងនោះ ដើម្បីទាញយកធនធានភស្តុតាង (ការពិនិត្យលើខ្លឹមសារនៃសេចក្តីសម្រេចរដ្ឋប្បវេណី)។

---

[182] សាលាឧទ្ធរណ៍, សំណុំរឿងជំនុំជម្រះសាជាថ្មី លេខ៖ ១៩ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥, ដីកាសម្រេចលេខ៖ ១៦ “ក្រVIIង” ដកស ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ (សូមមើលឧបសម្ព័ន្ធ៩)

[183] មាត្រា ១២៣ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[184] មេធាវី ស៊ីវិន អ៊ែម អូស្មើរមីឡឺរ៍, *ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ : សៀវភៅសិក្សាស្តីពីទស្សនាទានសំខាន់ៗ*, បោះពុម្ពលើកទី២ (ភ្នំពេញ៖ ២០១០), ១៨៤ : មជ្ឈត្តករ ទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ទទួលបានអាជ្ញាប័ណ្ណ និងត្រូវស្ថិតក្រោមការគ្រប់គ្រងនៃ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (NCAC) ដែលស្ថិតក្រោមឱវាទក្រសួងពាណិជ្ជកម្ម។

[185] មាត្រា ១៥៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

ចំពោះឯកសារជាលិខិតសាលក្រម ឬ សាលដីកា ច្បាប់ដើមនៃលិខិតទាំងនោះ ត្រូវរក្សាទុកនៅតុលាការដែលបានចេញ ហេតុនេះដើម្បីយកលិខិតសាលក្រម ឬសាលដីកា ភាគីដែលមានបន្ទុកក្នុងការបញ្ជាក់អំពីអាជ្ញាអស់ជំនុំ ត្រូវដាក់ពាក្យសុំ ***ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃលិខិតសាលក្រម ឬ សាលដីកា***[186] ទៅក្រឡាបញ្ជីនៃតុលាការដែលបានចេញសាលក្រម ឬ សាលដីកានោះ[187]។ ចំណែកឯ ឯកសារចម្លងនៃសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីដែលពុំចេញដោយតុលាការ ភាគីត្រូវដាក់ពាក្យសុំពីស្ថាប័នដែលបានចេញសេចក្តីសម្រេចនោះ។ នៅពេលដែលទទួលបានឯកសារចម្លងនោះហើយ ភាគីដែលមានបំណងអះអាងអំពីអាជ្ញាអស់ជំនុំ ត្រូវភ្ជាប់ឯកសារចម្លងនោះ ជាមួយនឹងពាក្យសុំឱ្យពិនិត្យភស្តុតាង ដែលមានសរសេរអំពីចំណុចដែលខ្លួនចង់ឱ្យតុលាការពិនិត្យ ព្រមទាំងបំភ្លឺចំណុចនោះ[188]។

នៅក្នុងផ្នែក ៣.១.៣ នឹងបង្ហាញអំពីការប្រើប្រាស់ភស្តុតាងទាំងនេះដើម្បីបញ្ជាក់អំពីវិសាលភាពអាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី។

### ៣.១.៣ នីតិវិធីនៃការអះអាងអំពីអាជ្ញាអស់ជំនុំ

ប្រសិនបើបណ្តឹងថ្មីស្ថិតក្នុងវិសាលភាពនៃអាជ្ញាអស់ជំនុំ ប្រាកដណាស់ថាភាគីដែលនឹងខូចប្រយោជន៍ដោយសារបណ្តឹងថ្មីនោះនឹងអះអាងអំពីអាជ្ញាអស់ជំនុំ។ ភាគីត្រូវអះអាងអំពីអាជ្ញាអស់ជំនុំដោយអនុវត្តតាមគោលការណ៍នៃការទាញហេតុផល។

---

[186] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១: នីតិវិធីបណ្តឹង*, (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០០៨), ១១២ [... ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់... គឺជាឯកសារដែលបានចម្លងតាមខ្លឹមសារនៃច្បាប់ដើម (ឯកសារដើម) ទាំងស្រុងតែម្តង ហើយជាឯកសារបញ្ជាក់អំពីអត្ថិភាព ព្រមទាំងខ្លឹមសារនៃច្បាប់ដើម (ឯកសារដើម) នោះ។...]

[187] ក្រមនីតិវិធីរដ្ឋប្បវេណីពុំបានបញ្ជាក់ពីតួនាទីរបស់ក្រឡាបញ្ជីក្នុងការចេញឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ (authenticated copy) នេះឡើយ ប៉ុន្តែតាមការអនុវត្តជាក់ស្តែង ក្រឡាបញ្ជីជាអ្នកចេញ។ ការអនុវត្តបែបនេះ មានបញ្ញត្តជាក់លាក់នៅក្នុងមាត្រា ៣៣ នៃវិធាននីតិវិធីរបស់តុលាការកំពូលប្រទេសជប៉ុន។

ចំពោះទម្រង់នៃឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសាលក្រម (សូមមើលឯកសារឧបសម្ព័ន្ធ១)

[188] មាត្រា ១២៤ កថាខណ្ឌទី១ និងមាត្រា ១២៥ កថាខណ្ឌទី១ និងទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

តាមលំហូរនៃនីតិវិធីបណ្តឹង ក្រោយពេលទទួលបានការបញ្ជូនពាក្យបណ្តឹង ប្រសិនបើចុងចម្លើយយល់ឃើញថាការទាមទារថ្មីត្រូវបានហាមឃាត់ដោយអាជ្ញាអស់ជំនុំ ខ្លួនត្រូវសរសេរនៅក្នុងឯកសារចម្លើយរបស់ខ្លួននូវចំណុចដូចខាងក្រោម[189]៖

**១. អត្តសញ្ញាណរបស់ភាគី និង អ្នកតំណាងដែលច្បាប់បានកំណត់**

**២. ការឆ្លើយតបនឹងការទាមទាររបស់ដើមចោទ ៖** សុំឱ្យ **តុលាការច្រានចោលការទាមទារ**របស់ដើមចោទ ដោយមូលហេតុ ដើមចោទពុំអាចអនុវត្តសិទ្ធិទាមទារដូចបានសរសេរក្នុងពាក្យបណ្តឹងបានឡើយ ក៏ព្រោះតែការទាមទារនេះត្រូវបានតុលាការច្រានចោលម្តងរួចហើយនៅក្នុងសាលក្រមស្ថាពរលេខ xxx ចុះថ្ងៃទីxx ខែxx ឆ្នាំxxxx។

**៣. ការឆ្លើយតបនឹងអង្គហេតុដែលអះអាងដោយដើមចោទ ៖** ចុងចម្លើយអាច ធ្វើការទទួលស្គាល់ មិនទទួលស្គាល់ ឬអាចឆ្លើយថាមិនដឹង។ ការទទួលស្គាល់អង្គហេតុដែលអះអាងដោយដើមចោទ ពុំបានន័យថាចុងចម្លើយទទួលស្គាល់ការទាមទារទេ ហើយក៏ពុំបានសេចក្តីថាចុងចម្លើយនឹងមិនអះអាងអំពីអាជ្ញាអស់ជំនុំដែរ។

**៤. អង្គហេតុតវ៉ា (អង្គហេតុដែលនាំឱ្យមានអាជ្ញាអស់ជំនុំ) ៖** ចុងចម្លើយត្រូវលើកឡើងអំពីភាពដូចគ្នានៃភាគី កម្មវត្ថុ និង អង្គហេតុ នៃបណ្តឹងមុន និងបណ្តឹងក្រោយ។ ភាពដូចគ្នានៃចំណុចទាំងបីនេះធ្វើឱ្យការទាមទាររបស់ដើមចោទត្រូវបានរារាំងដោយអាជ្ញាអស់ជំនុំនៃសាលក្រមមុនហេតុនេះវាជាអង្គហេតុរារាំងសិទ្ធិ។

**៥. អង្គហេតុសំខាន់ៗដែលទាក់ទងនឹងអង្គហេតុតវ៉ា ៖** វាជាអង្គហេតុប្រយោល ដែលគាំទ្រអោយអង្គហេតុតវ៉ា។

**៦. ភស្តុតាង ៖** ដូចបានបកស្រាយនៅក្នុងផ្នែក៣.១.២ ភស្តុតាងនៃអាជ្ញាអស់ជំនុំ គឺជាឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសាលក្រម ឬសាលដីកាស្ថាពរ។ ចុងចម្លើយត្រូវភ្ជាប់ភស្តុតាងនេះជាមួយនឹងពាក្យសុំឱ្យតុលាការពិនិត្យភស្តុតាង។

ក្រោយពេលបញ្ជូនពាក្យបណ្តឹង និងឯកសារត្រៀមរវាងភាគីរួច តុលាការត្រូវបើកកាលបរិច្ឆេទត្រៀមដើម្បីទាញហេតុផលដោយផ្ទាល់មាត់។ នីតិវិធីត្រៀមមានគោលបំណងដើម្បីរៀបចំការអះអាង និងកំណត់ចំណុចវិវាទ ព្រមទាំងភស្តុតាងដើម្បីរួចរាល់សម្រាប់ការទាញហេតុផល។

[189] គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ, ក្រសួងយុត្តិធម៌, រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, និង សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, រៀបរៀង, *មេរៀនស្តីពី ក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២,* (ភ្នំពេញ៖ គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ ដំណាក់កាលទី៤ របស់ក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា និងទីភ្នាក់ងារ JICA, ២០១៦), ៣៧៥-៣៧៩

ការអះអាងអំពីអាជ្ញាអស់ជំនុំរបស់ចុងចម្លើយ នឹងធ្វើឱ្យវាក្លាយទៅជាចំណុចវិវាទមួយនៅក្នុងបណ្តឹង។ តុលាការត្រូវទាញហេតុផលចំពោះចំណុចវិវាទនេះ ដោយពិចារណាលើភាពដូចគ្នាជាសារធាតុ ៣ គឺ ភាគី កម្មវត្ថុ និងអង្គហេតុ។

វិវាទចំពោះអាជ្ញាអស់ជំនុំ គឺជាវិវាទបឋម (Preliminary issue) ដែលត្រូវវិនិច្ឆ័យមុនអង្គសេចក្តីនៃការទាមទាររបស់ដើមចោទ ក៏ព្រោះតែមុននឹងសម្រេចថាមាន អត្ថិភាព ឬនត្ថិភាពនៃសិទ្ធិទាមទាររបស់ដើមចោទ តុលាការត្រូវទទួលស្គាល់ជាមុនសិនថា ដើមចោទមិនត្រូវបានហាមឃាត់ឱ្យអនុវត្តសិទ្ធិទាមទារនោះដោយអានុភាពនៃអាជ្ញាអស់ជំនុំសារធាតុ។ និម្មិតថាតុលាការបានវិនិច្ឆ័យលើអង្គសេចក្តីមុនវិវាទអំពីអាជ្ញាអស់ជំនុំ ហើយរកឃើញដើមចោទមានសិទ្ធិនោះមែន ប៉ុន្តែក្រោយមកសម្រេចថាសិទ្ធិទាមទារត្រូវបានហាមឃាត់ដោយអានុភាពអាជ្ញាអស់ជំនុំ។ ការណ៍នេះធ្វើឱ្យការវិនិច្ឆ័យអំពីអត្ថិភាពនៃសិទ្ធិទាមទារ ក្លាយទៅជាឥតបានការ ដោយសារតែចុងក្រោយ វាត្រូវបានហាមឃាត់ដោយអាជ្ញាអស់ជំនុំ។

អាជ្ញាអស់ជំនុំគឺជា បុរេល័ក្ខខ័ណ្ឌដើម្បីចេញសាលក្រមលើអង្គសេចក្តីចំពោះការទាមទាររបស់ដើមចោទ។ ប្រសិនបើតុលាការពុំវិនិច្ឆ័យថាមានអត្ថិភាព ឬនត្ថិភាពនៃអាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចស្ថាពរមុន ចំពោះបណ្តឹងក្រោយ តុលាការក៏មិនអាចចេញសាលក្រមលើអង្គសេចក្តីបានដែរ។ ក្នុងករណីដែលអាជ្ញាអស់ជំនុំក្លាយទៅជាចំណុចវិវាទនៃបណ្តឹងក្រោយ តុលាការត្រូវធ្វើការទាញហេតុផលចំពោះអាជ្ញាអស់ជំនុំជាមុនសិន មុននឹងធ្វើការទាញហេតុផលចំពោះអង្គសេចក្តីនៃការទាមទាររបស់ដើមចោទ។ ប្រសិនបើតុលាការយល់ឃើញថាការទាមទារក្រោយរបស់ដើមចោទពុំស្ថិតក្នុងវិសាលភាពនៃអានុភាពអាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចស្ថាពរមុនទេ តុលាការត្រូវចេញសាលក្រមរបៀប[190]។ ផ្ទុយមកវិញ តុលាការត្រូវចេញសាលក្រមលើកចោល ប្រសិនបើតុលាការរកឃើញថា ការទាមទារនៃបណ្តឹងថ្មី ស្ថិតក្រោមវិសាលភាពអាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចរដ្ឋប្បវេណីមុន។ មូលហេតុដែលតុលាការត្រូវចេញសាលក្រមលើកចោលបណ្តឹង ដោយសារតែការបដិសេធបណ្តឹងផ្អែកលើអាជ្ញាអស់ជំនុំ គឺជាការសម្រេចផ្នែកសិទ្ធិនីតិវិធី (សិទ្ធិធ្វើបណ្តឹង) ដែលវាពុំផ្អែកលើសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ឬច្បាប់សារធាតុផ្សេងទៀតទេ (ក្រមរដ្ឋប្បវេណីពុំបានបញ្ញត្តអំពីការហាមឃាត់ការទាមទារនេះទេ)។

---

190 អាជ្ញាអស់ជំនុំគឺជាល័ក្ខខ័ណ្ឌបណ្តឹង ដោយសារតែ វាជាបុរេល័ក្ខខ័ណ្ឌដែលត្រូវវិនិច្ឆ័យមុនចេញសាលក្រមអង្គសេចក្តីហេតុនេះ តុលាការត្រូវវិនិច្ឆ័យលើអត្ថិភាព ឬនត្ថិភាពនៃអាជ្ញាអស់ជំនុំ ដោយចេញសាលក្រមរបៀប មុននឹងឈានដល់ការទាញហេតុផលលើអង្គសេចក្តី។ (មាត្រា ១៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា)

## ៣.២ ការវិនិច្ឆ័យអំពីចំណុចវិវាទនៃអាជ្ញាអស់ជំនុំ

ក្រោយពេលអាជ្ញាអស់ជំនុំត្រូវបានកំណត់ជាចំណុចវិវាទ តាមរយៈនីតិវិធីត្រៀមសម្រាប់ទាញហេតុផលរួចហើយ និងក្រោយពេលដែលភស្តុតាងនៃអាជ្ញាអស់ជំនុំត្រូវបានដាក់ តុលាការត្រូវវិនិច្ឆ័យអំពីអានុភាពនៃអាជ្ញាអស់ជំនុំនៃបណ្តឹងមុនចំពោះបណ្តឹងក្រោយ ថាតើការទាមទារនៃបណ្តឹងក្រោយស្ថិតនៅក្នុងវិសាលភាពនៃអានុភាពអាជ្ញាអស់ជំនុំនៃបណ្តឹងមុនដែរឬទេ។ ភាពដូចគ្នាទាំង៣ត្រូវបានយកមកពិចារណា ដើម្បីកំណត់អំពីវិសាលភាពនៃអាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចស្ថាពរមុន ៖

- ប្រធាន
- កម្មវត្ថុនៃការទាមទារ និង
- អង្គហេតុ

មូលដ្ឋានក្នុងការពិចារណាទាំង៣ខាងលើ មានភាពប្រហាក់ប្រហែលទៅនឹងល័ក្ខខ័ណ្ឌនៃ **បណ្តឹងជាន់គ្នា**[191] និង **អានុភាពនៃការដកពាក្យបណ្តឹង**[192] ដែរ ។ វាគ្រាន់តែខុសគ្នាត្រង់ចំណុច ភាពស្ថាពរនៃនីតិវិធី។ នៅក្នុងបណ្តឹងជាន់គ្នា គឺជាស្ថានភាពដែលមានបណ្តឹងត្រូវបានដាក់ដែលមានភាគីដដែល ការទាមទារដដែល ចំពោះតុលាការដដែល ឬផ្សេង នៅពេលដែលនីតិវិធីមួយទៀតកំពុងដំណើរការ។

### ៣.២.១ ភាពដូចគ្នានៃប្រធាន

ផ្នែក ២.១.១.៣. នៃជំពូកទី២ខាងលើ បានបកស្រាយអំពីវិសាលភាពប្រធានដែលទទួលអានុភាពនៃអាជ្ញាអស់ជំនុំ។ តាមរយៈការបកស្រាយនេះ ការកំណត់អំពីភាពដូចគ្នានៃប្រធាន ពុំសំដៅលើការកំណត់សញ្ញាណនៃបុគ្គលដែលជាភាគីនៃបណ្តឹងមុនទេ ព្រោះទស្សនទាននៃប្រធានដែលបានសម្តែងនេះ ពង្រីកវិសាលភាពរហូតដល់បុគ្គលដែលពុំមែនជាភាគីនៃបណ្តឹងដែលពុំបានចូលរួមក្នុងនីតិវិធីបណ្តឹងដើម្បីចេញសាលក្រមមុន ផងដែរ។

ក្នុងករណីដែលភាគីនៃបណ្តឹងថ្មី ពុំមែនជាភាគីនៃបណ្តឹងមុន ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសេចក្តីសម្រេចស្ថាពរ ពុំគ្រប់គ្រាន់ដើម្បីកំណត់ថា ភាគីនោះត្រូវចងដោយអានុភាពអាជ្ញាអស់ជំនុំឡើយ ព្រោះករណីមួយចំនួនបុគ្គលដែលទទួលវិសាលភាពនៃសេចក្តីសម្រេចស្ថាពរមុន ពុំបានសរសេរចូលក្នុងសេចក្តីសម្រេចនោះទេ។ ដូច្នេះ ភាគីដែលអះអាងអំពីអាជ្ញាអស់ជំនុំត្រូវរក

[191] មាត្រា ៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

[192] មាត្រា ២១៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

ភស្តុតាងដែលបញ្ជាក់ថា អាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចមុន ត្រូវមានអានុភាពចំពោះភាគីនៃបណ្តឹងក្រោយ ជាអាទ៍ហេតុដែលនាំឱ្យភាគីថ្មីនោះ ទទួលបន្តនូវសិទ្ធិ ឬ កាតព្វកិច្ច ឬហេតុដែលភាគីថ្មីនោះបានកាន់កាប់កម្មវត្ថុនៃការទាមទារនៅក្នុងបណ្តឹងមុន (ការអះអាងឱ្យត្រូវនឹងល័ក្ខខ័ណ្ឌនៃមាត្រា ១៩៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

ក្នុងករណីដែលមានការរួមបញ្ចូលគ្នារវាងនីតិបុគ្គល បុគ្គលភាពគតិយុត្តនៃនីតិបុគ្គលដែលជាភាគីនៅក្នុងបណ្តឹងមុនត្រូវរលត់ ហើយសិទ្ធិ និងកាតព្វកិច្ចដែលមាន ត្រូវទទួលបន្តដោយនីតិបុគ្គលថ្មី ហេតុនេះនីតិបុគ្គលថ្មីគឺជាបុគ្គលដែលទទួលវិសាលភាពនៃអាជ្ញាអស់ជំនុំ ទោះបីជាសញ្ញាណនៃនីតិបុគ្គលមានការផ្លាស់ប្តូរដោយការរួមបញ្ចូលគ្នាក៏ដោយ។ ទោះបីជាការរួមបញ្ចូលគ្នានោះប្រព្រឹត្តក្នុងអំឡុងពេលនៃនីតិវិធីមុនក៏ដោយ ក៏នីតិបុគ្គលថ្មីពុំអាចរួចផុតពីចំណងនៃអានុភាពស្ពាពរនៃសាលក្រម ឬសាលដីកាបានឡើយ។ នីតិបុគ្គលដែលកើតពីការរួមបញ្ចូលគ្នាពីនីតិបុគ្គលដែលជាភាគីនៃវិវាទ ក្នុងអំឡុងពេលដំណើរការនីតិវិធីបណ្តឹងមុន ត្រូវបានធានាសិទ្ធិទទួលបន្តនូវនីតិវិធីតាមមាត្រា ១៧៣ កថាខណ្ឌទី២ ចំណុច ខ។ ហេតុនេះច្បាប់បានធានានូវគោលការណ៍ចំពោះមុខ ចំពោះនីតិបុគ្គលនៃការរួមបញ្ចូលរួចហើយ[193]។ ដូចគ្នាផងដែរ ចំពោះសន្តតិជនដែលទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចពីមតកជនដែលជាភាគីនៃបណ្តឹងមុន។

តុលាការត្រូវពិនិត្យមើលនៅក្នុងភស្តុតាងដែលជា ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសាលក្រម ឬ សាលដីកា ឬសេចក្តីសម្រេចរដ្ឋប្បវេណីផ្សេងទៀត ដើម្បីទទួលបានព័ត៌មានអំពីសញ្ញាណនៃភាគី។ នៅក្នុងសាលក្រមមានបញ្ជាក់យ៉ាងច្បាស់អំពីសញ្ញាណនៃភាគី ហេតុនេះវាពុំចោទជាបញ្ហាចោទក្នុងការស្រាវជ្រាវទេ។ ប៉ុន្តែចំពោះបុគ្គលដែលបានកំណត់ក្នុងមាត្រា ១៩៨ ចំណុច ខ ពុំបានបញ្ចូលទៅក្នុងលិខិតសាលក្រមទេ[194]។ ហេតុនេះយើងមិនអាចដឹងអំពីសញ្ញាណនៃបុគ្គលនេះដោយគ្រាន់តែមើលក្នុងលិខិតសាលក្រមបានឡើយ។ ដោយហេតុថាការជ្រើសរើសភាគីធ្វើនៅក្នុងដំណាក់កាលនៃនីតិវិធី ដូច្នេះហេតុដែលភាគីបានជ្រើសរើសនេះ ត្រូវកត់ចូលទៅក្នុងកំណត់ហេតុនៃការទាញហេតុផល។ ភាគីអាចយកឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃកំណត់ហេតុនៃការទាញហេតុផល ដែលមានកត់ត្រាអំពីការជ្រើសរើសភាគីនេះ មកធ្វើជាភស្តុតាងដើម្បីបញ្ជាក់អំពីអង្គហេតុនៃការជ្រើសរើសភាគីបាន។

---

[193] បើបានធានាសិទ្ធិចំពោះមុខរួចហើយ បុគ្គលនោះត្រូវស្ថិតក្នុងវិសាលភាពនៃអាជ្ញាអស់ជំនុំ (ការបកស្រាយក្នុងផ្នែក ១.៣.១.២ នៃជំពូកទី១ ខាងលើ)

[194] មាត្រា ១៨៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

(មានតែសញ្ញាណនៃភាគីទេទើបត្រូវសរសេរចូលនៅក្នុងលិខិតសាលក្រម)

ចំណែកឯរឿងក្តីដែលទាក់ទងនឹងឋានៈបុគ្គលវិញ ដោយសារអានុភាពនៃសាលក្រម មានចំពោះតតិយជន[195] ហេតុនេះ ពុំចាំបាច់ស្វែងរកថាបុគ្គលនោះធ្លាប់ជាភាគី ឬ មិនធ្លាប់នោះទេ សាលក្រមនោះ នឹងមានចំណងចំពោះបុគ្គលទាំងអស់។ ហេតុនេះការពិចារណាអំពី ភាពដូចគ្នានៃភាគី ពុំមានភាពចាំបាច់ទេ នៅក្នុងរឿងក្តីឋានៈបុគ្គល។

ការកំណត់ពីភាពដូចគ្នានៃភាគី ពុំសំដៅលើឋានៈរបស់ភាគីនៃនីតិវិធីមុន និងក្រោយឡើយ។ ទោះបីជាដើមចោទ នៃបណ្តឹងមុន ប្តូរទៅជាចុងចម្លើយនៃបណ្តឹងក្រោយ ឬ ប្តូរពីអ្នកចូលរួមជួយអន្តរាគមន៍នៃបណ្តឹងមុន ទៅជាភាគីនៅក្នុងបណ្តឹងក្រោយ ក៏ដោយ ក៏ស្ថានភាពនេះនៅតែមានភាគីដូចគ្នាដដែល។

***ឧទាហរណ៍ ៖*** បណ្តឹងទី១ ដើមចោទ ទាមទារឱ្យចុងចម្លើយសងប្រាក់ $១០០០ផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ។ បណ្តឹងទី២ ចុងចម្លើយនៃបណ្តឹងមុន បានយកដើមចោទនៃបណ្តឹងមុន ធ្វើជាចុងចម្លើយ ដែលមានការទាមទារឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារថា បញ្ជាក់អំពីនត្ថិភាពនៃកាតព្វកិច្ច។

### ៣.២.២ ភាពដូចគ្នានៃការទាមទារ

មុខងារនៃអាជ្ញាអស់ជំនុំចម្បងគឺហាមឃាត់ការទាមទារ។ ប្រសិនបើខ្លឹមសារនៃការទាមទារនៅក្នុងបណ្តឹងមុនដូចគ្នា ឬផ្អែកលើមូលដ្ឋានដូចគ្នា ការទាមទារបែបនេះត្រូវបានហាមឃាត់ដោយអាជ្ញាអស់ជំនុំ។ ដើម្បីដឹងអំពីភាពដូចគ្នានៃការទាមទារ តុលាការត្រូវពិនិត្យមើលលើ ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និងអង្គហេតុជាមូលហេតុនៃការទាមទារ ដែលមានសរសេរនៅក្នុងពាក្យបណ្តឹង[196] និងខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់នៅក្នុងសេចក្តីសម្រេចមុន។ ត្រូវចាត់ទុកថាជាការទាមទារដូចគ្នា ប្រសិនបើខ្លឹមសារនៃការទាមទារ និងខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់ដូចគ្នាទាំងស្រុង ឬ ផ្អែកលើអង្គច្បាប់ដូចគ្នា ឬ ខ្លឹមសារនៃសិទ្ធិ និងទំនាក់ទំនងគតិយុត្ត ដូចគ្នា។

#### ៣.២.២.១ ភាពដូចគ្នាទាំងស្រុងនៃការទាមទារ

ដោយពិនិត្យមើលលើខ្លឹមសារនៃសេចក្តីសម្រេចមុន និងការទាមទារនៅក្នុងបណ្តឹងក្រោយ យើងអាចឃើញអំពីលក្ខណៈដូចគ្នានៃការទាមទារនេះហើយ។ ប៉ុន្តែប្រសិនបើនៅក្នុងបណ្តឹងមុន

[195] មាត្រា ១៧ កថាខណ្ឌទី១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ២០១០

[196] មាត្រា ៧៥ កថាខណ្ឌទី២ ចំណុចខ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

តុលាការចេញសាលក្រមច្រានចោលការទាមទារ នៅក្នុងផ្នែកនៃសេចក្ដីសម្រេចបញ្ចប់ តុលាការគ្រាន់តែសរសេរ **ច្រានចោលការទាមទាររបស់ដើមចោទ** ហេតុនេះយើងពុំអាចដឹងអំពីខ្លឹមសារនៃការទាមទារតាមរយៈការពិនិត្យមើលលើផ្នែកសេចក្ដីបញ្ចប់តែមួយបានទេ ទោះបីជាវាជាចំណុចដែលមានអាជ្ញាអស់ជំនុំក្ដី។ នៅក្នុងផ្នែក អង្គហេតុ និងចំណុចវិវាទនៃសាលក្រម មានកត់ត្រាអំពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ ហេតុនេះសេចក្ដីសម្រេចច្រានចោលការទាមទារគឺជាការឆ្លើយតបទៅនឹងការទាមទាររបស់ដើមចោទ។ ដូច្នេះយើងអាចមើលលើផ្នែក អង្គហេតុ និងចំណុចវិវាទនេះ ដើម្បីកំណត់អំពីខ្លឹមសារនៃការទាមទារនៅក្នុងបណ្ដឹងមុនបាន។

ស្ដីពីការទាមទារមួយភាគ ដូចបានពន្យល់ក្នុងផ្នែក ២.១.១.១. ចំណុច គ ខាងដើម ទោះបីជាពុំមានបទប្បញ្ញត្តិច្បាប់ជាក់លាក់ចែងហាមឃាត់ចំពោះការទាមទារមួយភាគក៏ពិតមែន ក៏គប្បីបកស្រាយថា ការទាមទារភាគនៃសិទ្ធិដែលនៅសល់ក្រោយការទាមទារមុន ត្រូវបានហាមឃាត់ដោយអានុភាពអាជ្ញាអស់ជំនុំ។ ហេតុនេះ ទោះបីជាមានសាលក្រមសម្រេចចំពោះការទាមទារមួយភាគក៏ដោយ ប្រសិនបើមានការទាមទារភាគដែលនៅសល់ ត្រូវចាត់ទុកថាជាការទាមទារដូចគ្នា ហើយត្រូវហាមឃាត់ចំពោះការទាមទារប្រភេទនេះ។

### ៣.២.២.២ ភាពដូចគ្នាទាំងស្រុងនៃអង្គច្បាប់

បើពាក្យបណ្ដឹងរបស់ដើមចោទមានសរសេរនូវអង្គហេតុចាំបាច់បញ្ជាក់ការទាមទារ ដូចទៅនឹងអង្គច្បាប់ដែលតុលាការផ្អែកដើម្បីចេញសាលក្រមមុន វាគឺជាភាពដូចគ្នានៃអង្គច្បាប់។ ផ្ទុយទៅវិញប្រសិនបើដើមចោទ បានផ្លាស់ប្ដូរអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ ការណ៍នេះមិនត្រូវចាត់ទុកថាមានភាពដូចគ្នានៃអង្គច្បាប់ឡើយ។

***<u>ឧទាហរណ៍</u> ៖*** ប្រសិននៅក្នុងបណ្ដឹងមុន ដើមចោទ បានទាមទារឱ្យចុងចម្លើយសងប្រាក់ ១០០០$ ហើយនៅក្នុងអង្គហេតុចាំបាច់បញ្ជាក់ការទាមទារ ដើមចោទបានលើកឡើងអំពី**កិច្ចសន្យាខ្ចីបរិភោគ**។ សន្មតថាតុលាការបានច្រានចោលការទាមទារនេះ ដោយសារតែខ្វះល័ក្ខខ័ណ្ឌសារធាតុដែលអាចទាមទារផ្អែកលើកិច្ចសន្យាខ្ចីបរិភោគបាន។ ក្រោយមក ដើមចោទបានដាក់ពាក្យបណ្ដឹងដែលមានកម្មវត្ថុដដែល ទាមទារឱ្យចុងចម្លើយសងប្រាក់ ១០០០$ ប៉ុន្តែនៅក្នុងអង្គហេតុចាំបាច់បញ្ជាក់ការទាមទារ ដើមចោទបានលើកឡើងអំពី**សេចក្ដីចម្រើនដោយឥតហេតុ**វិញ។ ការដាក់បណ្ដឹងក្រោយនេះ ពុំត្រូវចាត់ទុកថាជាការទាមទារដូចគ្នាទេ ទោះបីជាខ្លឹមសារនៃការទាមទារដូចគ្នាទាំងស្រុង ប៉ុន្តែវាផ្អែកលើអង្គច្បាប់ខុសគ្នា (កិច្ចសន្យាខ្ចីបរិភោគ និង សេចក្ដីចម្រើនដោយឥតហេតុ)។

### ៣.២.២.៣ ភាពដូចគ្នានៃខ្លឹមសារនៃសិទ្ធិ និង ទំនាក់ទំនងគតិយុត្ត

ក្រៅពីភាពដូចគ្នាទាំងពីរខាងលើ ត្រូវចាត់ទុកថាមានការទាមទារដូចគ្នាផងដែរ ប្រសិនបើខ្លឹមសារនៃសិទ្ធិ និងទំនាក់ទំនងគតិយុត្ត ដែលជាកម្មវត្ថុនៃការទាមទារនៃបណ្តឹងក្រោយ ដូចគ្នាទៅនឹងការទាមទារនៅក្នុងបណ្តឹងមុន។ បើគ្រាន់តែប្តូរកម្មវត្ថុនៃការទាមទារ ប៉ុន្តែខ្លឹមសារនៅតែដូចបណ្តឹងមុន ក៏ត្រូវចាត់ទុកថាមានភាពដូចគ្នានៃការទាមទារដែរ។

***<u>ឧទាហរណ៍</u> ៖*** ដើមចោទបានធ្វើបណ្តឹងទាមទារឱ្យចុងចម្លើយ **ផ្តល់តាវកាលិកនូវទឹកប្រាក់ចំនួន ១០០០$** ហើយទទួលបានសាលក្រមតាមការទាមទារ។ ក្រោយពេលសាលក្រមចូលជាស្ថាពរ ចុងចម្លើយបានដាក់ពាក្យបណ្តឹងដោយយកដើមចោទនៅក្នុងបណ្តឹងមុនធ្វើជាចុងចម្លើយ ហើយខ្លឹមសារនៃសាលក្រម ដែលដើមចោទនៃបណ្តឹងថ្មីទាមទារ គឺ ទាមទារឱ្យតុលាការចេញសាលក្រម **បញ្ជាក់អំពីនត្ថិភាពនៃកាតព្វកិច្ច**។ ប្រសិនបើយើងប្រៀបធៀបខ្លឹមសារនៃការទាមទារ វាមានភាពខុសគ្នាយ៉ាងស្រឡះ ពោលគឺ ការទាមទារឱ្យផ្តល់តាវកាលិក និង ការទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃកាតព្វកិច្ច។ ប៉ុន្តែ ការទាមទារបញ្ជាក់អំពីនត្ថិភាពនៃកាតព្វកិច្ច គឺមានកម្មវត្ថុផ្អែកលើសិទ្ធិទាមទារដែលត្រូវបានតុលាការសម្រេចថាមានអត្ថិភាពរួចទៅហើយ ហេតុនេះ វាគឺជាការទាមទារដែលមានភាពដូចគ្នានៃខ្លឹមសារនៃសិទ្ធិ និងទំនាក់ទំនងគតិយុត្ត។

នៅក្នុងសាលក្រមក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ១៤៦៩ របស់សាលាដំបូងរាជធានីភ្នំពេញ ដើមចោទបានដាក់បណ្តឹងនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១១ កម្មវត្ថុនៃការទាមទារ សុំបែងចែកកូន និង បែងចែកទ្រព្យសម្បត្តិរួម។ ចុងចម្លើយបានដាក់បណ្តឹងតបដែលផ្អែកលើការទាមទារដូចគ្នា។ ក្នុងសំអាងហេតុចំណុចទី៤ តុលាការបានសម្រេចថា ៖

> "កម្មវត្ថុនៃបណ្តឹងតប ចុះថ្ងៃទី ១៧.១០.២០១១ របស់ចុងចម្លើយឈ្មោះ គ ឡ គឺមាន[**ចំណុចដូចគ្នា**] ទៅនឹងកម្មវត្ថុនៃបណ្តឹង ចុះថ្ងៃទី ២០.០៩.២០១១ របស់ដើមចោទឈ្មោះ ទ ម។ ដូច្នេះ បណ្តឹងតប ចុះថ្ងៃទី១៧.១០.២០១១ របស់ចុងចម្លើយឈ្មោះ គ ឡ គឺគ្មានការទាក់ទងនឹងការប្តឹងទាមទារដែលជាកម្មវត្ថុនៃបណ្តឹងដើម ឬជាមធ្យោបាយការពារខ្លួនឡើយ។ គប្បី តុលាការមិនពិចារណា។"[197]

[197] សាលាដំបូងរាជធានីភ្នំពេញ, សំណុំរឿងលេខ៖ ១៤៦៩ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១១, សាលក្រមលេខ៖ ៤៥ "ប" ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១១ (សូមមើលឧបសម្ព័ន្ធ១)

ការបកស្រាយខាងលើគឺជាការសម្រេចចំពោះបណ្ដឹងជាន់គ្នា ប៉ុន្តែយើងអាចយកមកប្រដូចនឹងការវិនិច្ឆ័យអំពីភាពដូចគ្នានៃកម្មវត្ថុ ចំពោះការកំណត់វិសាលភាពនៃអានុភាពអាជ្ញាអស់ជំនុំបាន ដោយសារតែវាមានលក្ខណៈដូចគ្នា[198]។

### ៣.២.៣. ភាពដូចគ្នានៃអង្គហេតុ

ក្រៅពីភាពដូចគ្នានៃប្រធាន និងការទាមទារ ដើម្បីកំណត់អំពីវិសាលភាពនៃអាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចមុន តុលាការត្រូវមើលលើ ភាពដូចគ្នានៃអង្គហេតុ។ ទោះបីជាមានភាពដូចគ្នានៃប្រធាន និងការទាមទារ ប៉ុន្តែបើបណ្ដឹងថ្មីនោះផ្អែកលើអង្គហេតុដែលកើតឡើងក្រោយកាលបរិច្ឆេទនៃការបញ្ចប់ការទាញហេតុផលលើអង្គសេចក្តីនៃសិទ្ធិទាមទារ អង្គហេតុនេះ ពុំរាំងភាគីមិនឱ្យធ្វើបណ្តឹងថ្មី ទោះបីជាមានការទាមទារ និងភាគីដូចគ្នាយ៉ាងណាក្តី។

កាលបរិច្ឆេទនៃការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ គឺជាពេលវេលាចុងក្រោយដែលតុលាការវិនិច្ឆ័យអំពីសិទ្ធិ និងទំនាក់ទំនងគតិយុត្តដែលមានវិវាទ ដោយផ្អែកលើអង្គហេតុដែលភាគីបានលើកឡើង និងភស្តុតាងដែលបានដាក់។ ហេតុនេះប្រសិនបើ ភាគីនៅតែអះអាងអំពីអង្គហេតុដដែល ឬមួយក៏អង្គហេតុដែលគួរតែបានលើកឡើងនៅក្នុងនីតិវិធីមុន តែបែរជាមិនបានលើកឡើង អង្គហេតុបែបនេះត្រូវចាត់ទុកថាមានភាពដូចគ្នានឹងអង្គហេតុក្នុងបណ្តឹងមុន ហើយវាត្រូវហាមឃាត់ដោយអាជ្ញាអស់ជំនុំ។ ប៉ុន្តែបើមានហេតុដែលកើតឡើងក្រោយការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ដែលធ្វើឱ្យសិទ្ធិ និងទំនាក់ទំនងគតិយុត្តដែលមានវិវាទផ្លាស់ប្តូរ អង្គហេតុថ្មីនោះត្រូវបានអនុញ្ញាតឱ្យលើកឡើង ក៏ព្រោះតែវាស្ថិតនៅក្រៅវិសាលភាពផ្នែកពេលវេលានៃអាជ្ញាអស់ជំនុំ[199]។

***ឧទាហរណ៍*** ៖ តុលាការបានបិទបញ្ចប់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់លើកចុងក្រោយនៅថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០១១ ហើយចេញសាលក្រមទទួលស្គាល់ការទាមទាររបស់ដើមចោទ (សាលក្រមបង្គាប់ឱ្យចុងចម្លើយសងប្រាក់១០០០$ ទៅដើមចោទផ្អែកលើកិច្ចសន្យាលក់ទិញ)។ ក្រោយមកនៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០១១ ចុងចម្លើយបានទទួលការលើកលែងកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងខាងលើ ពីដើមចោទ។ ចុងចម្លើយបានដាក់ពាក្យបណ្តឹងទាមទារបញ្ជាក់អំពីនត្ថិភាពនៃកាតព្វកិច្ចចំនួន ១០០០$ ដោយអះអាងអំពីអង្គហេតុនៃការលើកលែងដែល

[198] Prof Uchiyama, និង Prof Higashio Kazuyukii, *បញ្ហានានាដែលមាននៅក្នុងរឿងក្តីរដ្ឋប្បវេណី*, (ភ្នំពេញ ៖ក្រសួងយុត្តិធម៌ និង វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ, ២០១៦), ១២៣

[199] មាត្រា ១៩៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

កើតក្រោយពេលបញ្ចប់ការទាញហេតុផលផ្ទាល់មាត់។ ការអះអាងអង្គហេតុនេះត្រូវទទួលស្គាល់ ហើយការទាមទារបញ្ជាក់អំពីនត្ថិភាពនៃកាតព្វកិច្ចពុំស្ថិតក្នុងវិសាលភាពអាជ្ញាអស់ជំនុំសារធាតុនៃសាលក្រមបង្គាប់ឱ្យសងប្រាក់ ១០០០$ ខាងលើនេះទេ។

អង្គហេតុភាគីគួរតែត្រូវបានអះអាង មុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ប៉ុន្តែខកខានមិនបានអះអាង ភាគីត្រូវបានរារាំងសិទ្ធិក្នុងការអះអាងអង្គហេតុនោះនៅក្នុងនីតិវិធីក្រោយទៀត។ នៅក្នុងនីតិវិធីឧបាស្រ័យ ដែលគោរពប្រព័ន្ធនៃការជំនុំជម្រះបន្ត អង្គហេតុដែលភាគីអាចលើកឡើងនៅក្នុងនីតិវិធីនៃការជំនុំជម្រះលើកទី១ ប៉ុន្តែមិនបានលើកឡើង បើមានការដាក់ការអះអាងនេះនៅពេលក្រោយ តុលាការនៃបណ្តឹងឧបាស្រ័យមានឆន្ទានុសិទ្ធិច្រានចោលការអះអាងនេះ ដោយហេតុថាវាបង្កប់នូវចេតនាមិនសុចរិតរបស់ភាគី។[200] ជាការសន្និដ្ឋានផ្អែកលើគោលគំនិតដើមនៃការបដិសេធការអះអាងដែលបានដាក់ក្នុងពេលមិនសមស្របនេះ ការកំណត់អំពីភាពដូចគ្នានៃអង្គហេតុ ក៏ត្រូវពិចារណាអំពីការហាមឃាត់មិនឱ្យដាក់ការអះអាងចំពោះចំណុចដែលភាគីមានកំហុសក្នុងការខកខានមិនបានដាក់នៅក្នុងនីតិវិធីមុនផងដែរ។

***<u>ឧទាហរណ៍</u> ៖*** នៅក្នុងបណ្តឹងមុន ដើមចោទបានទាមទារឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារថា បង្គាប់ឱ្យចុងចម្លើយសងប្រាក់ចំនួន ១០០០$ ផ្អែកលើកិច្ចសន្យាលក់ទិញ។ នៅក្នុងនីតិវិធីនៃបណ្តឹងមុន មុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០១៥ ដើមចោទខកខានមិនបានអះអាងអំពីអង្គហេតុនៃការប្រគល់វត្ថុ(រថយន្ត) ជាហេតុធ្វើឱ្យតុលាការចេញសាលក្រមច្រានចោលការទាមទារ។ បន្ទាប់មកដើមចោទបានដាក់បណ្តឹងទាមទារសាជាថ្មីដែលមានកម្មវត្ថុដដែល ហើយនៅក្នុងពាក្យបណ្តឹងខ្លួនបានអះអាងអំពីអង្គហេតុនៃការប្រគល់រថយន្ត ដែលកើតឡើងនៅថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១៥។

តាមរយៈអង្គហេតុនិម្មិតខាងលើ អង្គហេតុនៃការប្រគល់រថយន្តពុំបានលើកឡើងនៅក្នុងនីតិវិធីនៃបណ្តឹងមុនទេ ប៉ុន្តែវាត្រូវបានលើកឡើងនៅក្នុងនីតិវិធីនៃបណ្តឹងក្រោយ។ ប្រសិនបើធ្វើការប្រៀបធៀបអង្គហេតុនៃនីតិវិធីមុន និងក្រោយ ពុំដូចគ្នាទេ។ ទោះបីជាយ៉ាងនេះក្តី ដើមចោទនៅតែត្រូវបានរារាំងមិនឱ្យអះអាងអំពីអង្គហេតុប្រគល់រថយន្តនេះ ដោយផ្អែកលើទស្សនៈសម្តែងនៅក្នុងកថាខណ្ឌមុន។

---

[200] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១: នីតិវិធីបណ្តឹង*, (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌, ២០០៨), ២១២

យើងអាចសន្និដ្ឋានបានថា ពេលវេលាជាមូលដ្ឋាននៃអាជ្ញាអស់ជំនុំដែលបញ្ញត្តក្នុងមាត្រា ១៩៤ កថាខណ្ឌទី២ កំណត់យកពេលវេលាដែលជាការកើតឡើងនៃអង្គហេតុ ទោះបីជាវាពុំត្រូវបាន លើកឡើងជាចំណុចវិវាទនៃក្នុងនីតិវិធីនៃបណ្តឹងមុនយ៉ាងណាក្តី។

ជាសេចក្តីសន្និដ្ឋានចំពោះខ្លឹមសារដែលបានរៀបរាប់ក្នុងជំពូកនេះ ដែលមានដូចជា វិធានភស្តុតាងដែលត្រូវយកមកអនុវត្តចំពោះការលើកឡើងនៃអាជ្ញាអស់ជំនុំ គោលការណ៍នៃបន្ទុកក្នុងការបញ្ជាក់ ព្រមទាំងនីតិវិធីនៅក្នុងការអះអាងអំពីអាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី និង ចំណុចជាសារធាតុដែលតុលាការត្រូវវិនិច្ឆ័យដើម្បីចេញសេចក្តីសម្រេចចំពោះអាជ្ញាអស់ជំនុំ យើងអាចមើលឃើញដោយជាក់ស្តែងអំពីការយកបទប្បញ្ញត្តិអាជ្ញាអស់ជំនុំនេះ ទៅអនុវត្តនៅក្នុងនីតិវិធីរដ្ឋប្បវេណីជាក់ស្តែង ដើម្បីជាប្រយោជន៍ដល់ការហាមឃាត់ការកកើតឡើងវិញនូវវិវាទដែលត្រូវបានបញ្ចប់ជាស្ថាពរ។ ការយកមកអនុវត្តឱ្យបានត្រឹមត្រូវនៃបទប្បញ្ញត្តិស្តីពីអាជ្ញាអស់ជំនុំនេះនឹងជួយឱ្យវិវាទរដ្ឋប្បវេណីត្រូវបានកាត់បន្ថយ ស្របពេលជាមួយគ្នានោះ វាក៏បានធ្វើឱ្យប្រជាពលរដ្ឋមានភាពជឿទុកចិត្តលើប្រព័ន្ធយុត្តាធិការ ថាពិតជាអាចបញ្ចប់វិវាទរបស់ពួកគេដោយមានប្រសិទ្ធភាព។

# សេចក្ដីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយខាងលើ អាជ្ញាអស់ជំនុំដើរតួនាទីយ៉ាងសំខាន់នៅក្នុងការធានាការបញ្ចប់វិវាទរវាងបុគ្គលឯកជន ជាស្ថាពរ។ សារណានេះបានរកឃើញនូវមធ្យោបាយក្នុងការបកស្រាយអំពីចរិតលក្ខណៈនៃអាជ្ញាអស់ជំនុំតាមក្រមនីតិវិធីកម្ពុជា ក៏ដូចជាអត្ថន័យនៃការយកមកអនុវត្តដូចគ្នា ចំពោះសេចក្ដីសម្រេចផ្សេងទៀតក្រៅពីសាលក្រម ឬសាលដីកា។ វាក៏បានពន្លាតអត្ថន័យឱ្យកាន់តែធំទូលាយ និងច្បាស់លាស់បន្ថែមទៀត ផ្អែកលើមូលដ្ឋានដែលជាគោលគំនិតដើមនៃប្រទេសដើមកំណើតនីតិកម្មក្រមនីតិវិធីរដ្ឋប្បវេណី និងទស្សនៈល្អៗនៃបណ្ដាប្រទេសមានប្រព័ន្ធច្បាប់ជឿនលឿន ចំពោះបទប្បញ្ញត្តិតែមួយគត់ដែលអភិបាលរបបអាជ្ញាអស់ជំនុំនៅកម្ពុជា។ ម្យ៉ាងទៀត ភាពមិនច្បាស់លាស់នៃបញ្ញត្តិអនុវត្តដូចគ្នា ក៏ត្រូវបានបកស្រាយឱ្យមានលក្ខណៈសមស្របទៅនឹងចរិតលក្ខណៈនៃសេចក្ដីសម្រេចនោះផងដែរ។ មិនតែប៉ុណ្ណោះ វាក៏បានបង្ហាញអំពីការយកបទប្បញ្ញត្តិនេះទៅអនុវត្តទៅតាមលំហូរនៃនីតិវិធីរដ្ឋប្បវេណី ចាប់តាំងពីការដាក់ឯកសារត្រៀមរហូតដល់ការចេញសាលក្រមសម្រេចលើអាជ្ញាអស់ជំនុំ។

នៅក្នុងទំនាក់ទំនងជីវភាពសាមញ្ញ វត្តមាននៃអាជ្ញាអស់ជំនុំ បានជួយការពារផលប្រយោជន៍ឯកជនរបស់ប្រជាពលរដ្ឋ និងធ្វើអោយពួកគាត់មានជំនឿទុកចិត្តលើប្រព័ន្ធតុលាការ ដោយសារតែវាហាមឃាត់មិនឱ្យមានការលើកឡើងនូវវិវាទដដែល ដែលត្រូវបានតុលាការសម្រេចជាស្ថាពររួចហើយ មកធ្វើវិវាទម្ដងទៀតទេ។ បើយើងពិនិត្យឱ្យកាន់ស៊ីជម្រៅទៅទៀត ភាពច្បាស់លាស់នៃលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងការយកបទប្បញ្ញត្តិទាំងនោះមកអនុវត្តត្រឹមត្រូវ នឹងទាក់ទាញឱ្យពាណិជ្ជករ ក្រុមហ៊ុនវិនិយោគជាតិ និងបរទេស មកធ្វើសកម្មភាពពាណិជ្ជកម្មនៅកម្ពុជាកាន់តែច្រើន ដោយសារតែ ពួកគេមានភាពជឿទុកចិត្តទៅនឹងប្រព័ន្ធដោះស្រាយវិវាទ ថាពិតជាអាចបញ្ចប់វិវាទរបស់ពួកគេយ៉ាងមានប្រសិទ្ធភាព។ ទាំងនេះជាការចូលរួមចំណែកមួយដល់កំណើនសេដ្ឋកិច្ចជាតិ ព្រោះកាលបើបុគ្គលឯកជនមានជំនឿទុកចិត្តលើប្រព័ន្ធច្បាប់ ពួកគេនឹងមិនមានការរារែកចិត្តក្នុងការបង្កើតសកម្មភាពប្រតិបត្តិការសេដ្ឋកិច្ច នោះឡើយ។

ទន្ទឹមនឹងការចូលរួមចំណែកនៃប្រព័ន្ធនីតិវិធីរដ្ឋប្បវេណីនៅក្នុងសេដ្ឋកិច្ចជាតិ វាក៏ជួបប្រទះភាពខ្វះខាត ដែលគួរតែបំពេញបន្ថែមទៀត។ នៅបណ្ដាប្រទេសជឿនលឿន ដើម្បីឱ្យមានភាពច្បាស់លាស់ក្នុងការអនុវត្ត តុលាការកំពូលបានដាក់ចេញនូវវិធាននីតិវិធីរដ្ឋប្បវេណី (Rule of Civil Procedure) សម្រាប់តុលាការគ្រប់ជាន់ថ្នាក់ អនុវត្តតាម ដែលវាអាចធានាភាពត្រឹមត្រូវក្នុងការអនុវត្តក្រមនីតិវិធីរដ្ឋប្បវេណី។ ចំណែកឯប្រព័ន្ធនីតិវិធីរដ្ឋប្បវេណីរបស់កម្ពុជា ពុំមានវត្តមាននូវយន្តការនេះឡើយ ដែលជាហេតុនាំឱ្យការអនុវត្ត នៅតែមានភាពមិនច្បាស់លាស់ត្រង់ចំណុចមួយចំនួន។

# អនុសាសន៍

តាមរយៈការសិក្សាស្រាវជ្រាវលើប្រធានបទ ស្តីពី **«អាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី»** ខ្ញុំបាទសូមផ្តល់ជាអនុសាសន៍ក្នុងន័យកែលម្អ ដើម្បីជាប្រយោជន៍ដល់ការអភិវឌ្ឍប្រព័ន្ធច្បាប់នៅកម្ពុជា។

ជាបឋម ខ្ញុំយល់ឃើញថា ក្រសួងយុត្តិធម៌ និង ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គួរបង្កើតជាប្រព័ន្ធក្នុងការចងក្រងប្រមូលផ្តុំសេចក្តីសម្រេចរដ្ឋប្បវេណីទាំងឡាយ និងផ្សព្វផ្សាយឱ្យបានយ៉ាងទូលំទូលាយ តាមរយៈគេហទំព័រ ឬព្រឹត្តបត្រគតិយុត្តប្រចាំខែ ដើម្បីជាប្រយោជន៍ដល់ ការធ្វើសេចក្តីសម្រេចផ្សេងៗទៀត ក៏ដូចជាដល់ការសិក្សាស្រាវជ្រាវ អភិវឌ្ឍន៍ទ្រឹស្តី ដូចដែលបណ្តាប្រទេសដទៃបានកំពុងតែអនុវត្ត។ ជាផលវិបាកនៃការតាក់តែងស្នាដៃនេះ គឺកង្វះខាតឯកសារដែលជាសេចក្តីសម្រេចរបស់តុលាការ។ នៅក្នុងការបកស្រាយអំពីអាជ្ញាអស់ជំនុំ សៀវភៅរបស់បរទេស អ្នកនិពន្ធពឹងផ្អែកយ៉ាងសំខាន់ទៅលើសេចក្តីសម្រេចរបស់តុលាការ ជាពិសេសការយល់ឃើញរបស់តុលាការចំពោះបទប្បញ្ញត្តិស្តីពីអាជ្ញាអស់ជំនុំ។

ស្ថាប័នដែលពាក់ព័ន្ធនឹងវិស័យតុលាការ គួរតាក់តែងនូវវិធាននីតិវិធីរដ្ឋប្បវេណី (Rule of Civil Procedure) ដើម្បីបញ្ញត្តបំពេញបន្ថែមចំពោះខ្លឹមសារដែលមានភាពមិនច្បាស់លាស់ និងចន្លោះប្រហោងនៃបទប្បញ្ញត្តិក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។ តាមការអនុវត្តនៅបណ្តាប្រទេសជឿនលឿន ជាអាទិ៍ ប្រទេសជប៉ុន វិធាននេះ ត្រូវបានដាក់ចេញដោយតុលាការកំពូល ហើយវាជាវិធាននីតិវិធីដែលមានលក្ខណៈបត់បែន ដោយសារតែវាមិនមែនជាច្បាប់ដែលត្រូវការចាំបាច់អនុម័តពីសភាជាតិ អាចធ្វើការកែប្រែដោយងាយស្រួល។ វត្តមាននៃវិធាននេះអាចនឹងជួយឱ្យការអនុវត្តតាមទំលាប់របស់មន្ត្រីអនុវត្តច្បាប់ ប្រែទៅជាការអនុវត្តតាមគន្លងច្បាប់ និងប្រែក្លាយភាពស្រពិចស្រពិលទាំងឡាយទៅជាភាពច្បាស់លាស់។

បន្ថែមពីនេះទៀត ក្រសួងស្ថាប័នដែលពាក់ព័ន្ធ គួរសហការជាមួយនឹងក្រសួងយុត្តិធម៌ នៅក្នុងគម្រោងតាក់តែងច្បាប់ស្តីពីនីតិវិធីដោះស្រាយវិវាទក្នុងទំនាក់ទំនងពិសេសនីមួយៗ ដូចជា នីតិវិធី ក្នុងការដោះស្រាយបណ្តឹងឧបាស្រ័យចំពោះសេចក្តីបង្គាប់របស់អាជ្ញាកណ្តាល ឬ នីតិវិធីតុលាការក្នុងការដោះស្រាយវិវាទពាណិជ្ជកម្ម ជាអាទិ៍ ឱ្យមានលក្ខណៈពិសេស ច្បាស់លាស់ ដាច់ដោយឡែកពីវិធាននីតិវិធីទូទៅ។ នីតិវិជ្ជមានបច្ចុប្បន្ន តាមរយៈច្បាប់ស្តីពីការរៀបចំអង្គការតុលាការ បានបញ្ញត្តឱ្យយកបញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី ទៅអនុវត្តចំពោះនីតិវិធីពិសេសទាំងនោះ ក្នុងអន្តរកាល ដែលមិនទាន់មានច្បាប់នីតិវិធី សម្រាប់អភិបាលវិវាទពិសេសនីមួយៗ ទោះបីជាចរិតលក្ខណៈ

នៃនីតិវិធីទាំងនោះមានភាពខុសគ្នាយ៉ាងណាក្តី។ ហេតុនេះវាបង្កើតឱ្យមានភាពកាន់តែច្បាស់លាស់ថែមទៀត ប្រសិនបើមានបញ្ញត្តិស្តីពីនីតិវិធីជាក់លាក់។

ទន្ទឹមនឹងនេះ អង្គវិនិច្ឆ័យទាំងឡាយ មិនថាតុលាការ ឬមជ្ឈត្តការ គួរបង្កើតជាសេចក្តីសន្និដ្ឋាន ការយល់ឃើញ ចំពោះអាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចរបស់ខ្លួន ដើម្បីឱ្យមានភាពច្បាស់លាស់ដល់ការសម្រេចសេចក្តីនៅក្នុងសំណុំរឿងក្រោយៗទៀត ព្រោះច្បាប់ ពុំមែនជាអ្វីដែលឥតខ្ចោះទេ ហើយក៏វាពុំធានាថាត្រូវបានគ្របដណ្តប់គ្រប់រូបភាពនៃវិវាទដែរ។ ជាឧទាហរណ៍ដ៏ល្អមួយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលស្ថាប័ននេះមានប្រព័ន្ធចងក្រងទិន្នន័យសេចក្តីសម្រេច និងផ្សព្វផ្សាយបានយ៉ាងទូលាយ ព្រមទាំងបង្កើតសេចក្តីបង្គាប់របស់ខ្លួនឱ្យទៅជាយុត្តិសាស្ត្រ ដើម្បីជាប្រយោជន៍ដល់ការដោះស្រាយវិវាទក្រោយៗ ដែលជាភាពខ្វះចន្លោះរបស់ច្បាប់។

# ឯកសារយោង

- **លិខិតបទដ្ឋានគតិយុត្ត**
  - **ច្បាប់ជាតិ**
    - រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
    - ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦
    - ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧
    - ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
    - ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៤
    - ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១០/០១៣ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០
    - ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១០/០០៨ ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០
    - ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១០ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៦
    - ច្បាប់ស្តីពីការងារ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧
    - ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ប្រកាសឱ្យប្រើដោយក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ (និរាករណ៍)
  - **ច្បាប់បរទេស**
    - ក្រមនីតិវិធីរដ្ឋប្បវេណីប្រទេសជប៉ុន (Code of Civil Procedure)
    - ក្រមនីតិវិធីរដ្ឋប្បវេណីប្រទេសអាឡឺម៉ង់ (Zivilprozessordnung-ZPO)
    - ច្បាប់ស្តីពីនីតិវិធីរឿងក្តីគ្រួសារប្រទេសជប៉ុន (Domestic Relation Case Procedure Act)

- វិធាននីតិវិធីរដ្ឋប្បវេណីនៃតុលាការកំពូលប្រទេសជប៉ុន (Rule of Civil Procedure)

## អនុក្រឹត្យ ប្រកាស សារាចរ សេចក្តីណែនាំ

- អនុក្រឹត្យលេខ ៩៧ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២
- ប្រកាសលេខ១១២ ដនស/ប្រក ស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២
- ប្រកាសអន្តរក្រសួង លេខ ០២ប្រកន/០៣ ស្តីពីការកំណត់ភារកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងរឿងវិវាទដីធ្លី ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០០៣
- ប្រកាសលេខ ០៩៩ ស.ក.ប.យ. ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤
- សេចក្តីណែនាំលេខ ១៩៥៥ ដនស/គសជ ស្តីពីនីតិវិធីសវនាការនៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០០៥

## សេចក្តីសម្រេច

- សាលាដំបូងរាជធានីភ្នំពេញ, សំណុំរឿងរដ្ឋប្បវេណីលេខ៖ ១០៦៦ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២, សាលក្រមលេខ ៥៣០ "ង" ភ.ព.រ.វ ចុះថ្ងៃទី២៩ ខែ មេសា ឆ្នាំ ២០១៥
- សាលាដំបូងរាជធានីភ្នំពេញ, សំណុំរឿងរដ្ឋប្បវេណីលេខ៖ ១៩៦៩ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១១, សាលក្រមលេខ៖ ៩៥ "ប" ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១១
- សាលាឧទ្ធរណ៍, សំណុំរឿងរដ្ឋប្បវេណីលេខ៖ ១៩៩ ចុះថ្ងៃទី០៥ ខែ មេសា ឆ្នាំ ២០១២, សាលដីកាលេខ៖ ៩២ "ក្រVIញ" ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១២
- រូបមន្តអនុវត្តសាលដីកាលេខ ២២ រមអវ/វវ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៣
- សាលាឧទ្ធរណ៍, សំណុំរឿងជំនុំជម្រះសាជាថ្មី លេខ៖ ១៩ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥, ដីកាសម្រេចលេខ៖ ១៦ "ក្រVIIង" ដកស ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥
- សេចក្តីបង្គាប់អាជ្ញាកណ្តាលការងារលេខ ០០៩/១៧-អ៊ឹម វ៉េ កាត់ដេរអន្តរជាតិ (សាខាទី៣) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧

- សេចក្តីបង្គាប់អាជ្ញាកណ្តាលការងារលេខ ៤២/០៧-សៅធន៍បេ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៧

## ❖ សៀវភៅដែលបានបោះពុម្ពផ្សាយ

### ជាភាសាខ្មែរ


- ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី. ២០០៧. *សេចក្តីកំណត់មាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី*. ភ្នំពេញ ៖ ក្រសួងយុត្តិធម៌។
- ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី. ២០១១. *សេចក្តីកំណត់មាត្រានីមួយនៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល*. ភ្នំពេញ៖ ក្រសួងយុត្តិធម៌។
- ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. ២០០៨ *សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១: នីតិវិធីបណ្តឹង*. ភ្នំពេញ ៖ ក្រសួងយុត្តិធម៌។
- ក្រុមការងារកិច្ចការរដ្ឋប្បវេណី នៃគណៈមេធាវី និងកម្មវិធីសហប្រតិបត្តិការផ្នែកតុលាការជាមួយគណៈមេធាវី. ២០១០. *សៀវភៅមេរៀនស្តីពីមូលដ្ឋាននៃអង្គហេតុចម្បង*. ភ្នំពេញ ៖ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។
- ក្រុមប្រឹក្សាអាជ្ញាកណ្តាល. ២០០៧. *សេចក្តីសង្ខេបយុត្តិសាស្ត្ររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ៨*. ភ្នំពេញ៖ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។
- គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ, ក្រសួងយុត្តិធម៌, រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, និង សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច. រៀបរៀង. ២០១៦. *មេរៀនស្តីពី ក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២*. ភ្នំពេញ ៖ គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ ដំណាក់កាលទី៤ របស់ក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា និងទីភ្នាក់ងារ JICA។
- មេធាវី ស៊ីវិន អ៊ែម អូស្មើរមីឡឺរ៍. ២០១០. *ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ : សៀវភៅសិក្សាស្តីពីទស្សនាទានសំខាន់ៗ*. បោះពុម្ពលើកទី២ ភ្នំពេញ៖ USAID។

- មេធាវី អ៊ីវ ប៉ូលី. ២០១៦. កម្រងមេរៀនឆ្នាំ២០១៥. នៅក្នុង *សិក្ខាសាលាលើកទី៤ : នីតិវិធីនៃការជំនុំជម្រះសាជាថ្មី*. ភ្នំពេញ ៖ វិភាគទានច្បាប់។
- សាស្ត្រាចារ្យ ស៊ុម សុខម្ភ. ២០០៩. *បច្ចេកទេស និងវិធីសាស្ត្របកស្រាយបទដ្ឋានគតិយុត្តនានា*. ភ្នំពេញ ៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។
- សាស្ត្រាចារ្យ បណ្ឌិត ហាប់ ផល្វី. ២០១៦. *វិធីសាស្ត្រ និងការសរសេរបែបសិក្សា*. ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

### ឯកសារបរទេស

- A.C. Freeman. ១៩២៥. *A TREATISE OF THE LAW OF JUDGMENTS*, បោះពុម្ពលើកទី៥. សេនហ្វ្រេនស៊ីស្កូ៖ Bancroft-Whitney Company
- Donald J. Lange. ២០១០. *The Doctrine of Res Judicata in Canada*. [ទ្រឹស្តីនៃអាជ្ញាអស់ជំនុំក្នុងប្រទេសកាណាដា]. បោះពុម្ពលើកទី៣. កាណាដា ៖ LexisNexis
- Larry L. Teply និង Ralph U. Whitten. ២០០៤. *Civil Procedure*. [នីតិវិធីរដ្ឋប្បវេណី]. បោះពុម្ពលើកទី៣. រដ្ឋធានីនូយ៉ក៖ Foundation Press

## ❖ សៀវភៅអេឡិចត្រូនិក

- តុលាការកំពូលនៃប្រទេសជប៉ុន. ២០១៤. *Outline of Civil Procedure in JAPAN.* [ការពណ៌នាអំពីនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន]. ប្រទេសជប៉ុន ៖ តុលាការកំពូលនៃប្រទេសជប៉ុន. http://www.courts.go.jp/english/vcms_lf/20140401-civiltext.pdf (ចូលអានថ្ងៃទី ០៥ ខែ មេសា ឆ្នាំ២០១៧)
- C. Theodore Leonard, JR. ១៩៥៦. *PLEADING AND PROVING THE DEFENSE OF RES JUDICATA IN NORTH CAROLINA.* [ការអះអាង និងការបញ្ជាក់អំពីមធ្យោបាយការពារនៃអាជ្ញាអស់ជំនុំ នៅរដ្ឋណ័ស ខារ៉ូឡាញណា]. សហរដ្ឋអាមេរិក ៖ UNC School of Law. http://scholarship.law.unc.edu/cgi/viewcontent.cgi?article=1947&context=nclr (ចូលអានថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០១៧)

- David A R WILLIAMS QC និង Mark TUSHINGHAM. ២០១៤. *The Application of The Henderson v Henderson Rule in International Arbitration.* [ការយកមកអនុវត្តនូវវិធាននៃរឿងក្តី ហេនដឺសិន ក្នុងមជ្ឈត្តការអន្តរជាតិ]. សិង្ហបុរី ៖ Singapore Academy of Law Journal. http://journalsonline.academypublishing.org.sg/Journals/Singapore-Academy-of-Law-Journal-Special-Issue/e-Archive/ctl/eFirstSALPDFJournalView/mid/513/ArticleId/327/Citation/JournalsOnlinePDF (ចូលអានថ្ងៃទី ០៥ ខែ មេសា ឆ្នាំ២០១៧)
- Gretta Walters. ២០១២. *Fitting a Square Peg into a Round Hole: Do Res Judicata Challenges in International Arbitration Constitute Jurisdictional or Admissibility Problems?*. Kluwer Law International. http://www.law.columbia.edu/sites/default/files/microsites/columbia-arbitration-day/files/01_2012_-_walters_.pdf (ចូលអានថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០១៧)
- Kubas Kos Galkowski. ២០១៦. *Supreme Court decides on res judicata of arbitral award* . [ការវិនិច្ឆ័យរបស់តុលាការកំពូលនៃមជ្ឈត្តវិនិច្ឆ័យ]. ប៉ូឡូញ ៖ Lexology. http://www.lexology.com/library/detail.aspx?g=0d4523ef-8109-45f5-aebb-ef079aa1ae3c (ចូលអានថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០១៧)
- L. Rachel Lerman & Peter Morris. ២០១៥. *Foreign Country Judgments and the Res Judicata Puzzle: Whose Preclusion Law Should U.S. Courts Apply?*. [សាលក្រមតុលាការបរទេស និង បញ្ហានៃអាជ្ញាអស់ជំនុំ: តើច្បាប់នៃប្រទេសណាដែលតុលាការអាមេរិកយកមកអនុវត្ត?]. សហរដ្ឋអាមេរិក ៖ Civil Procedure review. http://www.civilprocedurereview.com/busca/baixa_arquivo.php?id=109&embedded=true (ចូលអានថ្ងៃទី ១៩ ខែ មេសា ឆ្នាំ២០១៧)
- Prof Dr Nathalie Voser និង Julie Raneda.២០១៤. *New developments on res judicata (Swiss Supreme Court)*, [ការវិវឌ្ឍថ្មីៗនៃអាជ្ញាអស់ជំនុំ (តុលាការកំពូលប្រទេសស្វីស)]. អង់គ្លេស៖ Thomson Reuters. http://www.swlegal.ch/getdoc/10bc4fe8-cd51-4023-a832-e50faeaaf303/2014_Nathalie_Voser_Julie_Raneda_New-developments.aspx (ចូលអានថ្ងៃទី ២៥ ខែ មេសា ឆ្នាំ២០១៧)

- Prof Higashio Kazuyuki, Prof Yukawa Ryo, Prof Uchiyama Jun. ២០១៧. *បញ្ហានានាដែលមាននៅក្នុងរឿងក្ដីរដ្ឋប្បវេណី*. កម្ពុជា ៖ អង្គការ JICA https://www.jica.go.jp/project/english/cambodia/014/materials/c8h0vm00009678s9-att/1701_02.pdf (ចូលអានថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០១៧)
- Prof Uchiyama Jun និង Prof Higashio Kazuyuki. ២០១៦. *បញ្ហានានាដែលមាននៅក្នុងរឿងក្ដីរដ្ឋប្បវេណី*. កម្ពុជា ៖ អង្គការ JICA https://www.jica.go.jp/project/english/cambodia/014/materials/c8h0vm00009678s9-att/1608_01.pdf (ចូលអានថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ២០១៧)
- Yuval Sinai. *Reconsidering Res Judicata- A Comparative Perspective*. [ការទទួលស្គាល់អាជ្ញាអស់ជំនុំ - គោលបំណងក្នុងការប្រៀបធៀប]. http://scholarship.law.duke.edu/cgi/viewcontent.cgi?article=1025&context=djcil (ចូលអានថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ២០១៧)

## បញ្ជីឧបសម្ព័ន្ធ

| | |
|---|---|
| **ឧបសម្ព័ន្ធ១ ៖** | សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញលេខ ៤៥ "ប" ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១១។ |
| **ឧបសម្ព័ន្ធ២ ៖** | សាលដីការបស់សាលាឧទ្ធរណ៍ លេខ ៤២ "ក្រVIញ" ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១២។ |
| **ឧបសម្ព័ន្ធ៣ ៖** | របមន្តអនុវត្ត លេខ២២ រមអវ/រវ ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ២០១៣។ |
| **ឧបសម្ព័ន្ធ៤ ៖** | ដីកាសម្រេចលើបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី របស់សាលាឧទ្ធរណ៍ លេខ១៦ "ក្រVIIង" ដកស ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០១៥។ |
| **ឧបសម្ព័ន្ធ៥ ៖** | សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ លេខ ៥៣០ "ង" ភ.ព.រ.វ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០១៥។ |

# ឧបសម្ព័ន្ធ១

## សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញលេខ ៤៥ "ច"

## ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១១

សាលាដំបូងរាជធានីភ្នំពេញ

**សំណុំរឿងរដ្ឋប្បវេណី**
លេខ: ១៤៦៩
ចុះថ្ងៃទី២១.០៩.២០១១
សាលក្រមលេខ: ៤៥ "ម"
ចុះថ្ងៃទី២០.១២.២០១១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**តាមនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងរាជធានីភ្នំពេញ**

**បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១១**

**សាលក្រមប្រកាសជាសាធារណៈ នាថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១១**

**សមាសភាពជំនុំជម្រះ**

- លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ។
- លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ ។
- លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ។

**រវាង** ដើមចោទឈ្មោះ **ឆ ម** ភេទស្រី អាយុ ៣២ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើតុយទាវ ទីលំនៅផ្ទះលេខ xxx ផ្លូវលេខ xxx សង្កាត់ xxxx ខណ្ឌចំការមន រាជធានីភ្នំពេញ។ ឪពុកឈ្មោះ **ឆ ចយ** (រ) ម្តាយឈ្មោះ **ថ ក** (រ)។ ប្តីឈ្មោះ **ត ឡ** មានកូន ០២នាក់។ តំណាងដោយអាណត្តិមេធាវី **ត សផ** អត្តលេខ: xxx ។

**និង** ចុងចម្លើយឈ្មោះ **ត ឡ** ភេទប្រុស អាយុ ៤០ឆ្នាំ ជាតិខ្មែរ មុខរបរជាងជួសជុលគ្រឿងអេឡិចត្រូនិច ទីលំនៅផ្ទះលេខ xxx ផ្លូវលេខ xxx ក្រុមទី xx ភូមិ x សង្កាត់ xxxx ខណ្ឌចំការមន រាជធានីភ្នំពេញ។ ឪពុកឈ្មោះ **ត ស** (ស) ម្តាយឈ្មោះ **ត ឡហ** (រ)។ ប្រពន្ធឈ្មោះ **ឆ ម** មានកូន ០២នាក់។ តំណាងដោយអាណត្តិមេធាវី **ឆ សច** ។

**<u>អង្គហេតុ និងចំណុចវិវាទ</u>**

១-ការប្តឹងទាមទាររបស់ដើមចោទ :

-សុំឈប់រស់នៅជាអនីតិសង្វាសពីប្តីឈ្មោះ **ត ឡ** ។

-សុំសិទ្ធិគ្រប់គ្រងកូន និងអាហារកិច្ចចិញ្ចឹមកូន។

-សុំបែងចែកទ្រព្យរួម។

២-ការអះអាងរបស់គូភាគី :

ក-ដើមចោទឈ្មោះ **ឆ ម** បានថ្លែងការណ៍ពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា: ខ្ញុំបានរៀបការជាមួយឈ្មោះ **ត ឡ** កាលពីថ្ងៃទី២៧.០១.១៩៩៧ ដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ទេ។ ការរស់នៅជាប្តីប្រពន្ធគឺខ្ញុំមិនមានសេចក្តីសុខដូចគ្រួសារដទៃទេ ដោយសារតែមានការឈ្លោះប្រកែកគ្នាជាញឹកញាប់ ហើយចុងចម្លើយឈ្មោះ **ត ឡ**

មិនដែលទទួលខុសត្រូវលើប្រពន្ធ និងកូននោះទេ។ ទង្វើទាំងនេះបណ្តាលឱ្យខ្លួនអស់មនោសញ្ចេតនាជាប្តីប្រពន្ធ។ ម្យ៉ាងវិញទៀត ការរស់នៅជាប្តីប្រពន្ធមានកូនពីរនាក់ គឺឈ្មោះ **ឥ សឆរ** ភេទប្រុស កើតនៅថ្ងៃទី១០.០៣.២០០១ និងឈ្មោះ**ឥ សឧស** ភេទស្រី កើតនៅថ្ងៃទី២៥.០១.២០០៣។ ចំពោះទ្រព្យរួមមាន: ផ្ទះលេខ xx ផ្លូវលេខ xx ក្រុមទី xx ភូមិx សង្កាត់ xxxx ខណ្ឌចំការមន រាជធានីភ្នំពេញ ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: xxxxxxxxxx ចុះថ្ងៃទី០៧.០៧.២០០៨។ រីឯ ទ្រព្យដោយឡែក និងបំណុល គឺគ្មានទេ។ ចំពោះប្រាក់ប្រដាប់ក្តី គឺខ្លួនសុខចិត្តទទួលបន្ទុក ពីព្រោះប្រាក់នេះខ្លួនបានបង់រួចហើយ។

សំណូមពរ: សុំឱ្យតុលាការចេញសាលក្រមទទួលស្គាល់ការលែងលះរស់នៅជាអនីតិសង្វាសពីប្តីឈ្មោះ **ឥ ឡ** និងប្តឹងសុំសិទ្ធិគ្រប់គ្រងកូនទាំងពីរនាក់ ដោយប្តឹងទាមទារអាហារកិច្ចចិញ្ចឹមកូនទាំងពីរនាក់ក្នុងមួយខែចំនួន ៣០០ដុល្លារអាមេរិក និងប្តឹងសុំទាមទារបែងចែកទ្រព្យរួមឱ្យខ្លួនចំនួន ៧០ភាគរយ តាមតម្លៃជាក់ស្តែង។

ខ-តំណាងដោយអាណត្តិឱ្យដើមចោទមេធាវី **ឥ សឌ** បានថ្លែងការណ៍ថា: ខ្លួនឯកភាពតាមសេចក្តីថ្លែងការណ៍របស់ដើមចោទឈ្មោះ **ឧ ម** ទាំងស្រុងដោយគ្មានអ្វីបន្ថែមឡើយ។

គ-ចុងចម្លើយឈ្មោះ **ឥ ឡ** បានថ្លែងការណ៍ពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា: ខ្លួនពិតបានរៀបការជាមួយឈ្មោះ **ឧ ម** កាលពីថ្ងៃទី២៧.០១.១៩៩៧ ដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ប្រាកដមែន។ ខ្លួនឯកភាពក្នុងការសុំលែងលះរស់នៅជាអនីតិសង្វាសជាមួយប្រពន្ធឈ្មោះ **ឧ ម**។ ម្យ៉ាងវិញទៀត ការរស់នៅជាប្តីប្រពន្ធ គឺមានកូនពីរនាក់ឈ្មោះ **ឥ សឆរ** និងឈ្មោះ **ឥ សឧស** ដូចការណ៍ថ្លែងការណ៍របស់ដើមចោទឈ្មោះ **ឧ ម** ប្រាកដមែន។ ចំពោះទ្រព្យរួម គឺមានផ្ទះលេខ xx ផ្លូវលេខ xxx ក្រុមទី xx ភូមិx សង្កាត់ xxxx ខណ្ឌចំការមន រាជធានីភ្នំពេញ ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលវត្ថុលេខ: xxxxxxxxxxxx ចុះថ្ងៃទី០៧.០៧.២០០៨។ រីឯ ទ្រព្យដោយឡែក និងបំណុល គឺគ្មានទេ។ ជាងនេះ-ទៅទៀត មុខរបររបស់ខ្លួនអាចរកចំណូលបានក្នុងមួយខែចំនួន ១៥០ ទៅ ២០០ ដុល្លារអាមេរិក និងមានផ្ទះជួលផ្នែកខាងក្រោម គឺជាទ្រព្យរួមផ្ទះលេខ xxx ផ្លូវលេខ xxx ក្រុមទី xx ភូមិ x សង្កាត់ xxxx ខណ្ឌចំការមន រាជធានីភ្នំពេញ។

សំណូមពរ: សុំឱ្យតុលាការចេញសាលក្រមទទួលស្គាល់ការលែងលះរស់នៅជាអនីតិសង្វាសពីប្រពន្ធឈ្មោះ **ឧ ម** និងប្តឹងសុំសិទ្ធិគ្រប់គ្រងកូនប្រុសឈ្មោះ **ឥ សឆរ** ដោយមិនប្តឹងទាមទារអាហារកិច្ចចិញ្ចឹមកូនឡើយ។ រីឯ កូនស្រីឈ្មោះ **ឥ សឧស** គឺខ្លួនសុខចិត្តប្រគល់សិទ្ធិគ្រប់គ្រងឱ្យទៅដើមចោទឈ្មោះ **ឧ ម** តាមការប្តឹងសុំ ដោយខ្លួនគ្មានលទ្ធភាពបង់អាហារកិច្ចចិញ្ចឹមកូនទេ និងប្តឹងសុំទាមទារបែងចែកទ្រព្យរួមម្នាក់ពាក់កណ្តាលស្មើគ្នាតាមតម្លៃជាក់ស្តែង។

ឃ-តំណាងដោយអាណត្តិចុងចម្លើយមេធាវី **ឧ សឆ** បានថ្លែងការណ៍ថា: ខ្លួនឯកភាពតាមសេចក្តីថ្លែងការណ៍របស់កូនក្តីខ្លួនឈ្មោះ **ឥ ឡ** ទាំងស្រុងដោយគ្មានអ្វីបន្ថែមឡើយ។

ង-កុមារាឈ្មោះ **ឥ សឆរ** បានឆ្លើយបញ្ជាក់ថា: ខ្លួនចង់រស់នៅជាមួយម្តាយឈ្មោះ **ឧ ម** ជាងឪពុកឈ្មោះ **ឥ ឡ** ពីព្រោះម្តាយជាអ្នកថែរក្សាខ្លួន និងជាអ្នកចិញ្ចឹមបីបាច់ផ្តល់ផ្គង់ជីវភាពរបស់ខ្លួន។

ច-កុមារីឈ្មោះ **ឥ សឧស** បានឆ្លើយបញ្ជាក់ថា: ខ្លួនចង់រស់នៅជាមួយម្តាយឈ្មោះ **ឧ ម** ជាងឪពុកឈ្មោះ **ឥ ឡ** ពីព្រោះម្តាយជាអ្នកផ្តល់ភាពកក់ក្តៅដល់ខ្លួន។

៣-សេចក្តីថ្លែងការណ៍បញ្ចប់របស់មេធាវីតំណាងដោយអាណត្តិ :

ក-តំណាងដោយអាណត្តិឱ្យដើមចោទមេធាវី **ឥ សឌ** បានធ្វើសេចក្តីថ្លែងការណ៍បញ្ចប់ថា: គូភាគីបានឯកភាព

គ្នាក្នុងការឈប់រស់នៅជាអនីតិសង្វាស។ ដូច្នេះ សុំឱ្យតុលាការចេញសាលក្រមទទួលស្គាល់ការឈប់រស់នៅជាអនីតិសង្វាសពីប្តីឈ្មោះ **ឝ ឡ** តាមការប្តឹងសុំរបស់កូនក្តីខ្លួន និងសុំប្រគល់សិទ្ធិគ្រប់គ្រងកូនទាំងពីរនាក់ ព្រមទាំងអាហារកិច្ចចិញ្ចឹមកូន និងសុំបែងចែកទ្រព្យរួមចំនួន ៧០ភាគរយ ឱ្យមកកូនក្តីខ្លួនឈ្មោះ **ឆ ម** ។

សំណូមពរ: សុំឱ្យតុលាការសម្រេចតាមការប្តឹងសុំរបស់កូនក្តីខ្លួន។

៣-តំណាងដោយអាណត្តិចុងចម្លើយមេធាវី **ឆ សឆណា** បានធ្វើសេចក្តីថ្លែងការណ៍បញ្ចប់ថា: កូនក្តីខ្លួនឈ្មោះ **ឝ ឡ** បានឯកភាពក្នុងការឈប់រស់នៅជាអនីតិសង្វាសពីប្រពន្ធឈ្មោះ **ឆ ម** តាមការប្តឹងសុំ។ ម្យ៉ាងទៀត កូនក្តីខ្លួនបានប្តឹងសុំសិទ្ធិគ្រប់គ្រងកូនប្រុសឈ្មោះ **ឝ សឌរ** ដោយមិនប្តឹងទាមទារអាហារកិច្ចចិញ្ចឹមកូនឡើយ។ ម្យ៉ាងវិញទៀត ដើមចោទឈ្មោះ **ឆ ម** មិនបានផ្តល់ភស្តុតាងណាមួយដែលបញ្ជាក់ពីលទ្ធភាពក្នុងការចិញ្ចឹមកូននោះឡើយ។ ចំពោះផ្ទះលេខ xxx ផ្លូវលេខ xxx ក្រុមទី xx ភូមិ x សង្កាត់ xxxx ខណ្ឌចំការមន រាជធានីភ្នំពេញ ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលវត្ថុលេខ: xxxxxxxxxxxx ចុះថ្ងៃទី០៧.០៧.២០០៨ គឺជាទ្រព្យអវិភាគមិនមែនជាទ្រព្យរួមនោះឡើយ។ រីឯ ការប្តឹងសុំទាមទារអាហារកិច្ចចិញ្ចឹមកូនរបស់ដើមចោទឈ្មោះ **ឆ ម** គឺខ្លួនសុំឱ្យតុលាការពិចារណាលើលទ្ធភាពរបស់កូនក្តីខ្លួន។

សំណូមពរ: សុំឱ្យតុលាការសម្រេចតាមការប្តឹងសុំរបស់កូនក្តីខ្លួន។

៤-តំណាងអយ្យការលោក [redacted] បានបញ្ចេញយោបល់ថា: ចំណុចវិវាទនៅក្នុងរឿងនេះ គឺការឈប់រស់នៅជាអនីតិសង្វាស ការបែងចែកទ្រព្យរួម សិទ្ធិក្នុងការគ្រប់គ្រងកូន និងអាហារកិច្ចចិញ្ចឹមកូន។ ប៉ុន្តែ សុំឱ្យតុលាការពិចារណាលើការប្រគល់សិទ្ធិគ្រប់គ្រងកូនដោយគិតដល់ផលប្រយោជន៍កូនជាធំ ដោយសំអាងថា: តាមការឆ្លើយបញ្ជាក់របស់កូនទាំងពីរនាក់ គឺបានបញ្ជាក់ថា: ពួកខ្លួនស្រលាញ់ម្តាយជាងឪពុក។ ដូច្នេះ គប្បីតុលាការប្រគល់សិទ្ធិគ្រប់គ្រងកូនទាំងពីរនាក់ឱ្យទៅដើមចោទឈ្មោះ **ឝ ឡ**ដែលជាម្តាយតាមឆន្ទៈរបស់កូន។

## ការសំអាងហេតុ

១-ដើមចោទឈ្មោះ **ឆ ម** និងចុងចម្លើយឈ្មោះ **ឝ ឡ** ជាប្តីប្រពន្ធដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវស្របតាមបញ្ញត្តិមាត្រា១៤ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ចុះថ្ងៃទី១៧.០៧.១៩៨៩។ ប៉ុន្តែ គូភាគីបានរស់នៅជាមួយគ្នាជាប្តីប្រពន្ធយូរណាស់មកហើយ។ ដូច្នេះ ការប្តឹងសុំឈប់រស់នៅជាអនីតិសង្វាសពីប្តីឈ្មោះ **ឝ ឡ** របស់ដើមចោទឈ្មោះ **ឆ ម** គប្បីតុលាការពិចារណា។

២-គូភាគីបានថ្លែងការណ៍ថា: ការរស់នៅជាប្តីប្រពន្ធមានកូនពីរនាក់ គឺឈ្មោះ **ឝ សឌរ** ភេទប្រុស កើតថ្ងៃទី១០.០៣.២០០១ និងឈ្មោះ **ឝ សនស** ភេទស្រី កើតថ្ងៃទី២៥.០១.២០០៣។ ចំពោះកូនទាំងពីរនាក់ គឺដើមចោទឈ្មោះ **ឆ ម** បានប្តឹងសុំសិទ្ធិគ្រប់គ្រង ដោយប្តឹងទាមទារអាហារកិច្ចចិញ្ចឹមកូនទាំងពីរនាក់ក្នុងមួយខែចំនួន ៣០០ដុល្លារអាមេរិក។ រីឯ ចុងចម្លើយឈ្មោះ **ឝ ឡ** ប្តឹងសុំសិទ្ធិគ្រប់គ្រងកូនប្រុសឈ្មោះ **ឝ សឌរ** ដោយមិនប្តឹងទាមទារអាហារកិច្ចចិញ្ចឹមកូននោះទេ។ រីឯ កូនស្រីឈ្មោះ **ឝ សនស** គឺចុងចម្លើយឈ្មោះ **ឝ ឡ** សុខចិត្តប្រគល់ឱ្យសិទ្ធិគ្រប់គ្រងឱ្យទៅដើមចោទឈ្មោះ **ឆ ម** តាមការប្តឹងសុំ ដោយខ្លួនគ្មានលទ្ធភាពផ្តល់អាហារកិច្ចចិញ្ចឹមកូនទេ។ ប៉ុន្តែ តាមការថ្លែងការណ៍របស់កូនឈ្មោះ **ឝ សឌរ** និងឈ្មោះ **ឝ សនស** បានបញ្ជាក់ថា: ពួកខ្លួនស្រឡាញ់ម្តាយជាងឪពុក និងចង់ទៅរស់នៅជាមួយម្តាយ ពីព្រោះម្តាយគាត់យកចិត្ត

ទុកដាក់ក្នុងការមើលថែរក្សាពួកខ្លួន និងជាអ្នកចិញ្ចឹមបីបាច់ផ្គត់ផ្គង់ជីវភាពរបស់ខ្លួន។ គប្បី តុលាការពិចារណាលើការប្រគល់សិទ្ធិគ្រប់គ្រងកូន និងអាហារកិច្ចចិញ្ចឹមកូន។

៣-គូភាគីបានថ្លែងការណ៍ថា: ទ្រព្យរួមមាន: ផ្ទះលេខ xxx ផ្លូវលេខ xxx ក្រុមទី xx ភូមិ x សង្កាត់ xxxx ខណ្ឌចំការមន រាជធានីភ្នំពេញ ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលវត្ថុលេខ: xxxxxxxxx ចុះថ្ងៃទី០៧.០៧.២០០៨។ រីឯ ទ្រព្យដោយឡែក និងបំណុល គឺគ្មានទេ។ គប្បី តុលាការពិចារណាក្នុងការបែងចែកទ្រព្យរួម និងមិនពិចារណាលើទ្រព្យដោយឡែក និងបំណុលទេ។

៤-កម្មវត្ថុនៃពាក្យបណ្ដឹងតប ចុះថ្ងៃទី១៧.១០.២០១១ របស់ចុងចម្លើយឈ្មោះ **ឝ ឡ** គឺមានចំណុចដូចគ្នាទៅនឹងកម្មវត្ថុនៃពាក្យបណ្ដឹង ចុះថ្ងៃទី២០.០៩.២០១១របស់ដើមចោទឈ្មោះ **ឆ ម**។ ដូច្នេះពាក្យបណ្ដឹងតប ចុះថ្ងៃទី១៧.១០.២០១១ របស់ចុងចម្លើយឈ្មោះ **ឝ ឡ** គឺគ្មានការទាក់ទងនឹងការប្ដឹងទាមទារដែលជាកម្មវត្ថុនៃបណ្ដឹងដើម ឬជាមធ្យោបាយការពារខ្លួនឡើយ។ គប្បី តុលាការមិនពិចារណា។

៥-ចំពោះប្រាក់ប្រដាប់ក្ដី គឺដើមចោទឈ្មោះ **ឆ ម** សុខចិត្តទទួលបន្ទុក។

<u>**សេចក្ដីសម្រេចបញ្ចប់**</u>

១_ទទួលស្គាល់ការឈប់រស់នៅជាអនីតិសង្វាសរវាងឈ្មោះ **ឝ ឡ** និងនាងឈ្មោះ **ឆ ម** (តាមការព្រមព្រៀង)។

២_ក.ប្រគល់កូនឈ្មោះ **ឝ សថរ** ភេទប្រុស កើតនៅថ្ងៃទី១០.០៣.២០០១ និងឈ្មោះ **ឝ សឆស** ភេទស្រី កើតនៅថ្ងៃទី២៥.០១.២០០៣ ឱ្យទៅដើមចោទឈ្មោះ **ឆ ម** ចាប់ពីថ្ងៃប្រកាសសាលក្រម។

ខ.បង្គាប់ឱ្យឈ្មោះ **ឝ ឡ** បង់អាហារកិច្ចចិញ្ចឹមកូនទាំងពីរនាក់ក្នុងមួយខែចំនួន ៨០០.០០០(ប៉ែតសិបម៉ឺន)រៀល ឱ្យទៅឈ្មោះ **ឆ ម** រហូតដល់កូនមាននីតិភាព។

មាតាបិតាមានកាតព្វកិច្ចបីបាច់រក្សាកូន។ ចុងចម្លើយឈ្មោះ **ឝ ឡ** ដែលមិនបានរក្សាកូនមានសិទ្ធិទៅសួរសុខទុក្ខកូនដោយដើមចោទឈ្មោះ **ឆ ម** ត្រូវបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាង។

តាមមាត្រា៧២.៧៣.៧៤ និងមាត្រា៧៥ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ចុះថ្ងៃទី១៧.០៧.១៩៨៩។

៣_ប្រគល់ទ្រព្យរួម ទ្វារ: ផ្ទះលេខ xxx ផ្លូវលេខ xxx ក្រុមទី xx ភូមិ x សង្កាត់ xxxx ខណ្ឌចំការមន រាជធានីភ្នំពេញ ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលវត្ថុលេខ: xxxxxxxxxxxx ចុះថ្ងៃទី០៧.០៧.២០០៨ ឱ្យទៅដើមចោទឈ្មោះ **ឆ ម** ចំនួន ៦៥% (ហុកសិបប្រាំភាគរយ) និងចុងចម្លើយឈ្មោះ xxxxx ចំនួន ៣៥% (សាមសិបប្រាំភាគរយ) តាមតម្លៃជាក់ស្ដែង គិតចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ។

តាមមាត្រា៧០ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ចុះថ្ងៃទី១៧.០៧.១៩៨៩។

៤_ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទតាមការព្រមព្រៀង ដែលប្រាក់នេះត្រូវបានបង់រួចហើយ។

**ចៅក្រម**

**ហត្ថលេខា និងត្រា :** [redacted]

បានឃើញ
ចៅក្រម

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១
ក្រឡាបញ្ជី

[redacted]

# ឧបសម្ព័ន្ធ២

## សាលដីការបស់សាលាឧទ្ធរណ៍ លេខ ៤២ "ក្រVIញ"

## ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណី

លេខ:១៤៨

ចុះថ្ងៃទី០៥-៤-១២

សាលដីកា

លេខ:៨២"ក្រVញ"

ចុះថ្ងៃទី១៦-៨-២០១២

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១២

**<u>សមាសភាពក្រុមប្រឹក្សា</u>**

លោក [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted] ជាព្រះរាជអាជ្ញា

**<u>ក្រឡាបញ្ជី</u>**

លោក [redacted]

-ដើមចោទឈ្មោះ **ឆ ម** ភេទស្រី អាយុ៣២ឆ្នាំ ជាតិខ្មែរ មុខរបរ xxxx ទីលំនៅសព្វថ្ងៃផ្ទះលេខ: xxx ផ្លូវលេខ xxxx សង្កាត់ xxxx ខណ្ឌចំការមន រាជធានីភ្នំពេញ (ជាចុងបណ្តឹងឧទ្ធរណ៍)។

មានមេធាវី **ឆ សគ** ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ។

-ចុងចម្លើយឈ្មោះ **គ ឡ** ភេទប្រុស អាយុ៤០ឆ្នាំ ជាតិខ្មែរ មុខរបរ xxxxxxxxxx

ទីលំនៅសព្វថ្ងៃផ្ទះលេខ xxx ផ្លូវលេខ xxx ក្រុមទី xx ភូមិ xx សង្កាត់ xxxxxxx ខណ្ឌចំការមន រាជធានីភ្នំពេញ (ជាដើមបណ្តឹងឧទ្ធរណ៍)។

<u>អំពីរឿង:</u> ប្តីងឈប់រស់នៅជាអនីតិសង្វាស

## <u>អំពីអង្គហេតុ និងចំណុចវិវាទ</u>

តាមពាក្យបណ្តឹងចុះថ្ងៃទី២០-៩-២០១១ របស់ដើមចោទបានឲ្យដឹងថា: ខ្លួនបានរៀបការជាមួយជាមួយឈ្មោះ **គ ឡ** នៅថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៩៧ ហើយបានបង្កើតបានកូនពីរនាក់។ តាំងពីពេលរៀបការរហូតមកដល់ពេលនេះឈ្មោះ **គ ឡ** មិនបានបំពេញកាតព្វកិច្ចជាស្វាមីល្អ ជាឪពុកល្អទេ។ ខ្លួន

គ្មានមនោសញ្ចេតនាជាប្តីប្រពន្ធជាមួយឈ្មោះ **ឝ ឡ** តទៅទៀតហើយ។

## ការអះអាងរបស់គូភាគី

ចុងចម្លើយឈ្មោះ **ឝ ឡ** បានធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួនប្តឹងឧទ្ធរណ៍ដោយហេតុថា ការលើកឡើងសុទ្ធតែពាក់មិនពិត ការពិតប្រពន្ធរបស់ខ្លួនបានចុះចោលរូបខ្លួនអស់រយៈពេលជិត៣ឆ្នាំ។ ចំពោះកូនខ្លួនសុំយកម្នាក់ ចំនែកទ្រព្យសម្បត្តិរួមខ្លួនសុំបែងចែកជា២ចំណែកស្មើគ្នា តែកូនប្រសិនបើចង់ទៅរស់នៅជាមួយម្តាយ សុខចិត្តតាមឆន្ទៈរបស់កូន រីឯអាហារកិច្ចខ្លួនយល់ព្រមបង់ តាមការសម្រេចរបស់តុលាការ។ ខ្លួនសុខចិត្តចែកទ្រព្យសម្បត្តិរបស់ខ្លួនឲ្យទៅកូន ៥% ។

មេធាវី **ឆ សឝ** ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ បានធ្វើសេចក្តីថ្លែងហេតុថា រឿងនេះកូនក្តីខ្លួនឯកភាពលើការលែងលះ និងកូនអស់ហើយ។ ការដែលមិនឯកភាពគ្នា តែទៅលើទ្រព្យសម្បត្តិដោយហេតុថា កូនក្តីខ្លួនទទួលបន្ទុកចិញ្ចឹមកូន ដូចនេះកូនក្តីខ្លួនសុំចំណែកលើសដើម្បីទុកចិញ្ចឹមកូន គឺសុំទុក ៣០% ឲ្យកូន ទ្រព្យសល់កូនក្តីខ្លួនសុំបែងចែកជាពីរចំណែកស្មើគ្នា។ នៅពេលនេះខ្លួនជាមេធាវីតំណាងឲ្យដើមចោទ សំណូមពរសុំតម្កល់សាលក្រមរបស់សាលាដំបូងដដែល។

សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

នៅពេលនេះ សំណូមពរដល់គូភាគី យល់ព្រមទទួលយកចំណែកទ្រព្យសម្បត្តិរួម ៧០% ចែកជា២ ហើយនៅសល់ ៣០% ទុកឲ្យកូន។ នៅពេលនេះសុំលោកប្រធានក្រុមប្រឹក្សាពិចារណាសម្រេចតាមច្បាប់។

## សំអាងហេតុ

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២០-០១-២០១២ របស់ឈ្មោះ **ឝ ឡ** ចំណុចទី២ និង ៣ ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបានយោងមាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២-នៅពេលទាញហេតុផលដោយផ្ទាល់មាត់នៅសាលាឧទ្ធរណ៍ ដើមបណ្តឹងឧទ្ធរណ៍បានប្តឹងទាមទារតែចំណុចទី៣ នៃសាលក្រមស្តីពីការបែងចែកទ្រព្យសម្បត្តិរួម ដោយនៅពេលនេះខ្លួនទាមទារយក ៤៥% ដោយទុកឲ្យកូន ៥% ប៉ុន្តែក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថា ដើម្បីគិតគូរពីផលប្រយោជន៍អនីតិជនសម្រាប់ពេលអនាគត់ គួរតម្កល់ចំណុចទី៣ នៃសាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញដដែល យោងមាត្រា៧០ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ។

៣-រឿងក្តីនេះត្រូវបានសាលាដំបូងរាជធានីភ្នំពេញធ្វើការអង្កេត និងលើកយកសំអាងហេតុមកបញ្ជាក់ត្រឹមត្រូវហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនោះ ដោយពុំចាំបាច់លើកយកសំអាងហេតុដដែលនោះយកមកបញ្ជាក់ជាថ្មីទៀតទេ។

៤-សាលក្រមរដ្ឋប្បវេណីលេខ:៤៥ "ប" ចុះថ្ងៃទី២០-១២-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញសម្រេចត្រឹមត្រូវតាមច្បាប់ហើយ គប្បីតម្កល់ទុកជាបានការតទៅ។

<u>ហេតុដូច្នេះ</u>

<u>វិនិច្ឆ័យសេចក្តី</u>

១-ច្រានបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២០-០១-២០១២ របស់ឈ្មោះ **គ ឡ** ចោលជាអសារបង់។

២-តម្កល់ចំនុចទី២ និង ៣ នៃសាលក្រមរដ្ឋប្បវេណីលេខៈ ៤៥ "ប" ចុះថ្ងៃទី២០-១២-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការតទៅ។

៣-ប្រាក់ប្រដាក់ក្តីជាបន្ទុករបស់ចុងចម្លើយ។

៤-សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី១៦-៨-២០១២ ទុកសិទ្ធិឲ្យប្តឹងសាទុក្ខរយៈពេលមួយខែគិតពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
| --- | --- | --- |
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

---

...ត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃ [illegible] ឆ្នាំ២០១២

ក្រឡាបញ្ជី

[redacted]

[redacted]

# ឧបសម្ព័ន្ធ៣

**រូបមន្តអនុវត្ត លេខ២២ រមអវ/រវ**

**ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ២០១៣**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

## រូបមន្តអនុវត្តសាលដីកា

លេខ: ២២......រមអ/រវ

យើង [redacted] ជាក្រឡាបញ្ជីសាលាឧទ្ធរណ៍

-បានឃើញមាត្រា៥៨, ៣៥៥ និង ៣៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-បានឃើញពាក្យសុំចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១២ របស់ភាគីនៃម្ចាស់ការអនុវត្តឈ្មោះ **ឆ ម** ជាភាគីដើមចោទ ។

## សូមបញ្ជាក់ពីខ្លឹមសារអនុវត្តដូចខាងក្រោមនេះ

-ម្ចាស់នៃការអនុវត្តដោយបង្ខំឈ្មោះ **ឆ ម** ទីលំនៅផ្ទះលេខ xxx ផ្លូវ xxx សង្កាត់បឹង xxxx ខណ្ឌចំការមន រាជធានីភ្នំពេញ ។

-តំណាងដោយឈ្មោះ **ឆ សគ** (មេធាវីតំណាងដោយអាណត្តិ)

-អាចអនុវត្តដោយបង្ខំ តាមអំណាចសាលដីកាលេខ: ៥២ "ក្រVIញ" ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍

-ពីកូនបំណុលនៃការអនុវត្តឈ្មោះ **គ ឡ** មានទីលំនៅផ្ទះលេខ xxx ផ្លូវលេខ xxx ក្រុមទី xx ភូមិ x សង្កាត់ xxxx ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**សេចក្តីនេះ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកស្ថាប័ន នៃការអនុវត្តដោយបង្ខំឲ្យសម្រេចតាមសាលដីកាស្ថាពរនេះ និង ឲ្យអាជ្ញាធរសាធារណៈ ជួយអនុវត្តសាលដីកានេះ បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

ភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០១៣

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

បានចំលងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី 03 ខែ... ឆ្នាំ 2016

ក្រឡាបញ្ជី

[redacted]

# ឧបសម្ព័ន្ធ៤

## ដីកាសម្រេចលើបណ្ដឹងទាមទារជំនុំជម្រះសាជាថ្មី
## របស់សាលាឧទ្ធរណ៍ លេខ១៦ "ក្រVIIខ" ដកស
## ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០១៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

<u>សំណុំរឿងរដ្ឋប្បវេណី</u>
<u>ជំនុំជម្រះសាជាថ្មី</u>
លេខ៖ ១៩
ចុះថ្ងៃទី ២៩-៩-២០១៥
<u>ដីកាសម្រេច</u>
លេខ៖ ១៦ "ក្រVIIង" ដកស
ចុះថ្ងៃទី ២៥-១២-២០១៥

## ដីកាសម្រេច

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥

<u>**សមាសភាពក្រុមប្រឹក្សា**</u>

លោក [redacted] ជាប្រធាន
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

<u>**ក្រឡាបញ្ជី**</u>

លោក [redacted]

-ឈ្មោះ: **គ ឡ** ភេទប្រុស អាយុ ៤០ឆ្នាំ ជាតិខ្មែរ មុខរបរ xxxxxxxxxxxxxxxxxxxxxxx ផ្ទះលេខ xxx ផ្លូវលេខ xxx ក្រុមទី xx ភូមិ x សង្កាត់ xxxx ខណ្ឌ xxxxx រាជធានីភ្នំពេញ ។ ឪពុកឈ្មោះ: **គ ស** (ស) ម្ដាយឈ្មោះ: **គ ឡហ** (រ) ។ ប្រពន្ធឈ្មោះ: **ឧ ម** មានកូន ០២នាក់ ។

<u>**កម្មវត្ថុបណ្ដឹង**</u> ៖ ជំនុំជម្រះសាជាថ្មី ចំពោះសាលដីកាលេខ ៤២ "ក្រVIញ" ចុះថ្ងៃទី ១៦-០៨-២០១២ របស់សាលាឧទ្ធរណ៍ ។

-**បានឃើញ** សាលក្រមលេខ: ៤៥ "ម" ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១១ របស់ **សាលាដំបូងរាជធានីភ្នំពេញ** ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១/-ទទួលស្គាល់ការឈប់រស់នៅជាអនីតិសង្វាស រវាងឈ្មោះ: **គ ឡ** និងនាងឈ្មោះ: **ឧ ម** (តាមការព្រមព្រៀង) ។

២/-ក.ប្រគល់កូនឈ្មោះ: **គ សខ៖** ភេទប្រុស កើតនៅថ្ងៃទី ១០-០៣-២០១១ និងឈ្មោះ: ភេទស្រី កើតនៅថ្ងៃទី ២៥.០១.២០០៣ ឲ្យទៅដើមចោទឈ្មោះ: **ឧ ម** ចាប់ពីថ្ងៃប្រកាសសាលក្រម ។

ខ.បង្គាប់ឲ្យឈ្មោះ: **គ ឡ** បង់អាហារកិច្ចចិញ្ចឹមកូនទាំងពីរនាក់ក្នុងមួយខែ ចំនួន ៨០០.០០០ (ប៉ែតសិបម៉ឺន) រៀល ឲ្យទៅឈ្មោះ: **ឧ ម** រហូតដល់កូនមាននីតិភាព ។

មាតាបិតាមានកាតព្វកិច្ចបីបាច់រក្សាកូន ។ ចុងចម្លើយឈ្មោះ: **គ ឡ** ដែលមិនបានរក្សាកូនមានសិទ្ធិទៅសួរសុខទុក្ខកូនដោយដើមចោទឈ្មោះ: **ឧ ម** ត្រូវបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាង ។

តាមមាត្រា ៧២, ៧៣, ៧៤ និងមាត្រា ៧៥ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ចុះថ្ងៃទី ១៧.០៧.១៩៨៩ ។

៣/-ប្រគល់ទ្រព្យរួម នូវៈ ផ្ទះលេខ xxx ផ្លូវលេខ xxx ក្រុមទី xx ភូមិ x សង្កាត់ xxxx ខណ្ឌ xxxxx រាជធានីភ្នំពេញ ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: xxxxxxxxxxxxxx ចុះថ្ងៃទី ០៧.០៧.២០០៨ ឲ្យទៅដើមចោទឈ្មោះ **ឌ ម** ចំនួន ៦៥% (ហុកសិបប្រាំភាគរយ) និងចុងចម្លើយឈ្មោះ **គ ឡ** ចំនួន ៣៥% (សាមសិបប្រាំភាគរយ) តាមតម្លៃជាក់ស្តែង គិតចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ ។

តាមមាត្រា ៧០ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ចុះថ្ងៃទី ១៧.០៧.១៩៨៩ ។

៤/-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទតាមការព្រមព្រៀងដែលប្រាក់នេះត្រូវបានបង់រួចហើយ។

*សាលក្រមនេះ ត្រូវបានឈ្មោះ* **គ ឡ** *ប្តឹងឧទ្ធរណ៍ តាមពាក្យបណ្តឹងចុះថ្ងៃទី ២០-០១-២០១២ ត្រង់ចំណុចៈ ទី២ និង ទី៣ នៃសេចក្តីសម្រេច ។*

**-បានឃើញ** សាលដីកាលេខ: ៤២ "ក្រវ.ញ" ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១២ របស់ **សាលាឧទ្ធរណ៍** ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ច្រានបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២០-០១-២០១២ របស់ឈ្មោះ **គ ឡ** ចោលជាអសារបង់ ។

២-តម្កល់ចំណុចទី ២ និង ទី៣ នៃសាលក្រមរដ្ឋប្បវេណីលេខ: ៤៥ "ប" ចុះថ្ងៃទី ២០-១២-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការតទៅ ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

៤-សាលដីកានេះប្រកាសជាសាធារណៈ នៅថ្ងៃទី ១៦-៨-២០១២ ទុកសិទ្ធិឲ្យប្តឹងសាទុក្ខរយៈពេលមួយខែ គិតពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ ។

**-បានឃើញ** ពាក្យស្នើសុំឲ្យជំនុំជម្រះសាជាថ្មី ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ របស់ឈ្មោះ **គ ឡ** ចំពោះសាលដីកាលេខ:៤២ "ក្រវ.ញ" ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍។

**<u>ការអះអាងរបស់គូភាគី៖</u>**

-ដើមបណ្តឹងឈ្មោះ **គ ឡ** (អវត្តមាន)

-ចុងបណ្តឹងឈ្មោះ **ឌ ម** (អវត្តមាន)

-មេធាវីតំណាងដោយអាណត្តិឱ្យដើមបណ្តឹងលោក **ស ឆរ** (វត្តមាន)

-មេធាវីតំណាងដោយអាណត្តិឱ្យដើមបណ្តឹងលោក **ស ឆរ** ធ្វើសេចក្តីថ្លែងការណ៍ថាៈ ដើមបណ្តឹងឈ្មោះ **គ ឡ** បានដាក់ពាក្យឱ្យជំនុំជម្រះសារជាថ្មីចំពោះសាលដីកាលេខ: ៤២ "ក្រវ.ញ" ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១២ ប៉ុន្តែដោយសារភាគីដើមបណ្តឹងពុំមានមូលហេតុត្រឹមត្រូវស្របតាមមាត្រា ៣០៧ ដែលបានចែងពីមូលហេតុនៃការជំនុំជម្រះសារជាថ្មី ហើយអ្វីដែលបានចែងនៅក្នុងពាក្យស្នើសុំជាជំនុំជម្រះសារជាថ្មីនេះគឺពុំមានហេតុផល ដែលបញ្ជាក់អំពីភស្តុតាងថ្មី ដែលស្របតាមមាត្រា ៣០៧ នោះទេ ដូច្នេះក្នុងនាមខ្ញុំជាមេធាវីតំណាងដោយអាណត្តិឱ្យចុងបណ្តឹង សំណូមពរឱ្យលោកប្រធានច្រានចោលពាក្យស្នើសុំឱ្យជំនុំជម្រះសារជាថ្មី ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ របស់ឈ្មោះ **គ ឡ** ចោលទាំងស្រុង និងតម្កល់សាលដីកាលេខ: ៤២ "ក្រវ.ញ" ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។

## <u>សំអាងហេតុ</u>

## <u>យល់ឃើញថា៖</u>

១-ពាក្យសុំឱ្យជំនុំជម្រះសាជាថ្មី ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ របស់ឈ្មោះ **គ ឡ** ដែលបានដាក់ពាក្យសុំឱ្យជំនុំជម្រះសាជាថ្មីលើសំណុំរឿងរដ្ឋប្បវេណីលេខ: ១៤៤ ចុះថ្ងៃទី០៥-០៤-២០១២ ដែលមានសាលដីកាស្ថាពរលេខ: ៤២ "ក្រVI" ចុះថ្ងៃទី១៦-៨-២០១២ របស់សាលាឧទ្ធរណ៍ ឃើញថាមូលហេតុដែលសុំឱ្យជំនុំជម្រះសាជាថ្មីនេះ ពុំមានហេតុផលត្រឹមត្រូវតាមមាត្រា ៣០៧ និងមាត្រា ៣០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឡើយ។ គប្បីច្រានចោលពាក្យបណ្តឹងនេះ យោងតាមបញ្ញត្តិមាត្រា ៣១៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## <u>ហេតុដូច្នេះ</u>

## <u>សម្រេច៖</u>

១-ច្រានចោលពាក្យសុំឱ្យជំនុំជម្រះសាជាថ្មី ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ របស់ឈ្មោះ **គ ឡ**

២-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

៣-ដីកាសម្រេចនេះអាចប្តឹងជំទាស់បាន យោងតាមមាត្រាបញ្ញត្តិមាត្រា ៣១៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| លោក [redacted] | លោក [redacted] , លោក [redacted] | លោក [redacted] |

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

[redacted]

ភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ២០១៦

**ក្រឡាបញ្ជី**

[redacted]

[redacted]

# ឧបសម្ព័ន្ធ៥

## សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ

## លេខ ៥៣០ "ទ" ត.ព.រ.វ

## ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០១៥

**សាលាដំបូងរាជធានីភ្នំពេញ**

សំណុំរឿងរដ្ឋប្បវេណីលេខ ១០៦៦
ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២
សាលក្រមលេខ **៥៣០ "ខ" ត.ព.រ.ទ**
ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ ២០១៥

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

(វាយឡើងវិញ)

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងរាជធានីភ្នំពេញ

## ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញជាប្រធានក្រុមប្រឹក្សា
លោកជំទាវ [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

## ក្រឡាបញ្ជីកត់ត្រា

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ក្រោយពីបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៥ លើសំណុំរឿងរដ្ឋប្បវេណីលេខ ១០៦៦ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២។

(ចេញសាលក្រមដែលមានខ្លឹមសារដូចតទៅ)

**ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ ៖**

១-សុំរំលាយកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ លិខិតប្រគល់-ទទួលប្រាក់ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ និងលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១០ ចោលអសារបង់។

២-បង្គាប់ឱ្យឈ្មោះ [redacted] សងថ្លៃខូចខាតផ្សេងៗចំនួន ៤,០០០,០០០ ដុល្លារ (បួនលានដុល្លារអាមេរិក)។

៣-ប្រាក់ប្រដាប់ក្ដីជាបន្ទុកចុងចម្លើយឈ្មោះ [redacted]។

**ខ្លឹមសារនៃសាលក្រមដែលទាមទារដោយចុងចម្លើយក្នុងបណ្ដឹងតប ៖**

១-បង្គាប់ឱ្យឈ្មោះ [redacted] និងឈ្មោះ [redacted] សងប្រាក់ដើមចំនួន ១,០៤០,៥០០ ដុល្លារ (មួយលានប្រាំបួនម៉ឺនប្រាំរយដុល្លារអាមេរិក) ការប្រាក់ចំនួន ២,៥% (ពីរក្បៀសប្រាំភាគរយ) ក្នុងមួយខែ គិតពីថ្ងៃខ្ចីដល់ថ្ងៃសងរួចឱ្យខ្លួនឈ្មោះ [redacted]។

២-ទាមទារភាគហ៊ុនពីឈ្មោះ [redacted] និងឈ្មោះ [redacted] សរុបចំនួន ១,២៧៣,៩១៩.៨១ ដុល្លារ (មួយលានពីរសែនប្រាំពីរម៉ឺនបីពាន់បួនរយដប់ប្រាំបួនដុល្លារអាមេរិក និងប៉ែតសិបមួយសេន) ឱ្យខ្លួន ([redacted]) ដែលជាប្រាក់ចំណាយលើការសាងសង់ផ្សារ និងសោហ៊ុយទាំងអស់លើការសាងសង់ផ្សារ និងចំណាយផ្សេងៗ បូករួមទាំងបង់សងបំណុលធនាគាររបស់ឈ្មោះ [redacted] និងទាមទារការប្រាក់ចំនួន ២,៥% (ពីរក្បៀសប្រាំភាគរយ) ក្នុងមួយខែ លើចំនួន ១,២៧៣,៩១៩.៨១ ដុល្លារ (មួយលានពីរសែនប្រាំពីរម៉ឺនបីពាន់បួនរយដប់ប្រាំបួនដុល្លាអាមេរិក និងប៉ែតសិបមួយសេន) គិតពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១០ រហូតដល់ថ្ងៃសងគ្រប់។

៣- ទាមទារផលប្រយោជន៍បានមកពីផ្សារទាំង៥ ដែលកើតចេញពីទ្រព្យសម្បត្តិ និងពលកម្មរបស់ខ្លួន ([redacted]) ចំនួន ១,០០០,០០០ដុល្លា (មួយលានដុល្លារអាមេរិក)។

៤-ទាមទារការខូចខាត និងសេវាកម្មច្បាប់សរុបចំនួន ៥០០,០០០ ដុល្លារ (ហាសិបម៉ឺនដុល្លាអាមេរិក)។

***__រវាង៖__*** -ដើមចោទឈ្មោះ [redacted] ភេទស្រី អាយុ ៤០ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃផ្ទះលេខ [redacted] ផ្លូវ [redacted] ភូមិ [redacted] សង្កាត់ [redacted] ខណ្ឌ [redacted] រាជធានីភ្នំពេញ។

-ដើមចោទឈ្មោះ [redacted] ភេទប្រុស សញ្ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃផ្ទះលេខ [redacted] ផ្លូវ [redacted] ភូមិ [redacted] សង្កាត់ [redacted] ខណ្ឌ [redacted] រាជធានីភ្នំពេញ។

អ្នកតំណាងដោយអាណត្តិ: លោក [redacted] និងលោក [redacted] និងលោក [redacted]។

**__និង៖__**

-ចុងចម្លើយឈ្មោះ [redacted] ភេទប្រុស អាយុ ៤២ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅផ្ទះលេខ [redacted] ផ្លូវលេខ [redacted] សង្កាត់ [redacted] ខណ្ឌ [redacted] រាជធានីភ្នំពេញ។

-ចុងចម្លើយឈ្មោះ [redacted] ភេទស្រី សញ្ជាតិខ្មែរ មានទីលំនៅផ្ទះលេខ [redacted] ផ្លូវលេខ [redacted] សង្កាត់ [redacted] ខណ្ឌ [redacted] រាជធានីភ្នំពេញ។

អ្នកតំណាងដោយអាណត្តិ: លោក [redacted]។

## __អង្គហេតុ និងចំណុចវិវាទ__

(រំលងចោល)

## សេចក្តីថ្លែងការណ៍របស់គូភាគី

(រំលងចោល)

## អង្គហេតុដែលគ្មានវិវាទ

(រំលងចោល)

## អង្គហេតុដែលមានវិវាទ

(រំលងចោល)

## ចំណុចវិវាទ

១- តើសហដើមចោទពិតជាបានទទួលប្រាក់ចំនួន ១,០៩០,៥០០ដុល្លារ (មួយលានប្រាំបួនម៉ឺនប្រាំរយដុល្លារអាមេរិក) ពីចុងចម្លើយតាមកិច្ចសន្យាខ្ចីប្រាក់ និងលិខិតប្រគល់ទទួលប្រាក់ ចុះថ្ងៃទី ០១ ខែមករា ឆ្នាំ២០១០ ដែរឬទេ?

២- តើសហដើមចោទពិតជាបានជំពាក់ប្រាក់ម្ចាស់បំណុល ០៦នាក់ ប្រហែល ២៥០,០០០ ដុល្លារ (ម្ភៃប្រាំម៉ឺនដុល្លារអាមេរិក) ឬចំនួន ៨១៧,៥០០ដុល្លារ (ប៉ែតសិបមួយម៉ឺនប្រាំពីរពាន់ប្រាំរយដុល្លារអាមេរិក)?

៣-តើសហដើមចោទពិតជាបានយល់ព្រមឱ្យចុងចម្លើយជាអ្នកសងបំណុលទៅម្ចាស់បំណុល ចំនួន ០៦នាក់ ជំនួសខ្លួនដែរឬទេ?

៤- តើសហដើមចោទពិតជាបានខ្ចីប្រាក់ពីចុងចម្លើយចំនួន ២៧៣,០០០ដុល្លារ (ម្ភៃប្រាំពីរម៉ឺនបីពាន់ដុល្លារអាមេរិក) ដែរ ឬទេ?

៥- តើការទាមទាររបស់ចុងចម្លើយចំពោះសហដើមចោទនូវប្រាក់ដើមចំនួន ១,០៩០,៥០០ (មួយលានប្រាំបួនម៉ឺនប្រាំរយដុល្លារអាមេរិក) និងការប្រាក់ចំនួន ២,៥% (ពីរក្បៀសប្រាំភាគរយ) ក្នុងមួយខែ គិតចាប់ពីថ្ងៃខ្ចីរហូតដល់ថ្ងៃសងប្រាក់រួច ចុងចម្លើយមានសិទ្ធិលើបំណុលចំពោះសហដើមចោទដែរ ឬទេ?

៦- តើចុងចម្លើយមានសិទ្ធិទាមទារភាគហ៊ុនពីសហដើមចោទចំនួន ៨៣៩,០៦៨.១៦ (ប៉ែតសិបបីម៉ឺនប្រាំបួនពាន់ហុកសិបប្រាំបីដុល្លារអាមេរិក និងដប់ប្រាំមួយសេន) និងការប្រាក់២,៥% (ពីរក្បៀសប្រាំភាគរយ) ក្នុងមួយខែ លើចំនួនប្រាក់នេះគិតចាប់ពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១០ រហូតដល់ថ្ងៃសងគ្រប់ចំនួនដែរឬទេ?

៧- តើចុងចម្លើយមានសិទ្ធិក្នុងការទាមទារផលប្រយោជន៍បានមកពីផ្សារទាំង ០៥កន្លែង ដែលកើតចេញពីទ្រព្យសម្បត្តិ និងពលកម្មរបស់ខ្លួនចំនួន ១,០០០,០០០ដុល្លារ (មួយលានដុល្លារអាមេរិក) ពីសហដើមចោទដែរឬទេ?

៨- តើចុងចម្លើយមានមូលដ្ឋាន និងភស្តុតាងដើម្បីទាមទារការខូចខាត និងសេវាកម្មច្បាប់ជាប្រាក់ចំនួន ៥០០,០០០ដុល្លារ (ហាសិបម៉ឺនដុល្លារអាមេរិក) ពីសហដើមចោទដែរឬទេ?

## សំអាងហេតុ

តាមលទ្ធផលពិនិត្យភស្តុតាងក្នុងដំណាក់កាលនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់។

## យល់ឃើញថា

**១-ស្តីពីចំណុចវិវាទទី១៖** តើសហដើមចោទពិតជាបានទទួលប្រាក់ចំនួន ១,០៩០,៥០០ ដុល្លារ(មួយលានប្រាំបួនម៉ឺនប្រាំរយដុល្លារអាមេរិក ពីចុងចម្លើយតាមកិច្ចសន្យាខ្ចីប្រាក់ និងលិខិតប្រគល់ទទួលប្រាក់ ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ ដែរឬទេ?

-ការអះអាងរបស់ដើមចោទ ៖ (រំលងចោល)

-ការអះអាងរបស់ចុងចម្លើយ ៖ (រំលងចោល)

-ភស្តុតាងជាឯកសារ ៖ (រំលងចោល)

ស្តីពីចំណុចវិវាទនេះតុលាការពិចារណាថា ការអះអាងរបស់ដើមចោទ ដែលអះអាងថាខ្លួនមិនបានទទួលប្រាក់ពីចុងចម្លើយនោះមិនពិតទេ ពីព្រោះកិច្ចសន្យានេះជាចេតនាដែលដើមចោទ

និងចុងចម្លើយបង្កើតឡើងសម្រាប់បង្ហាញឈ្មោះ [redacted] ដែលត្រូវជាប្តីរបស់ដើមចោទ ឈ្មោះ [redacted] កុំឱ្យទាមទារទ្រព្យសម្បត្តិក្រោយពេលដែលមានការលែងលះគ្នា អង្គហេតុនេះមានលក្ខណៈសមហេតុផល ដែលអាចឱ្យតុលាការពិចារណាដែរ ព្រោះថាតាមរយៈសាលក្រមរដ្ឋប្បវេណីលេខ ៣៣ "ខ" ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ សហដើមចោទទាំងពីរត្រូវបានលែងលះគ្នា។ ម្យ៉ាងវិញទៀតដោយពិចារណាលើភស្តុតាងជាឯកសារស្តីពីលិខិតប្រគល់ទទួលប្រាក់ចុះថ្ងៃទី ០១ ខែមករា ឆ្នាំ២០១០ ដើម្បីបញ្ជាក់ពីភាពច្បាស់លាស់នៃឯកសារនេះចាំបាច់ត្រូវតែមានការបញ្ជាក់បន្ថែមពីសាក្សីឈ្មោះ [redacted] និងឈ្មោះ [redacted] ដែលអ្នកទាំងពីរជាសាក្សីដ៏សំខាន់ដើម្បីបញ្ជាក់លើតម្លៃនៃភស្តុតាងនេះឱ្យកាន់តែមានតម្លៃខ្ពស់ ក៏ប៉ុន្តែសាក្សីទាំងពីរអវត្តមានដោយគ្មានមូលហេតុ ហេតុនេះគប្បីតុលាការទទួលស្គាល់ និងជឿជាក់ថាកិច្ចសន្យានេះបង្កើតឡើងដោយមានកិច្ចសន្យា និងលិខិតប្រគល់ទទួលប្រាកដមែន តែដើមចោទមិនបានទទួលនូវទឹកប្រាក់ចំនួន ១,០៩០,៥០០ (មួយលានប្រាំបួនម៉ឺនប្រាំរយដុល្លារអាមេរិក) ពិតប្រាកដមែន។

**២- ស្តីពីចំណុចវិវាទទី២៖** តើសហដើមចោទពិតជាបានជំពាក់ប្រាក់ម្ចាស់បំណុល ០៦នាក់ ប្រហែល ២៥០,០០០ ដុល្លារ (ម្ភៃប្រាំម៉ឺនដុល្លារអាមេរិក) ឬចំនួន ៨១៧,៥០០ដុល្លារ (ប៉ែតសិបមួយម៉ឺនប្រាំពីរពាន់ប្រាំរយដុល្លារអាមេរិក)?

-ការអះអាងរបស់ដើមចោទ៖ (រំលងចោល)
-ការអះអាងរបស់ចុងចម្លើយ៖ (រំលងចោល)
-ភស្តុតាងជាឯកសារ៖ (រំលងចោល)
-ភស្តុតាងជាសាក្សី៖ (រំលងចោល)

ស្តីពីចំណុចវិវាទនេះតុលាការពិចារណាឃើញថា ដើមចោទពិតជាបានបង្កើតកិច្ចសន្យាខ្ចីប្រាក់ជាមួយនឹងម្ចាស់បំណុលចំនួន ០៦នាក់ រួមនឹងចុងចម្លើយពិតប្រាកដមែន តាមរយៈការទទួលស្គាល់របស់ដើមចោទ និងភស្តុតាងជាឯកសារ ម្យ៉ាងទៀតតាមការបូកនឹងទឹកប្រាក់សរុបដែលដើមចោទបានខ្ចីប្រាក់ពីម្ចាស់បំណុលទាំង០៦នាក់ គឺមានចំនួន ២៣៨,០០០ដុល្លារ (ម្ភៃបីម៉ឺនប្រាំបីពាន់ដុល្លារអាមេរិក) ផ្អែកតាមភស្តុតាងជាឯកសារខាងលើ។ ទន្ទឹមនឹងនេះតុលាការពិចារណាឃើញថាចំនួននៃទឹកប្រាក់ដែលដើមចោទបានអះអាងមានចំនួនប្រហាក់ប្រហែលនឹងចំនួនទឹកប្រាក់ដែលបូកសរុបជាក់ស្តែងដែលមានចំនួនត្រឹមតែ ២៣៨,០០០ ដុល្លារ (ម្ភៃបីម៉ឺនប្រាំបីពាន់ដុល្លារអាមេរិក)។ តែទោះជាយ៉ាងនេះក្តី លទ្ធផលនៃទឹកប្រាក់នេះក៏ពុំទាន់មានភាពច្បាស់លាស់នោះដែរ ព្រោះនេះជា

សិទ្ធិលើបំណុលដែលម្ចាស់បំណុលទាំង០៦នាក់ត្រូវអះអាង និងបង្ហាញភស្តុតាងផ្សេងទៀតដើម្បីទាមទារចំពោះសិទ្ធិលើបំណុលរបស់ពួកគេ តែក្នុងរឿងក្តីនេះ ម្ចាស់បំណុលទាំងអស់ពុំបានអះអាងអំពីសិទ្ធិរបស់ខ្លួនចំពោះដើមចោទឡើយ គឺមានតែចុងចម្លើយប៉ុណ្ណោះដែលបានបង្ហាញនូវភស្តុតាងទាំងនេះជំនួសម្ចាស់បំណុល ហេតុនេះគប្បីតុលាការមិនធ្វើការពិចារណាអំពីទឹកប្រាក់ដែលសហាដើមចោទជំពាក់ម្ចាស់បំណុលទាំង០៦នាក់ឡើយ ព្រោះវាអាចនឹងប៉ះពាលដល់សិទ្ធិ និងផលប្រយោជន៍របស់ម្ចាស់បំណុលទាំង០៦នាក់ នាពេលអនាគតចំពោះនីតិវិធីបណ្តឹងទាក់ទងនឹងសហាដើមចោទ។

៣- **ស្តីពីចំណុចវិវាទទី៣៖** តើសហាដើមចោទពិតជាបានយល់ព្រមឱ្យចុងចម្លើយជាអ្នកសងបំណុលទៅម្ចាស់បំណុលចំនួន ០៦នាក់ ជំនួសខ្លួនដែរឬទេ?

-ការអះអាងរបស់ដើមចោទ៖ (រំលងចោល)

-ការអះអាងរបស់ចុងចម្លើយ៖ (រំលងចោល)

-ភស្តុតាងជាឯកសារ៖ (រំលងចោល)

-ភស្តុតាងជាសាក្សី៖ (រំលងចោល)

ស្តីពីចំណុចវិវាទនេះ តុលាការពិចារណាឃើញថា ផ្អែកតាមមាត្រា ៥៥៣ នៃក្រមរដ្ឋប្បវេណីអំពីអត្ថន័យនៃសំណើផ្តល់ការសងគឺមានតែកូនបំណុលដែលមានកាតព្វកិច្ចអនុវត្តការសងចំពោះម្ចាស់បំណុលតែប៉ុណ្ណោះទើបអានុភាពនៃការសងត្រូវបានទទួលស្គាល់ទៅតាមផ្លូវច្បាប់។ រីឯភស្តុតាងក្នុងចំណុចវិវាទនេះគឺចុងចម្លើយបានសងបំណុលជំនួសចុងចម្លើយទៅម្ចាស់បំណុល ដែលការសងនេះពុំបានបង្កើតអានុភាពទៅតាមច្បាប់ឡើយ ព្រោះចុងចម្លើយមិនមែនជាភាគីដែលត្រូវអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យាជាមួយម្ចាស់បំណុលទាំង ០៦នាក់នោះទេ តាមភស្តុតាងបញ្ជាក់ថា ចុងចម្លើយគ្រាន់តែជាសាក្សីក្នុងកិច្ចសន្យាប៉ុណ្ណោះ។ ម្យ៉ាងវិញទៀតចំពោះការសងនេះ ពុំទទួលបានការយល់ព្រម ឬមានការឯកភាពពីភាគីដើមចោទដែលជាកូនបំណុលនៃកិច្ចសន្យាដើម្បីឱ្យចុងចម្លើយមានសិទ្ធិសងប្រាក់ជំនួសខ្លួននោះដែរ ព្រោះតាមការអះអាងរបស់ដើមចោទ និងសាក្សីឈ្មោះ [redacted] និងឈ្មោះ [redacted] បានបញ្ជាក់ដូចៗគ្នាថា ពុំមានការជូនដំណឹង ឬនិយាយពីបញ្ហានេះទេ។

ដូច្នេះឃើញថា ដើមចោទបានសារភាពថាខ្លួនពិតជានៅជំពាក់ម្ចាស់បំណុលទាំង ០៦នាក់ប្រាកដមែន ដែលសិទ្ធិលើបំណុលនេះម្ចាស់បំណុលទាំងអស់អាចធ្វើការទាមទារចំពោះដើមចោទទៅតាមច្បាប់បាន ម្យ៉ាងវិញទៀតប្រសិនបើចុងចម្លើយបានសងប្រាក់ទៅឱ្យម្ចាស់បំណុលដែលមានសិទ្ធិលើបំណុលចំពោះដើមចោទ គឺចុងចម្លើយអាចធ្វើបណ្តឹងទាមទារស្តីពីសេចក្តីចម្រើនឥតហេតុចំពោះដើមចោទបាន ដោយបង្ហាញភស្តុតាងទៅតាមច្បាប់ ហេតុដូច្នេះចំពោះចំណុចវិវាទនេះតុលាការពិចារណាឃើញថា ដើមចោទមិនបានយល់ព្រមឱ្យចុងចម្លើយជាអ្នកសងបំណុលជំនួសខ្លួនទៅម្ចាស់បំណុលទាំង ០៦នាក់ពិតប្រាកដមែន។

៤- **ស្តីពីចំណុចវិវាទទី៤៖** តើសហដើមចោទពិតជាបានខ្ចីប្រាក់ពីចុងចម្លើយចំនួន ២៧៣,០០០ដុល្លារ (ម្ភៃប្រាំពីរម៉ឺនបីពាន់ដុល្លារអាមេរិក) ដែរ ឬទេ?

-ការអះអាងរបស់ដើមចោទ៖ (រំលងចោល)

-ការអះអាងរបស់ចុងចម្លើយ៖ (រំលងចោល)

ស្តីពីចំណុចនេះ តុលាការពិចារណាឃើញថា ភាពដែលមិនស្របគ្នារវាងភាគីដើមចោទ និងចុងចម្លើយនៅត្រង់ថា តើប្រាក់ ២៧៣,០០០ដុល្លារ (ម្ភៃប្រាំពីរម៉ឺនបីពាន់ដុល្លារអាមេរិក) នោះដើមចោទខ្ចីពីចុងចម្លើយនៅមុនកិច្ចសន្យាថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ ឬក្រោយប៉ុណ្ណោះ ដូច្នេះចំណុចនេះឃើញថា ពុំចាំបាច់បញ្ជាក់ដោយភស្តុតាងនោះទេ ព្រោះថាជារួមដើមចោទបានទទួលស្គាល់នូវទឹកប្រាក់ចំនួន ២៧៣,០០០ ដុល្លារ (ម្ភៃប្រាំពីរម៉ឺនបីពាន់ដុល្លារអាមេរិក) ចំពោះចុងចម្លើយដូចការអះអាងរបស់ចុងចម្លើយរួចហើយ ដូច្នេះចំណុចនេះតុលាការពិចារណាឃើញថាដើមចោទពិតជាបានខ្ចីប្រាក់ចំនួន ២៧៣,០០០ដុល្លារ(ម្ភៃប្រាំពីរម៉ឺនបីពាន់ដុល្លារអាមេរិក) ពីចុងចម្លើយប្រាកដមែន។

**៥- ស្តីពីចំណុចវិវាទទី៥៖** តើការទាមទាររបស់ចុងចម្លើយចំពោះសហដើមចោទនូវប្រាក់ដើមចំនួន ១,០៩០,៥០០ (មួយលានប្រាំបួនម៉ឺនប្រាំរយដុល្លារអាមេរិក និងការប្រាក់ចំនួន ២,៥% (ពីរក្បៀស៥ភាគរយ) ក្នុងមួយខែ គិតចាប់ពីថ្ងៃខ្ចីរហូតដល់ថ្ងៃសងប្រាក់រួច ចុងចម្លើយមានសិទ្ធិលើបំណុលចំពោះសហដើមចោទដែរ ឬទេ?

ចំណុចនេះតុលាការពិចារណាថា តាមការអះអាងរបស់ដើមចោទថាខ្លួនពិតជាបានខ្ចីប្រាក់ចំនួន ២៧៣,០០០ ដុល្លារ (ម្ភៃប្រាំពីរម៉ឺនបីពាន់ដុល្លារអាមេរិក) ពីចុងចម្លើយប្រាកដមែន ហើយតុលាការបានទទួលស្គាល់ថាដើមចោទពិតជាបានខ្ចីប្រាក់ចំនួន ២៧៣,០០០ដុល្លារ (ម្ភៃប្រាំពីរម៉ឺនបី

ពាន់ដុល្លារអាមេរិក) ពីចុងចម្លើយដូចមាននៅក្នុងចំណុចវិវាទទី៤រួចហើយ ដូច្នេះតុលាការមិនទទួលស្គាល់ចំពោះការទាមទារប្រាក់ចំនួន ១,០៩០,៥០០ ដុល្លារ (មួយលានប្រាំបួនម៉ឺនប្រាំរយដុល្លារអាមេរិក) និងការប្រាក់តាមការទាមទាររបស់ចុងចម្លើយឡើយ។

៦- **ស្តីពីចំណុចវិវាទទី៦៖** តើចុងចម្លើយមានសិទ្ធិទាមទារភាគហ៊ុនពីសហដើមចោទចំនួន ៨៣៩,០៦៨.១៦ (ប៉ែតសិបបីម៉ឺនប្រាំបួនពាន់ហុកសិបប្រាំបីដុល្លារអាមេរិក និងដប់ប្រាំមួយសេន) និងការប្រាក់ ២,៥% (ពីរក្បៀសប្រាំភាគរយ) ក្នុងមួយខែ លើចំនួនប្រាក់នេះគិតចាប់ពីថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០១០ រហូតដល់ថ្ងៃសងគ្រប់ចំនួនដែរឬទេ? និង**ចំណុចវិវាទទី៧៖** តើចុងចម្លើយមានសិទ្ធិក្នុងការទាមទារផលប្រយោជន៍បានមកពីផ្សារទាំង ០៥កន្លែង ដែលកើតចេញពីទ្រព្យសម្បត្តិ និងពលកម្មរបស់ខ្លួនចំនួន ១,០០០,០០០ដុល្លារ (មួយលានដុល្លារអាមេរិក) ពីសហដើមចោទដែរឬទេ?

ចំណុចនេះតុលាការពិចារណាថា ការទាមទាររបស់សហចុងចម្លើយដែលមាននៅក្នុងចំណុចវិវាទទី៦ និងទី៧ ពុំមានមូលដ្ឋានដែលអាចឱ្យតុលាការសម្រេចតាមការទាមទារឡើយ ដូច្នេះចុងចម្លើយគប្បីធ្វើបណ្តឹងទាមទារនៅក្នុងនីតិវិធីបណ្តឹងផ្សេង ហេតុដូច្នេះចំណុចនេះគប្បីតុលាការច្រានចោលការទាមទាររបស់សហចុងចម្លើយ។

**៧- ស្តីពីចំណុចវិវាទទី៨៖** តើចុងចម្លើយមានមូលដ្ឋាន និងភស្តុតាងដើម្បីទាមទារការខូចខាត និងសេវាកម្មច្បាប់ជាប្រាក់ចំនួន ៥០០,០០០ដុល្លារ (ហាសិបម៉ឺនដុល្លារអាមេរិក) ពីសហដើមចោទដែរឬទេ?

ចំណុចនេះតុលាការពិចារណាឃើញថា ចំពោះកំហុសដែលកើតឡើងដោយភាគីដើមចោទនោះពិតជាបណ្តាលឱ្យមានការខូចខាតទៅដល់ភាគីចុងចម្លើយយ៉ាងពិតប្រាកដ ហើយភាគីចុងចម្លើយបានធ្វើការទាមទារនូវសំណងការខូចខាតរបស់ខ្លួនចំនួន ៥០០,០០០ដុល្លារ (ហាសិបម៉ឺនដុល្លារអាមេរិក) ដែលចំណុចនេះគប្បីតុលាការពិចារណាតាមស្ថានភាពដែលមានការខូចខាត។

**៨-** ប្រាក់ប្រដាប់ក្តីគប្បីអនុវត្តតាមមាត្រា ៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ក្រោយពីបានពិនិត្យលើភស្តុតាងនានា ក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងក្រោយពីបានពិចារណារួចហើយ ៖

# សេចក្តីសម្រេចបញ្ចប់

១-ច្រានចោលការទាមទាររបស់សហាដើមចោទដែលសុំឱ្យរំលាយកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី ០១ ខែមករា ឆ្នាំ២០១០ លិខិតប្រគល់-ទទួលប្រាក់ ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ និងលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១០។

២- សហាដើមចោទត្រូវសងប្រាក់ចំនួន ២៧៣,០០០ដុល្លារ (ម្ភៃប្រាំពីរម៉ឺនបីពាន់ដុល្លារអាមេរិក) ទៅឱ្យសហាចុងចម្លើយ។

៣- សហាដើមចោទត្រូវសងសំណងការខូចខាតទៅឱ្យសហាចុងចម្លើយជាប្រាក់ចំនួន ៥០,០០០ដុល្លារ (ប្រាំម៉ឺនដុល្លារអាមេរិក) ដោយច្រានចោលការទាមទារលើសពីនេះ។

៤-ច្រានចោលការទាមទាររបស់សហាចុងចម្លើយដែលទាមទារភាគហ៊ុនពីសហាដើមចោទឈ្មោះ [redacted] និងឈ្មោះ [redacted] សរុបចំនួន ១,២៧៣,៥១៩.៨១ ដុល្លារ (មួយលានពីរសែនប្រាំពីរម៉ឺនបីពាន់បួនរយដប់ប្រាំបួនដុល្លារអាមេរិក និងប៉ែតសិបមួយសេន) ឱ្យខ្លួន ([redacted]) ដែលជាប្រាក់ចំណាយលើការសាងសង់ផ្សារ និងសោហ៊ុយទាំងអស់លើការសាងសង់ផ្សារ និងចំណាយផ្សេងៗបូករួមទាំងបង់សងបំណុលធនាគាររបស់ឈ្មោះ [redacted] និងទាមទារការប្រាក់ចំនួន ២,៥% (ពីរក្បៀសប្រាំភាគរយ) ក្នុងមួយខែ លើចំនួន ១,២៧៣,៥១៩.៨១ដុល្លារ (មួយលានពីរសែនប្រាំពីរម៉ឺនបីពាន់បួនរយដប់ប្រាំបួនដុល្លារអាមេរិក និងប៉ែតសិបមួយសេន) គិតពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១០ រហូតដល់ថ្ងៃសងគ្រប់។

៥- ច្រានចោលការទាមទាររបស់សហាចុងចម្លើយដែលទាមទារផលប្រយោជន៍បានមកពីផ្សារទាំង៥ ដែលកើតចេញពីទ្រព្យសម្បត្តិ និងពលកម្មរបស់ខ្លួន ([redacted]) ចំនួន ១,០០០,០០០ ដុល្លារ (មួយលានដុល្លារអាមេរិក)។

៦- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

សាលក្រមនេះទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី ០២ ខែមីនា ឆ្នាំ២០១៥ ចំពោះមុខដើមចោទ និងចុងចម្លើយ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០១៥ រក្សាសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីកត់ត្រា　　ចៅក្រមប្រឹក្សា　　ចៅក្រមប្រឹក្សា　　ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**